IX 9Marks

ការកសាងក្រុមជំនុំដែលមានសុខភាពល្អ
BUILDING HEALTHY CHURCHES

# ការបង្កើតសិស្ស

# DISCIPLING

របៀបជួយ
អ្នកផ្សេង
ទៀតឲ្យដើរតាម
ព្រះយេស៊ូវ



MARK DEVER

«សូមចំណាយពេលអានសៀវភៅនេះ ប្រសិនបើលោកអ្នកចង់ផ្លាស់ប្ដូរទៅកាន់កម្រិតមួយផ្សេងទៀតក្នុងជីវិតខាងឯវិញ្ញាណ និងភាពជាអ្នកដឹកនាំរបស់លោកអ្នក។ សៀវភៅនេះមិនគ្រាន់តែផ្ដល់ជាចំណេះដឹងខាងឯព្រះគម្ពីរប៉ុណ្ណោះទេ ប៉ុន្តែលោកអ្នកក៏អាចអនុវត្តនូវអ្វីដែលលោកអ្នកអានបានផងដែរ។ សៀវភៅនេះមានការសង្កត់ធ្ងន់លើក្រុមជំនុំតាមតំបន់ និងតួនាទីរបស់ពួកគេក្នុងការបង្កើតសិស្ស ដែលធ្វើឲ្យសៀវភៅនេះ មានលក្ខណៈពិសេសខុសប្លែកពីសៀវភៅដទៃ។ សូមអានសៀវភៅនេះ ហើយចែករំលែកវាជាមួយអ្នកដទៃចុះ»។

លោក Ronnie Floyd, President, Southern Baptist
Convention; Senior Pastor,
Cross Church, Springdale, Arkansas

«លោក ម៉ាក ដិវើរ ត្រូវបានគេស្គាល់ថាជាគ្រូអធិប្បាយម្នាក់ដែលបង្រៀនព្រះបន្ទូលព្រះយ៉ាងប្រុងប្រយ័ត្ន ដោយចិត្តស្មោះត្រង់។ ប៉ុន្តែ អ្វីដែលលោកអ្នកប្រហែលជាមិនដឹងអំពីលោក ម៉ាក នោះគឺថា គាត់ជាអ្នកមានបំណងចិត្តចង់បង្កើតសិស្សផងដែរ។ លោក ម៉ាក ក៏ធ្វើអ្វីដែលគាត់បានរំពឹងឲ្យអ្នកដទៃធ្វើផងដែរ  មិនថាពេលគាត់កំពុងជួបប្រជុំជាមួយអ្នកដឹកនាំស្ម័គ្រចិត្តនៅថ្ងៃសៅរ៍អំឡុងពេលអាហារថ្ងៃត្រង់ ដើម្បីពិភាក្សាអំពីការអនុវត្តនៅក្នុងសេចក្ដីអធិប្បាយព្រះបន្ទូលរបស់គាត់សម្រាប់ថ្ងៃអាទិត្យ ឬក៏ពេលពិភាក្សាអំពីការគ្រប់គ្រងនៃក្រុមជំនុំនៅក្នុងការសិក្សារបស់គាត់ជាមួយក្រុមនិស្សិតអន្តេវាសិកនោះទេ។ ខ្ញុំជឿជាក់ថា កេរដំណែលរបស់គាត់នឹងមិនគ្រាន់តែមានបន្សល់ទុកនៅលើទំព័រនៃសៀវភៅនេះដែលគាត់បានសរសេរប៉ុណ្ណោះទេ ប៉ុន្តែវានឹងស្ថិតនៅក្នុងដួងចិត្តរបស់អស់អ្នកដែលគាត់បានវិនិយោគពេលវេលាផ្ទាល់ផងដែរ។ សូមកុំគ្រាន់តែអានសៀវភៅនេះឡើយ តែសូមអនុវត្តគោលការណ៍ខាងឯព្រះគម្ពីរដែលបានសរសេរចុះនៅក្នុងសៀវភៅនេះផងដែរ»។

លោក Robby Gallaty, Senior Pastor, Long Hollow
Baptist Church, Hendersonville,
Tennessee

«ខ្ញុំចូលចិត្តអានសៀវភៅដែលសរសេរដោយអ្នកនិពន្ធដែលមានការខ្នះខ្នែងចំពោះប្រធានបទដែលពួកគាត់បានសរសេរឡើង។ ខ្ញុំច្រើនតែចង់ត្រាប់តាមគំរូនៃការណែនាំមុនពេលខ្ញុំអានដល់ទំព័រចុងក្រោយទៀតផង។ ប្រសិនបើលោកអ្នកស្គាល់លោក ម៉ាក ដិវើរ នោះលោកអ្នកក៏នឹងដឹងផងដែរថា គាត់ជាអ្នកបង្កើតសិស្សដែលមានការប្ដេជ្ញាចិត្ត។ ភាពជាអ្នកបង្កើតសិស្សជ្រាបចេញមកពីគាត់ផ្ទាល់។ អ្វីដែលជំរុញចិត្តគាត់ និងរបៀបដែលគាត់បង្រៀនដល់អ្នកដទៃ និងជួយឲ្យសមាជិកក្រុមជំនុំរបស់គាត់ធ្វើដែរ នោះគឺជាអ្វីដែលសៀវភៅនេះបានរៀបរាប់។ សូមត្រៀមខ្លួនទទួលបានបទពិសោធន៍ដែលផ្លាស់ប្ដូរជីវិត នៅពេលលោកអ្នកអានសៀវភៅនេះ»។

លោក Conrad Mwebe, Pastor, Kabwata Baptist Church, Lusaka, Zambia

«សៀវភៅមួយក្បាលនេះផ្ដល់នូវការក្រើនរម្លឹក ការដាស់តឿន និងការណែនាំអ្នកដើរតាមព្រះគ្រីស្ទអំពីការត្រាស់ហៅទៅកាន់ជីវិតនៃការបង្កើតសិស្ស។ វាក៏ផ្ដល់នូវភាពកក់ក្ដៅចំពោះការត្រាស់ហៅនេះ ដែលទទួលបានការឆ្លើយតបនៅក្នុងជីវិតរបស់គ្រូគង្វាល និងក្រុមជំនុំរបស់គាត់។ លោក ម៉ាក ដិវើរ បាននាំយើងចូលទៅកាន់ព្រះគម្ពីរ ហើយជួយយើងឲ្យចាក់ឫសនៅក្នុងក្រុមជំនុំ ដោយផ្ដោតជាពិសេសលើអ្នកដឹកនាំក្រុមជំនុំ និងការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះគ្រប់កិច្ចការទាំងអស់។ យើងក៏ត្រូវចងចាំផងដែរថា ដំណើរការនៃការបង្កើតសិស្សគឺជាការត្រាស់ហៅដ៏ច្បាស់លាស់ និងអំណរអរសប្បាយរបស់អ្នកជឿគ្រប់ៗរូប»។

លោកស្រី Kathleen B. Nielson, Director of Women’s Initiatives, The Gospel Coalition

«ដោយមានការយល់ដឹងដ៏សាមញ្ញ ប៉ុន្តែមានភាពស៊ីជម្រៅ លោក ម៉ាក ដិវើរ បានយកព្រះរាជបញ្ជាចុងក្រោយរបស់ព្រះយេស៊ូវដែលបង្គាប់ឲ្យបង្កើតសិស្ស ហើយបង្រៀនពួកយើងឲ្យបានដឹងថា ព្រះរាជបញ្ជានេះមានអត្ថន័យយ៉ាងណាចំពោះពួកយើង និងក្រុមជំនុំរបស់ពួកយើងដែរ។ តាមរយៈការឆ្លើយតបទៅនឹងសំណួររបស់ពួកយើងដែលសួរថា ហេតុអ្វី? តាមរយៈអ្វី? នៅទីកន្លែងណា? និងអំពីរបៀប

នៃការបង្កើតសិស្ស—លោក ម៉ាក ដិវើរ នឹងបង្រៀនយើងអំពីរបៀបនៃការដើរតាមព្រះគ្រីស្ទ ដោយជួយអ្នកដទៃឲ្យចេះដើរតាមទ្រង់ដែរ ជួយឲ្យស្គាល់សេចក្តីពិត និងចេះរស់នៅតាមសេចក្តីពិតផងដែរ។ អ្នកដើរតាមព្រះគ្រីស្ទគ្រប់ៗរូបចាំបាច់ត្រូវអានសៀវភៅមួយក្បាលនេះ! វាជាសៀវភៅដ៏ល្អបំផុតដែលខ្ញុំធ្លាប់បានអានទាក់ទងនឹងការបង្កើតសិស្ស»។

លោកស្រី Jani Ortlund, Executive Vice President,
Renewal Ministries; author, Fearlessly Feminine and
His Loving Law, Our Lasting Legacy

«នេះគឺជាសៀវភៅសម្រាប់ពង្រឹងក្រុមជំនុំ ដែលពោរពេញដោយដំបូន្មានដែលយើងអាចអនុវត្តបាន ក្នុងជីវិតលើផែនដីនេះ អំពីចំណុចស្នូល និងគន្លឹះនៃការបង្កើតសិស្ស។ សេចក្តីស្រឡាញ់របស់លោក ដិវើរ ចំពោះព្រះយេស៊ូវ និងរាស្ត្ររបស់ទ្រង់បានភ្លឺពេញពេញសៀវភៅនេះ ហើយការដែលគាត់បាននិយាយសង្កត់ធ្ងន់អំពីភាពជាសិស្សនៅក្នុងបរិបទ និងដែនកំណត់នៃក្រុមជំនុំតាមតំបន់ ដែលនោះគឺជាទេវវិទ្យាអំពីក្រុមជំនុំរបស់លោក ដិវើរ។ គាត់មានភ្នែកមុតមាំសម្រាប់គ្រូៗ ដោយនិយាយរៀបរាប់ទៅកាន់ពួកគាត់អំពីតួនាទីរបស់ពួកគាត់នៅក្នុងក្រុមជំនុំ ដោយមានភាពកក់ក្តៅ និងច្បាស់លាស់។ លោក ដិវើរ បានជំរុញខ្ញុំឲ្យមានការផ្លាស់ប្តូរដោយផ្ទាល់ ដែលខ្លួនគាត់ផ្ទាល់មានមានប្រវត្តិដាក់អាទិភាពលើការបង្កើតសិស្សខណៈពេលដែលគាត់នៅមានទំនួលខុសត្រូវជាច្រើនទៀត។ ប្រសិនបើលោក ម៉ាកអាចធ្វើវាបាន ខ្ញុំក៏អាចធ្វើបានដែរ»។

លោក Grant J. Retief, Rector, Christ Church,
Umhlanga, Durban, South Africa

«លោក ដិវើរ បានរម្លឹកមិត្តអ្នកអានថា ការបង្កើតសិស្សគឺជាសេចក្តីបង្គាប់ពីព្រះគម្ពីរ ដែលមានការជំរុញឲ្យស្តាប់បង្គាប់តាមបទបញ្ញត្តិរបស់ព្រះគ្រីស្ទ និងការមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ហើយវាក៏មិនមែនជាការខិតខំប្រឹងប្រែងដែលត្រូវបានបម្រុងទុកសម្រាប់មនុស្សតែមួយចំនួន ដែលបានជ្រើសតាំងទុកនោះទេ។ វា

មិនបានកាត់បន្ថយមនុស្ស ឲ្យមកនៅត្រឹមគម្រោងនោះទេ ប៉ុន្តែជាការស្វែងរកការអភិវឌ្ឍទំនាក់ទំនងជាមួយពួកគាត់ដោយគោលបំណងវិញ។ ការបង្កើតសិស្សទាមទារឲ្យមានការវិនិយោគពេលវេលាក្នុងជីវិតរបស់អស់អ្នក ដែលមានការចាប់អារម្មណ៍ និងមានចិត្តចង់ដើរតាមព្រះយេស៊ូវ។ ជាចុងក្រោយ មានតែគ្រូៗដែលមានចិត្តបន្ទាបខ្លួនប៉ុណ្ណោះដែលគួរបង្រៀនចៀមរបស់ព្រះយេស៊ូវ ពីព្រោះ «នៅពេលដែលសិស្សម្នាក់ត្រូវបានបង្ហាត់បង្រៀនយ៉ាងពេញលេញ នោះគាត់នឹងបានដូចជាគ្រូរបស់គាត់»។ មានការផ្ដោតលើចំណុចទាំងនេះ និងច្រើនទៀតនៅក្នុងសៀវភៅមួយក្បាលនេះ។ នៅពេលដែលលោកអ្នកបានអានសៀវភៅនេះហើយ នោះលោកអ្នកទំនងជានឹងណែនាំវាទៅដល់អ្នកដទៃទៀតដែរ ព្រោះខ្ញុំដឹងថា ខ្ញុំនឹងណែនាំសៀវភៅនេះទៅកាន់អ្នកដទៃ»។

លោក Miguel Núñez, Senior Pastor, International Baptist Church of Santo Domingo; President, Wisdom and Integrity

# ការបង្កើតសិស្ស

## DISCIPLING

MARK DEVER

ផ្លូវពិត

Discipling

ការបង្កើតសិស្ស

រក្សាសិទ្ធិ ©2016 by Mark Dever

Published by Crossway

1300 Crescent Street

Wheaton, Illinois 60187

This edition in Khmer copyright ©2025 by ACTION Cambodia Organization

All rights reserved.

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៥

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ង៉ែត រិទ្ធ

ជំនួយការបកប្រែ៖ លោក J.D. Crowley លោក ឈាង បូរ៉ា និងលោក បេឃីរ យ៉ូសៀស ដាវីឌ

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ឯក សត្យា, លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ហុង សម្ផស, លោក ឡង់ គីមឡុង, លោក ស៊ូ ទិត្យ  និងលោកស្រី អមរិន្ទ សុធាកែវ, លោកស្រី ឡូញ ស្រីរ័ត្ន, លោកស្រី កែវ សិរីវុឌ្ឍី និងលោកស្រី ចារ ប៊ុនរី

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉េល ណាថាន និងលោក វណ្ណដ្ឋា សុតរ៉ាប៊ី

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ plovpit.com

បោះពុម្ពលើកទី១ ចំនួន ៣.០០០ ក្បាល ២០២៥ នៃគ.ស.

9Marks ISBN: 979-8-89218-225-6

# មាតិកា

**បុព្វកថាស៊ីរី** ៩

**សេចក្តីផ្តើម** ១១

**ផ្នែកទី៖១** ២៥

តើការបង្កើតសិស្សជាអ្វី?

**ជំពូកទី១** ២៧

លោកអ្នកកំពុងតែមានឥទ្ធិពលដល់អ្នកដទៃ

**ជំពូកទី២** ៣៣

តម្រង់ទិសទៅរកអ្នកដទៃ

**ជំពូកទី៣** ៤៥

ការងារនៃការបង្កើតសិស្ស

**ជំពូកទី៤** ៥៩

ការជំទាស់ផ្សេងៗទៅនឹងការបង្កើតសិស្ស

**ផ្នែកទី២៖** ៦៥

តើយើងគួរបង្កើតសិស្សនៅឯណា?

**ជំពូកទី៥** ៦៧

ក្រុមជំនុំតាមតំបន់

**ជំពូកទី៦** ៧៥

គ្រូគង្វាល និងសមាជិកក្រុមជំនុំ

**ផ្នែកទី៣៖** ៩១

តើយើងគួរបង្កើតសិស្សដោយរបៀបណា?

**ជំពូកទី៧** ៩៣

ការជ្រើសរើសនរណាម្នាក់

**ជំពូកទី៨** ១០៥

ត្រូវមានគោលដៅច្បាស់លាស់

**ជំពូកទី៩** ១១១

ការលៃលកមើលជាមុន

**ជំពូកទី១០** ១១៩

ការបណ្តុះបណ្តាលឲ្យមានអ្នកដឹកនាំបន្ថែម

**សេចក្តីសន្និដ្ឋាន៖** ១៣៥

**ឧបសម្ព័ន្ធ** ១៤៧

**ឯកសារយោង** ១៥១

**លិបិក្រមទូទៅ** ១៥៣

# បុព្វកថាស៊ីរី

តើលោកអ្នកជឿថា ការជួយកសាងក្រុមជំនុំដែលមានសុខភាពល្អ គឺជាការទទួលខុសត្រូវរបស់លោកអ្នកដែរឬទេ? ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ យើងជឿថា នេះគឺជាការទទួលខុសត្រូវរបស់លោកអ្នក។

ព្រះយេស៊ូវបានបង្គាប់ឲ្យលោកអ្នកបង្កើតសិស្ស (ម៉ាថាយ ២៨:១៨-២០)។ លោក យូដាស បានមានប្រសាសន៍ថា យើងត្រូវស្អាងចិត្តឡើងក្នុងជំនឿ (ខ.២០-២១)។ សាវ័ក ពេត្រុស ហៅលោកអ្នកឲ្យប្រើប្រាស់អំណោយទានរបស់លោកអ្នក ដើម្បីបម្រើអ្នកដទៃ (១ពេត្រុស ៤:១០)។ សាវ័ក ប៉ុល ប្រាប់លោកអ្នកឲ្យនិយាយសេចក្តីពិតដោយសេចក្តីស្រឡាញ់ ដើម្បីឲ្យក្រុមជំនុំរបស់លោកអ្នកបានពេញវ័យ (អេភេសូរ ៤:១៣, ១៥)។ តើលោកអ្នកយល់ថា យើងទទួលបានសេចក្តីទាំងនេះមកពីណាដែរឬទេ?

មិនថាលោកអ្នកជាសមាជិក ឬជាអ្នកដឹកនាំក្នុងក្រុមជំនុំនោះទេ ស៊េរីសៀវភៅការកសាងក្រុមជំនុំដែលមានសុខភាពល្អនេះ (Building Healthy Churches) មានគោលបំណងជួយលោកអ្នកឲ្យសម្រេចតាមបង្គាប់ក្នុងព្រះគម្ពីរទាំងនេះ ហើយសូមបំពេញតួនាទីរបស់ខ្លួនក្នុងការកសាងក្រុមជំនុំដែលមានសុខភាពល្អចុះ។ បើនិយាយម្យ៉ាងវិញទៀត យើងសង្ឃឹមថា សៀវភៅទាំងនេះនឹងជួយលោកអ្នកឲ្យកាន់តែស្រឡាញ់ក្រុមជំនុំរបស់លោកអ្នក ដូចដែលព្រះយេស៊ូវស្រឡាញ់ក្រុមជំនុំរបស់លោកអ្នកដែរ។

ក្រុម 9Marks មានផែនការផលិតសៀវភៅខ្លីៗដែលងាយស្រួលអាន អំពីចំណុចនីមួយៗដែលលោកគ្រូ ម៉ាក ដិវើរ (Mark Dever) បានហៅថាសញ្ញាសម្គាល់ទាំងប្រាំបួននៃក្រុមជំនុំដែលមានសុខភាពល្អ ព្រមទាំងសៀវភៅមួយក្បាលទៀតស្តីអំពីគោលលទ្ធិដ៏ត្រឹមត្រូវ។ សូមរង់ចាំអានសៀវភៅស្តីអំពីការអធិប្បាយ

តាមអត្ថន័យព្រះគម្ពីរ ទេវវិទ្យាតាមព្រះគម្ពីរ ដំណឹងល្អ ការក្លាយជាគ្រីស្ទបរិស័ទ ការផ្សព្វផ្សាយដំណឹងល្អ សមាជិកភាពក្រុមជំនុំ ការដាក់វិន័យក្រុមជំនុំ ការបង្កើតសិស្ស និងការលូតលាស់ ព្រមទាំងការដឹកនាំក្រុមជំនុំ។

ព្រះបានបង្កើតឡើងក្រុមជំនុំតាមតំបន់ ដើម្បីបង្ហាញសិរីល្អរបស់ព្រះដល់អស់ទាំងជាតិសាសន៍។ យើងធ្វើកិច្ចការនោះតាមរយៈការរំពឹងមើលទៅឯដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ទុកចិត្តលើទ្រង់សម្រាប់ឲ្យទទួលបានសេចក្តីសង្គ្រោះ ហើយបន្ទាប់មកគឺឲ្យស្រឡាញ់គ្នាទៅវិញទៅមកដោយដោយភាពបរិសុទ្ធ ភាពរួបរួម និងសេចក្តីស្រឡាញ់របស់ព្រះអង្គផ្ទាល់។ យើងខ្ញុំអធិស្ឋានសូមឲ្យសៀវភៅដែលអ្នកកំពុងកាន់នេះក្លាយជាជំនួយដល់លោកអ្នក។

ដោយសេចក្តីសង្ឃឹម

លោកគ្រូ ម៉ាក ដីវ័រ (Mark Dever)

និងលោកគ្រូ ចនណាថាន លីមែន (Jonathan Leeman)

អ្នកកែសម្រួលស៊េរី

# សេចក្តីផ្តើម

នៅពេលដែលលោកអ្នក ដើរសួរសុខទុក្ខអ្នកជិតខាងនៅជុំវិញតំបន់ដែលលោកអ្នករស់នៅ លោកអ្នកនឹងសង្កេតឃើញថា ពួកគាត់ភាគច្រើនរស់ជាមួយនឹងទូរស័ព្ទរបស់ពួកគេ។ ពីផ្ទះមួយទៅផ្ទះមួយ ពីគ្រួសារមួយទៅគ្រួសារមួយ យើងឃើញឪពុកកំពុងតែមើលយូធូប (YouTube) ម្តាយកំពុងមើលខ្សែភាពយន្តថៃ កូនប្រុសកំពុងតែលេងហ្គេមនៅលើទូរស័ព្ទ កូនស្រីកំពុងតែមើលរឿងតុក្កតានៅលើអាយផេត (iPad)។ ទោះបីជាពួកគេនៅជុំគ្នាក្តី ក៏ពួកគេនៅតែឯងនៅក្នុងពិភពរបស់ពួកគេរៀងៗខ្លួនដែរ។

ម្ចាស់ហាងនៅឯផ្សារធ្លាប់តែចំណាយពេលសន្ទនាជាមួយអ្នកលក់ដូចគ្នា ប៉ុន្តែសព្វថ្ងៃនេះ ពួកគេឈ្ងោកមុខមើលតែកញ្ចក់ទូរស័ព្ទរបស់ពួកគេ។

ហើយនេះមិនមែននៅតែប្រទេសកម្ពុជាយើងប៉ុណ្ណោះទេ។ នៅពាសពេញសកលលោក មនុស្សចំណាយពេលជាច្រើនជាមួយនឹងទូរស័ព្ទ ឬស្តាប់ចម្រៀងពីកាសជាប់ត្រចៀករបស់ពួកគេ។ សូម្បីតែនៅពេលដែលពួកគេអង្គុយជាមួយមិត្តភ័ក្តិជាក្រុមក្តី ក៏ពួកគេនៅតែ «នៅដោយរៀងៗខ្លួន»—មានតែខ្លួនគេជាមួយនឹងទូរស័ព្ទរបស់ពួកគេដដែល។

ជនជាតិអាស៊ីយើងតែងតែល្បី ខាងផ្តល់គុណតម្លៃខ្ពស់ ទៅលើសហគមន៍ និងក្រុមគ្រួសារ។ ប៉ុន្តែ ទូរស័ព្ទបានផ្លាស់ប្តូរទាំងនោះអស់ទៅហើយ។

តើព្រះជាម្ចាស់ទ្រង់មានព្រះទ័យយ៉ាងណាចំពោះការនេះ? ជាការពិតណាស់ ទូរស័ព្ទ និងយូធូបអាចជាព្រះពរមកពីព្រះជាម្ចាស់សម្រាប់ឲ្យយើងអាចស្តាប់សេចក្តីអធិប្បាយ និងផ្ញើសារលើកទឹកចិត្តគ្នាទៅវិញទៅមកបាន។ ប៉ុន្តែ គ្រោះថ្នាក់ដែលអាចកើតមានឡើងចំពោះគ្រីស្ទបរិស័ទនោះគឺថា យើងមានទំនោរក្នុងការរស់នៅតែម្នាក់ឯង ហើយចំណាយពេលវេលានៃជីវិតរបស់យើងកាន់តែច្រើន

ជាមួយខ្លួនឯង និងទូរស័ព្ទរបស់យើង ជំនួសឲ្យការចំណាយពេលជាមួយនឹងគ្រីស្ទបរិស័ទផ្សេងៗទៀត ដើម្បីជួយពួកគាត់ឲ្យស្គាល់អំពីរបៀបដើរតាមព្រះគ្រីស្ទ។

ជំនឿរបស់គ្រីស្ទបរិស័ទមិនមែនជាជំនឿដោយយើងត្រូវនៅតែឯងនោះទេ។ លោកអ្នកមិនអាចសង្គ្រោះខ្លួនឯងដោយ «ខ្លួនទីពឹងខ្លួន» នោះទេ [ម្នាក់ៗត្រូវជួយសង្គ្រោះខ្លួនឯង] ។ លោកអ្នកមិនអាចក្លាយជាគ្រីស្ទបរិស័ទដ៏ស្មោះត្រង់ដោយខ្លួនឯងបាននោះទេ។ ផែនការណ៍របស់ព្រះជាម្ចាស់នោះ គឺព្រះអង្គគាប់ព្រះទ័យឲ្យគ្រីស្ទបរិស័ទទាំងអស់ ស្ថិតក្នុងសហគមន៍ថ្មីមួយដែលជាក្រុមជំនុំ ជាកន្លែងដែលគ្រីស្ទបរិស័ទពេញវ័យនៅក្នុងសេចក្ដីជំនឿជួយអ្នកជឿថ្មីឲ្យរីកចម្រើនឡើងក្នុងការដើរតាមព្រះគ្រីស្ទ ហើយជាកន្លែងដែលគ្រប់គ្នាអាចរៀនអំពីរបៀបដើម្បីនឹង...

ស្រឡាញ់គ្នាទៅវិញទៅមក (យ៉ូហាន ១៣:៣៥; ១យ៉ូហាន ៣:១១; ៤:៧)

បម្រើគ្នាទៅវិញទៅមក (កាឡាទី ៥:១៣)

ទទួលគ្នាទៅវិញទៅមក (រ៉ូម ១៥:៧)

លន់តួទោសនឹងគ្នាទៅវិញទៅមក (យ៉ាកុប ៥:១៦)

អត់ទោសឲ្យគ្នាទៅវិញទៅមក (អេភេសូរ ៤:៣២)

ខំរាប់អានទៅវិញទៅមក (រ៉ូម ១២:១០)

ចំណុះគ្នាទៅវិញទៅមក (អេភេសូរ ៥:២១)

និយាយសេចក្ដីពិត ចំពោះគ្នាទៅវិញទៅមក (អេភេសូរ ៤:២៥)

កម្សាន្ត ហើយស្អាងចិត្តគ្នាទៅវិញទៅមក (១ថេសាឡូនីច ៥:១១)

អធិស្ឋានឲ្យគ្នាទៅវិញទៅមក (យ៉ាកុប ៥:១៦)

ប្រព្រឹត្តដោយចៅរ៉ៅនឹងគ្នាទៅវិញទៅមក (១ពេត្រុស ៤:៩)

លើកទឹកចិត្តគ្នាឲ្យស្រឡាញ់ និងធ្វើការដែលល្អ (ហេព្រើរ ១០:២៤)

យកអាសាគ្នាទៅវិញទៅមក (កាឡាទី ៦:២)

បង្រៀន ហើយទូន្មានគ្នាដោយនូវទំនុកតម្កើង ទំនុកបរិសុទ្ធជាដើម (កូឡូស ៣:១៦)។ល។

យើងមិនអាចប្រតិបត្តិតាមបទបញ្ញត្តិទាំងឡាយខាងលើនេះបានទេ បើសិន

ជាលោកអ្នកសម្រេចចិត្តរស់នៅដោយខ្លួនឯង គ្រាន់តែដោយមានតែលោកអ្នកជាមួយនឹងទូរស័ព្ទ ឬលោកអ្នកជាមួយនឹងស្រៃចម្ការ ឬលោកអ្នកជាមួយនឹងការងាររបស់អ្នកនោះទេ។

នៅក្នុងចំណុចស្នូលនៃជំនឿគ្រីស្ទបរិស័ទ គឺព្រះអង្គសព្វព្រះទ័យឲ្យរាស្ត្ររបស់ព្រះអង្គបង្ហាញពីលក្ខណសម្បត្តិរបស់ទ្រង់ ដល់អ្នកដែលនៅជុំវិញ។ គ្រីស្ទបរិស័ទគ្រប់រូបត្រូវធ្វើដូច្នេះ តាមរយៈការស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់ ហើយក្នុងទំនាក់ទំនងរបស់ពួកគេជាមួយទ្រង់ផ្ទាល់ និងជាមួយអ្នកដទៃ។ ហេតុនេះហើយបានជាព្រះបានចាត់បុត្រារបស់ទ្រង់មកផែនដីនេះ ដើម្បីធ្វើការត្រាស់ទៅហៅមនុស្សនៅលើផែនដីនេះ ឲ្យដើរតាមទ្រង់។ ហើយនៅក្នុងផ្នែកនៃការដើរតាមព្រះរាជបុត្រានោះ គឺទ្រង់នៅតែអំពាវនាវឲ្យអ្នកដទៃដើរតាមព្រះរាជបុត្រាទ្រង់បន្ថែមទៀតដែរ។ បន្ទាប់មក នៅក្នុងជីវិតរស់នៅរបស់ពួកគេជាមួយគ្នា ពួកគេបង្ហាញឲ្យគេឃើញការរស់នៅ «ដោយស្រឡាញ់គ្នាទៅវិញទៅមក» ដែលការនោះក៏បានកើតឡើងដូចគ្នាជាមួយនឹងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ។ គ្រីស្ទបរិស័ទទាំងនោះរួមគ្នាបង្ហាញពីសេចក្តីស្រឡាញ់ ភាពបរិសុទ្ធ និងភាពរួមគ្នាតែមួយរបស់ព្រះផ្ទាល់ នៅក្នុងជីវិតរបស់ពួកគេ។

ដូច្នេះ ព្រះរាជបុត្រាទ្រង់បានប្រទានបញ្ញត្តិចុងក្រោយនេះ មុននឹងទ្រង់ត្រូវបានលើកឡើងទៅស្ថានសួគ៌វិញថា ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ (ម៉ាថាយ ២៨:១៩)។ អ្វីដែលទ្រង់ចង់ផ្តល់អត្ថន័យនោះគឺថា ជីវិតនៃរាស្ត្ររបស់ទ្រង់ គួរតែត្រូវលះបង់ ដើម្បីជួយអ្នកដទៃទៀត ហើយឲ្យមានមនុស្សកាន់តែច្រើនទៀតដើរតាមព្រះយេស៊ូវដែរ។

នេះហើយ គឺជានិយមន័យនៃការបង្កើតសិស្ស នៅក្នុងសៀវភៅនេះ៖ គឺការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ។ លោកអ្នកអាចមើលឃើញវានៅក្នុងចំណងជើង នៅក្នុងសៀវភៅនេះ។ ក្នុងរបៀបផ្សេងមួយទៀត ដែលយើងអាចកំណត់ការបង្កើតសិស្សគឺជា៖ មានចេតនាធ្វើល្អខាងវិញ្ញាណចំពោះនរណាម្នាក់ ដើម្បីឲ្យគាត់កាន់តែមានភាពដូចគ្នាទៅនឹងព្រះគ្រីស្ទ។ ភាពជាសិស្ស គឺជាពាក្យដែលខ្ញុំប្រើ ដើម្បីពណ៌នាអំពីការដើរតាមព្រះគ្រីស្ទ។ ការបង្កើតសិស្សគឺជាផ្នែកតូចមួយ

នៅក្នុងការជួយអ្នកដទៃ ឲ្យដើរតាមព្រះគ្រីស្ទ។

ជីវិតគ្រីស្ទបរិស័ទគឺជាជីវិត នៃភាពជាសិស្ស និងជាជីវិតដែលត្រូវបង្កើតសិស្សផងដែរ។ ជំនឿគ្រីស្ទបរិស័ទ គឺមិនមែនសម្រាប់មនុស្សឯកោ ឬបុគ្គលនិយមនោះទេ។ ជំនឿគ្រីស្ទបរិស័ទ គឺសម្រាប់មនុស្សដែលធ្វើដំណើរជាមួយគ្នាតាមផ្លូវតូចចង្អៀត ដែលនាំទៅឯជីវិត។ លោកអ្នកត្រូវតែដើរតាម ហើយលោកអ្នកក៏ត្រូវតែដឹកនាំអ្នកដទៃផងដែរ។ លោកអ្នកត្រូវតែទទួលបានសេចក្តីស្រឡាញ់ ហើយលោកអ្នកក៏ត្រូវតែស្រឡាញ់អ្នកដទៃផងដែរ។ ហើយយើងត្រូវស្រឡាញ់អ្នកដទៃឲ្យល្អបំផុត ដោយជួយពួកគេឲ្យដើរតាមព្រះយេស៊ូវ គឺដើរតាមផ្លូវនៃជីវិត។

តើនេះជារបៀបដែលលោកអ្នកបានយល់អំពីជំនឿគ្រីស្ទបរិស័ទឬទេ ហើយតើការក្លាយជាគ្រីស្ទបរិស័ទមានន័យដូចម្តេច?

## តើសិស្សជាអ្វី?

មុនពេល យើងអាចបង្រៀនអ្នកដទៃឲ្យក្លាយជាសិស្ស យើងត្រូវតែក្លាយជាសិស្សជាមុនសិន។ យើងត្រូវតែប្រាកដថា យើងក៏កំពុងតែដើរតាមព្រះគ្រីស្ទដែរ។

ដូច្នេះ តើការធ្វើជាសិស្សមានន័យដូចម្តេច? សិស្ស គឺជាអ្នកដើរតាម។ លោកអ្នកអាចក្លាយជាសិស្សរបស់អ្នកណាម្នាក់បាន ដោយធ្វើតាមការបង្រៀនរបស់បុគ្គលនោះពីចម្ងាយបាន ដូចជាមាននរណាម្នាក់ ដែលគាត់អាចនិយាយថា គាត់ធ្វើតាមការបង្រៀន និងគំរូរបស់លោក ហ្គាន់ឌី។ ហើយការក្លាយជាសិស្សរបស់ព្រះគ្រីស្ទ អាចមានន័យច្រើនជាងនេះ។ សិស្សរបស់ព្រះយេស៊ូវ គឺត្រូវដើរតាមដានរបស់ទ្រង់ ហើយប្រព្រឹត្ត និងរស់នៅតាមអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួកគេ។

ប៉ុន្តែ វាអាចមានអត្ថន័យច្រើនជាងនេះ។ ការដើរតាមព្រះយេស៊ូវ ដែលជាដំបូងមានន័យថា លោកអ្នកបានចូលទៅក្នុងទំនាក់ទំនង និងរក្សាទំនាក់ទំនងផ្ទាល់ខ្លួនរបស់លោកអ្នកជាមួយនឹងទ្រង់។ លោកអ្នកបាន “រួមជាមួយព្រះគ្រីស្ទ” ដូចដែលព្រះគម្ពីរបានថែង (ភីលីព ២:១, គខប)។ លោកអ្នកបានរួមគ្នាជាមួយព្រះគ្រីស្ទ តាមរយៈសេចក្តីសញ្ញាថ្មីដោយសារព្រះលោហិតរបស់ទ្រង់។ តាមរយៈការ

សុគត និងការរស់ឡើងវិញរបស់ទ្រង់ នាំឲ្យកំហុសឆ្គងនៃអំពើបាបទាំងអស់របស់លោកអ្នក ត្រូវបានធ្លាក់ទៅលើអង្គទ្រង់ ហើយភាពសុចរិតទាំងអស់ដែលជារបស់ទ្រង់ ត្រូវបានក្លាយជារបស់លោកអ្នក។

យើងអាចនិយាយម្យ៉ាងទៀតថា ការក្លាយជាសិស្សរបស់ព្រះគ្រីស្ទមិនចាប់ផ្ដើមជាមួយនឹងអ្វី ដែលយើងធ្វើនៅក្នុងជីវិតរបស់យើងនោះទេ។ វាចាប់ផ្ដើមជាមួយនឹងអ្វី ដែលព្រះគ្រីស្ទបានធ្វើនៅក្នុងជីវិតរបស់យើងវិញ។ ព្រះយេស៊ូវ គឺជាអ្នកគង្វាលល្អ ដែលស៊ូប្ដូរជីវិតជំនួសចៀមទ្រង់ (យ៉ូហាន ១០:១១)។ ទ្រង់បានស្រឡាញ់ពួកជំនុំ ហើយបានប្រគល់អង្គទ្រង់ជំនួសពួកជំនុំទ្រង់ផង (អេភេសូរ ៥:២៥)។ ទ្រង់បានសងបំណុល ដែលទ្រង់មិនបានជំពាក់ ប៉ុន្តែជាបំណុលដែលយើងជំពាក់វិញ ហើយបន្ទាប់មកទ្រង់បានបង្រួបបង្រួមយើង ឲ្យបានក្លាយជារាស្ត្រដ៏បរិសុទ្ធរបស់ទ្រង់។

លោកអ្នកបានឃើញទេថា ព្រះទ្រង់ល្អ ហើយទ្រង់បានបង្កើតលោក អ័ដាម និងនាង អេវ៉ា មកយ៉ាងល្អប្រពៃណាស់។ ប៉ុន្តែ ពួកយើងម្នាក់ៗបានប្រព្រឹត្តអំពើបាប ដោយងាកបែរចេញពីព្រះ និងបញ្ញត្តិដ៏ល្អរបស់ទ្រង់។ ហើយដោយសារព្រះទ្រង់ល្អ នោះទ្រង់នឹងដាក់ទោសនូវរាល់អំពើបាបរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ ក៏ដំណឹងល្អនៃជំនឿរបស់គ្រីស្ទបរិស័ទគឺថា ព្រះយេស៊ូវបានរស់នៅជីវិតដ៏ល្អឥតខ្ចោះ ដែលយើងគួររស់នៅតាមគំរូរបស់ទ្រង់ ហើយបន្ទាប់មកទ្រង់បានសុគតជំនួសសេចក្ដីស្លាប់របស់យើងដែលយើងគួរទទួលនោះ។ ទ្រង់បានថ្វាយរូបអង្គទ្រង់ផ្ទាល់ជាយញ្ញបូជាសម្រាប់អស់អ្នកដែលប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន ហើយជឿទុកចិត្តទៅលើទ្រង់តែមួយអង្គប៉ុណ្ណោះ។ នេះគឺជាអ្វីដែលព្រះយេស៊ូវមានបន្ទូលហៅថា ជាសេចក្ដីតាំងសញ្ញាថ្មីតាមរយៈព្រះលោហិតរបស់ទ្រង់។

ដូច្នេះ ការធ្វើជាសិស្សរបស់ព្រះគ្រីស្ទត្រូវតែចាប់ផ្ដើមនៅត្រង់នេះ ដោយការទទួលយកអំណោយដោយឥតគិតថ្លៃនេះ ពីទ្រង់ផ្ទាល់គឺជា៖ ព្រះគុណ សេចក្ដីមេត្តាករុណា ទំនាក់ទំនងជាមួយព្រះ និងសេចក្ដីសន្យាប្រទានជីវិតអស់កល្បជានិច្ច។

តើយើងទទួលយកអំណោយទាននេះ ហើយរួបរួមជាមួយទ្រង់ដោយរបៀប

ណា? គឺតាមរយៈជំនឿ! យើងត្រូវបែរចេញពីអំពើបាបរបស់យើង ហើយដើរតាមទ្រង់ ដោយទុកចិត្តលើទ្រង់ធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់យើង។ នៅពេលមួយក្នុងការបម្រើរបស់ទ្រង់ ព្រះយេស៊ូវបានបែរទៅរកហ្វូងមនុស្ស ហើយមានបន្ទូលទៅពួកគេថា «អ្នកណាដែលចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯងចោល ទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ» (ម៉ាកុស ៨:៣៤)។

ភាពជាសិស្សរបស់យើងចំពោះព្រះគ្រីស្ទ គឺចាប់ផ្តើមនៅពេលដែលយើងឮពាក្យទាំងបួននោះ ហើយស្តាប់តាម៖ គឺពាក្យបង្គាប់ថា «មកតាមខ្ញុំចុះ»។

មិត្តអ្នកអានទាំងអស់គ្នាអើយ! បើលោកអ្នកចង់ក្លាយជាគ្រីស្ទបរិស័ទម្នាក់ ទោះបីគ្រូឯទៀត ដែលលោកអ្នកបានឮការនិយាយរបស់ពួកគាត់យ៉ាងណាក៏ដោយ ចូរស្តាប់តាមព្រះយេស៊ូវចុះ។ ទ្រង់បានមានបន្ទូលថា ការក្លាយជាគ្រីស្ទបរិស័ទម្នាក់ គឺពាក់ព័ន្ធនឹងការលះកាត់ចិត្តខ្លួនឯងចោល ផ្ទុកឈើឆ្កាងរបស់អ្នក ហើយមកតាមទ្រង់ចុះ។ ការឆ្លើយតបដ៏សំខាន់ចំពោះសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះចំពោះយើង គឺជាការដែលយើងត្រូវស្រឡាញ់ទ្រង់ឲ្យបានជ្រាលជ្រៅវិញដែរ។

ការក្លាយជាគ្រីស្ទបរិស័ទម្នាក់គឺមានន័យថា យើងបានក្លាយជាសិស្សរបស់ព្រះយេស៊ូវ។ គ្មានគ្រីស្ទបរិស័ទណាម្នាក់ ដែលមិនមែនជាសិស្សរបស់ព្រះយេស៊ូវនោះទេ។ ហើយការធ្វើជាសិស្សរបស់ព្រះយេស៊ូវគឺមានន័យថា យើងត្រូវដើរតាមព្រះយេស៊ូវ។ គ្មានសិស្សរបស់ព្រះយេស៊ូវណា ដែលមិនដើរតាមព្រះយេស៊ូវនោះទេ។ ការមានឪពុកម្តាយដែលជាគ្រីស្ទបរិស័ទ ក៏មិនបានធ្វើឲ្យលោកអ្នកក្លាយជាគ្រីស្ទបរិស័ទដែរ។ ការធ្វើការឲ្យអង្គការគ្រីស្ទបរិស័ទក៏មិនបានធ្វើឲ្យលោកអ្នកក្លាយជាគ្រីស្ទបរិស័ទដែរ។ គ្រីស្ទបរិស័ទ គឺជាអ្នកដែលមានជំនឿពិតប្រាកដលើព្រះគ្រីស្ទ ហើយបង្ហាញនៅក្នុងជីវិតរបស់ពួកគាត់ ដោយទទួលយកសេចក្តីសង្ឃឹម និងថ្វាយការភ័យខ្លាច និងរស់នៅពឹងអាងលើទ្រង់ទាំងស្រុង។ ពួកគាត់ដើរតាមទ្រង់ ទៅគ្រប់ទីកន្លែងដែលទ្រង់ដឹកនាំ។ លោកអ្នកលែងត្រូវការកំណត់របៀបវារៈសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់លោកអ្នកទៀតហើយ គឺព្រះយេស៊ូវគ្រីស្ទទ្រង់ជាអ្នកកំណត់សម្រាប់លោកអ្នកវិញ។ ឥឡូវនេះ លោកអ្នកជាកម្មសិទ្ធិរបស់ទ្រង់។ សាវ័ក

ប៉ុល បានមានប្រសាសន៍ថា «ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ ដ្បិតព្រះគ្រីស្ទទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ» (១កូរិនថូស ៦:១៩-២០)។ ព្រះយេស៊ូវទ្រង់មិនគ្រាន់តែជាព្រះអង្គសង្គ្រោះរបស់យើងប៉ុណ្ណោះទេ ទ្រង់ក៏ជាព្រះអម្ចាស់របស់យើងផងដែរ។

សាវ័ក ប៉ុល បានពន្យល់បែបនេះថា៖ «ទ្រង់ក៏បានសុគតជំនួសមនុស្សទាំងអស់យ៉ាងនោះ គឺដើម្បីឲ្យពួកអ្នកដែលរស់នៅ មិនរស់នៅសម្រាប់តែខ្លួនឯងទៀត គឺរស់សម្រាប់ព្រះអង្គ ដែលសុគតជំនួសគេ ហើយបានរស់ឡើងវិញ» (២កូរិនថូស ៥:១៥)។ តើការសម្លាប់និស្ស័យសាច់ឈាម ហើយការរស់នៅសម្រាប់ទ្រង់មានន័យដូចម្តេច? លោក ដុន ខាសុន (Don Carson) បានមានប្រសាសន៍ថា «ការសម្លាប់និស្ស័យសាច់ឈាម» មានន័យថាជាការគិតថា ការសម្លាប់និស្ស័យសាច់ឈាមប្រសើរជាងការមានដំរេកតណ្ហា ហើយជាការគិតថា ការសម្លាប់និស្ស័យសាច់ឈាម គឺប្រសើរជាងការនិយាយពាក្យមិនពិត និងជាការគិតថា ការសម្លាប់និស្ស័យសាច់ឈាម វាប្រសើរជាង....[លោកអ្នកអាចសរសេរឈ្មោះអំពើបាបនៅត្រង់នេះ]»។ ជីវិតគ្រីស្ទបរិស័ទ គឺជាជីវិតនៃភាពជាសិស្ស។ វាត្រូវបានចាប់ផ្តើមឡើង ដោយការក្លាយជាសិស្សរបស់ព្រះគ្រីស្ទ។

## ហេតុអ្វីត្រូវបន្តបង្កើតសិស្សទៀត?

ប៉ុន្តែ ជីវិតគ្រីស្ទបរិស័ទក៏ជាជីវិតដែលត្រូវបង្កើតសិស្សផ្សេងទៀតដែរ។ សិស្សបង្កើតឲ្យមានសិស្សផ្សេងទៀត។ យើងដើរតាមព្រះអម្ចាស់ ដែលបានហៅមនុស្សដទៃផ្សេងឲ្យបានដើរតាម ដោយការហៅអ្នកផ្សេងឲ្យដើរតាមទ្រង់ដែរ។ ហេតុអ្វីបានជាយើងធ្វើបែបនេះ? គឺដើម្បីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។

## សេចក្តីស្រឡាញ់

ការជំរុញចិត្តយើងឲ្យបង្រៀនអ្នកដទៃគឺជាការស្រឡាញ់របស់ព្រះ ហើយមិនមែនចាប់ផ្តើមជាមួយអ្វីដែលតិចជាងនោះទេ។ ព្រះបានស្រឡាញ់យើងនៅក្នុងព្រះគ្រីស្ទ ដូច្នេះហើយ យើងត្រូវស្រឡាញ់ទ្រង់វិញ។ ហើយរបៀបមួយដែលយើងស្រឡាញ់

ទ្រង់ គឺជាការស្រឡាញ់អស់អ្នកដែលទ្រង់បានដាក់នៅជុំវិញយើង។

ពេលមានអាចារ្យម្នាក់សួរព្រះយេស៊ូវថា តើបញ្ញត្តិណាសំខាន់ជាងគេទាំងអស់ នោះព្រះយេស៊ូវមានបន្ទូលឆ្លើយថា “ឯងត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកម្លាំងនៃឯង” (ម៉ាកុស ១២:៣០)។ អ្វីដែលព្រះសព្វព្រះទ័យចង់បានបំផុតពីលោកអ្នក គឺទ្រង់ចង់ឲ្យលោកអ្នកស្រឡាញ់ទ្រង់តែមួយអង្គគត់ គឺពីរាល់ការខិតខំ ការជំរុញចិត្ត សេចក្តីប៉ងប្រាថ្នា សេចក្តីសង្ឃឹម ការគិត ការផ្តល់ហេតុផល កម្លាំងថាមពល ដែលអ្វីទាំងអស់នេះត្រូវបានដឹង ហើយបន្សុទ្ធ និងបានទូន្មានប្រដៅដោយព្រះបន្ទូលរបស់ទ្រង់។

តាមពិត លោកអ្នកនឹងបង្ហាញសេចក្តីស្រឡាញ់ព្រះអង្គតែមួយអង្គគត់ តាមរយៈភក្តីភាពរបស់លោកអ្នកចំពោះទ្រង់ ពោលគឺតាមរយៈដែលលោកអ្នកស្រឡាញ់អស់អ្នកដែលព្រះបានបង្កើតមកក្នុងរូបអង្គទ្រង់។ អាចារ្យម្នាក់នោះប្រហែលជាបានទូលសួរទៅកាន់ព្រះយេស៊ូវ ដោយគាត់ចង់ដឹងពីបញ្ញត្តិតែ១ប៉ុណ្ណោះ ប៉ុន្តែគាត់ទទួលបានចម្លើយពីរពីទ្រង់ ដែលទ្រង់មានបន្ទូលប្រាប់គាត់ពីបញ្ញត្តិ២៖ ព្រះយេស៊ូវមានបន្ទូលថា “បញ្ញត្តិទី២” គឺថា “ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង” គ្មានបញ្ញត្តិណាទៀតធំជាងបទទាំង២នេះទេ (ម៉ាកុស ១២:៣១)។ ការលុបបំបាត់បញ្ញត្តិទី២ចោល គឺដូចជាលុបបំបាត់ចោលបញ្ញត្តទី១ដែរ។ សេចក្តីស្រឡាញ់ចំពោះព្រះ គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីស្រឡាញ់របស់លោកអ្នកចំពោះអ្នកជិតខាងដូចគ្នាដែរ។ ហើយសេចក្តីស្រឡាញ់ចំពោះព្រះ ត្រូវបង្ហាញនៅក្នុងសេចក្តីស្រឡាញ់ចំពោះអ្នកជិតខាងរបស់យើងដែរ។ នេះគឺជាការបំពេញតួនាទីសម្រាប់សេចក្តីស្រឡាញ់។

សេចក្តីស្រឡាញ់របស់ព្រះចំពោះយើង បានចាប់ផ្តើមលក្ខណៈឆ្លងពីមួយទៅមួយ។ ទ្រង់បានស្រឡាញ់យើង បន្ទាប់មកយើងត្រូវស្រឡាញ់ទ្រង់វិញ បន្ទាប់មកទៀតយើងត្រូវស្រឡាញ់អ្នកដទៃ។ សាវ័ក យ៉ូហាន បានច្របាច់បញ្ចូលសេចក្តីស្រឡាញ់ទាំងនេះថា៖ “ឯយើងរាល់គ្នា យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន។ បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូន

វិញ អ្នកនោះជាអ្នកកុហក ដ្បិតអ្នកណាដែលមិនស្រឡាញ់បងប្អូន ដែលបានមើលឃើញទៅហើយ នោះធ្វើដូចម្ដេចឡើយឲ្យស្រឡាញ់ដល់ព្រះដែលមើលមិនឃើញទៅបាន។ មួយទៀត យើងបានទទួលបញ្ញត្តិនេះពីព្រះមកថា អ្នកណាដែលស្រឡាញ់ដល់ព្រះ នោះត្រូវតែស្រឡាញ់ដល់បងប្អូនដែរ» (១យ៉ូហាន ៤:១៩-២១)។

នៅពេលដែលលោកអ្នកអះអាងថា លោកអ្នកស្រឡាញ់ព្រះ ប៉ុន្ដែមិនមានការបង្ហាញសេចក្ដីស្រឡាញ់នោះចំពោះអ្នកជិតខាងរបស់ខ្លួន នោះគឺលោកអ្នកកំពុងតែបង្ហាញថា ខ្លួនកំពុងតែស្រឡាញ់ព្រះក្លែងក្លាយទេ ហើយវាជាទម្រង់មួយទៀតនៃការថ្វាយបង្គំរូបព្រះក្លែងក្លាយ។ នៅក្នុងខគម្ពីរទាំងនេះ ព្រះយេស៊ូវ និងសាវ័កយ៉ូហាន បានភ្ជាប់ទំនាក់ទំនងមួយចំនួនឡើងវិញ បន្ទាប់ពីយើងបានធ្លាក់ក្នុងអំពើបាប គឺជាការភ្ជាប់រវាងការដែលព្រះជាម្ចាស់ស្រឡាញ់យើង និងការដែលយើងស្រឡាញ់អ្នកជិតខាងរបស់យើង។

ការបង្រៀនអ្នកដទៃដោយស្ម័គ្រចិត្តធ្វើអំពើល្អខាងឯវិញ្ញាណ ដើម្បីជួយពួកគេឲ្យដើរតាមព្រះគ្រីស្ទ គឺបានបង្ហាញពីសេចក្ដីស្រឡាញ់នេះចំពោះព្រះ និងអ្នកដទៃព្រមទាំងធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់សេចក្ដីស្រឡាញ់មួយនេះ។

## ការស្ដាប់បង្គាប់

ប៉ុន្ដែ សេចក្ដីស្រឡាញ់របស់យើងត្រូវចងភ្ជាប់នឹងការស្ដាប់បង្គាប់របស់យើងចំពោះព្រះដែរ។ ព្រះយេស៊ូវបានបង្រៀនថា «បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ» (យ៉ូហាន ១៤:១៥; យ៉ូហាន ១៤:២៣; ១៥:១២-១៤)។ ហើយតើបញ្ញត្តិអ្វីដែលទ្រង់បានបង្គាប់? «ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្ដីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង។ ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប» (ម៉ាថាយ ២៨:១៩-២០)។ ការនាំអ្នកដទៃផ្សេងទៀតឲ្យស្ដាប់បង្គាប់ចំពោះបញ្ញត្តិរបស់ព្រះយេស៊ូវគឺជាផ្នែកមួយ

នៃការស្តាប់បង្គាប់របស់យើងដែរ។

បញ្ញត្តិចុងក្រោយរបស់ព្រះយេស៊ូវ គឺមិនមែនជំរុញឲ្យសិស្សរបស់ទ្រង់ ធ្វើការតស៊ូប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់ចក្រភពរ៉ូម ឬធ្វើការសងសឹកចំពោះអស់អ្នកដែលបានធ្វើគត់ទ្រង់នោះទេ។ ផ្ទុយទៅវិញ ព្រះយេស៊ូវបានទតមើលទៅអ្នកដើរតាមទ្រង់ ហើយមានបន្ទូលប្រាប់ពួកគេថា «ឲ្យបង្កើតសិស្ស» មិនមែនគ្រាន់តែឲ្យពួកគេធ្វើជាសិស្សទ្រង់ប៉ុណ្ណោះទេ។ ព្រះយេស៊ូវមិនបានមានបន្ទូលបែងចែករវាង អស់អ្នកដែលទទួលសេចក្តីបង្គាប់នេះ និងសិស្សដែលនឹងមាននៅពេលក្រោយនោះទេ។ ទ្រង់បានមានព្រះបន្ទូលសន្យាថា ទ្រង់នឹងមានព្រះវត្តមានគង់នៅជាមួយគ្រីស្ទបរិស័ទទាំងអស់ ដូចនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបានយាងមកនៅថ្ងៃបុណ្យទី៥០ ដែលនឹងបង្ហាញក្នុងពេលឆាប់ៗខាងមុខនេះ។ ហើយព្រះបន្ទូលសន្យានោះ មានរហូតដល់ចុងបំផុតអស់កល្បដែលយូរលើសពីជីវិតរបស់សាវ័កទ្រង់នៅលើផែនដីនេះទៅទៀត។ ក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូល គ្រីស្ទបរិស័ទទាំងអស់នឹងធ្វើតាមសេចក្តីបង្គាប់នេះ ដោយធ្វើកិច្ចការទៅតាមសមត្ថភាពឱកាស និងការត្រាស់ហៅរបស់ពួកគេ។ មហាបេសកកម្មនេះត្រូវបានផ្តល់ឲ្យដល់អស់អ្នក ដែលចង់ក្លាយជាសិស្សរបស់ព្រះយេស៊ូវ។ បញ្ញត្តិនេះត្រូវបានប្រទានដល់អ្នកជឿគ្រប់រូប នៅគ្រប់សម័យកាល។

ការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ គឺជាមូលដ្ឋានគ្រឹះនៃជំនឿរបស់គ្រីស្ទបរិស័ទ។ តើវាអាចមានភាពច្បាស់លាស់ជាងនេះបានដែរឬទេ? ប្រសិនបើយើងមិនខិតខំបង្កើតសិស្សថ្វាយទ្រង់ នោះទំនងយើងផ្ទាល់គឺមិនមែនជាសិស្សរបស់ព្រះអង្គទេ។

## តើយើងគួរបង្កើតសិស្សនៅឯណា និងដោយរបៀបណា?

ប៉ុន្តែ មានរឿងមួយទៀត ដែលត្រូវកត់សម្គាល់នៅក្នុងបញ្ញត្តិចុងក្រោយរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវបានប្រាប់យើងអំពីទីកន្លែងដែលទ្រង់ចង់ឲ្យយើងបង្កើតសិស្ស៖ គឺនៅក្នុងគ្រប់ចំណោមនៃគ្រប់ទាំងសាសន៍។ ហើយព្រះអង្គក៏ប្រាប់យើងអំពីរបៀបដែលទ្រង់ចង់ឲ្យបង្កើតសិស្សផងដែរ គឺតាមរយៈក្រុមជំនុំរបស់យើង។

តើការបង្កើតសិស្សនៅគ្រប់ទាំងសាសន៍ និងតាមរយៈក្រុមជំនុំរបស់យើងមានន័យដូចម្តេច?

## នៅគ្រប់ទាំងសាសន៍

មុនពេលទ្រង់មានបន្ទូលប្រាប់សិស្សរបស់ទ្រង់ឲ្យបង្កើតសិស្ស ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង ដូច្នេះហើយ ពួកគេត្រូវតែ «ចេញទៅ»។ ព្រះយេស៊ូវមានអំណាច និងការយកព្រះទ័យទុកដាក់ជាសកល។ ហើយសកលភាពនៃអំណាច និងការយកព្រះទ័យទុកដាក់របស់ទ្រង់បាននាំទៅរកសកលភាពនៃបេសកកម្មរបស់យើង៖ យើងនឹងចេញទៅគ្រប់ជាតិសាសន៍ទាំងអស់។ ការបង្កើតសិស្សមិនមែនគ្រាន់តែជាការងារមួយសម្រាប់តែប្រជាជាតិអ៊ីស្រាអែល ឬមជ្ឈិមបូព៌ា ឬអាហ្វ្រិកនោះទេ។ ជំនឿគ្រីស្ទបរិស័ទមិនមែនសម្រាប់តែប្រទេសអឺរ៉ុប ឬប្រទេសអាស៊ីទេ។ ព្រះគ្រីស្ទមានអំណាចគ្រប់ទាំងអស់ ដូច្នេះហើយ យើងនឹងចេញទៅ ដើម្បីបង្កើតឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍។

## តាមរយៈក្រុមជំនុំរបស់យើង

បន្ទាប់ពីព្រះយេស៊ូវមានបន្ទូលប្រាប់សិស្សទ្រង់ឲ្យបង្កើតសិស្ស នោះទ្រង់មានបន្ទូលប្រាប់ពួកគេអំពីរបៀបនៃការបង្កើតសិស្ស គឺតាមរយៈការធ្វើបុណ្យជ្រមុជទឹកឲ្យ និងការបង្រៀនផងដែរ។ ប្រាកដណាស់ បេសកជនម្នាក់ៗ ឬអ្នកផ្សាយដំណឹងល្អម្នាក់ៗ គឺពួកគាត់បានចេញទៅពាសពេញលោកីយ៍នេះ ដើម្បីបង្កើតសិស្ស នៅក្នុងកន្លែងធ្វើការ នៅតាមសាលា នៅតាមផ្ទះរបស់អ្នកជិតខាង មិនថានៅផ្នែកណាមួយ ឬផ្នែកផ្សេងនៃផែនដីនេះក៏ដោយ។ ប៉ុន្តែ ការធ្វើព័ន្ធកិច្ចនៃការធ្វើពិធីបុណ្យជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ និងការបង្រៀនគឺកើតឡើងជាចម្បងតាមរយៈក្រុមជំនុំ។ ក្រុមជំនុំ មិនមែនគ្រាន់តែជាបុគ្គលម្នាក់ៗដែលត្រូវបំពេញនូវមហាបេសកកម្មដែលព្រះយេស៊ូវបានប្រទានមក ក្នុងការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវនោះទេ។ ទាំងនេះគឺជាកិច្ចការរបស់ក្រុមជំនុំទាំងមូល។

ជាការពិតណាស់ ការប្រកបគ្នាល្អ និងការបង្កើតសិស្ស អាចកើតឡើងនៅខាងក្រៅបរិបទនៃសមាជិកភាពរបស់ក្រុមជំនុំ។ ប៉ុន្តែ តាមរយៈព័ន្ធកិច្ចរបស់ក្រុមជំនុំដែលមានពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ គឺយើងទទួលស្គាល់គ្នាទៅវិញទៅមកថា ជាអ្នកដែលមានជំនឿលើព្រះគ្រីស្ទ។ ការនេះជួយទំនាក់ទំនងរបស់យើងនៅក្នុងក្រុមជំនុំឲ្យកាន់តែមានការមើលខុសត្រូវគ្នាទៅវិញទៅមក ហើយការដែលយើងកាន់តែចេះមើលខុសត្រូវគ្នាទៅវិញទៅមក ក៏នឹងនាំឲ្យមានប្រយោជន៍ដល់ព្រលឹងវិញ្ញាណរបស់យើងផងដែរ។ ក្រុមជំនុំ និងពួកចាស់ទុំក៏បង្រៀនយើងផងដែរ ហើយតាមរយៈការនេះ នោះគ្រីស្ទបរិស័ទបានរៀនធ្វើតាមគ្រប់ទាំងសេចក្ដីដែលព្រះយេស៊ូវបានបង្គាប់មក។

ប្រសិនបើគ្រីស្ទបរិស័ទណាម្នាក់ចង់ឲ្យអ្នកដទៃជួយគាត់ក្នុងការដើរតាមព្រះគ្រីស្ទ ហើយគាត់ក៏ចង់ជួយអ្នកដទៃឲ្យដើរតាមព្រះគ្រីស្ទដែរ នោះក្រុមជំនុំគឺជាទីកន្លែងដែលការនេះគួរតែកើតឡើង  គឺទាំងក្រុមជំនុំជួបជុំគ្នាដើម្បីថ្វាយបង្គំ និងទាំងក្រុមជំនុំដែលបញ្ជូនឲ្យមានការចេញទៅបង្កើតសិស្សនៅកន្លែងផ្សេងៗទៀតផងដែរ។ លោក ដេវីដ វែល បានសង្កេតឃើញថា «វាមានភាពងាយស្រួលណាស់ ក្នុងការសង់ក្រុមជំនុំ ដែលមានអ្នកកំពុងស្វែងរកការជួបជុំ ប៉ុន្តែវាពិបាកណាស់ ក្នុងការសង់ក្រុមជំនុំ ដែលមានសេចក្ដីជំនឿតាមព្រះគម្ពីរ ហើយមានភាពពេញវ័យនៅក្នុងភាពជាសិស្សដ៏ពិតប្រាកដរបស់ព្រះយេស៊ូវ»[១]។

## សេចក្ដីសន្និដ្ឋាន

គោលដៅនៃសៀវភៅនេះ គឺដើម្បីជួយលោកអ្នកឲ្យមានការយល់ដឹងពីការបង្កើតសិស្សដោយយោងតាមព្រះគម្ពីរ និងដើម្បីលើកទឹកចិត្តលោកអ្នកឲ្យស្ដាប់បង្គាប់ព្រះគ្រីស្ទ។ ដូចដែលខ្ញុំបានលើកឡើងថា ការបង្កើតសិស្សដោយយោងតាមព្រះគម្ពីរ គឺការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ ដោយមានចិត្តចង់ធ្វើការល្អខាងឯ

---

១ លោក David F. Wells, *Above All Earthly Pow'rs: Christ in a Postmodern World* (Grand Rapids, MI: Eerdmans, ឆ្នាំ២០០៥), ទំព័រ១១៩។

វិញ្ញាណចំពោះពួកគេ។ ហើយការបង្កើតសិស្សដោយយោងតាមព្រះគម្ពីរ គឺភាគច្រើនកើតឡើងនៅក្នុងក្រុមជំនុំ និងតាមរយៈក្រុមជំនុំ។ សព្វថ្ងៃនេះ វាមានភាពងាយស្រួលសម្រាប់គ្រីស្ទបរិស័ទក្នុងការខកខានយល់ដឹងអំពីចំណុចនេះ។

ដូច្នេះ នៅពេលលោកអ្នកចូលរួមថ្វាយបង្គំក្នុងព្រះវិហារនៅថ្ងៃអាទិត្យ តើលោកអ្នកគ្រាន់តែសម្លឹងមើលពីអ្វីដែលលោកអ្នកអាចទទួលបាន ឬតើលោកអ្នកក៏បានសម្លឹងមើលវិធីផ្សេងៗទៀត ដើម្បីផ្ដល់ឲ្យដល់អ្នកដទៃដែរឬទេ? ហើយតើលោកអ្នកប្រើប្រាស់ពេលវេលាទទួលទានអាហារ និងពេលទំនេរពេញមួយសប្ដាហ៍របស់លោកអ្នកយ៉ាងដូចម្ដេចខ្លះ? តើលោកអ្នកបានរៀបចំយុទ្ធសាស្ត្រសម្រាប់ការផ្សាយដំណឹងល្អ ឬសម្រាប់វិធីផ្សេងៗទៀត ដើម្បីធ្វើការស្អាងដល់គ្រីស្ទបរិស័ទផ្សេងទៀតដែរឬទេ?

ប្រហែលជាលោកអ្នកបានគិតថា លោកអ្នកពិតជាត្រូវការនរណាម្នាក់ជាមុនសិនក្នុងការជួយលោកអ្នកឲ្យដើរតាមព្រះយេស៊ូវ មុនលោកអ្នកអាចជួយអ្នកផ្សេងទៀតឲ្យដើរតាមព្រះយេស៊ូវបានដែរ។ ការក្លាយជាសិស្ស ពិតជាមានសារៈសំខាន់ណាស់។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលបង្គាប់លោកអ្នកឲ្យទៅបង្កើតសិស្ស។ ហើយប្រាកដណាស់ ផ្នែកនៃការក្លាយជាសិស្ស គឺជាការជួយអ្នកដទៃធ្វើជាសិស្សរបស់ទ្រង់ដែរ។ ផ្នែកនៃការរីកលូតលាស់ទៅក្នុងភាពពេញវ័យនៃសេចក្ដីជំនឿ គឺជាការជួយអ្នកដទៃឲ្យរីកចម្រើនទៅក្នុងភាពពេញវ័យនៃសេចក្ដីជំនឿរបស់ពួកគេដូចគ្នា។ ព្រះសព្វព្រះទ័យចង់ឲ្យលោកអ្នកនៅក្នុងក្រុមជំនុំ មិនមែនដើម្បីឲ្យលោកអ្នកគ្រាន់តែបំពេញតម្រូវការខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែដើម្បីឲ្យលោកអ្នកត្រៀមខ្លួនជាស្រេចទទួលបានសមត្ថភាព ដើម្បីឲ្យលោកអ្នកអាចប្រដាប់ខ្លួន និងលើកទឹកចិត្តថែទាំអ្នកដទៃទៀតនៅក្នុងក្រុមជំនុំដែរ។

ជំនឿគ្រីស្ទបរិស័ទ ដែលជាសេចក្ដីជំនឿដោយយោងតាមព្រះគម្ពីរ គឺមិនមែនសម្រាប់បុគ្គលម្នាក់នោះទេ ឬក៏ជាមនុស្សដែលនៅតែម្នាក់ឯងនោះដែរ ដែលមិនត្រូវការអ្នកដទៃនោះឡើយ។ វាគឺជាជំនឿសម្រាប់សិស្សរបស់ព្រះគ្រីស្ទ ជាអ្នកដើរតាមទ្រង់ ដែលជាអ្នកដឹកនាំអ្នកដទៃឲ្យបានដើរតាមព្រះយេស៊ូវដូចគ្នាផងដែរ។

ផ្នែកទី៖១

# តើការបង្កើតសិស្សជាអ្វី?

ជំពូកទី១

# លោកអ្នកកំពុងតែមានឥទ្ធិពល ដល់អ្នកដទៃ

ចរិតលក្ខណៈ ឬលក្ខណសម្បត្តិ របស់ព្រះប្រាប់យើងថា ទ្រង់មានលក្ខណៈយ៉ាងដូចម្តេច។ ហើយទេវវិទូ បានបែងចែកលក្ខណសម្បត្តិរបស់ទ្រង់ជាពីរប្រភេទ គឺលក្ខណសម្បត្តិដែលទ្រង់បានចែកចាយជាមួយមនុស្ស និងលក្ខណសម្បត្តិដែលទ្រង់មិនអាចចែកចាយជាមួយមនុស្សបាន។ លក្ខណសម្បត្តិដែលទ្រង់ចែកចាយដល់មនុស្ស មានដូចជាការស្រឡាញ់របស់ព្រះអង្គ និងភាពបរិសុទ្ធរបស់ទ្រង់។ យើងក៏អាចស្រឡាញ់ និងមានភាពបរិសុទ្ធបានដែរ។ លក្ខណសម្បត្តិដែលទ្រង់មិនអាចចែកចាយដល់មនុស្សបាន គឺជាលក្ខណៈដែលមានតែទ្រង់មួយអង្គគត់ដែលមាន។ លក្ខណសម្បត្តិដែលទ្រង់មិនអាចចែកចាយដល់មនុស្ស គឺជាលក្ខណសម្បត្តិដូចជា សព្វវត្តមានរបស់ទ្រង់ (ទ្រង់គង់នៅគ្រប់ទីកន្លែង) ឬសព្វញ្ញូញាណ (ទ្រង់ជ្រាបគ្រប់ការទាំងអស់)។

លក្ខណសម្បត្តិមួយរបស់ព្រះដែលទ្រង់មិនអាចចែកចាយដល់មនុស្សបាន គឺថា ទ្រង់មិនចេះប្រែប្រួល។ យើងតែងតែមានការផ្លាស់ប្តូរ ប៉ុន្តែទ្រង់មិនផ្លាស់ប្តូរ ឬប្រែប្រួលនោះទេ។

## យើងគឺជាមនុស្សដែលតែងតែប្រែប្រួល

ប្រហែលជាលោកអ្នកកំពុងគិតថា “លោកគ្រូមិនស្គាល់ស្វាមីខ្ញុំទេ។ គាត់មិនដែលប្តូរទម្លាប់ចាស់របស់គាត់នោះទេ!” នេះគឺជាការពិត។ ខ្ញុំពិតជាមិនស្គាល់គាត់មែន។ ប៉ុន្តែ ខ្ញុំសន្យានឹងលោកអ្នកថា មនុស្សយើងតែងតែមានការផ្លាស់ប្តូរមិនថា ស្វាមីអ្នកមានទម្លាប់ចាក់ឫសយ៉ាងជ្រៅយ៉ាងណាក៏ដោយ ក៏យើងជាមនុស្សនៅអាច

មានការផ្លាស់ប្តូរបានដែរ។

យើងបានចាប់កំណើតមក បានរីកធំធាត់ឡើង បានចូលដល់វ័យចំណាស់ និងរហូតដល់យើងស្លាប់ទៅវិញ។ ទាំងអស់នេះ គឺជាការផ្លាស់ប្តូររបស់យើង។ យើងរៀនពីរឿងរ៉ាវមួយចំនួនដែលយើងមិនធ្លាប់ដឹង ហើយយើងក៏ភ្លេចរឿងរ៉ាវមួយចំនួនដែលយើងធ្លាប់បានដឹងពីមុនមកដែរ។ យើងក៏មានភាពបរិសុទ្ធកាន់តែច្រើនឡើង ឬកាន់តែតិចជាងមុនផងដែរ។ ទាំងអស់នេះ គឺជាការផ្លាស់ប្តូររបស់យើងដូចគ្នា។ ហើយជាការពិតណាស់ ស្ថានភាពមួយចំនួនអាចមានផលប៉ះពាល់មកលើយើងមែន ដែលពេលខ្លះ វាមានប្រយោជន៍ចំពោះយើង តែពេលខ្លះទៀតក៏អាចមានការអាក្រក់ដែរ។

ព្រះទ្រង់មិនផ្លាស់ប្តូរឡើយ ប៉ុន្តែយើងតែងតែផ្លាស់ប្តូរ។ យើងជាស្នាព្រះហស្តទ្រង់បង្កើតដែលមានការផ្លាស់ប្តូរ និងមានការប្រែប្រួល។

ជាងនេះទៅទៀត យើងរស់នៅក្នុងលោកីយ៍ដែលមានជម្លោះខាងឯវិញ្ញាណធ្ងន់ធ្ងរ។ សាវ័ក ពេត្រុស បានយល់ដឹងពីសម្ពាធដែលលោកីយ៍នេះមានមកលើអ្នកអានសំបុត្រគាត់៖ «គេក៏ឆ្ងល់ ដែលអ្នករាល់គ្នាមិនរត់ទៅ តាមសេចក្តីខូចអាក្រក់ដ៏ហូរហៀរ ជាមួយនឹងគេដែរ បានជាគេប្រមាថដល់អ្នករាល់គ្នា» (១ពេត្រុស ៤:៤)។ សាវ័ក ប៉ុល បានសង្កេតឃើញថា មេគ្រប់គ្រងរាជ្យលើអាកាស «ដែលសព្វថ្ងៃនេះបណ្តាលមកក្នុងពួកមនុស្សរឹងចចេស» (អេភេសូរ ២:២)។ ហេតុដូច្នេះហើយ បានជាសាវ័ក ប៉ុល បានដាស់តឿនយើង កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង (រ៉ូម ១២:២)។

លោកគ្រូ អហ្គូស្ទីន (Augustine) ដែលជាគ្រូគង្វាលនៅទ្វីបអាហ្វ្រិកនៅសតវត្សរ៍ទី៥ បានពណ៌នាអំពីជម្លោះខាងឯវិញ្ញាណនេះថា ជាការប៉ះទង្គិចគ្នារវាងទីក្រុងពីរ គឺទីក្រុងរបស់មនុស្ស និងទីក្រុងរបស់ព្រះ។ ហើយទីក្រុងទាំងពីរ គឺកំពុងចង់ជ្រើសរើសពួកយើងសម្រាប់ការងាររបស់ពួកគេ។ មូលដ្ឋានពិតនៅទីនេះ គឺមនុស្សអាចផ្លាស់ប្តូរបាន គឺទាំងភាពវិជ្ជមាន និងភាពអវិជ្ជមាន។

## យើងមានឥទ្ធិពលដល់អ្នកដទៃ ហើយក៏ទទួលឥទ្ធិពលពីអ្នក

## ដទៃដែរ

យើងអាចនិយាយម្យ៉ាងទៀតថា យើងជាមនុស្សដែលមានការបើកចំហ ដើម្បីទទួលឥទ្ធិពល។

កាលពីប៉ុន្មានថ្ងៃមុន ខ្ញុំបានធ្វើដំណើរទៅកាន់ធនាគារដែលមិត្តភក្តិខ្ញុំឈ្មោះ ម៉ាត បានណែនាំឲ្យខ្ញុំទៅ នៅពេលខ្ញុំបានផ្លាស់ប្តូរទីលំនៅរបស់ខ្ញុំទៅរស់នៅក្នុងតំបន់នោះកាលពីម្ភៃឆ្នាំមុន។ បន្ទាប់មក ខ្ញុំបានធ្វើដំណើរពីទីនោះ ទៅហាងកាត់សក់ដែលទីនោះខ្ញុំបានកាត់សក់របស់ខ្ញុំ ហើយជាកន្លែងដដែលដូចគ្នានោះ ដែលលោក ម៉ាត បានណែនាំខ្ញុំ នៅពេលខ្ញុំបានផ្លាស់ប្តូរទីលំនៅរបស់ខ្ញុំទៅរស់នៅតំបន់នោះ កាលពីម្ភៃឆ្នាំមុន។ លោក ម៉ាត បានបង្ហាញខ្ញុំ ពីអ្វីដែលគាត់បានធ្វើនៅទីនោះ ហើយខ្ញុំក៏ចាប់ផ្តើមធ្វើកិច្ចការដូចគ្នា នៅតំបន់នោះដែរ។ លោក ម៉ាត បានបង្រៀនខ្ញុំពីរបៀបរស់នៅក្នុងតំបន់របស់យើង។ ហើយម្ភៃឆ្នាំក្រោយមក ខ្ញុំបានរស់នៅទីនេះ ខ្ញុំអាចរកផ្លូវទៅកាន់ធនាគារ និងហាងកាត់សក់នោះដោយខ្លួនឯង។ សូមលោកអ្នកចងចាំនូវអ្វីដែលព្រះយេស៊ូវមានបន្ទូលនៅត្រង់នេះ៖ អ្នកណាដែលបានគ្រប់លក្ខណ៍ នោះនឹងបានដូចជាគ្រូដែរ (លូកា ៦:៤០)។

តាមពិតទៅ ខ្ញុំចង់យករឿងនេះមកបកស្រាយមួយជំហានបន្ថែមទៀត៖ យើងទាំងអស់គ្នានឹងទទួលរងឥទ្ធិពលពីអ្នកដទៃ ដោយជៀសមិនបាន ហើយយើងនឹងផ្តល់ឥទ្ធិពលរបស់យើងទៅលើអ្នកដទៃផងដែរ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ពីព្រោះពួកម៉ាកអាក្រក់តែងនឹងបង្ខូចកិរិយាល្អ» (១កូរិនថូស ១៥:៣៣) ហើយ «ដំបែតែបន្តិច អាចនឹងធ្វើឲ្យម្សៅទាំងអស់ដោរឡើងបាន» (១កូរិនថូស ៥:៦) ។ មនុស្សជុំវិញខ្លួនលោកអ្នកនឹងមានឥទ្ធិពលលើលោកអ្នក សម្រាប់ជួយឲ្យលោកអ្នកកាន់តែប្រសើរ ឬនាំឲ្យលោកអ្នកកាន់តែអាក្រក់ជាងនេះ។ ហើយលោកអ្នកក៏នឹងជះឥទ្ធិពលដល់មនុស្សជុំវិញខ្លួនលោកអ្នកផងដែរ មិនថាឲ្យកាន់តែប្រសើរ ឬក៏កាន់តែអាក្រក់។ សូម្បីតែឪពុកដែលមិនចេះនៅផ្ទះជាមួយនឹងកូនៗ ក៏កំពុងតែជះឥទ្ធិពលទៅដល់កូនៗរបស់គាត់ តាមរយៈការអវត្តមានរបស់គាត់ផងដែរ។ គ្មាននរណាម្នាក់ក្នុងចំណោមពួកយើងដែលត្រូវបានហៅថា ជាកោះមួយ

ដាច់ដោយឡែកនោះទេ។

## តើលោកអ្នកនឹងប្រើប្រាស់ឥទ្ធិពលរបស់លោកអ្នកដោយរបៀបណា?

មានសំណួរតែមួយគត់ដែលបានសួរទៅកាន់លោកអ្នកគឺ តើលោកអ្នកនឹងប្រើប្រាស់ឥទ្ធិពលរបស់លោកអ្នកដោយរបៀបណា?

ប្រហែលជាលោកអ្នកមិនធ្លាប់បានគិតថា លោកអ្នកមានឥទ្ធិពលដល់អ្នកដទៃនោះទេ ប៉ុន្តែលោកអ្នកកំពុងតែមានហើយ។ ព្រះបានបង្កើតលោកអ្នកឲ្យដូចរូបអង្គទ្រង់ផ្ទាល់ ហើយទ្រង់ពិតជាមានឥទ្ធិពល និងសំខាន់ណាស់ សូម្បីតែអ្នកដែលទ្រង់បានបង្កើតមកក្នុងរូបអង្គរបស់ទ្រង់ក៏មានឥទ្ធិពល និងសំខាន់ផងដែរ។ ជីវិតរបស់លោកអ្នកនឹងមានឥទ្ធិពលដល់មនុស្សជុំវិញខ្លួន ទោះបីជាលោកអ្នកកំពុងស្ថិតនៅក្នុងឋានៈដ៏ទាបក៏ដោយ ឬលោកអ្នកមិនមានអារម្មណ៍ថា លោកអ្នកត្រូវបានទទួលការគោរពពីមនុស្សនៅជុំវិញលោកអ្នកក៏ដោយ។

សូមពិចារណាអំពីរបៀបដែលសាវ័ក ពេត្រុស បានណែនាំអ្នកបម្រើរបស់ចៅហ្វាយដែលកាច ឬភរិយាមានស្វាមីដែលមិនជឿព្រះ (១ពេត្រុស ២:១៨-២០; ៣:១)។ គាត់បានដឹងថា អ្នកទាំងពីរមានឥទ្ធិពលបាន ដោយសារភាពស្មោះត្រង់របស់ពួកគេ។ សាវ័ក ពេត្រុស បានមានប្រសាសន៍ថា ភរិយាដែលមានស្វាមីមិនមែនជាគ្រីស្ទបរិស័ទ នោះពួកគាត់នឹងទាញចិត្តស្វាមីមកបាន «ដោយសារកិរិយាល្អក្រៅពីពាក្យសម្ដី» នៅក្នុងជីវិតរបស់ពួកគាត់ (គខប)។ ហើយព្រះយេស៊ូវគ្រីស្ទគឺជាគំរូសម្រាប់គ្រីស្ទបរិស័ទគ្រប់រូបក្នុងការធ្វើកិច្ចការទាំងនេះ។ តាមរយៈការរងទុក្ខរបស់ទ្រង់ ទ្រង់បាននាំមកនូវការព្យាបាល និងជីវិតដល់យើងរាល់គ្នា (១ពេត្រុស ២:២១-២៥)។

និយាយម្យ៉ាងទៀត លោកអ្នកនឹងមានឥទ្ធិពលមកលើអ្នកដទៃ តាមរយៈអំណោយទានរបស់លោកអ្នក។ ប៉ុន្តែលើសពីនេះទៅទៀត លោកអ្នកមានឥទ្ធិពលខាងឯផ្នែកដំណឹងល្អ ហើយជាការគួរឲ្យអស្ចារ្យណាស់ ការមានឥទ្ធិពលនៅក្នុងជីវិតរបស់អ្នកដទៃមិនមែនមកតាមរយៈតែកម្លាំងរបស់លោកអ្នកប៉ុណ្ណោះទេ ប៉ុន្តែ

ក៏មកតាមរយៈភាពកម្សោយផងដែរ។ ព្រះជាម្ចាស់សព្វព្រះទ័យធ្វើការនេះ ដើម្បីឲ្យព្រះចេស្ដារបស់ព្រះអង្គបានបង្ហាញតាមរយៈភាពកម្សោយរបស់យើង ហើយទ្រង់ក៏ទទួលបានសិរីល្អតាមរយៈការទាំងអស់នោះផងដែរ (២កូរិនថូស ១២:៩)។

ដូច្នេះ ខ្ញុំនឹងនិយាយម្ដងទៀតថា លោកអ្នកមានឥទ្ធិពលដល់អ្នកដទៃ។ តើលោកអ្នកនឹងប្រើប្រាស់ឥទ្ធិពលរបស់លោកអ្នកដោយរបៀបណា? នៅពេលលោកអ្នកបោះជំហានចេញពីច្រកផ្លូវនៃជីវិតនេះ ហើយលោកអ្នកឈានជើងចូលក្នុងភាពអស់កល្ប តើលោកអ្នកនឹងបន្សល់ទុកអ្វីខ្លះ នៅក្នុងជីវិតរបស់អ្នកដទៃ?

យោងតាមព្រះគម្ពីរ សិស្សរបស់ព្រះគ្រីស្ទក៏ត្រូវតែបង្រៀនអ្នកដទៃឲ្យបានក្លាយជាសិស្សទ្រង់ដែរ ដោយតាមរយៈការជួយពួកគេឲ្យដើរតាមព្រះគ្រីស្ទ។ តើនោះជារបៀបដែលលោកអ្នកកំពុងបញ្ចេញឥទ្ធិពលរបស់លោកអ្នកឬទេ?

## ជំពូកទី២

# តម្រង់ទិសទៅរកអ្នកដទៃ

យើងទាំងអស់គ្នាសុទ្ធតែធ្លាប់បានឃើញ សត្វជ្រូកដើរទៅរកស្នូកស៊ីចំណីវា។ ទិដ្ឋភាពបែបនោះ នឹងមានការរុញ ការច្រាន ការបញ្ចេញខ្យល់ខ្លាំងៗតាមច្រមុះ និងសត្វជ្រូកទាំងនោះ បានព្យាយាមលេបចំណីឲ្យបានច្រើនតាមដែលពួកវាអាចធ្វើទៅបាន ដោយមិនគិតពីសត្វជ្រូកដទៃផ្សេងទៀតទេ។

នេះជាសំណួរ គួរឲ្យអស់សំណើចមួយ ដែលតម្រូវឲ្យលោកអ្នកពិចារណាបន្តិចៈ តើនោះជារបៀបដែលលោកអ្នកបានចូលរួមថ្វាយបង្គំនៅក្នុងព្រះវិហារកាលពីថ្ងៃអាទិត្យមុនឬ?

ទេ ខ្ញុំមិនបានថា លោកអ្នកជាសត្វជ្រូកទេ។ ប៉ុន្តែ សូមឈប់បន្តិច និងពិចារណាថាៈ តើលោកអ្នកបានមកដល់ព្រះវិហារទាន់ម៉ោងដែរឬទេ? តើលោកអ្នកបានសួរសុខទុក្ខអ្នកដទៃដែរឬទេ? តើលោកអ្នកបានចាប់កន្លែងអង្គុយដែលល្អជាងគេបំផុតមែនឬ? តើលោកអ្នកបានស្វាគមន៍អ្នកមកលេងក្រុមជំនុំដែរឬទេ? ហើយបន្ទាប់មក តើលោកអ្នកបានត្រឡប់ទៅផ្ទះភ្លាមៗ ឬក៏បានចំណាយពេលលើកទឹកចិត្តអ្នកដទៃជាមុនសិនដែរឬទេ? ការសម្រេចចិត្តក្នុងសកម្មភាពនីមួយៗនេះបានផ្តល់ឱកាសឲ្យលោកអ្នកចំណាយពេលវេលាជាមួយអ្នកដទៃ ហើយក៏បានផ្តល់ឱកាសឲ្យលោកអ្នកចូលរួមក្នុងកិច្ចការរបស់ព្រះគ្រីស្ទដែរ។ ឬក៏ពួកគាត់បានផ្តល់ឲ្យលោកអ្នកនូវឱកាសមួយ ដើម្បីពិនិត្យមើលខ្លួនឯង ដែលអាចធ្វើអ្វីដែលល្អបំផុតសម្រាប់ខ្លួនផ្ទាល់បាន។ ដូច្នេះ តើវាជារបៀបមួយណា? តើលោកអ្នកបានអធិស្ឋាន ហើយគិតទុកជាមុនអំពីរបៀបដែលលោកអ្នកអាចប្រទានពរដល់អ្នកដទៃ តាមរយៈឱកាសទាំងនោះដែរឬទេ?

ការធ្វើជាសិស្សរបស់ព្រះយេស៊ូវ មានន័យថា ជាការតម្រង់ទិសជីវិតរបស់

យើងទៅរកអ្នកដទៃ ដូចដែលព្រះយេស៊ូវបានធ្វើអញ្ចឹងដែរ។ វាមានន័យផងដែរថា យើងត្រូវខិតខំធ្វើការ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ។ សេចក្ដីស្រឡាញ់ចំពោះអ្នកដទៃនេះ គឺជាដួងចិត្តនៃការបង្កើតសិស្ស។ យើងបានកំណត់គោលបំណងរបស់យើងក្នុងការបម្រើអ្នកដទៃសម្រាប់ប្រយោជន៍ព្រះគ្រីស្ទ ដ្បិតព្រះគ្រីស្ទបានយាងមកផែនដីនេះ មិនមែនឲ្យគេបម្រើទេ គឺដើម្បីនឹងបម្រើគេវិញ ហើយនិងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង (ម៉ាកុស ១០:៤៥)។ បុគ្គលដែលចំណាយជីវិតរបស់ខ្លួនក្នុងការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវគឺជាបុគ្គលដែលតម្រង់ទិសជីវិតរបស់ខ្លួនទៅកាន់អ្នកដទៃ។ គាត់ខិតខំធ្វើការដោយអំណាចព្រះចេស្ដានៃព្រះ ដើម្បីប្រកាសអំពីព្រះនាមព្រះគ្រីស្ទ ហើយបង្ហាញអ្នកដទៃពីភាពពេញវ័យនៃសេចក្ដីជំនឿក្នុងព្រះគ្រីស្ទ។ នោះហើយគឺជាលំនាំដែលយើងបានមើលឃើញនៅក្នុងព្រះគម្ពីរ។

## គំរូតាមព្រះគម្ពីរ

មុនពេលដែលព្រះគម្ពីរបញ្ចេញព្រះនាមរបស់ព្រះយេស៊ូវ ព្រះអម្ចាស់បានបង្កើតគ្រួសារ ដើម្បីបង្ហាញយើងអំពីសារៈសំខាន់នៃការតម្រង់ទិសជីវិតរបស់យើងទៅកាន់អ្នកដទៃ។ សូមពិចារណាអំពីរបៀបដែលព្រះបានបង្កើតយើងឲ្យក្លាយជាឪពុកម្ដាយ។ ទ្រង់បានដាក់នៅក្នុងនិស្ស័យធម្មជាតិរបស់យើងនូវបំណងប្រាថ្នា ដើម្បីផ្ដល់ឲ្យនូវការយកចិត្តទុកដាក់ដោយក្ដីស្រឡាញ់ដ៏ច្រើន ដល់ការចិញ្ចឹមបីបាច់ ការថែទាំ និងដឹកនាំគាត់ ឆ្ពោះទៅរកភាពពេញវ័យ។

បន្ទាប់មក នៅក្នុងប្រទេសអ៊ីស្រាអែលបុរាណ ទ្រង់បានប្រើអំណាចនៃទំនាក់ទំនងឪពុកម្ដាយទាំងនេះ ដើម្បីធ្វើការងាររបស់ទ្រង់ ដូចជាខ្សែទឹកដែលត្រូវបង្ហូរដោយព្រះបន្ទូលរបស់ទ្រង់។ ហេតុដូច្នេះហើយបានជាលោក ម៉ូសេ បានផ្ដល់បញ្ញត្តិដប់ប្រការទៅដល់ប្រជាជាតិអ៊ីស្រាអែល។ លោកបានមានប្រសាសន៍ប្រាប់មកជនជាតិអ៊ីស្រាអែលឲ្យស្រឡាញ់ព្រះ។ បន្ទាប់មក លោកក៏បានបង្គាប់ប្រជាជនអ៊ីស្រាអែលថា៖ «សេចក្ដីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ។ ត្រូវឲ្យប្រិតប្រៀនសេចក្ដីទាំងនេះដល់កូនចៅឯង ព្រមទាំងនិយាយដំណាល ក្នុងកាលដែលអង្គុយនៅក្នុងផ្ទះហើយដើរតាមផ្លូវ ក្នុងកាល

ដែលដេក ហើយក្រោកឡើងផង»  (ចោទិយកថា ៦:៦-៧)។ នៅត្រង់នេះ ព្រះបាន ប្រទាននូវមេរៀនមួយដល់យើងក្នុងការបង្រៀនដល់មនុស្សម្នាក់ផ្សេងទៀត។ ការ បង្កើតសិស្ស គឺរាប់បញ្ចូលការនាំចំណេះដឹងអំពីព្រះ និងព្រះបន្ទូលទ្រង់ទៅកាន់ អ្នកដទៃនៅគ្រប់ពេលវេលានៃជីវិតរបស់យើង។

ក្រៅពីគ្រួសារផ្ទាល់ ព្រះគម្ពីរគឺពោរពេញដោយទំនាក់ទំនង  ដែលមានមនុស្ស ម្នាក់បង្រៀនអ្នកដទៃទៀត។ សូមគិតអំពីរបៀបដែលលោក ម៉ូសេ បានលើកតាំង លោក យ៉ូស្វេ ដើម្បីស្នងតំណែងបន្តពីគាត់ ហើយលោក អេលី ជាមួយលោក សាំយូអែល និងលោក អេលីយ៉ា ជាមួយលោក អេលីសេ។ [លោក ម៉ូសេ បាន ចំណាយពេលជាច្រើនជាមួយលោក យ៉ូស្វេ។ លោក អេលី បានចំណាយពេល ជាច្រើនជាមួយលោក សាំយូអែល។ លោក អេលីយ៉ា បានចំណាយពេលជាច្រើន ជាមួយលោក អេលីសេ។]

ពិតណាស់ អ្នកបង្កើតសិស្សដ៏ល្បីល្បាញបំផុត គឺព្រះយេស៊ូវគ្រីស្ទ។ ជំនឿ គ្រីស្ទបរិស័ទមិនមែនបានចាប់ផ្ដើមជាមួយនឹងការដាក់លក់ផលិតផលនៅទីផ្សារ ដ៏ធំនោះទេ។ វាក៏មិនមែនជាប្រព័ន្ធផ្សព្វផ្សាយ  ដែលបានផ្សព្វផ្សាយ២៤ម៉ោង ក្នុងមួយថ្ងៃ ឬ៧ថ្ងៃក្នុងមួយសប្ដាហ៍អំពីគ្រប់ពេលវេលានៃការធ្វើដំណើររបស់ព្រះ គ្រីស្ទនោះទេ។ ជំនឿគ្រីស្ទបរិស័ទបានចាប់ផ្ដើមដោយការចូលរួមនូវទំនាក់ទំនង ផ្ទាល់ក្នុងចំណោមក្រុមមនុស្សតូចមួយ ដែលមានអ្នកដទៃផ្សេងទៀតក្នុងរយៈពេល លើសពី-បីឆ្នាំ។

ពិតណាស់ ជាញឹកញាប់ ហ្វូងមនុស្សបានមករកព្រះយេស៊ូវ ហើយពេល ខ្លះពួកគេឮអំពីការអស្ចារ្យរបស់ទ្រង់បានសាយភាយដូចជាភ្លើងឆេះព្រៃអញ្ចឹង ដែរ។ ប៉ុន្តែ ក្នុងហ្វូងមនុស្សដ៏ច្រើននោះ ក៏មានមួយក្រុមតូចជាសិស្សរបស់ទ្រង់ ផងដែរ ដែលព្រះយេស៊ូវបានត្រាស់ហៅពួកគេមកឲ្យដើរជាមួយទ្រង់។ ទ្រង់បាន វិនិយោគពេលវេលារបស់ទ្រង់ជាពិសេសនៅក្នុងជីវិតរបស់ពួកគេ។ ដំណឹងល្អតាម រយៈលោក ម៉ាកុស បានប្រាប់យើងថា ព្រះយេស៊ូវ «មានព្រះបន្ទូលហៅអស់អ្នក ដែលទ្រង់សព្វព្រះហឫទ័យចង់ហៅ ហើយអ្នកទាំងនោះក៏ចូលមកឯទ្រង់។ រួច ទ្រង់តម្រូវឲ្យសិស្សដប់ពីរនាក់បាននៅជាមួយនឹងទ្រង់ (ដែលទ្រង់បានដាក់ឈ្មោះ

ឲ្យពួកគេថា ជាសាវ័កផងដែរ) ដើម្បីទ្រង់បានចាត់គេ ឲ្យចេញទៅប្រកាសប្រដៅ» (ម៉ាកុស ៣:១៣-១៤) ។

ពួកអ្នកទាំងដប់ពីរនាក់នោះបានប្រកាសថា ព្រះយេស៊ូវគឺជាព្រះមេស្ស៊ី។ ភាគច្រើន ពួកគេបានចំណាយពេលជាច្រើនរបស់ខ្លួនជាមួយទ្រង់។ ហើយទ្រង់មានព្រះទ័យចង់ឲ្យពួកគេ «នៅជាមួយនឹងទ្រង់» ដែរ។ (ខ្ញុំពិតជាចូលចិត្តឃ្លានេះណាស់!) នៅក្នុងពួកអ្នកទាំងដប់ពីរនាក់ ទ្រង់បានបង្ហូរការបង្រៀនរបស់ទ្រង់ជាពិសេស ទៅកាន់សិស្សទ្រង់បីនាក់គឺៈ សាវ័ក ពេត្រុស សាវ័ក យ៉ាកុប និងសាវ័ក យ៉ូហាន។

ប៉ុន្តែ លោកអ្នកអាចនឹងនិយាយថា «ជាការពិតណាស់ ទ្រង់អាចធ្វើបែបនេះបាន ដោយព្រោះទ្រង់គឺជាព្រះយេស៊ូវ។ ទ្រង់គឺជាព្រះ»។

ដូច្នេះ សូមយើងពិចារណាអំពីគំរូរបស់សាវ័ក ប៉ុល។ កណ្ឌគម្ពីរ កិច្ចការ ជំពូក១៦ បានពណ៌នាអំពីដំណើរបេសកកម្មមួយរបស់សាវ័ក ប៉ុល។ ប៉ុន្តែ ជំពូក១៦នេះបានចាប់ផ្តើមជាមួយការណែនាំយើងឲ្យស្គាល់សិស្សម្នាក់របស់សាវ័ក ប៉ុល ដែលមានឈ្មោះថាលោក ធីម៉ូថេ ហើយនៅក្នុងព្រះគម្ពីរ កិច្ចការ ១៦:៣ បានប្រាប់យើងថា «សាវ័ក ប៉ុល ចង់ឲ្យ ធីម៉ូថេ ទៅជាមួយគាត់»។ ដូចគ្នាទៅនឹង ព្រះយេស៊ូវ និងពួកសិស្សទ្រង់ដែរ សាវ័ក ប៉ុល ក៏ចង់ឲ្យលោក ធីម៉ូថេ នៅជាមួយគាត់ និងធ្វើដំណើរជាមួយគាត់ ដើម្បីឲ្យលោក ធីម៉ូថេ បានចូលរួមជាមួយគាត់ក្នុងកិច្ចការនៃនគរស្ថានសួគ៌។ វាមិនពិបាកទេក្នុងការសន្និដ្ឋានថា សាវ័ក ប៉ុល បានបង្រៀនលោក ធីម៉ូថេ ដូចជាឪពុកបានបង្រៀនដល់កូនប្រុសរបស់គាត់ ក្នុងកណ្ឌគម្ពីរសញ្ញាចាស់ ហើយគាត់បានបង្រៀនព្រះបន្ទូលរបស់ព្រះដល់លោក ធីម៉ូថេ ដោយប្រិតប្រៀន នៅពេលពួកគាត់ដើរតាមផ្លូវ ពេលពួកគាត់សម្រាក និងនៅពេលពួកគាត់ភ្ញាក់ពីដំណេកផងដែរ។

ជាច្រើនឆ្នាំក្រោយមកសាវ័ក ប៉ុល បានប្រាប់លោក ធីម៉ូថេ ឲ្យធ្វើអស់ទាំងសេចក្តីដូចគ្នាដែលបានទទួលពីគាត់ ចំពោះអ្នកដទៃផងដែរៈ «ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្ហឹកបង្រៀនតទៅអ្នកឯទៀតដែរ» (២ធីម៉ូថេ ២:២)។ គោលបំណងនៃការបង្កើតសិស្សរបស់សាវ័ក ប៉ុល គឺជាកិច្ចការសម្រាប់គ្រប់ជំនាន់។

សាវ័ក ប៉ុល ចង់បានចៅទួតខាងវិញ្ញាណ។ លោក ធីម៉ូថេ (ជាកូន) គឺត្រូវស្វែងរកមនុស្សស្មោះត្រង់ (ចៅៗ) ជាអ្នកអាចនឹងបង្វឹកបង្រៀនអ្នកដទៃទៀតបានដែរ (ចៅទួត)។

## ការខិតខំធ្វើការ និងការតយុទ្ធ

ចំពោះលោកអ្នក តើការប្ដេជ្ញាចិត្តយកគំរូតាមព្រះគម្ពីរក្នុងការវិនិយោគទៅលើអ្នកដែលមានភាពក្មេងខ្ចីខាងឯវិញ្ញាណមានន័យដូចម្ដេចខ្លះ? សៀវភៅទាំងមូលនេះនឹងឆ្លើយតបទៅកាន់សំណួរនេះ។ ប៉ុន្តែ កណ្ឌគម្ពីរ កូឡុស ១:២៨-២៩ បានផ្ដល់នូវចំណុចចាប់ផ្ដើមដ៏មានអត្ថប្រយោជន៍។

កាលខ្ញុំនៅជាគ្រីស្ទបរិស័ទក្មេងខ្ចីម្នាក់ ខ្ញុំបានជ្រើសរើសខគម្ពីរទាំងពីរនេះ ដូចជា «ខគម្ពីរនៃជីវិត» របស់ខ្ញុំ។ នៅក្នុងខគម្ពីរទាំងពីរនេះ សាវ័ក ប៉ុល បានសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅទីក្រុងកូឡូស ដែលជាទីក្រុងមួយនៅភាគខាងលិចប្រទេសទួរគីសព្វថ្ងៃនេះ។ សាវ័ក ប៉ុល បានរំឭកដល់គ្រីស្ទបរិស័ទនៅទីក្រុងនោះ អំពីអ្វីដែលគាត់បានធ្វើសម្រាប់ពួកគេ៖ «យើងខ្ញុំប្រកាសប្រាប់ពីទ្រង់ ទាំងទូន្មានដល់គ្រប់មនុស្ស ហើយទាំងបង្រៀនដល់គ្រប់មនុស្ស ដោយគ្រប់ទាំងប្រាជ្ញា ដើម្បីឲ្យបានថ្វាយគ្រប់មនុស្ស ជាដង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ។ ខ្ញុំក៏ខំធ្វើការនោះឯង ទាំងតយុទ្ធតាមឫទ្ធិបារមីទ្រង់ ដែលបណ្ដាលឡើងក្នុងខ្ញុំដោយព្រះចេស្ដា» (កូឡុស ១:២៨-២៩)។

សាវ័ក ប៉ុល បានខិតខំធ្វើការនោះឯង។ សាវ័ក ប៉ុល បានទាំងតយុទ្ធតាមឫទ្ធិបារមីរបស់ព្រះ។ ដូច្នេះ ប្រសិនបើសាវ័ក ប៉ុល បានធ្វើល្អដល់អ្នកដទៃ យើងក៏ត្រូវតែធ្វើវាដែរ។

តើលោកអ្នកធ្លាប់ងឿងឆ្ងល់ពីរបៀបប្រើអំណាចខាងឯវិញ្ញាណដែរឬទេ? ប្រហែលជាមានមនុស្សមួយចំនួន បានប្រាប់លោកអ្នកឲ្យ «បរិភោគម្ហូបទាំងនេះ»។ «និយាយពាក្យទាំងនេះ»។ «អធិស្ឋានបែបដូច្នេះវិញ»។ «អានសៀវភៅដែលសរសេរឡើងដោយអ្នកនិពន្ធនេះ»។ «មានបទពិសោធន៍បែបនេះ»។ «ចូលរួមសន្និសីទមួយនេះ»។ «សម្លឹងមើលខាងក្នុងខ្លួនរបស់លោកអ្នក»។

ប៉ុន្តែ មិនដូច្នោះទេ! អំណាចខាងវិញ្ញាណ ត្រូវបានអនុវត្តន៍ក្នុងការបម្រើអ្នកដទៃដោយការលះបង់ផ្ទាល់យ៉ាងលំបាក។ ពាក្យថា "ការតយុទ្ធ" នៅក្នុងកណ្ឌគម្ពីរ កូឡូស ១:២៩ ក៏អាចបកប្រែថាជា "ការឈឺចាប់ ឬក៏ការរងទុក្ខ" ផងដែរ ដែលមានន័យថា ផ្លូវទៅរកអំណាចខាងវិញ្ញាណ គឺមានការឈឺចាប់ច្រើនជាងភាពរីករាយ។ តើលោកអ្នកចង់ដឹងពីព្រះចេស្តានៃព្រះ និងសេចក្តីជំនឿដែលមានការប្រព្រឹត្តដែរឬទេ? ដូច្នេះ សូមធ្វើការលះបង់ផ្ទាល់ខ្លួន ទៅក្នុងការខិតខំធ្វើការ និងទាំងតយុទ្ធ ដើម្បីការល្អរបស់អ្នកដ៏ទៃ ដូចជាព្រះគ្រីស្ទផ្ទាល់បានធ្វើការនោះឯង និងទាំងតយុទ្ធ ដើម្បីការល្អរបស់យើងដែរ។ ជំនឿគ្រីស្ទបរិស័ទដ៏ពិត គឺមិនមែនជាជំនឿដែលមានភាពខ្ជិលច្រអូសនោះទេ។ ដូចជាការរស់នៅរបស់សាវ័ក ប៉ុល បានបង្ហាញថា វាគឺជាសេចក្តីជំនឿដែលមានការប្រព្រឹត្ត។

## ការងារដ៏មានព្រះចេស្តារបស់ព្រះ

ប៉ុន្តែ នៅក្នុងកណ្ឌគម្ពីរ កូឡូស ១:២៨-២៩ តើសាវ័ក ប៉ុល បានអួតអាងឬទេ នៅពេលដែលគាត់មានប្រសាសន៍អំពីការខិតខំធ្វើការនោះឯង និងបានទាំងតយុទ្ធដើម្បីពួកគេ? គាត់មិនបានអួតអាងទេ។ សូមពិនិត្យមើលឃ្លាចុងក្រោយនៅក្នុងបទគម្ពីរនេះ៖ ព្រះបានធ្វើការនោះឯងដែលបណ្តាលឡើងក្នុងគាត់ ដោយព្រះចេស្តារបស់ទ្រង់។ គ្រប់ការបង្រៀនដែលអ្នកក្រុងកូឡូសបានទទួលពីសាវ័ក ប៉ុល គឺមិនមែនដោយសារសាវ័ក ប៉ុល នោះឡើយ តែគឺដោយសារព្រះទ្រង់ផ្ទាល់វិញ។

ប្រសិនបើលោកអ្នក ឬខ្ញុំសង្ឃឹមថា នឹងរួមចំណែកក្នុងការផ្តល់ការល្អដល់អ្នកដទៃ ឬបើយើងសង្ឃឹមថានឹងមានឥទ្ធិពលទៅលើអ្នកដទៃ ដើម្បីជាប្រយោជន៍ដល់ព្រះគ្រីស្ទដូចដែលយើងបានពិភាក្សានៅក្នុងជំពូកមុន នោះមែន នោះវានឹងកើតឡើងបានតាមតែការដែលព្រះវិញ្ញាណរបស់ព្រះធ្វើការនៅក្នុងយើង និងតាមរយៈយើងតែប៉ុណ្ណោះ។

ដោយដឹងថា ព្រះកំពុងធ្វើការនៅក្នុងជីវិតរបស់យើង ដើម្បីប្រឆាំងទៅនឹងអំនួតណាមួយដែលយើងមាន។ ការនោះបានរម្លឹកយើងថា អ្វីទាំងអស់ដែលយើងមាន និងអ្វីទាំងអស់ដែលយើងអាចធ្វើ និងសម្រេចបាន គឺមកតែពីព្រះទេ។ ប្រសិន

បើលោកអ្នក ឬខ្ញុំបានសង្កេតឃើញផលផ្លែពីការងាររបស់យើង នោះយើងមិនត្រូវមានហេតុផលណាមួយ ដើម្បីនឹងអួតនោះទេ។ ព្រះជាម្ចាស់ជាអង្គដែលធ្វើកិច្ចការទាំងនោះ។ វាគឺដោយព្រះចេស្ដារបស់ទ្រង់។ ជាលទ្ធផលនៃគ្រប់ទាំងផលផ្លែខាងឯវិញ្ញាណទាំងអស់ វាគួរតែធ្វើឲ្យយើងសរសើរតម្កើងទ្រង់វិញ។

ហើយដោយដឹងថា ព្រះកំពុងធ្វើការក្នុងជីវិតរបស់យើង ការនោះក៏ជួយយើងកុំឲ្យមានការភ័យខ្លាចដែរ។ ប្រសិនបើយើងបានដឹងច្បាស់ពីការល្អរបស់ព្រះ ដែលទ្រង់កំពុងធ្វើនៅក្នុងយើង ហើយបើយើងបានប្ដេជ្ញាចិត្តចំពោះគោលដៅរបស់ទ្រង់ នោះយើងអាចចោលការភ័យខ្លាចនៃការងារដែលគ្មានប្រយោជន៍របស់យើង ឬការងារខុសគោលដៅណាមួយរបស់យើងបានជាមិនខាន។ យើងអាចទុកការភ័យខ្លាចណាមួយដូចជា ការធ្លាក់ចុះនៃសុខភាព ឬបាត់បង់ទ្រព្យសម្បត្តិរបស់យើងមួយទៀតបាន។ យើងអាចបាត់បង់របស់ទាំងនោះបាន ប៉ុន្តែការងាររបស់ទ្រង់តាមរយៈពួកយើងនឹងនៅស្ថិតស្ថេរអស់កល្បជានិច្ច។

## ការប្រកាស និងការថ្វាយ

សូមកត់សម្គាល់អំពីពាក្យទាំងពីរនេះ ដែលប្រាប់យើងអំពីអ្វីដែលសាវ័ក ប៉ុល មានបំណងប្រកាស និងថ្វាយ៖ «យើងខ្ញុំប្រកាសប្រាប់ពីទ្រង់...ដើម្បីឲ្យបានថ្វាយគ្រប់មនុស្សជាដង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ» (កូឡូស ១:២៨)។ សាវ័ក ប៉ុល បានប្រកាសអំពីទ្រង់ ដើម្បីឲ្យគាត់បានថ្វាយគ្រប់មនុស្សទៅដល់ព្រះអង្គបាន។ សូមប្រកាសអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ឥឡូវនេះ និងថ្វាយពួកអ្នកបរិសុទ្ធដែលគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទទៅដល់ទ្រង់ នៅពេលដែលទ្រង់យាងមកម្ដងទៀតនាពេលខាងមុខ។ ពាក្យទាំងពីរនេះបានប្រាប់យើងអំពីរបៀបដែលសាវ័ក ប៉ុល បានខិតខំធ្វើការនោះឯង ទាំងតយុទ្ធ (ដោយការប្រកាសព្រះបន្ទូលទ្រង់) និងមូលហេតុដែលគាត់ខិតខំធ្វើការនោះឯង និងទាំងតយុទ្ធផងដែរ ដើម្បីឲ្យបានថ្វាយពួកបរិសុទ្ធទៅដល់ទ្រង់បាន។

សាវ័ក ប៉ុល ក៏បានពន្យល់អំពីអ្វីដែលពាក់ព័ន្ធនឹងការប្រកាសដែរថា៖ «យើងខ្ញុំប្រកាសប្រាប់ពីទ្រង់ ទាំងទូន្មានដល់គ្រប់មនុស្ស ហើយទាំងបង្រៀនដល់គ្រប់

មនុស្សដោយគ្រប់ទាំងប្រាជ្ញា» (កូឡូស ១:២៨)។ ការប្រកាសរបស់សាវ័ក ប៉ុល មានរួមបញ្ចូលទាំងការទូន្មាន និងការបង្រៀនផងដែរ។ គាត់បានទូន្មានក្រុមជំនុំឲ្យឃ្លាតឆ្ងាយពីអ្វីដែលឥតប្រយោជន៍ និងការអាក្រក់ ព្រមទាំងបានបង្រៀនពួកគេឲ្យរួបរួមក្នុងប្រាជ្ញា និងចំណេះដ៏បរិបូរនៃដំណឹងល្អរបស់ព្រះគ្រីស្ទទៀតផង។ ហើយគាត់មិនមែនចេះតែទូន្មាន និងបង្រៀនគ្រប់មនុស្សដោយមិនមានភាពជាក់លាក់នោះទេ ប៉ុន្តែគាត់បានទូន្មាន ហើយបង្រៀនគ្រប់គ្នាពោលគឺថា ពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ទៀត។

នៅពីរខបន្ទាប់ សាវ័ក ប៉ុល បានពណ៌នាអំពីបំណងប្រាថ្នារបស់គាត់ សម្រាប់ពួកជំនុំនៅទីក្រុងកូឡូស ដើម្បីឲ្យគេមាន «ប្រាជ្ញាវាងវៃបំផុត យល់សព្វគ្រប់ទាំងអស់» (កូឡូស ២:២ គខប) ។ សូមកំណត់ចំណាំថា អ្វីដែលមានការកើនឡើង គឺ៖ ប្រាជ្ញាវាងវៃបំផុត យល់សព្វគ្រប់ទាំងអស់! ទាំងនេះគឺជាកំណប់ទ្រព្យនៃប្រាជ្ញា និងចំណេះដឹងដែលត្រូវបានរកឃើញនៅទីនេះ! ផ្នែកមួយនៃភាពពេញវ័យនៃជំនឿ គឺជាការយល់ដឹងអំពីរបៀបនៃការបែងចែករវាង អ្វីដែលត្រឹមត្រូវ និងអ្វីដែលមិនត្រឹមត្រូវ អ្វីដែលពិត និងអ្វីដែលមិនពិត ព្រមទាំងអ្វីដែលមានតម្លៃ និងអ្វីដែលគ្មានតម្លៃ។ នេះជារបៀបដែលសាវ័ក ប៉ុល ចង់បង្ហាញប្រាប់ដល់រាស្ត្ររបស់ព្រះឲ្យមានភាពពេញវ័យនៃជំនឿ និងការរីកចម្រើនយ៉ាងពេញលេញនៅក្នុងជីវិតរបស់ពួកគេជាគ្រីស្ទបរិស័ទ។

កិច្ចការនៃការបង្កើតសិស្សបានកើតឡើងនៅពេលបច្ចុប្បន្ន ប៉ុន្តែមានការសម្លឹងឆ្ពោះទៅរកគ្រាចុងក្រោយ។ ការនេះទាមទារនូវការគិតឲ្យបានវែងឆ្ងាយ។ ការនេះក៏ទាមទារឲ្យមានផ្នត់គំនិតជាអ្នកវិនិយោគផងដែរ ដោយដឹងថា លទ្ធផលដែលផ្តល់ត្រឡប់មកវិញគឺជាភាពអស់កល្បជានិច្ច។ ហើយការវិនិយោគអាចកើតឡើងបាន គឺតាមរយៈការបង្រៀនព្រះបន្ទូលរបស់ព្រះ។ យើងត្រូវតែប្រកាសព្រះបន្ទូលទៅដល់អ្នកដទៃ។ ព្រះបន្ទូលរបស់ព្រះ គឺជាគ្រាប់ពូជដែលនឹងបង្កើតផលជាក់ប្រាកដ ទោះជាយើងមិនអាចឃើញការបង្កើតផលនោះក្នុងរយៈពេលខ្លីក៏ដោយ។ សូមសាបព្រួសព្រះបន្ទូលនៅពេលឥឡូវនេះចុះ។ សូមសាបព្រោះព្រះបន្ទូលជាមួយប្តីប្រពន្ធ និងជាមួយកូនៗរបស់លោកអ្នកចុះ។ សូមសាបព្រោះព្រះ

បន្ទូលជាមួយសមាជិកដទៃទៀត នៅក្នុងក្រុមជំនុំរបស់លោកអ្នក។ ហើយសូមមានការទុកចិត្តថា ព្រះបន្ទូលរបស់ព្រះដែលបានសាបព្រោះនោះនឹងមិនផ្តល់ផលត្រឡប់មកវិញជាការឥតប្រយោជន៍នោះឡើយ។ លោកអ្នកនឹងមើលឃើញ អំពីរដូវចម្រូតនៅពេលខាងមុខ។ អស់អ្នកជឿដែលមានភាពពេញវ័យនៃជំនឿ ពួកគាត់នឹងត្រៀមខ្លួនជាស្រេចក្នុងការទទួលព្រះគ្រីស្ទ នៅពេលទ្រង់យាងមកម្តងទៀត។

ការរស់នៅសម្រាប់អ្នកដទៃ គឺបង្ហាញអំពីជីវិតរបស់សាវ័ក ប៉ុល ទាំងមូល។ គាត់ថែមទាំងបានសរសេរសំបុត្រទៅកាន់គ្រីស្ទបរិស័ទ ដែលគាត់មិនធ្លាប់បានជួប ដូចជាសំបុត្រទៅកាន់ក្រុមជំនុំនៅក្រុងកូឡូសនេះ ដើម្បីលើកទឹកចិត្តពួកគេ នៅក្នុងដំណឹងល្អរបស់ព្រះគ្រីស្ទទៀតផង។ យើងអាចនិយាយបានថា ជីវិតរបស់គាត់ គឺជាការបង្ហាញឲ្យឃើញពីឈើឆ្កាង ដែលឈើឆ្កាងនោះ ត្រូវបានបង្កើតឡើងតាមគំរូនៃឈើឆ្កាងរបស់ព្រះគ្រីស្ទ។ គាត់បានធ្វើតាមការត្រាស់ហៅរបស់ព្រះគ្រីស្ទ ដើម្បីឲ្យលីឈើឆ្កាងរបស់ព្រះគ្រីស្ទ ហើយដើរតាមគំរូរបស់ទ្រង់។ ដូចជាព្រះគ្រីស្ទដែរ សាវ័ក ប៉ុល បានរងទុក្ខដោយការស្តាប់បង្គាប់ព្រះ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ។

តើអ្នកមានជីវិតដូចនេះទេ? សូមស្រមៃមើលថា តើវាទៅជាយ៉ាងណាក្នុងការធ្វើការទាំងនោះដោយ «ឫទ្ធិបារមីទ្រង់ ដែលបណ្តាលឡើងដោយព្រះចេស្តា» នៅក្នុងអ្នករាល់គ្នា!

## បណ្តាំខ្លីមួយទៅកាន់ គ្រូគង្វាល

ប្រសិនបើលោកជាគ្រូគង្វាល ឬកំពុងពិចារណាចង់ក្លាយជាគ្រូគង្វាលក្នុងក្រុមជំនុំ លោកគួរតែមានការគិតឲ្យបានច្រើន និងវែងឆ្ងាយអំពីបទគម្ពីរនេះ។ សូមកត់សម្គាល់ថា ការធ្វើព័ន្ធកិច្ច ត្រូវរួមបញ្ចូលទាំងការប្រកាសព្រះបន្ទូលរបស់ព្រះ និងការថ្វាយគ្រប់មនុស្សជាដង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ។

ការនេះទាមទារមិនឲ្យមានភាពអាត្មានិយមទាំងស្រុងក្នុងផ្នែកណាមួយនៃជីវិតរបស់យើងនោះទេ។ មានរឿងល្អជាច្រើនក្នុងការក្លាយជាគ្រូគង្វាល ប៉ុន្តែក៏មានរឿងជាច្រើន ដែលពិបាកដោយសារតែអំពើបាបរបស់សមាជិកក្រុមជំនុំ និងអំពើបាបរបស់គ្រូគង្វាលផ្ទាល់ផងដែរ។ ក្នុងនាមជាគ្រូគង្វាល លោកនឹងត្រូវខិតខំ

ធ្វើការនោះ និងទាំងតយុទ្ធ ដោយសេចក្តីស្រឡាញ់ចំពោះសមាជិកក្រុមជំនុំរបស់ខ្លួន ហើយពេលខ្លះពួកគេ នឹងឆ្លើយតបមកកាន់លោក ដោយការពន្យល់អំពីរបៀបនៃសេចក្តីស្រឡាញ់របស់លោក ដែលមានកំហុស និងជាសេចក្តីស្រលាញ់មិនគ្រប់គ្រាន់សម្រាប់ពួកគេ។

ដូច្នេះហើយ នៅទីបំផុត ការខិតខំ និងកម្លាំងពលកម្មរបស់លោកទៅលើការនោះ គឺមិនមែនជាប្រភពនៃសេចក្តីស្រឡាញ់របស់លោកចំពោះពួកគេ ឬសេចក្តីស្រឡាញ់របស់ពួកគេចំពោះលោកបានទេ។ វាត្រូវតែជាការចាក់ឫសនៅក្នុងសេចក្តីស្រឡាញ់របស់លោកចំពោះព្រះគ្រីស្ទ ហើយសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះលោក និងសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះពួកគេ។ ទ្រង់បានទិញពួកគេដោយព្រះលោហិតរបស់ព្រះអង្គទ្រង់ផ្ទាល់។ ហើយគោលបំណងរបស់លោកគឺត្រូវថ្វាយពួកគេទៅដល់ទ្រង់។ យើងរាល់គ្នាធ្វើការទាំងអស់នេះ គឺដើម្បីព្រះអង្គទ្រង់។

ជាការពិតណាស់ ពាក្យពេចន៍ទាំងនេះ គឺសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូបឲ្យអនុវត្តតាម មិនមែនគ្រាន់តែសម្រាប់គ្រូគង្វាលនោះទេ។ យើងត្រូវបង្កើតសិស្ស ហើយបង្រៀន និងទូន្មានពួកគេ ដើម្បីឲ្យបានថ្វាយគ្រប់មនុស្ស ដែលយើងស្រឡាញ់ដល់ព្រះដោយព្រោះយើងស្រឡាញ់ទ្រង់ខ្លាំងណាស់ ហើយដោយព្រោះទ្រង់ក៏ស្រឡាញ់យើងខ្លាំងណាស់ដែរ។

## សេចក្តីជំនឿពិតប្រាកដនឹងមានការប្រព្រឹត្តសម្រាប់អ្នកដទៃ

សេចក្តីជំនឿរបស់គ្រីស្ទបរិស័ទពិតប្រាកដ គឺមិនមែនមានទម្រង់ដូចជាសត្វជ្រូកដែលកំពុងតែស៊ីចំណីនោះទេ។ សេចក្តីជំនឿពិតប្រាកដ គឺមិនមានភាពខ្ជិលច្រអូស និងមិនមែនគិតតែប្រយោជន៍ខ្លួនឯងនោះទេ។ វាប្រៀបដូចជាសេចក្តីជំនឿរបស់សាវ័ក ប៉ុល ដែលត្រូវតែមានការប្រព្រឹត្ត។ វាត្រូវតែមានការប្រព្រឹត្ត សម្រាប់អ្នកដទៃ។ វាត្រូវតែមានការប្រព្រឹត្តដោយព្រះចេស្តាមកពីព្រះដែលបណ្តាលឡើងក្នុងយើង។ វាត្រូវតែមានការប្រព្រឹត្តទៅដោយការប្រកាស ហើយការទូន្មាន និងការបង្រៀនតាមរយៈព្រះបន្ទូលទ្រង់។ ហើយវាត្រូវតែមានការប្រព្រឹត្ត ដើម្បីឲ្យអ្នកដទៃផ្សេងទៀតអាចត្រូវបានថ្វាយនូវភាពពេញវ័យរបស់ពួកគេក្នុងព្រះគ្រីស្ទ នៅថ្ងៃដែល

ទ្រង់នឹងយាងមកផងដែរ។

យើងមិនតែងតែមើលឃើញដើមឈើដែលចេញផ្លែភ្លាមៗនោះទេ។ ដើម្បីបង្កើតសិស្សបាន លោកអ្នកត្រូវមានការអត់ធ្មត់ដូចជាកសិករដែលដាំដំណាំរបស់គាត់នៅចម្ការ ដោយគាត់មានការជឿទុកចិត្តថា គ្រាប់ពូជទាំងនោះនឹងដុះពន្លកឡើងនៅពេលខាងមុខ។ យើងត្រូវទុកចិត្តព្រះ ដើម្បីឲ្យទ្រង់ប្រើប្រាស់ព្រះបន្ទូលរបស់ព្រះអង្គសម្រាប់ការបង្កើតសិស្សរបស់យើង ទោះបីជាយើងមិនទាន់ឃើញផលផ្លែណាមួយដុះពន្លកឡើងក៏ដោយ។ វាប្រៀបដូចជាអ្វីដែលអ្នកនិពន្ធម្នាក់បាននិយាយថា «គ្រាប់ពូជអាចស្ថិតនៅក្រោមដុំដីធំៗ រហូតដល់យើងទម្រេតនៅទីនោះ ហើយបន្ទាប់មកវាក៏ដុះពន្លកឡើង»[២]។

សម្រាប់ខ្ញុំផ្ទាល់ ការបង្កើតសិស្ស គឺជារបៀបតែមួយគត់ដែលខ្ញុំអាចផ្សាយដំណឹងល្អដល់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ ហើយក៏ជួយគ្រីស្ទបរិស័ទនៅកន្លែងណាមួយដែលខ្ញុំមិនធ្លាប់ទៅ និងកន្លែងផ្សេងទៀតលើសពីលទ្ធភាពដែលខ្ញុំអាចធ្វើដំណើរទៅបាននាពេលអនាគតទៀតផង។ មនុស្សដែលខ្ញុំជួយក្នុងការដើរតាមព្រះយេស៊ូវគ្រីស្ទនឹងបន្តរស់នៅបន្ទាប់ពីខ្ញុំស្លាប់ទៅ។ ហើយមនុស្សដែលពួកគាត់នឹងជួយដើរតាមព្រះយេស៊ូវគ្រីស្ទក៏នឹងបន្តរស់នៅកាន់តែយូរនៅឯអនាគតថែមទៀតដែរ។

សិស្សរបស់ព្រះយេស៊ូវគឺជាអ្នកដែលបង្កើតសិស្ស។ គាត់ប្រកាសពីព្រះបន្ទូលព្រះឥឡូវនេះ ដើម្បីឲ្យគាត់អាចថ្វាយអស់អ្នកដែលបានឮព្រះបន្ទូលនោះដល់ទ្រង់នៅពេលអនាគត។ ដូច្នេះ សូមសរសេរឈ្មោះមនុស្សពីរបីនាក់នៅក្នុងជីវិតរបស់លោកអ្នក ដែលលោកអ្នកចង់ថ្វាយភាពពេញវ័យ និងការគោរពកោតខ្លាចព្រះរបស់ពួកគាត់ដល់ព្រះគ្រីស្ទ នៅថ្ងៃចុងក្រោយ។ តើលោកអ្នកមានឈ្មោះពួកគេកត់ទុកក្នុងចិត្តលោកអ្នកហើយឬនៅ? ឥឡូវនេះ តើលោកអ្នកកំពុងប្រកាសដំណឹងល្អដល់ពួកគាត់ដោយរបៀបណា ដើម្បីជួយពួកគាត់ឲ្យបានរៀបចំខ្លួនសម្រាប់ពេល

---

២ លោក Charles Bridges, The Christian Ministry: *With an Inquiry into the Causes of Its Inefficiency* (Carlisle, PA: Banner of Truth, ឆ្នាំ១៩៥៩), ទំព័រ៧៥។

ដែលព្រះគ្រីស្ទយាងមកវិញនោះ?

## ជំពូកទី៣

# ការងារនៃការបង្កើតសិស្ស

ការបង្កើតសិស្ស គឺមិនដូចរបៀបដ៏ច្បាស់លាស់បំផុតដូចដែលស្តេចអង្គណាមួយបង្កើត និងពង្រឹងនគរទ្រង់មួយនោះទេ។ ជាធម្មតា នគររីកចម្រើនឡើងដោយសមរភូមិរាជវង្ស សង្គ្រាមរាជវង្ស ការប្រមូលទ្រព្យសម្បត្តិដ៏អស្ចារ្យ ឬស្នាដៃនៃទស្សនវិជ្ជានយោបាយដែលបាននិពន្ធឡើងដោយអ្នកប្រាជ្ញដែលមានវ័យចាស់ៗ។

ប៉ុន្តែ ព្រះយេស៊ូវបានបញ្ចប់ពេលវេលារបស់ទ្រង់នៅលើផែនដីដោយទ្រង់មានបន្ទូលបង្គាប់ដល់សិស្សរបស់ទ្រង់ឲ្យពួកគេបង្កើតសិស្ស។ តើនោះពិតជារបៀបដែលនគររបស់ទ្រង់ត្រូវបានបង្កើតឡើងមែនឬទេ? មែនហើយ! ជាការពិតណាស់ សូមនឹកចាំពីអ្វីដែលព្រះយេស៊ូវបានបង្រៀនពីខាងដើមៈ

> «ទ្រង់មានព្រះបន្ទូលជាពាក្យប្រៀបប្រដូច១ទៀតថា “នគរស្ថានសួគ៌ប្រៀបដូចគ្រាប់ពូជម៉្យាង ដែលមនុស្សម្នាក់បានយកទៅព្រោះក្នុងចំការខ្លួន។ គ្រាប់នេះល្អិតជាងគ្រាប់ពូជទាំងអស់ពិតមែន តែកាលណាបានដុះឡើង នោះក៏ធំជាងតិណជាតិទាំងអស់ក្នុងចំការ ហើយក៏ត្រឡប់ជាដើមធំ ដល់ម៉្លេះបានជាសត្វហើរលើអាកាស មកទំនៅលើមែកផង”» (ម៉ាថាយ ១៣:៣១-៣២)។

ព្រះយេស៊ូវបានបង្រៀនសិស្សទ្រង់ឲ្យគិតអំពីភាពអស់កល្បជានិច្ច គឺមិនមែនអំពីថ្ងៃនេះ ឬថ្ងៃស្អែកឡើយ។ មូលហេតុដែលយើងព្យាយាមជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ ហើយយើងមានចេតនាល្អខាងឯវិញ្ញាណ និងយើងអធិស្ឋានសូមឲ្យដំណឹងល្អមានឥទ្ធិពលសម្រាប់ជីវិតពួកគេ ព្រមទាំងយើងប្រកាសព្រះបន្ទូលរបស់ព្រះ នេះគឺ ដើម្បីជាប្រយោជន៍របស់យើង នៅថ្ងៃនៃគ្រាចុងក្រោយ ដែលព្រះគ្រីស្ទនឹងយាងមកផែនដីនេះម្តងទៀត។ ឥឡូវនេះ យើងប្រហែលជាមើលឃើញ

ផលផ្លែខ្លះៗនៅក្នុងជីវិតយើងហើយ។ ប៉ុន្តែ គោលដៅរបស់យើង គឺតែងតែឲ្យបាន ថ្វាយគ្រប់មនុស្សជាដង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ នៅពេលដែលព្រះទ្រង់យាងមកវិញនោះ។

តើយើងអាចនិយាយអ្វីបន្ថែមទៀតអំពីការបង្កើតសិស្សដែរឬទេ? ខ្ញុំបាននិយាយរួចមកហើយថា ការបង្កើតសិស្ស គឺជាការជួយអ្នកដទៃឲ្យបានដើរតាមព្រះយេស៊ូវ។ វាជាការជួយពួកគេ ដោយចេតនាល្អខាងឯវិញ្ញាណរបស់ពួកគេ។ ប៉ុន្តែ ដើម្បីឲ្យកាន់តែជាក់លាក់ជាងនេះ ការបង្កើតសិស្ស គឺជាការផ្តួចផ្តើមនៃទំនាក់ទំនងជាមួយអ្នកដទៃដែលលោកអ្នកត្រូវបង្រៀន ផ្តល់ការកែតម្រូវ ធ្វើជាគំរូ និងផ្តល់សេចក្តីស្រឡាញ់ដល់ពួកគេ។ លោកអ្នកត្រូវតែមានការបន្ទាបខ្លួនយ៉ាងខ្លាំងដើម្បីធ្វើការនេះបាន។

## ការផ្តួចផ្តើមទំនាក់ទំនង

ការបង្កើតសិស្សគឺចាំបាច់ត្រូវពាក់ព័ន្ធនឹងការផ្តួចផ្តើមទំនាក់ទំនង—លោកអ្នកត្រូវតែជាអ្នកដែលចាប់ផ្តើមដំណើរការនោះ។ លោកអ្នកមិនអាចនៅស្ងៀមបានទេ។ ហើយវាអាចមានអារម្មណ៍ឆ្គាំឆ្គង នៅពេលលោកអ្នកធ្វើដូច្នោះ។ លោកអ្នកមិនអាចបង្រៀនមនុស្សគ្រប់គ្នាបានទេ ដូច្នេះលោកអ្នកត្រូវជ្រើសរើសមនុស្សមួយចំនួន ដែលអាចដាក់ខ្លួនជាសិស្ស ដើម្បីបង្រៀន។ ជាក់ស្តែង លោកអ្នកត្រូវរកម៉ោងជួបគ្នាបានដែរ។

លោកអ្នកក៏ត្រូវដឹងថា លោកអ្នកមិនត្រឹមស្វែងរកតែអ្នកណាដែលត្រូវការជំនួយនោះទេ ប៉ុន្តែត្រូវស្វែងរកអស់អ្នកដែលពួកគេដឹងខ្លួនថា ពួកគេក៏ត្រូវការជំនួយ ហើយព្រមទទួលការជួយរបស់លោកអ្នកផងដែរ។ ជាទូទៅ លោកអ្នកមិនគួរបង្កើតសិស្សជាមួយនឹងអ្នកដែលមិនអាចទទួលការបង្រៀនបាននោះឡើយ ដោយព្រោះលោកអ្នកនឹងខ្ជះខ្ជាយពេលវេលាជាមួយពួកគេឥតប្រយោជន៍។ សូមសម្លឹងរកមើលមនុស្ស ប្រៀបដូចជាកូនដែលមានប្រាជ្ញានៅក្នុងកណ្ឌគម្ពីរសុភាសិត ដោយគាត់ទទួលយកការប្រឹក្សាយោបល់ និងការណែនាំប្រដៅពីលោកអ្នកបាន។

សូមចាំថា ការបង្កើតសិស្សជាមួយអ្នកជឿលើដំណឹងល្អមិនមែនមានន័យ

ថា លោកអ្នកជាអ្នកគ្រីស្ទបរិស័ទដែលតែងតែមាន «ប្រាជ្ញាជាង» ម្នាក់ទៀតនោះទេ ដល់ថ្នាក់ថា លោកអ្នកត្រូវតែមានចម្លើយសម្រាប់គ្រប់សំណួរទាំងអស់នោះឡើយ។ ដោយសារដំណឹងល្អ ការបង្កើតសិស្សមានន័យថា ពេលខ្លះលោកអ្នកត្រូវដឹកនាំសិស្សរបស់ខ្លួន ដោយសារភាពនូវភាពទន់ខ្សោយ ឬអំពើបាបរបស់ខ្លួន។ តាមរយៈការធ្វើដូច្នេះ នោះលោកអ្នកបានបង្ហាញថា លោកអ្នកមិនមែនស្វែងរកការរាប់ជាសុចរិតនៅក្នុងលោកអ្នកផ្ទាល់ទេ ប៉ុន្តែកំពុងស្វែងរកនៅក្នុងព្រះគ្រីស្ទវិញ។ ដូច្នេះហើយ លោកអ្នកត្រូវរស់នៅដោយស្មោះត្រង់ និងឲ្យអ្នកដទៃអាចមើលឃើញពីជីវិតរបស់លោកអ្នកបាន។ មួយវិញសោត ការបង្កើតសិស្សជាគ្រីស្ទបរិស័ទ គឺមិនមែនគ្រាន់តែបង្ហាញអំពីភាពខ្លាំងរបស់លោកអ្នកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការបង្ហាញអំពីភាពទន់ខ្សោយរបស់លោកអ្នកផងដែរ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឲ្យឥទ្ធិឫទ្ធិលើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ» (២កូរិនថូស ៤:៧)។

## ការងារនៃការបង្កើតសិស្ស

ទំនាក់ទំនងនៃការបង្កើតសិស្សនៅតែជាផ្នែកដែលលោកអ្នកជាអ្នកនាំមុខពួកគេ ទោះបីជាអ្នកផ្សេងទៀតបានស្នើសុំឲ្យលោកអ្នកបង្រៀនពួកគេក៏ដោយ។ លោកអ្នកគឺជាអ្នកដែលដឹកនាំក្នុងទំនាក់ទំនងនោះ ដោយកំណត់ការប្រើប្រាស់ពេលវេលាជាមួយពួកគេ ដើម្បីចង្អុលបង្ហាញពួកគេទៅរកផ្លូវរបស់ព្រះគ្រីស្ទ។ ភរិយាដែលមានស្វាមីមិនមែនជាគ្រីស្ទបរិស័ទ (១ពេត្រុស ៣:១) គឺជាអ្នកដែលយើងបានគិតដល់នៅក្នុងជំពូក១ គាត់បានចង្អុលបង្ហាញអំពីផ្លូវទៅកាន់ព្រះគ្រីស្ទដល់ស្វាមី ដោយកិរិយាល្អស្មោះត្រង់របស់គាត់។

## នៅក្រៅ និងខាងក្នុងក្រុមជំនុំ

ដំណាក់កាលដំបូងនៃការបង្កើតសិស្ស អាចពាក់ព័ន្ធនឹងការបង្កើតមិត្តភាពជាមួយនឹងអ្នកមិនមែនជាគ្រីស្ទបរិស័ទ។ លោកអ្នកអាចពន្យល់ពីដំណឹងល្អ ហើយអញ្ជើញគាត់មកទទួលការបង្រៀនពីលោកអ្នក ដើម្បីឲ្យមានការប្រែចិត្ត និងផ្លាស់

ប្តូរសេចក្តីជំនឿរបស់គាត់។ នៅពេលអ្នកនោះបានប្រែចិត្ត ហើយមានជំនឿលើព្រះយេស៊ូវ នោះគាត់ត្រូវទទួលបុណ្យជ្រមុជទឹក ដើម្បីអាចឲ្យគាត់ក្លាយជាសមាជិកម្នាក់នៅក្នុងក្រុមជំនុំបាន។ ម្យ៉ាងទៀត ការបង្កើតសិស្សក្នុងន័យពេញលេញបំផុតគឺជាការរួមបញ្ចូលគ្នានៃការប្រែចិត្ត និងការផ្សាយដំណឹងល្អ។

ពេលខ្លះ ក្រុមជំនុំរបស់លោកអ្នកទទួលបានសមាជិកថ្មីដែលបានប្រែចិត្តរួចហើយ ប៉ុន្តែពួកគាត់នៅមានភាពក្មេងខ្ចីក្នុងសេចក្តីជំនឿ។ សូមចងចាំថា មហាបេសកកម្មដែលព្រះយេស៊ូវបានបង្គាប់ឲ្យយើងបង្កើតសិស្ស គឺតាមរយៈព័ន្ធកិច្ចនៃការធ្វើពិធីជ្រមុជទឹក និងការបង្រៀន (និងការធ្វើពិធីលៀងព្រះអម្ចាស់)។ ការបង្គាប់នេះមានន័យថា យើងត្រូវបង្រៀនពួកគេ ទាំងការបង្រៀនម្នាក់ៗ និងការបង្រៀនជាក្រុម។ យើងទាំងអស់គ្នាអង្គុយរួមគ្នាជាមួយព្រះបន្ទូលដែលបានអធិប្បាយ ហើយយើងរីករាយជាមួយគ្នានឹងពិធីលៀងព្រះអម្ចាស់ ដើម្បីប្រកាសអំពីការសុគតរបស់ព្រះអម្ចាស់ ហើយក៏ជាការរម្លឹកគ្នាទៅវិញទៅមកថា «ពួកយើងដែលមានគ្នាច្រើនក៏ជារូបកាយតែ១យ៉ាងនេះដែរ» (១កូរិនថូស ១០:១៧)។

នៅពេលដែលក្រុមជំនុំមានការបែកខ្ញែកគ្នាចូលទៅសង្គមរបស់ខ្លួនវិញ នោះការបង្រៀន និងការមើលថែគួរតែនៅបានបន្ត នៅក្នុងជីវិតរបស់សមាជិកក្រុមជំនុំដែរ។ លោកអ្នកមិនគ្រាន់តែបង្កើតសិស្សជាមួយនឹងអ្នកជឿនៅតែថ្ងៃអាទិត្យប៉ុណ្ណោះនោះទេ។ ការនេះអាចកើតឡើងនៅពេលលោកអ្នកទៅសួរសុខទុក្ខគ្នានៅតាមផ្ទះ ជួបគ្នានៅហាងកាហ្វេ ជួយធុរៈគ្នានៅឯស្រែចម្ការ ទៅផ្សារជាមួយគ្នា ឬក៏ជួបគ្នាអធិស្ឋាននៅពេលព្រឹកព្រលឹមៗជាដើម។ ការបង្កើតសិស្ស គឺមានរយៈពេលពេញមួយសប្តាហ៍ នៅពេលដែលសមាជិកជួបជុំគ្នា ដើម្បីនិយាយចែករំលែកអំពីបញ្ហា ការអធិស្ឋានឲ្យគ្នា ផ្តល់ការលើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមកក្នុងការតស៊ូរួមគ្នា ដើម្បីសេចក្តីស្រឡាញ់ និងភាពបរិសុទ្ធនៅក្នុងព្រះគ្រីស្ទ។

## ការបង្រៀន

ការបង្រៀនគឺជាចំណុចស្នូលនៃការបង្កើតសិស្ស។ យើងបង្រៀនអ្នកដទៃដោយប្រើប្រាស់ពាក្យពេចន៍។ យើងបង្រៀនព្រះបន្ទូលទាំងប៉ុន្មានដែលព្រះយេស៊ូវបាន

បង្រៀនដល់សិស្សរបស់ទ្រង់ និងបង្រៀនពីគ្រប់ទាំងព្រះបន្ទូលនៅក្នុងព្រះគម្ពីរទាំងមូល។

នេះហើយជាមូលហេតុដែលក្រុមជំនុំរបស់ខ្ញុំមានការអធិប្បាយតាមអត្ថន័យព្រះគម្ពីរ និងតាមលំដាប់នៃកណ្ឌព្រះគម្ពីរនីមួយៗ ដោយមានការឆ្លាស់គ្នារវាងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី និងរវាងកណ្ឌគម្ពីរធំៗ និងកណ្ឌគម្ពីរតូចៗ។ យើងក៏បានលើកទឹកចិត្តមនុស្សគ្រប់គ្នាឲ្យចូលរួមថ្នាក់សិក្សាព្រះគម្ពីរ សម្រាប់មនុស្សពេញវ័យដែលពួកយើងបានផ្តល់គម្រោងកម្មវិធីសិក្សារយៈពេលជាច្រើនឆ្នាំ ទៅតាមដំណាក់កាលផ្សេងៗនៃជីវិតរបស់ពួកគេជាគ្រីស្ទបរិស័ទដែរ។ នៅពេលដែលអ្នកណាម្នាក់បានបញ្ចប់ការសិក្សា ជាមួយគម្រោងកម្មវិធីសិក្សានោះ យើងលើកទឹកចិត្តពួកគេឲ្យបង្រៀនទៅដល់អ្នកផ្សេងទៀត ក្នុងកម្មវិធីសិក្សាដដែលនេះ។ ក្រុមជំនុំរបស់យើងក៏ស្វែងរកវិធីជាច្រើន ដើម្បីផ្គត់ផ្គង់ឲ្យមានសៀវភៅល្អៗ ហើយលើកទឹកចិត្តសមាជិកឲ្យអានផងដែរ។

យើងក៏មានការបង្រៀនបែបជាបុគ្គលមួយទល់នឹងមួយ នៅពេលដែលសមាជិកចាប់ផ្តើមរៀនចេះសន្ទនាជាមួយគ្នាអំពីព្រះជាម្ចាស់ ហើយនេះគឺជាអ្វីដែលក្នុងនាមខ្ញុំជាគ្រូគង្វាលម្នាក់បានលើកទឹកចិត្តសមាជិកក្រុមជំនុំឲ្យធ្វើស្ទើរតែរៀងរាល់សប្តាហ៍។ វាមិនមែនជារឿងខុសទេក្នុងការនិយាយគ្នាអំពីបាល់ទាត់ ឬសាលាសម្រាប់កូនរបស់ខ្លួន។ ប៉ុន្តែ សូមនិយាយអំពីសេចក្តីអធិប្បាយនៅថ្ងៃអាទិត្យផងដែរ។ សូមសួរទៅកាន់មិត្តភក្តិរបស់លោកអ្នកនូវអ្វីដែលព្រះបានបង្រៀនគាត់អំពីអង្គទ្រង់ផ្ទាល់។ ក្រុមតូចក៏អាចមានប្រយោជន៍ សម្រាប់ការសម្របសម្រួលនៃទំនាក់ទំនងទាំងនេះផងដែរ។

## ការកែតម្រង់

ពេលខ្លះ ការបង្កើតសិស្ស គឺតម្រូវឲ្យលោកអ្នកត្រូវព្រមានទៅនរណាម្នាក់អំពីជម្រើសដែលគាត់បានជ្រើសរើសធ្វើ។ ពួកគាត់នឹងមានភាពរីកចម្រើន នៅពេលលោកអ្នកបានបង្រៀនពួកគាត់អំពីសេចក្តីពិតទូទៅ ប៉ុន្តែក៏ទាមទារឲ្យលោកអ្នកត្រូវកែតម្រង់នូវកំហុសផ្ទាល់ខ្លួនរបស់ពួកគាត់ផងដែរ។ ផ្នែកនៃភាពជាគ្រីស្ទបរិស័ទ គឺ

ការទទួលស្គាល់ថា អំពើបាបបានបញ្ឆោតយើង ហើយយើងត្រូវការអ្នកជឿដទៃទៀត ដើម្បីជួយយើងឲ្យអាចមើលឃើញនូវអ្វីដែលយើងមិនអាចមើលឃើញដោយខ្លួនយើងផ្ទាល់។ ខ្ញុំធ្លាប់បាននិយាយជាញឹកញាប់ថា ការចូលរួមក្នុងក្រុមជំនុំ គឺដូចជាការបើកបង្ហាញបាបរបស់យើង។ តាមរយៈទំនាក់ទំនងនៃការបង្កើតសិស្សរបស់យើង នោះគេនឹងចាប់ផ្ដើមឃើញអំពើបាបថ្មីៗ ដែលគេមិនធ្លាប់ដឹងថាមានពីមុនមក។

ជាការពិតណាស់ លោកអ្នកអាចដឹកនាំទំនាក់ទំនងក្នុងការបង្កើតសិស្ស ដោយការអញ្ជើញអ្នកដទៃឲ្យកែតម្រូវលោកអ្នក ហើយធ្វើឲ្យមានភាពងាយស្រួលសម្រាប់ពួកគេក្នុងការធ្វើកិច្ចការនោះដែរ។ ប៉ុន្តែ លោកអ្នកត្រូវតែមានការកោតខ្លាចដល់ព្រះអម្ចាស់ឲ្យបានច្រើនជាងមនុស្ស ដោយមានឆន្ទៈក្នុងការកែតម្រូវអ្នកដទៃនៅពេលចាំបាច់ណាមួយ ហើយត្រូវហ៊ានប្រឈមនឹងការបដិសេធរបស់ពួកគេចំពោះលោកអ្នកផងដែរ។

នៅទីបំផុត ការងារនៃការកែតម្រូវ គឺជាកាតព្វកិច្ចរបស់ក្រុមជំនុំទាំងមូលដែលត្រូវធ្វើឡើង នៅពេលដែលសមាជិកណាម្នាក់បានបង្ហាញឲ្យឃើញនូវការប្ដេជ្ញាចិត្តរបស់គាត់ ចំពោះអំពើបាបរបស់ខ្លួនជាជាងការប្ដេជ្ញាចិត្តដើរតាមព្រះគ្រីស្ទ។ បន្ទាប់ពីមានការព្រមានជាច្រើនលើកច្រើនសារហើយ អ្នកនោះនឹងត្រូវដកចេញពីសមាជិកភាព និងពីពិធីលៀងព្រះអម្ចាស់ (ម៉ាថាយ ១៨:១៥-២០)។ ទោះជាយ៉ាងណាក៏ដោយ ការកែតម្រូវភាគច្រើននៅក្នុងក្រុមជំនុំ គួរតែធ្វើឡើងនៅក្នុងបរិបទជាឯកជនក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស។

## ការធ្វើជាគំរូ

សូមកត់សម្គាល់ថា ព្រះយេស៊ូវមិនគ្រាន់តែមានបន្ទូលបង្គាប់ដល់សិស្សរបស់ទ្រង់ឲ្យបង្រៀនអ្នកដទៃតែប៉ុណ្ណោះទេ។ ទ្រង់ក៏បានមានបន្ទូលប្រាប់ពួកគេឲ្យបង្រៀនមនុស្សឲ្យកាន់តាមគ្រប់ទាំងសេចក្ដីដែលពួកគេបានរៀនពីទ្រង់ដែរ។ គោលដៅនៃការបង្កើតសិស្ស គឺជាការចង់ឃើញជីវិតមានការផ្លាស់ប្ដូរ ដែលមានន័យថាវាលើសពីការអានសៀវភៅ ឬអានព្រះគម្ពីរជាមួយនឹងនរណាម្នាក់ទៀត។ ជា

ចុងក្រោយ ការបង្កើតសិស្ស គឺពាក់ព័ន្ធនឹងការរស់នៅនៃជីវិតគ្រីស្ទបរិស័ទពេញមួយជីវិតជាគំរូនៅចំពោះមុខអ្នកដទៃ។ នេះគឺជាអ្វីដែលព្រះគ្រីស្ទបានធ្វើ។ ទ្រង់បាន “ទាំងទុកតម្រាប់ ឲ្យយើងរាល់គ្នាដើរតាមលំអានដាននៃទ្រង់” (១ពេត្រុស ២:២១)។

យើងបានធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញមក គឺមិនគ្រាន់តែជាមួយពាក្យសម្ដីរបស់យើងទេ ប៉ុន្តែដោយជីវិតរស់នៅទាំងមូលរបស់យើងផងដែរ។ ហើយអ្វីដែលកើតឡើងក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស គឺតម្រូវឲ្យមានសកម្មភាពច្រើនជាងត្រឹមតែការបង្រៀននៅក្នុងថ្នាក់ (ដូចជាអ្វីយើងដែលធ្វើរៀងរាល់ថ្ងៃអាទិត្យ)។ វាទាមទារឲ្យមានការណែនាំដែលកើតមានឡើង នៅពេលដែលគ្រូបង្រៀនសិស្ស ឬអ្នកបង្វឹកបង្រៀនដល់ក្រុមខ្លួន។ អ្នកហាត់រៀនធ្វើការ គឺពួកគាត់ត្រូវរៀនដោយការស្ដាប់ ហើយដោយការមើល និងការចូលរួមបន្តិចម្ដងៗជាមួយនឹងការទទួលខុសត្រូវកាន់តែច្រើនឡើងទៅតាមពេលវេលា។ ហើយសំខាន់ជាងនេះទៅទៀត ការបង្កើតសិស្ស មានលក្ខណៈដូចជាទំនាក់ទំនងដែលព្រះបានរចនាសម្រាប់ក្រុមគ្រួសារអញ្ចឹងដែរ ដែលឪពុកម្ដាយបង្រៀនកូនៗដោយពាក្យសម្ដី និងការប្រព្រឹត្តតាមដំណាក់កាលនីមួយៗនៃជីវិត ហើយបន្ទាប់មក ពួកគាត់ជំរុញឲ្យកូនៗពួកគាត់ចូលរួមក្នុងកិច្ចការនៃមនុស្សពេញវ័យ។

ជាការពិតណាស់ ការបង្កើតសិស្សគឺជាការបង្ហាញអំពីរបៀបរស់នៅ ដើម្បីឲ្យអ្នកដទៃយកគំរូតាមលោកអ្នក។ ការបង្កើតសិស្ស គឺលោកអ្នកកំពុងអញ្ជើញពួកគេឲ្យត្រាប់តាមគំរូលោកអ្នក ដោយលោកអ្នកត្រូវមានការជឿទុកចិត្តចំពោះព្រះគ្រីស្ទ យើងយកទ្រង់ជាគំរូតែមួយដែលលោកអ្នកត្រូវយកតម្រាប់តាម។ វាទាមទារឲ្យលោកអ្នកមានឆន្ទៈក្នុងការឲ្យអ្នកដទៃមើលជីវិតលោកអ្នក ហើយបន្ទាប់មកអនុញ្ញាតឲ្យពួកគេចូលក្នុងជីវិតរបស់លោកអ្នក ដើម្បីឲ្យពួកគេពិតជាបានឃើញជីវិតរបស់លោកអ្នកមែន។ ជាឧទាហរណ៍៖ ពួកចាស់ទុំម្នាក់ៗក្នុងក្រុមជំនុំរបស់ខ្ញុំបានធ្វើរបៀបនេះ ដើម្បីឲ្យសមាជិកក្រុមជំនុំរបស់យើងអាចស្ដាប់តាមដំបូន្មានរបស់ព្រះដែលមានចែងនៅកណ្ឌគម្ពីរហេព្រើរ៖ “ចូរនឹកចាំពីពួកអ្នកនាំមុខ ដែលបានផ្សាយព្រះបន្ទូលមកអ្នករាល់គ្នា ត្រូវតែត្រាប់តាមសេចក្ដីជំនឿរបស់អ្នកទាំង

នោះ ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង» (ហេព្រើរ ១៣:៧)។ យើងទាំងអស់គ្នា គួរតែអាចនិយាយទៅកាន់គ្រីស្ទបរិស័ទដទៃទៀត តាមរយៈជីវិតរបស់យើងដូចជាសាវ័ក ប៉ុល បានធ្វើដែរ «ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ» (១កូរិនថូស ១១:១)។ ប្រហែលនេះគឺជាមូលហេតុដែលធ្វើឲ្យជីវប្រវត្តិរបស់គ្រីស្ទបរិស័ទ មានប្រយោជន៍ខ្លាំងសម្រាប់កិច្ចការបង្កើតសិស្ស។

## ចូរស្រឡាញ់គ្នាជាបងប្អូន

ផ្នែកបន្ថែមមួយទៀតនៃការពណ៌នាអំពីការបង្កើតសិស្ស វាគឺជាទម្រង់មួយនៃការស្រឡាញ់គ្នាជាបងប្អូន។ ជាការពិតណាស់ គឺមានទំនាក់ទំនងរវាងគ្រូ និងសិស្ស។ ប៉ុន្តែ ក៏នឹងនៅមានការបង្ហាញសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមកក្នុងនាមជាមិត្តភក្ដិផងដែរ។ ការនេះមានន័យថា ការលើកទឹកចិត្តឲ្យដើរតាមព្រះគ្រីស្ទ ជាញឹកញាប់ តម្រូវឲ្យមានទាំងពីររបៀបនេះ។ ក្នុងនាមខ្ញុំជាមនុស្សម្នាក់ដែលបានជួយអ្នកដទៃដើរតាមព្រះយេស៊ូវជាយូរឆ្នាំមកហើយ ខ្ញុំអាចនិយាយបានថា ជាញឹកញាប់ខ្ញុំបានទទួលការបម្រើ ហើយទទួលព្រះពរ និងទទួលបានការលើកទឹកចិត្តក្នុងសេចក្ដីជំនឿរបស់ខ្ញុំពីសំណាក់សិស្ស ដែលខ្ញុំកំពុងបង្រៀនផងដែរ។ ទោះបីខ្ញុំធ្វើការល្អខាងវិញ្ញាណសម្រាប់ពួកគេក៏ដោយ ក៏ពួកគេបានធ្វើការល្អខាងឯវិញ្ញាណតបមកកាន់ខ្ញុំវិញដែរ។ ពួកគេជួយខ្ញុំឲ្យដើរតាមព្រះយេស៊ូវបានកាន់តែប្រសើរជាងមុន។ ជាមួយគ្នា យើងបានរៀនរួមគ្នាអំពីអ្វីដែលសាវ័ក ប៉ុល ចង់បង្ហាញប្រាប់ពីអត្ថន័យដល់យើងនៅក្នុងកណ្ឌគម្ពីរ កូឡូស ៣:១៦ ដោយគាត់មានប្រសាសន៍ថា៖ «ចូរឲ្យព្រះបន្ទូលនៃព្រះគ្រីស្ទ បានសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ ដោយប្រាជ្ញាគ្រប់យ៉ាង ទាំងបង្រៀន ហើយទូន្មានគ្នា...»។

យើងធ្វើការរួមជាមួយគ្នា ដើម្បីបំពេញនូវអ្វីដែលកណ្ឌគម្ពីរ ហេព្រើរ ១០:២៤-២៥ បានលើកឡើង៖ «ត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថា ថ្ងៃនោះជិតមកដល់ហើយ»។ គោលដៅរបស់ខ្ញុំក្នុងការបង្កើតសិស្ស គឺ

ដើម្បីស្រឡាញ់គ្រីស្ទបរិស័ទក្មេងខ្ចីខាងជំនឿ ដែលជួយពួកគេឲ្យរស់នៅដោយមានការយល់ដឹងអំពីគ្រាចុងក្រោយ។ ប៉ុន្តែ ជាធម្មតា គ្រីស្ទបរិស័ទដែលមានវ័យក្មេងជាងទាំងនោះក៏ត្រូវទទួលស្គាល់ផងដែរថា សមត្ថភាពរបស់ខ្ញុំក្នុងការជួយពួកគេឲ្យដើរតាមព្រះយេស៊ូវ គឺអាស្រ័យលើពួកគេជួយខ្ញុំក្នុងការធ្វើកិច្ចការនេះដូចគ្នា។

## ការបន្ទាបខ្លួន

មានរបៀបច្រើនទៀត ដែលខ្ញុំនឹងរៀបរាប់នៅក្នុងជំពូកក្រោយៗអំពីរបៀបធ្វើកិច្ចការទាំងអស់នេះ។ ប៉ុន្តែ ខ្ញុំបានសង្កេតឃើញនៅពេលនេះថា ការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ គឺមិនអាចធ្វើឡើងដោយគ្មានបញ្ហាប្រឈមនោះទេ។ ដូចដែលលោកអ្នកត្រូវមានការបន្ទាបខ្លួន ដើម្បីឲ្យអ្នកដទៃជួយលោកអ្នកក្នុងការដើរតាមព្រះយេស៊ូវ នោះលោកអ្នកក៏ត្រូវមានការបន្ទាបខ្លួនក្នុងជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវដែរ។ ការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវក៏អាចជាប់ពាក់ព័ន្ធនឹងរឿងរ៉ាវពិបាកៗជាច្រើន ដូចជាការបដិសេធ ការស៊ូទ្រាំនឹងបញ្ហា ការយល់ដឹងអំពីពេលវេលាដែលត្រូវមាន ការយកអាសាជាមួយនរណាម្នាក់ ដែលពិតជាបង្ហាញការជួយដល់គាត់មែន។ ការអញ្ជើញរបស់លោកអ្នកចំពោះនរណាម្នាក់អាចត្រូវបានបដិសេធ ហើយដំបូន្មានរបស់លោកអ្នក ក៏អាចត្រូវបានច្រានចោលដែរ។

ដូចដែលបានកត់សម្គាល់ពីខាងដើម យើងបង្កើតសិស្ស គឺមិនត្រឹមតែតាមរយៈភាពខ្លាំងរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏តាមរយៈភាពទន់ខ្សោយរបស់យើងផងដែរ។ ការបង្កើតសិស្សក្នុងជំនឿគ្រីស្ទបរិស័ទ គឺមិនមែនជាការងាររបស់អ្នកជំនាញនោះទេ។ គឺដូចពាក្យចាស់ពោលថា «វាជាការងាររបស់អ្នកសុំទានម្នាក់ដែលកំពុងចង្អុលប្រាប់អ្នកសុំទានម្នាក់ទៀតឲ្យទៅស្គាល់កន្លែងរកនំបុ័ងដែរ»។

លោកស្រី អ៊ែរីន វីល័រ (Erin Wheeler) ជាភរិយារបស់លោក ប្រាដ វីល័រ (Brad Wheeler) ដែលធ្លាប់បានបម្រើជាគ្រូគង្វាលម្នាក់ជាមួយខ្ញុំនៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី។ លោកស្រី អ៊ែរីន បានសរសេរអត្ថបទសម្រាប់ទស្សនាវដ្ដី 9Marks អំពីរបៀបដែលគាត់ត្រូវរៀនមេរៀននៃការបន្ទាបខ្លួន។ មានពេលមួយមានស្ត្រីម្នាក់ទៀតនៅក្នុងក្រុមជំនុំបានមកដល់ផ្ទះរបស់លោកស្រី អ៊ែរីន ហើយ

បានស្នើឲ្យលោកស្រីជួយបង្រៀនគាត់ឲ្យចេះដើរតាមព្រះយេស៊ូវដែរ។ លោកស្រី អ័ររីន បានទទួលស្វាគមន៍គាត់ ឲ្យចូលទៅខាងក្នុងផ្ទះ ហើយបិទទ្វារផ្ទះគាត់ ពេលនោះគាត់បានគិតក្នុងចិត្តតែម្នាក់ឯងថា៖

> «ខ្ញុំជាមនុស្សម្នាក់ ដែលអត់សណ្ដាប់ធ្នាប់។ ខ្ញុំមិនដឹងថា ខ្ញុំកំពុងធ្វើអ្វីនៅទីនេះទេ។ ថ្ងៃនេះ កូនៗរបស់ខ្ញុំមិនសូវស្ដាប់បង្គាប់សោះ ហើយចិត្តរបស់ខ្ញុំកំពុងតែខឹងប្ដីដែរ។ ខ្ញុំមិនគួរបង្រៀននរណាម្នាក់នៅក្នុងសភាពបែបនេះទេ។ ខ្ញុំជាមនុស្សម្នាក់ ដែលត្រូវការការបង្រៀនពីអ្នកដទៃ! ព្រះអម្ចាស់អើយ! តើទ្រង់ចង់ឲ្យយើងខ្ញុំធ្វើអ្វី?»។

ទោះជាយ៉ាងណាក៏ដោយក៏ក្នុងពេលឆាប់ៗនេះ ព្រះកំពុងបង្រៀនអ្នកស្រី អ័ររីន តាមរយៈស្ថានភាពទាំងនេះ ដែលទ្រង់នឹងប្រើប្រាស់ភាពទន់ខ្សោយរបស់គាត់ឲ្យដូចជាភាពខ្លាំងរបស់គាត់ដែរ។ ស្ត្រីវ័យក្មេងនៅក្នុងសេចក្ដីជំនឿទាំងនេះ ត្រូវការនរណាម្នាក់បង្រៀនពួកគេឲ្យអាចស្រឡាញ់ព្រះឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត និងអស់អំពីកម្លាំង ដោយមិនត្រឹមតែនៅក្នុងពេលវេលាល្អប៉ុណ្ណោះទេ ប៉ុន្ដែនៅក្នុងគ្រាដ៏លំបាកៗផងដែរ។ អ្នកស្រី អ័ររីន បានពន្យល់ថា៖

> «ក្នុងការបង្រៀនស្ត្រីទាំងនេះ ខ្ញុំបានព្យាយាមណែនាំ សួរសំណួរពួកគេ ពិភាក្សាសៀវភៅមួយចំនួន និងអធិស្ឋានជាមួយពួកគេ ប៉ុន្តែបន្តិចក្រោយមក ពួកគេបានប្រាប់ខ្ញុំថា ជាញឹកញាប់ ការបង្រៀនដ៏ល្អបំផុតរបស់ខ្ញុំកើតឡើងមកពីការសម្លឹងមើលដ៏សាមញ្ញរបស់ពួកគេមកកាន់ជីវិតរបស់ខ្ញុំ។ ពួកគេបានមើលឃើញថា ព្រះបានប្រើប្រាស់ភាពទន់ខ្សោយរបស់ខ្ញុំក្នុងការតយុទ្ធជាមួយភាពអត់ធ្មត់ នៅពេលដែលខ្ញុំកំពុងមានថ្ងៃដ៏លំបាក។ ពួកគេបានមើលឃើញពីការតយុទ្ធរបស់ខ្ញុំ ដើម្បីស្រឡាញ់ស្វាមីរបស់ខ្ញុំ ពីព្រោះខ្ញុំអន់ចិត្តនឹងគាត់ដោយសារការងារនៅឯក្រុមជំនុំបានធ្វើឲ្យគាត់ត្រូវចំណាយពេលច្រើនជាងពេលនៅផ្ទះទៅទៀត»។

ស្ត្រីទាំងនេះបានទទួលបានកៅអីជួរមុខ ពួកគាត់បានសង្កេតឃើញថា គាត់

ជាភាជនៈដីដ៏ពិតនោះ គឺជារូបគាត់ផ្ទាល់នោះហើយ (២កូរិនថូស ៤:៧)។ ប៉ុន្តែតាមរយៈការរៀនអំពីទស្សនៈនៃដំណឹងល្អនេះបានលើកទឹកចិត្តគាត់ឲ្យបន្តចាក់ច្រួចខ្លួនគាត់ដូចជាយញ្ញបូជា ដើម្បីជួយស្ត្រីទាំងនេះក្នុងការដើរតាមព្រះយេស៊ូវ (ភីលីព ២:១៧) ដោយដឹងថា ព្រះនឹងប្រើភាពទន់ខ្សោយរបស់គាត់ជារបៀបមួយ ដើម្បីបង្ហាញពីព្រះចេស្ដារបស់ទ្រង់។ ហើយប្រាកដណាស់ ម្ដងហើយម្ដងទៀត ព្រះបានបង្ហាញភាពស្មោះត្រង់របស់ទ្រង់ ក្នុងការផ្គត់ផ្គង់អ្វីគ្រប់យ៉ាងដែលជាតម្រូវការរបស់គាត់ ដើម្បីសេចក្ដីស្រឡាញ់ និងការបម្រើដល់ស្ត្រីវ័យក្មេងទាំងនេះ។ គាត់បានសន្និដ្ឋានថា៖

> «ច្រើនឆ្នាំក្រោយមក ព្រះបាននាំមិត្តភក្តិថ្មី និងជាប្អូនស្រីម្នាក់មកព្រះវិហារ ដែលគាត់អាចមានពេលដើរលេងជាមួយខ្ញុំ នៅរសៀលថ្ងៃសៅរ៍ណាមួយ នៅពេលដែលស្វាមីខ្ញុំមានការរវល់រៀបចំសេចក្ដីអធិប្បាយ។ រាល់ពេលដែលនាងមកលេងផ្ទះរបស់ខ្ញុំ វាហាក់បីដូចជា មានអ្វីមួយខុសប្រក្រតីដូចជាខ្ញុំខឹងសម្បារនឹងកូនរបស់ខ្ញុំ ដោយសារនៅបន្ទប់ទឹកមានទឹកហៀរព្រៀប! គឺក្នុងពេលបែបនេះហើយ ដែលខ្ញុំបានសម្លឹងមើលគាត់ដោយស្នាមញញឹម ហើយដោយមានទំនុកចិត្តជាមួយពេលវេលាដ៏ល្អឥតខ្ចោះរបស់ព្រះ ហើយខ្ញុំបាននិយាយទៅកាន់គាត់ថា «អ្នកដឹងទេ ព្រះពិតជាស្រឡាញ់អ្នកណាស់ បានជាព្រះអង្គឲ្យអ្នកឃើញរឿងទាំងអស់នេះ»។
>
> នោះគឺជាទំនុកចិត្តរបស់យើង៖ មិនមែនថា យើងមានគ្រួសារដ៏ល្អឥតខ្ចោះ និងកូនដែលមានអាកប្បកិរិយាល្អៗនោះទេ ប៉ុន្តែនៅក្នុងស្ថានភាពនៃជីវិត ដែលមានភក់ជ្រាំ និងភាពស្មោកគ្រោករបស់យើង នោះព្រះវិញ្ញាណរបស់ព្រះកំពុងធ្វើការនៅក្នុងជីវិតបែបនោះរបស់យើងហើយ។ ទោះបីនៅក្នុងភាពទន់ខ្សោយរបស់យើងក៏ដោយ ក៏ព្រះទ្រង់ប្រើប្រាស់ពាក្យសម្ដីរបស់យើង «ដើម្បីដាស់តឿនអ្នកដែលខ្ជិលច្រអូស លើកទឹកចិត្តអ្នកដែលខ្មាសអៀន កម្សាន្តចិត្តអ្នកទន់ខ្សោយ ហើយបង្ហាញការអត់ធ្មត់របស់យើង ចំពោះមនុស្សគ្រប់គ្នា ដើម្បីសិរីរុងរឿងដ៏អស្ចារ្យរបស់ទ្រង់»[៣]។

---

៣ លោកស្រី Erin Wheeler, “Discipling When You Need to Be Discipled,”

ដូចដែលខ្ញុំអាចនឹងសង្កេតឃើញវាបានក្នុងពេលដ៏ខ្លីនេះ ក្រុមជំនុំតាមតំបន់គឺជាកន្លែងដ៏ល្អបំផុត សម្រាប់ការរីកចម្រើននៃទំនាក់ទំនងបែបនេះ។ ក្រុមជំនុំមួយអាចមានទំនាក់ទំនងដែលហ៊ុំព័ទ្ធជាមួយការណែនាំ ទោះបីជាពួកគេមិនត្រូវបានគេហៅជាផ្លូវការថា «ទំនាក់ទំនងដែលបង្កើតសិស្ស» ក៏ដោយ។ លើសពីនេះ ការបង្កើតសិស្សគឺគ្រាន់តែជាក្រុមនៃសមាជិកក្រុមជំនុំ ដែលទទួលខុសត្រូវជួយគ្នាក្នុងការរៀបចំគ្នាទៅវិញទៅមក សម្រាប់សិរីរុងរឿងរបស់ព្រះ ដូចដែលលោកស្រី អ័ររីន និងស្ត្រីទាំងនេះបានធ្វើសម្រាប់គ្នាទៅវិញទៅមកអញ្ចឹងដែរ។ វាគឺជាវិធីមួយ ដែលយើងអាចមើលឃើញអំពីគំនិតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីថា យើងជាពួកសង្ឃហ្លួង និងជាសាសន៍បរិសុទ្ធ (១ពេត្រុស ២:៩)។ តើការមើលថែក្រុមជំនុំត្រូវបានធ្វើឡើងច្រើនប៉ុណ្ណាក្នុងជីវិតធម្មតារបស់ក្រុមជំនុំ នៅពេលដែលគ្រប់គ្នាជួយគ្នាទៅវិញទៅមកក្នុងការដើរតាមព្រះយេស៊ូវ!

ចំណុចចុងក្រោយនៃការបន្ទាបខ្លួន គឺតម្រូវឲ្យមានការទទួលស្គាល់ថា ពេលខ្លះមនុស្សមួយចំនួននឹងចាកចេញពីលោកអ្នកដោយទៅរស់នៅកន្លែងផ្សេងទៀត។ ជាពិសេស ពួកគេចូលចិត្តរើទៅនៅឯទីក្រុង ដើម្បីទៅនៅផ្ទះថ្មី ឬក៏ភូមិថ្មី។ ការនេះតម្រូវឲ្យយើងមានតែការចិត្តស្រឡាញ់ពួកគាត់។ យើងមិនវិនិយោគ ចែករំលែក បង្ហូរបំពេញ អធិស្ឋានឲ្យ និងស្រឡាញ់ ដើម្បីឲ្យយើងអាចទទួលបានអ្វីមួយនៅថ្ងៃខាងមុខនោះទេ—ប៉ុន្តែ គឺសម្រាប់ការស្កប់ចិត្ត និងអំណរដែលបានមកពីការដឹងថា ពួកគេត្រូវបានត្រៀមខ្លួនកាន់តែប្រសើរសម្រាប់គ្រប់ទីកន្លែងដែលពួកគេទៅបន្ទាប់ ហើយចុងក្រោយនោះ គឺសម្រាប់ព្រះគ្រីស្ទដែលទ្រង់នឹងយាងមកវិញ។

## ការណែនាំឆ្ពោះទៅកាន់ស្ថានសួគ៌

ក្នុងនាមជាមនុស្ស គឺយើងត្រូវតែមានភាពជាសិស្សដែលមានន័យថា យើងនៅបន្តរៀនរហូត។ ព្រះមិនបានប្រទានដល់លោក អ័ដាម និងនាង អេវ៉ា នូវជម្រើស

---

នៅក្នុងទស្សនាវដ្តី 9Marks, "Discipling in the Church," ខែកញ្ញា-ខែតុលា ឆ្នាំ២០១២, http://៩marks.org/article/journaldiscipling-when-you-need-be-discipled/.

រវាងភាពជាសិស្ស និងភាពឯករាជ្យរបស់ពួកគេទេ ប៉ុន្តែជាជម្រើសរវាងការដើរតាមទ្រង់ និងការដើរតាមសាតាំង។ យើងទាំងអស់គ្នាសុទ្ធតែជាអ្នកដើរតាមអ្នកដទៃ ហើយមានសំណួរតែមួយគត់ដែលយើងត្រូវសួរនោះគឺថា តើយើងកំពុងដើរតាមអ្នកណា? តើយើងកំពុងដើរតាមអ្នកជឿផ្សេងទៀត ដើម្បីឆ្ពោះទៅកាន់ស្ថានសួគ៌ ហើយតើយើងនៅតែជួយអ្នកជឿផ្សេងបន្ថែមទៀត ដើម្បីឲ្យពួកគេបានធ្វើកិច្ចការបែបដូចគ្នានេះដែរឬទេ?

ខ្ញុំចូលចិត្តរបៀបដែលលោកគ្រូ ឆាល ស្ពើជិន (Charles Spurgeon) បានពណ៌នាអំពីព័ន្ធកិច្ចផ្ទាល់របស់គាត់។ នៅក្នុងជីវប្រវត្តិរបស់គាត់ គាត់បានប្រៀបធៀបខ្លួនគាត់ ទៅនឹងលោក ហ្គ្រេតថ៍ ហាតថ៍ (តួអង្គឈ្មោះ Great-heart មានន័យថា "ចិត្តល្អ") នៅក្នុងសៀវភៅរបស់លោក ចន ប៊ុនយ៉ាន ដែលមានចំណងជើងថា "ផ្លូវស្ថានសួគ៌" (Pilgrim's Progress)។ នៅក្នុងរឿងនេះ លោក ហ្គ្រេតថ៍ ហាតថ៍ គឺជាតួអង្គដែលមានចិត្តសប្បុរស និងក្លាហានដែលបានជួយអ្នកដទៃឲ្យឆ្ពោះតម្រង់ទៅកាន់ស្ថានសួគ៌ ដែលនៅក្នុងរឿងនោះហៅថា ជាទីក្រុងសេឡេស្ទាល (Celestial City)។ លោកគ្រូ ឆាល ស្ពើជិន បានប្រាប់ទៅកាន់អ្នកនៅក្នុងក្រុមជំនុំគាត់ថា៖

> «ខ្ញុំរវល់នឹងការងារតូចតាចរបស់ខ្ញុំ ដូចការងាររបស់លោក ហ្គ្រេតថ៍ ហាតថ៍ បានធ្វើនៅក្នុងដំណើររឿងរបស់លោក ប៊ុនយ៉ាន ដែរ។ ខ្ញុំមិនបានប្រៀបធៀបខ្លួនខ្ញុំ ជាមួយនឹងម្ចាស់ជើងឯកនោះទេ ប៉ុន្តែខ្ញុំធ្វើការងារទាក់ទងនឹងការនេះដែរ។ ខ្ញុំជាអ្នកចង្អុលបង្ហាញ និងអ្នកនាំផ្លូវម្នាក់ក៏ដូចជាអ្នកចូលរួមក្នុងដំណើរដោយផ្ទាល់ឆ្ពោះទៅកាន់ស្ថានសួគ៌....ការងាររបស់ខ្ញុំ តាមដែលខ្ញុំអាចធ្វើទៅបាន គឺត្រូវសម្លាប់សត្វនាគ និងកាត់ក្បាលយក្ស ហើយនាំមុខអ្នកអៀនខ្មាស និងភ័យញាប់ញ័រ។ ជារឿយៗខ្ញុំខ្លាចបាត់បង់គ្រីស្ទបរិស័ទទន់ខ្សោយមួយចំនួន។ ចិត្តរបស់ខ្ញុំខ្វេចខ្វាំសម្រាប់ពួកគេ ប៉ុន្តែដោយសារព្រះគុណរបស់ព្រះ និងការជួយដោយចិត្តមេត្តា និងសប្បុរសរបស់អ្នកក្នុងការផ្តល់ឲ្យមើលថែគ្នាទៅវិញទៅមកដែរ ខ្ញុំមានសង្ឃឹមថា យើងទាំងអស់គ្នានឹងធ្វើដំណើរដោយសុវត្ថិភាព ទៅដល់មាត់ទន្លេ (មានន័យថា ស្លាប់ដោយមានសន្តិភាព)។ អូហ៎!

តើខ្ញុំត្រូវបែកគ្នាជាមួយមនុស្សប៉ុន្មាននាក់នៅទីនោះ! ខ្ញុំបានឈរនៅមាត់ច្រាំង ហើយខ្ញុំបានឮពួកគេច្រៀងនៅកន្លែងដែលមានទឹកហូរ ហើយខ្ញុំស្ទើរតែបាន ឃើញអ្នកចាំងបំភ្លឺផ្លូវដែលនាំពួកគេឡើងលើភ្នំ និងតាមច្រកទ្វារចូលទៅក្នុង ក្រុង សេឡេស្ទាល[៤]។

---

៤ លោក C. H. Spurgeon, C. H. Spurgeon Autobiography, vol. ២, The Full Harvest (Carlisle, PA: Banner of Truth, ឆ្នាំ១៩៧៣), ទំព័រ១៣១។

ជំពូកទី៤

# ការជំទាស់ផ្សេងៗទៅនឹងការបង្កើតសិស្ស

ខ្ញុំដឹងថា ខ្ញុំបានប្រើពាក្យបង្កើតសិស្សនេះ ខណៈពេលដែលអ្នកដទៃផ្សេងទៀតបានប្រើប្រាស់ពាក្យផ្សេងខុសពីនេះ។ នៅប្រទេសអង់គ្លេស គ្រីស្ទបរិស័ទប្រើពាក្យ "អាន" សៀវភៅជាមួយអ្នកដទៃ។ នៅទីនេះនៅក្នុងសហរដ្ឋអាមេរិក ការបង្កើតសិស្ស គឺប្រជាជនចង់សំដៅទៅលើ ការមានដៃគូទទួលខុសត្រូវ ឬដៃគូអធិស្ឋានរួមគ្នា។ ទោះបីលោកអ្នកបានហៅវាថា ជាអ្វីក៏ដោយ ខ្ញុំកំពុងប្រើពាក្យ "ការបង្កើតសិស្ស" សម្រាប់ការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ ដោយការមានចេតនាធ្វើការល្អខាងវិញ្ញាណសម្រាប់ជីវិតរបស់ពួកគេ។ ដូចដែលយើងបានឃើញនៅក្នុងជំពូកមុន វាពាក់ព័ន្ធនឹងការផ្ដួចផ្ដើមគំនិត ការបង្រៀន ការយកគំរូតាម ការស្រឡាញ់ និងការបន្ទាបខ្លួនផងដែរ។

ប៉ុន្តែ ទោះបីជាយើងអាចយល់ស្របលើពាក្យនេះក៏ដោយ ក៏គ្រីស្ទបរិស័ទមួយចំនួននៅតែពិបាកយល់ក្នុងការបង្រៀនអំពីការបង្កើតសិស្ស។ ពួកគាត់មានអារម្មណ៍ថា មានភាពឆ្គងក្នុងការធ្វើវា។ ពួកគាត់មិនចង់បង្ខំឲ្យអ្នកដទៃត្រូវតែទទួលយកគំនិតរបស់គាត់នោះទេ។ ពួកគាត់មិនចង់ប្រព្រឹត្តទៅ ហាក់ដូចជាពួកគាត់នៅ "ខាងលើ" អ្នកដទៃនោះឡើយ[៥]។

មានចំនួននៃការជំទាស់ច្រើនទាក់ទងទៅនឹងការបង្កើតសិស្ស។ ប៉ុន្តែ ខ្ញុំសូមចែករំលែកជាមួយលោកអ្នក តែមួយចំនួនប៉ុណ្ណោះ រួមជាមួយនឹងការឆ្លើយតបយ៉ាង

៥ លោកស្រី Alice Fryling, Disciplemakers' Handbook: Helping People Grow in Christ (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៩), ទំព័រ៨៨។

ឆាប់រហ័សរបស់ខ្ញុំទៅនឹងការជំទាស់នីមួយៗដែរ។

***ការជំទាស់ទី១៖*** «អ្នកបង្កើតសិស្សម្នាក់នេះ មិនល្អឥតខ្ចោះទេ»។
***ចម្លើយ៖*** លោកអ្នកក៏មិនល្អឥតខ្ចោះដែរ។ មានតែព្រះទេ ដែលទ្រង់តែមួយអង្គគត់ គឺល្អឥតខ្ចោះនៅក្នុងហេតុផលនេះ។ ទ្រង់បានទទួលសិរីល្អ ដោយប្រើប្រាស់ភាជនៈដែលមិនល្អឥតខ្ចោះដូចខ្ញុំ និងលោកអ្នករាល់គ្នាដែរ។ នៅពេលលោកអ្នកកាន់តែបន្ទាបខ្លួនកាន់តែច្រើន នោះលោកអ្នកនឹងរកឃើញថា លោកអ្នកត្រូវរៀនពីសិស្សដ៏ពិតប្រាកដរបស់ព្រះយេស៊ូវផ្សេងទៀតកាន់តែច្រើនដូចគ្នា។

***ការជំទាស់ទី២៖*** «ប្រសិនបើមនុស្សម្នាក់តែងតែស្តាប់អ្នកកំពុងជួយគាត់ឲ្យដើរតាមព្រះយេស៊ូវ នោះគាត់ប្រហែលជាឈប់ចុះចូលនឹងអំណាចល្អៗផ្សេងទៀតដូចជាឪពុកម្តាយ ប្តី/ប្រពន្ធ ឬក្រុមជំនុំរបស់គាត់ទៀតហើយ»។
***ចម្លើយ៖*** ប្រសិនបើការបង្កើតសិស្សធ្វើទៅបានល្អ នោះការបង្កើតសិស្សដែលល្អនឹងជំរុញឲ្យមានការចុះចូលសមស្របចំពោះអំណាចនានា ដែលព្រះបានបង្កើតឡើងជាមិនខាន។

***ការជំទាស់ទី៣៖*** «ប្រសិនបើមានមនុស្សម្នាក់ប្រាប់ខ្ញុំថា គាត់ចង់ជួយខ្ញុំឲ្យដើរតាមព្រះយេស៊ូវ មើលទៅហាក់បីដូចជាគាត់កំពុងតែគិតអំពីខ្លួនឯង និងមានអំនួតដោយសារគាត់បាននិយាយដូច្នោះ»។
***ចម្លើយ៖*** ខ្ញុំយល់អំពីរបៀបដែលវាអាចមើលឃើញទៅបែបដូច្នោះដែរ។ ប៉ុន្តែ ការបង្កើតសិស្សក្នុងជំនឿគ្រីស្ទបរិស័ទ គឺជាការត្រាស់ហៅឲ្យយើងដើរតាមនរណាម្នាក់ដែលគាត់កំពុងដើរតាមព្រះគ្រីស្ទដែរ។ ព្រះអង្គមិនបានត្រាស់ហៅឲ្យយើងធ្វើតាមគំនិតរបស់អ្នកដទៃ ឬតាមវប្បធម៌ ឬប្រាជ្ញាខាងលោកីយ៍ ឬទម្លាប់ផ្ទាល់ខ្លួនរបស់យើងនោះទេ។ ការបង្កើតសិស្សមានន័យថា យើងត្រូវតែធ្វើជាគំរូចំពោះគ្នាទៅវិញទៅមក  ខណៈពេលដែលយើងត្រាប់តាមព្រះគ្រីស្ទ ហើយការនេះតម្រូវឲ្យយើងបន្ទាបខ្លួនខ្លាំងណាស់ មិនមែនឲ្យមានអំនួតទេ។ លើសពីនេះទៅទៀត ការ

ជួយអ្នកដទៃឲ្យដើរតាមព្រះគ្រីស្ទគឺជាការបង្គាប់ដែលមានចែងនៅក្នុងព្រះគម្ពីរ។

***ការជំទាស់ទី៤៖*** «ប្រសិនបើមានគេប្រាប់ខ្ញុំថា គាត់ចង់ជួយខ្ញុំឲ្យដើរតាមព្រះយេស៊ូវ នោះហាក់បីដូចជាមានន័យថា គាត់កំពុងតែបង្ខំខ្ញុំឲ្យធ្វើការនេះ ឬក៏ការនោះ»?
***ចម្លើយ៖*** ការបង្កើតសិស្សក្នុងជំនឿគ្រីស្ទបរិស័ទគឺជាទំនាក់ទំនងដែលមានការព្រមព្រៀងគ្នាទាំងសងខាងជាមួយគ្នាទៅវិញទៅមក។

***ការជំទាស់ទី៥៖*** ខ្ញុំមិនត្រូវការការបង្កើតសិស្សទេ។ ខ្ញុំចង់មានន័យថា ខ្ញុំបានយល់ច្បាស់ហើយនូវអ្វីដែលសំខាន់បំផុតនៃជីវិតជាគ្រីស្ទបរិស័ទ! ដូច្នេះ ខ្ញុំរវល់ខ្លាំងពេក មិនអាចយករឿងនេះទុកជាអាទិភាពនៅក្នុងជីវិតខ្ញុំបានទេ។
***ចម្លើយ៖*** សូមមានការប្រុងប្រយ័ត្នក្នុងការធ្វើជា «អ្នកដែលដើរតាមព្រះយេស៊ូវតែម្នាក់ឯង»។ ព្រះយេស៊ូវបានសុគត គឺមិនមែនសម្រាប់បុគ្គលណាម្នាក់ដាច់ដោយឡែកនោះទេ ប៉ុន្តែទ្រង់បានសុគត សម្រាប់ក្រុមជំនុំទាំងមូល។ នៅពេលដែលព្រះជាម្ចាស់ទទួលយកលោកអ្នកធ្វើជាកូនចិញ្ចឹមរបស់ទ្រង់ នោះទ្រង់បាននាំលោកអ្នកចូលទៅក្នុងគ្រួសាររបស់ព្រះ ដូច្នេះហើយ ឥឡូវនេះលោកអ្នកមានបងប្អូនប្រុសស្រីនៅក្នុងសេចក្តីជំនឿ។ លើសពីនេះទៅទៀត ទ្រង់បានមានបន្ទូលឲ្យយើងបង្ហាញថា យើងជាសមាជិកគ្រួសារព្រះអង្គ និងស្រឡាញ់ព្រះអង្គតាមរយៈការស្រឡាញ់គ្នាទៅវិញទៅមកផងដែរ។ យើងធ្វើដូច្នេះបាន គឺតាមរយៈការចុះចូល និងការដែលយើងប្រកបគ្នាជាមួយនឹងក្រុមជំនុំតាមតំបន់។ ជំនឿគ្រីស្ទបរិស័ទ គឺជាជំនឿផ្ទាល់ខ្លួន ហើយប្រាកដណាស់ វាតែងតែតម្រូវឲ្យមានបែបដូច្នេះ! ប៉ុន្តែ ជំនឿគ្រីស្ទបរិស័ទ គឺមិនមែនជាសេចក្តីជំនឿឯកជននោះទេ។ លោកអ្នកត្រូវតែមានចំណែកក្នុងជីវិតរបស់អ្នកដទៃ ហើយលោកអ្នកក៏ត្រូវការអ្នកដទៃឲ្យមកធ្វើបែបដូចគ្នានេះ នៅក្នុងជីវិតរបស់លោកអ្នកដែរ។ មានតែព្រះអម្ចាស់ទេ ដែលមិនត្រូវការ ការបង្រៀនពីអ្នកណាម្នាក់នោះឡើយ!

***ការជំទាស់ទី៦៖*** «ការបង្កើតសិស្សគឺគ្រាន់តែសម្រាប់មនុស្សណា ដែលចូលចិត្ត

មានទំនាក់ទំនងច្រើនប៉ុណ្ណោះ។ ខ្ញុំជាបុគ្គលដែលមិនចូលចិត្តនៅម្នាក់ឯងទេ»។
***ចម្លើយ៖*** មិនមែនទេ នេះគឺសម្រាប់គ្រីស្ទបរិស័ទទាំងអស់។ ចំនួននៃទំនាក់ទំនងទាំងនេះ ដែលប្រហែលតិចឬច្រើន អាស្រ័យទៅលើបុគ្គលិកលក្ខណៈ ស្ថានភាពជីវិត និងអ្វីៗផ្សេងទៀត។ ប៉ុន្តែ ការមិនមានទំនាក់ទំនងនៃការបង្កើតសិស្ស គឺមិនមែនជាជម្រើសសម្រាប់សេចក្តីជំនឿ ដែលផ្តោតលើសេចក្តីស្រឡាញ់ និងការអត់ទោសនោះទេ។ ចូរសូមគ្រីស្ទបរិស័ទដទៃទៀត ដែលមានភាពពេញវ័យខាងឯសេចក្តីជំនឿ ដើម្បីឲ្យគាត់អាចជួយលោកអ្នកក្នុងការមើលឃើញអំពីទម្រង់នៃរឿងទាំងនេះ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់លោកអ្នក។

***ការជំទាស់ទី៧៖*** «ខ្ញុំមិនអាចជួយនាំអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវបានទេ ដោយព្រោះខ្ញុំមិនល្អឥតខ្ចោះ ខ្ញុំនៅតែធ្វើខុស ហើយខ្ញុំក៏នៅក្មេងពេក»។
***ចម្លើយ៖*** ប្រសិនបើលោកអ្នកពិតជាកំពុងដើរតាមព្រះគ្រីស្ទមែន នោះអ្វីដែលលោកអ្នកត្រូវធ្វើ គឺចែករំលែកដល់អ្នកដទៃនូវអ្វីដែលលោកអ្នកបានដឹង មិនមែនចែករំលែកអ្វីដែលលោកអ្នកមិនបានដឹងនោះទេ។ សូមចែករំលែកដល់មនុស្សជាច្រើននៅជុំវិញលោកអ្នកអំពីដំណឹងល្អរបស់ព្រះគ្រីស្ទ! ចែករំលែកដំណឹងល្អនោះ ជាមួយសមាជិកក្រុមជំនុំផ្សេងទៀត ហើយការនេះអាចមានន័យថា លោកអ្នកកំពុងចាប់ផ្តើមការសន្ទនាខាងឯវិញ្ញាណ ដោយការសួរសំណួរ ចែករំលែកអ្វីដែលលោកអ្នកកំពុងរៀន និងអធិស្ឋានសម្រាប់ពួកគាត់ផងដែរ។ អស់អ្នកណាដែលដើរតាមព្រះគ្រីស្ទពិតប្រាកដ នោះនឹងពិតជាអាចបង្កើតសិស្សថ្វាយទ្រង់បាន។

## សេចក្តីសន្និដ្ឋាន

ការបង្កើតសិស្ស គឺជាការជួយនរណាម្នាក់ឲ្យដើរតាមព្រះយេស៊ូវ ដោយមានចេតនាធ្វើការល្អខាងឯវិញ្ញាណ ក្នុងជីវិតរបស់គាត់។ យើងក្លាយជាគ្រីស្ទបរិស័ទ ដោយព្រោះមាននរណាម្នាក់បានធ្វើកិច្ចការបែបនេះ សម្រាប់យើង ហើយមាននរណាម្នាក់ផ្សេងទៀតបានធ្វើកិច្ចការដដែលនេះ សម្រាប់អ្នកដទៃផ្សេងទៀតដែរ។ ហើយការធ្វើបែបនេះ នឹងនាំយើងឲ្យត្រឡប់ទៅឃើញអំពីអ្វីដែលពួកសិស្សដំបូងបង្អស់

របស់ទ្រង់បានធ្វើ។ ស្មរបន្ទាល់បានឃើញហេតុការផ្ទាល់ភ្នែកដំបូងរបស់ព្រះយេស៊ូវ បានបង្រៀននូវអ្វីដែលទ្រង់មានបន្ទូលបង្គាប់ដល់អ្នកជំនាន់បន្ទាប់ឲ្យធ្វើ ហើយអ្វីដែលពួកគាត់បានឮអំពីសេចក្តីបង្គាប់នោះ ក៏បានបង្កើតជាស្មរបន្ទាល់ដែលបានឮដោយត្រចៀកជាបន្តបន្ទាប់ផងដែរ។ ការធ្វើរបៀបនេះបានបន្តរហូតដល់សព្វថ្ងៃ ហើយឥឡូវនេះ ដល់វេនរបស់យើងហើយ។ នៅក្រោមអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ សិស្សជំនាន់ក្រោយរបស់ទ្រង់ គឺពឹងផ្អែកលើយើងដែលធ្វើតាមគំរូរបស់សិស្សដំបូងរបស់ទ្រង់ទាំងនោះ។ ការបង្កើតសិស្ស គឺជាផ្នែកមួយនៃភាពជាសិស្សផ្ទាល់របស់យើងនៅក្នុងព្រះគ្រីស្ទ។

•••

ប៉ុន្តែ រហូតមកដល់ពេលនេះ ភាគច្រើន ខ្ញុំលើកទឹកចិត្តគេឲ្យបង្កើតសិស្សដែលជាសកម្មភាពនៃការបង្រៀនម្នាក់ទល់នឹងម្នាក់។ ទំនាក់ទំនងនៃការបង្កើតសិស្សមួយចំនួនរបស់យើង ដែលយើងធ្វើឡើងជាមួយអ្នកជឿផ្សេងទៀត ក៏ទំនងជាអាចកើតឡើងខាងក្រៅសមាជិកភាពនៅក្នុងក្រុមជំនុំមួយរបស់យើងបានដែរ។ ប៉ុន្តែ ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទត្រូវបានបង្ហាញឲ្យឃើញច្បាស់ដល់មនុស្សជុំវិញយើង (យ៉ូហាន ១៣:៣៤-៣៥) ការបង្កើតសិស្សរបស់យើងភាគច្រើននឹងកើតឡើងនៅក្នុងបរិបទនៃក្រុមជំនុំតាមតំបន់។ គ្រីស្ទបរិស័ទគ្រប់រូបមិនមែនត្រូវការតែគ្រីស្ទបរិស័ទម្នាក់ផ្សេងទៀតនោះទេ ដោយព្រោះយើងម្នាក់ៗត្រូវការរូបកាយទាំងមូល! នេះគឺជាអ្វីដែលយើងនឹងពិភាក្សានៅក្នុងផ្នែកនៃជំពូកបន្ទាប់ទៀត។

ផ្នែកទី២៖

# តើយើងគួរបង្កើតសិស្សនៅឯណា?

## ជំពូកទី៥

# ក្រុមជំនុំតាមតំបន់

ការបង្កើតសិស្សដែលធ្វើក្រៅពីក្រុមជំនុំគឺមិនមែនជារឿងដែលមានប្រាជ្ញាទេ។ ហើយការដែលមានក្រុមជំនុំដែលមិនមានការបង្កើតសិស្សក៏កាន់តែជារឿងអាក្រក់ជាងនេះទៅទៀត។ ហើយនេះក៏ជារឿងធម្មតាដែលកំពុងកើតមានឡើងនៅក្នុងក្រុមជំនុំតាមតំបន់ទៀតផង។

នៅពេលដែលមានគ្រីស្ទបរិស័ទបានមកចូលរួមជាមួយនឹងក្រុមជំនុំណាមួយ គេក៏មិនសូវឃើញមានសមាជិកណាមួយមកជួយបង្រៀនពួកគាត់ឲ្យចេះដើរតាមព្រះយេស៊ូវដែរ។ គេឃើញថាមិនសូវមានសេចក្តីចៅរ៉ៅប៉ុន្មានទេ។ គ្រីស្ទបរិស័ទមិនសូវអញ្ជើញអ្នកជឿផ្សេងឲ្យទៅលេងផ្ទះខ្លួនបរិភោគអាហារជាមួយគ្នា ឬក៏អធិស្ឋានឲ្យគ្នាទៅវិញទៅមកប៉ុន្មានទេ។ បុរសៗពុំបានបំពេញតួនាទីជាអ្នកគង្វាលដ៏ល្អដល់ប្រពន្ធ និងកូនៗឡើយ។ ស្ត្រីវ័យចំណាស់ក៏មិនបានបង្រៀនដល់ស្ត្រីវ័យក្មេងដែរ។ គ្រីស្ទបរិស័ទក៏ពុំមានការប្រឹក្សាយោបល់ដល់គ្នាទៅវិញទៅមក ប៉ុន្តែបែរជាពឹងតែលើគ្រូគង្វាលម្នាក់ក្នុងការផ្តល់យោបល់ទៅវិញ។ ពួកគេមិនបានគិតអំពីការជួយគ្រួសារ ឬជីវិតអាពាហ៍ពិពាហ៍ដែលកំពុងមានបញ្ហាទេ។ គ្រីស្ទបរិស័ទមិនសូវមានការឈោងចាប់ជនអន្តោប្រវេសន៍ ឬអ្នកនិយាយដែលមានតុងភាសាផ្សេងៗគ្នាឡើយ។ មានយុវជនតិចតួចណាស់ដែលបានជួបយុវជនផ្សេងទៀត ដើម្បីសិក្សាព្រះគម្ពីរជាមួយគ្នា។

## ក្រុមជំនុំផ្ទាល់ គឺជាអ្នកបង្កើតសិស្ស

ប៉ុន្តែ ព្រះគម្ពីរបង្រៀនថា ក្រុមជំនុំតាមតំបន់មានបរិយាកាសងាយស្រួលសម្រាប់ការបង្កើតសិស្ស។ តាមការពិត ព្រះគម្ពីរក៏បានបង្រៀនថា ក្រុមជំនុំតាមតំបន់ផ្ទាល់

គឺជាកន្លែងដែលអាចជួយគ្រីស្ទបរិស័ទផ្សេងទៀតក្នុងការដើរតាមព្រះយេស៊ូវ។ ការនេះកើតឡើងបានតាមរយៈការជួបជុំគ្នាប្រចាំសប្ដាហ៍ និងមានទំនាក់ទំនងក្នុងការជួយមើលខុសត្រូវគ្នាទៅវិញទៅមក (ជំពូកនេះ) ក៏ដូចជាការមានពួកចាស់ទុំ និងសមាជិករបស់ក្រុមជំនុំ (ជំពូកបន្ទាប់)។ ជាលទ្ធផល មនុស្សទាំងនេះ និងការមានទំនាក់ទំនង នឹងបង្កើតចេញជាការបង្កើតសិស្សមួយទល់នឹងមួយ ដូចជាអ្វីដែលយើងបាននិយាយរហូតមកដល់ពេលនេះ។

នៅពេលដែលក្រុមជំនុំតាមតំបន់ជួបជុំគ្នា គឺក្រុមជំនុំមានទំនួលខុសត្រូវក្នុងការប្រកាសប្រាប់ពីដំបូន្មានទាំងស្រុងរបស់ព្រះដល់ក្រុមជំនុំ តាមរយៈអស់អ្នកដែលមានអំណោយទានសម្រាប់គោលបំណងនេះ។ តាមរយៈការធ្វើពិធីបុណ្យជ្រមុជទឹក នោះក្រុមជំនុំអាចបញ្ជាក់អំពីការទទួលស្គាល់ជាសាធារណៈ ដែលគួរឲ្យទុកចិត្តបាន នៅពីមុខសមាជិកក្រុមជំនុំដទៃទៀត។ តាមរយៈការធ្វើពិធីលៀងព្រះអម្ចាស់ គឺវាជាការប្រកាសអំពីការសុគតរបស់ព្រះអម្ចាស់ ហើយបាននាំឲ្យមនុស្សជាច្រើនបានមករួមគ្នាតែមួយនៅក្នុងព្រះគ្រីស្ទដែរ។ ហើយតាមរយៈការបណ្ដេញចេញពីក្រុមជំនុំ គឺជាការដកសមាជិកណាម្នាក់ ដែលមិនព្រមកែប្រែចិត្ត ឬក៏ថាជីវិតរបស់គាត់រស់នៅផ្ទុយពីការដែលគាត់បានប្រកាសជាសាធារណៈនៅក្នុងក្រុមជំនុំ។

សូមគិតអំពីការនេះថា ដូចជាគ្រោងឆ្អឹង ឬក៏រចនាសម្ព័ន្ធរបស់ក្រុមជំនុំ។ បន្ទាប់មក យើងមានទំនាក់ទំនងនៅក្នុងក្រុមជំនុំដែលនោះប្រៀបដូចជារូបកាយ និងសាច់ដុំរបស់ក្រុមជំនុំ។ នៅក្នុងការរស់នៅជាមួយគ្នា សមាជិកនៃក្រុមជំនុំត្រូវអនុវត្តការស្រឡាញ់គ្នាទៅវិញទៅមក ដូចដែលព្រះយេស៊ូវបានស្រឡាញ់ពួកគេដែរ៖ «ខ្ញុំឲ្យសេចក្ដីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក» (យ៉ូហាន ១៣:៣៤-៣៥)។ តើព្រះយេស៊ូវបានស្រឡាញ់ពួកសិស្សរបស់ទ្រង់ជាមួយនឹងសេចក្ដីស្រឡាញ់អ្វី? ទ្រង់បានស្រឡាញ់ពួកគេ ដោយសេចក្ដីស្រឡាញ់ដែលតែងតែចង្អុលបង្ហាញទៅកាន់ព្រះបន្ទូលរបស់ព្រះវរបិតា។ ព្រះអង្គបានបង្ហាញអំពីសេចក្ដីស្រឡាញ់របស់

ទ្រង់ តាមរយៈការស្តាប់បង្គាប់តាមព្រះវរបិតារបស់ទ្រង់។ ព្រះអង្គក៏បានធានាដល់ពួកសិស្សទ្រង់អំពីកន្លែងដែលទ្រង់កំពុងរៀបចំឡើងសម្រាប់ពួកគេ។ ហើយនៅទីបំផុត ទ្រង់ក៏បានស៊ូប្តូរព្រះជន្មទ្រង់ ដើម្បីឲ្យពួកគេអាចទទួលបានការអត់ទោសផងដែរ។ ឥឡូវនេះ សូមគិតពិចារណាថា៖ តើយើងអាចមានសេចក្តីស្រឡាញ់ដែលល្អបែបនេះចំពោះអ្នកជឿដូចគ្នានៅកន្លែងណាបាន? ចម្លើយ៖ យើងអាចមានសេចក្តីស្រឡាញ់ល្អបែបនេះបាន គឺនៅពេលដែលយើងស្ថិតក្នុងបរិយាកាសមួយ ដែលយើងអាចមានសេចក្តីស្រឡាញ់ ដោយចង្អុលបង្ហាញទៅកាន់ព្រះបន្ទូលរបស់ព្រះវរបិតា និងព្រះរាជបុត្រា និងនៅកន្លែងដែលយើងអាចបញ្ជាក់អំពីការប្រែចិត្តរបស់យើង តាមរយៈការធ្វើពិធីបុណ្យជ្រមុជទឹក និងតាមរបៀបដែលមនុស្សជាច្រើនមានការរួមគ្នាតែមួយតាមរយៈការធ្វើពិធីលៀងព្រះអម្ចាស់ ហើយនៅកន្លែងដែលយើងអាចលះបង់បំណងចិត្ត និងបំណងប្រាថ្នាសម្រាប់ការសងសឹករបស់យើង តាមរយៈការអត់ទោសឲ្យអ្នកដទៃផ្សេងទៀត។ នៅក្នុងក្រុមជំនុំ រូបកាយ និងគ្រោងឆ្អឹងត្រូវតែភ្ជាប់មកជាមួយគ្នា។ នៅក្នុងរបៀបជាមូលដ្ឋានគ្រឹះទាំងនេះ ក្រុមជំនុំតាមតំបន់ គឺជាអ្នកបង្កើតសិស្សជាចម្បងសម្រាប់គ្រីស្ទបរិស័ទទាំងអស់។

ក្រុមជំនុំរបស់យើងនឹងមិនដែលមានភាពល្អឥតខ្ចោះនោះឡើយ។ ប៉ុន្តែប្រសិនបើស្ថានសួគ៌គឺជាអ្វីដែលលោក យ៉ូណាថាន់ អេដវឺដស៍ បានហៅថា “ជាពិភពនៃសេចក្តីស្រឡាញ់” (ហើយដូចដែលកណ្ឌគម្ពីរ ១កូរិនថូស ជំពូក១៣ បានបញ្ជាក់អត្ថន័យបែបដូច្នេះដែរ) នោះក្រុមជំនុំតាមតំបន់ គួរតែមានការសម្លឹងមើលជាមុន ឬមានការភ្លក់មើលមុននៃពិភពមួយនោះ។

## ការប្រជុំគ្នា

កិច្ចការបង្កើតសិស្សរបស់ក្រុមជំនុំចាប់ផ្តើមយ៉ាងសាមញ្ញជាមួយការប្រជុំគ្នា។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានសរសេរថា “ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថា ថ្ងៃនោះជិតមកដល់ហើយ” (ហេព្រើរ

១០:២៤-២៥)។

សូមកត់ចំណាំថា គោលដៅរបស់ក្រុមជំនុំនៅត្រង់នេះ គឺដើម្បីជួយគ្នាទៅវិញទៅមកឲ្យបានដើរតាមព្រះយេស៊ូវ ឬដូចដែលកណ្ឌគម្ពីរហេព្រើរបានបង្គាប់ថា «ឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមក ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង»។ ហើយតើអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរ បានប្រាប់ក្រុមជំនុំឲ្យសម្រេចគោលដៅនោះបានដោយរបៀបណា? គឺដោយឥតលែងប្រជុំគ្នា។ ដោយការប្រជុំគ្នា! នេះហើយគឺជារបៀបដែលយើង «កំឡាចិត្ត» គ្នាទៅវិញទៅមក។ ទ្រង់ចង់មានបន្ទូលប្រាប់យើងថា យើងត្រូវប្រជុំគ្នាម្តងហើយម្តងទៀត និងឲ្យបានទៀងទាត់ ហើយការប្រជុំគ្នាទៀងទាត់នោះនឹងបង្ហាញឲ្យឃើញពីការដែលយើងដើរតាមព្រះយេស៊ូវ និងការជួយអ្នកដទៃឲ្យចេះដើរតាមព្រះយេស៊ូវដែរ។

## រចនាសម្ព័ន្ធនៃអំណាច

នេះគឺជារចនាសម្ព័ន្ធរបស់ព្រះយេស៊ូវផ្ទាល់។ ព្រះយេស៊ូវបានបង្រៀនសិស្សទាំងដប់ពីររបស់ទ្រង់ អស់មួយរយៈពេល ហើយ...

១. ទ្រង់បានមានបន្ទូលសួរពួកគេថា តើទ្រង់ជានរណា (ម៉ាថាយ ១៦:១៣)។
២. សាវ័ក ពេត្រុស បានទូលឆ្លើយថា ទ្រង់ជាព្រះមេស្ស៊ីដែលព្រះគម្ពីរបានសន្យាតាំងពីយូរណាស់មកម្ល៉េះ។
៣. ព្រះយេស៊ូវបានបញ្ជាក់ដោយទទួលយកចម្លើយរបស់សាវ័ក ពេត្រុស ជំនួសឲ្យ «ព្រះវរបិតានៃទ្រង់ដែលគង់នៅស្ថានសួគ៌» ហើយបន្ទាប់មក...
៤. ទ្រង់បានមានបន្ទូលសន្យាថា ទ្រង់នឹងសង់ពួកជំនុំទ្រង់ឡើងតាមរយៈសាវ័ក ពេត្រុស និងចម្លើយដ៏ត្រឹមត្រូវរបស់គាត់អំពីព្រះយេស៊ូវ។
៥. បន្ទាប់មក ព្រះយេស៊ូវបានចាប់ផ្តើមប្រើរចនាសម្ព័ន្ធនៃអំណាចនេះ ដោយឲ្យសាវ័ក ពេត្រុស នូវអំណាច ដើម្បីធ្វើអ្វីដែលព្រះអង្គបានធ្វើជាមួយនឹងគាត់ដែរ៖ ដើម្បីនឹងចងទុក ហើយនឹងស្រាយអ្វីៗ «នៅផែនដី» និងដើម្បីនឹងចងទុក ហើយនឹងស្រាយអ្វីៗ «នៅលើស្ថានសួគ៌ដែរ»។ ដែលនេះមានន័យថា សាវ័ក ពេត្រុស និងពួកសាវ័កផ្សេងទៀតរបស់ទ្រង់អាចនឹងឮចម្លើយ (ឬក៏

ការប្រកាស) របស់មនុស្សផ្សេងទៀត ហើយបន្ទាប់មកអាចទទួលយក ឬក៏ បដិសេធមិនព្រមទទួលចម្លើយនោះ និងសម្រាប់អស់អ្នកដែលបានធ្វើការ នោះជំនួសឲ្យការឆ្លើយតបពីស្ថានសួគ៌ ដូចជាព្រះយេស៊ូវបានធ្វើជាមួយនឹង សាវ័ក ពេត្រុស ដែរ (ម៉ាថាយ ១៦:១៣-២០)។

៦. ក្រោយមក ព្រះយេស៊ូវក៏បានប្រទានអំណាចដូចគ្នានេះទៅដល់ក្រុមជំនុំតាម តំបន់ដែរ។ ព្រះអង្គបានឃើញជាមុនអំពីស្ថានភាពដែលអ្នកអះអាងបាន ធ្វើដោយមានភាពផ្ទុយនឹងការបញ្ជាក់ជាសាធារណៈនៃសេចក្ដីជំនឿរបស់ បុគ្គលម្នាក់នោះ។ ដូច្នេះហើយ បានជាព្រះយេស៊ូវបានប្រទានអំណាចដល់ ក្រុមជំនុំ ដែលមានការប្រជុំគ្នាឲ្យអាចចង ហើយនិងស្រាយបានដែរ។ ក្រុម ជំនុំត្រូវមានការវិនិច្ឆ័យថា តើត្រូវបន្តបញ្ជាក់អំពីការទទួលយកនរណាម្នាក់ ជាសាធារណៈ ឬក៏ដកអ្នកនោះចេញពីសមាជិកភាពនៃក្រុមជំនុំរបស់ខ្លួន (ម៉ាថាយ ១៨:១៥-២០)។

សរុបមក ពួកជំនុំដែលប្រជុំគ្នាមានអំណាចបដិសេធ ឬទទួលយកថា អ្នក ណាជាកម្មសិទ្ធិនៃរូបកាយរបស់ព្រះគ្រីស្ទ ឬអ្នកណាម្នាក់ជាសិស្សរបស់ទ្រង់។ ហើយក្នុងការធ្វើបែបនេះ វាបានផ្ដល់នូវបរិបទនៃទំនួលខុសត្រូវសម្រាប់ការបង្កើត សិស្ស។ តើមនុស្សម្នាក់នេះ ដែលខ្ញុំកំពុងបង្រៀនមិនមែនជាអ្នកជឿលើព្រះយេស៊ូវ? ឬជាអ្នកជឿលើព្រះយេស៊ូវ? តើមាននរណាម្នាក់ដែលខ្ញុំត្រូវប្រាប់ថា គាត់កំពុងរស់ នៅក្នុងជីវិតដូចជាអ្នកមិនជឿលើព្រះយេស៊ូវដែរឬទេ?

## ធ្វើបុណ្យជ្រមុជទឹកឲ្យ និងការបង្រៀនគ្នាទៅវិញទៅមក

តើក្រុមជំនុំត្រូវធ្វើការបញ្ជាក់យ៉ាងណាថា តើពួកសិស្សជាអ្នកណា? *តាមរយៈ ការធ្វើបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់។* បន្ទាប់ពីបានទទួលគ្រប់ទាំង អំណាចនៅលើស្ថានសួគ៌ ហើយនៅលើផែនដី នោះព្រះយេស៊ូវបានមានបន្ទូល បង្គាប់ពួកសិស្សរបស់ទ្រង់ឲ្យទៅ “បញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះ

វិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀន ឲ្យគេកាន់តាមគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង»។ ការធ្វើបុណ្យជ្រមុជទឹកឲ្យដល់អ្នកណាម្នាក់ គឺមានការទទួលស្គាល់ជាផ្លូវការថា «គាត់នៅជាមួយនឹងព្រះយេស៊ូវ»។ អ្នកតំណាងឲ្យព្រះយេស៊ូវទាំងនេះ គឺត្រូវតែទទួលការបង្រៀនជាមុនសិន (ម៉ាថាយ ២៨:១៨-២០)។ ហើយតាមរយៈការធ្វើពិធីលៀងព្រះអម្ចាស់ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ចំណែកពួកយើងដែលមានគ្នាច្រើន ក៏ជារូបកាយតែ១យ៉ាងនេះដែរ» (១កូរិនថូស ១០:១៧)។

ពេលចូលទៅដល់កណ្ឌគម្ពីរកិច្ចការ និងកណ្ឌសំបុត្រទាំងឡាយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី នោះយើងនឹងឃើញអំពីរបៀបនៃការបង្កើតសិស្សរបស់ពួកសាវ័ក។ ពួកគាត់មិនចេញទៅបង្កើតសិស្សជាមួយនឹងមនុស្ស ដែលមិនមានទំនាក់ទំនងជាមួយនឹងក្រុមជំនុំផ្ទាល់ណាមួយនោះទេ។ ជាងនេះទៅទៀត ពួកគេបានធ្វើបុណ្យជ្រមុជទឹកឲ្យបណ្ដាមនុស្ស ឲ្យអ្នកទាំងនោះបានចូលរួមក្នុងក្រុមជំនុំ តាមរយៈទំនាក់ទំនងដែលបានកើតឡើងចេញពីកន្លែងដែលពួកគេបានបង្រៀនម្នាក់ទល់ម្នាក់ និងមានការប្រកបគ្នាទៅវិញទៅមក។ ដូច្នេះ សាវ័ក ពេត្រុស បានប្រកាសអំពីដំណឹងល្អនៅបុណ្យថ្ងៃទី៥០ ដែលមានមនុស្សជាច្រើនបានប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹកនៅថ្ងៃនោះ ហើយបណ្ដាមនុស្សបន្តប្រជុំគ្នាយ៉ាងទៀងទាត់ ទាំងនៅតាមផ្ទះ និងនៅក្នុងព្រះវិហារ ដើម្បីកាច់នំប៉័ង ហើយកិច្ចការទាំងនេះបានកើតឡើងបន្ថែមទៅក្នុងព្រះវិហារមួយ គឺនៅព្រះវិហារនៅក្រុងយេរូសាឡឹម។ បន្ទាប់មកពួកសិស្សបានចេញទៅបង្កើតសិស្សផ្សេងទៀតនៅគ្រប់ទាំងសាសន៍។ ពួកគេនឹងមិនបង្កើតសិស្សដោយមិនធ្វើពិធីបុណ្យជ្រមុជទឹក មិនមានការបង្រៀន ឬក៏មិនធ្វើពិធីលៀងព្រះអម្ចាស់ ឬមិនមានគ្រូៗដែលបានទទួលអំណោយទានបង្រៀនពីព្រះនោះឡើយ។ ទេ! មិនមែនទេ! ពួកសិស្សបានដាំក្រុមជំនុំដោយមានការស្ដាប់បង្គាប់តាមព្រះយេស៊ូវ ហើយបង្រៀនដល់អ្នកដទៃឲ្យកាន់តាមគ្រប់ទាំងសេចក្ដីដែលព្រះយេស៊ូវបានបង្គាប់មកពួកគេដែរ។

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ក្រុមជំនុំតាមតំបន់ គឺជាទីកន្លែងចម្បងនៃការងារស្ដាប់បង្គាប់ និងការបង្កើតសិស្ស។ សម្រាប់ក្រុមជំនុំ ការនេះមិនមែនជាជម្រើស

នោះឡើយ ប៉ុន្តែជាមូលដ្ឋានគ្រឹះ។ យើងនឹងគិតពិចារណាអំពីរឿងនេះបន្ថែមទៀត នៅក្នុងជំពូកបន្ទាប់ ជាពិសេសការពិចារណាទាក់ទងនឹងការងាររបស់ពួកចាស់ទុំ និងសមាជិកក្រុមជំនុំ។

ជំពូកទី៦

# គ្រូគង្វាល និងសមាជិកក្រុមជំនុំ

ក្រុមជំនុំតាមតំបន់ គឺជាកន្លែងដែលព្រះជាម្ចាស់បានបង្កើតមក សម្រាប់ឲ្យមានទំនាក់ទំនងក្នុងការបង្កើតសិស្ស ដូចដែលយើងបានពិចារណាចំណុចនេះនៅក្នុងជំពូកមុននេះ។ យើងបានលើកឡើងអំពីការបង្កើតសិស្សនៅក្នុងបរិបទនៃការប្រជុំគ្នារបស់ក្រុមជំនុំ។ ហើយយើងក៏បានលើកឡើងអំពីទំនួលខុសត្រូវដែលក្រុមជំនុំត្រូវធ្វើពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់។ ប៉ុន្តែ មានរឿងដ៏មានតម្លៃពីរទៀតដែលយើងគួរស្វែងយល់នៅក្នុងជីវិតនៃក្រុមជំនុំ៖ ១) ការងាររបស់គ្រូគង្វាល និង ២) ការទទួលខុសត្រូវរបស់ក្រុមជំនុំ ឬសមាជិកក្រុមជំនុំ។ រឿងដ៏មានតម្លៃទាំងពីរនេះ ក៏មានសារៈសំខាន់ផងដែរ សម្រាប់ការងារដ៏សាមញ្ញនៃការបង្កើតសិស្សនៅក្នុងជីវិតនៃគ្រីស្ទបរិស័ទ។

## គ្រូគង្វាលធ្វើការបង្កើតសិស្ស និងផ្តល់គ្រប់ចំណេះដឹងដល់អ្នកបង្កើតសិស្សដោយព្រះបន្ទូលរបស់ព្រះ

សូមចាប់ផ្តើម ដោយគិតពិចារណាអំពីគ្រូគង្វាល។ នៅក្នុងកណ្ឌគម្ពីរសញ្ញាថ្មី តួនាទីជាចម្បងរបស់គ្រូគង្វាល ឬពួកចាស់ទុំ (ព្រះគម្ពីរ បានប្រើប្រាស់ពាក្យទាំងពីរនេះ ក្នុងលក្ខណៈឆ្លាស់គ្នា) គឺជាការជួយ គ្រីស្ទបរិស័ទឲ្យដើរតាមព្រះយេស៊ូវ ដោយការបង្រៀនព្រះបន្ទូលរបស់ព្រះ និងការប្រកាសដំណឹងល្អទៅកាន់អ្នកមិនជឿ។ ជាដំបូង ពួកគាត់បានធ្វើកិច្ចការនេះ ដូចជាអ្នកផ្សាយដំណឹងល្អ។ សាវ័ក ប៉ុល បានប្រាប់ឲ្យ ធីម៉ូថេ "ចូរឲ្យអ្នកធ្វើការជាគ្រូផ្សាយដំណឹងល្អចុះ" (២ធីម៉ូថេ ៤:៥) ដោយសារសេចក្តីជំនឿកើតឡើងដោយការឮព្រះបន្ទូលរបស់ព្រះគ្រីស្ទ (រ៉ូម ១០:១៧)។

ប៉ុន្តែ ការយល់ដឹងកាន់តែទូលំទូលាយនោះគឺព្រះបានញែកគ្រូគង្វាលឲ្យធ្វើ

ការបង្កើតសិស្សក្នុងក្រុមជំនុំ ដោយការបង្រៀនពួកគេនូវព្រះបន្ទូលរបស់ទ្រង់។ គ្រូគង្វាល ត្រូវធ្វើការបង្រៀនទៅតាមការកំណត់ណាមួយ ទាំងការបង្រៀននៅក្នុងការប្រជុំគ្នាជាក្រុម និងការបង្រៀនម្នាក់ទល់ម្នាក់ ឬក៏ការបង្រៀននៅតាមក្រុមតូចៗជាដើម។ ហើយគោលដៅមួយក្នុងការបង្រៀនរបស់ពួកគាត់ គឺដើម្បីផ្តល់ឲ្យក្រុមជំនុំនូវគ្រប់ចំណេះដឹង សម្រាប់ការងារព័ន្ធកិច្ច ដើម្បីឲ្យក្រុមជំនុំស្អាងខ្លួនក្នុងសេចក្តីស្រឡាញ់ (អេភេសូរ ៤:១១–១៦)។ ពួកគាត់ត្រូវបង្រៀនសមាជិកក្រុមជំនុំ ដើម្បីជួយឲ្យពួកគេអាចចេះបង្រៀនអ្នកដទៃបានដែរ។

អំណោយទានជាគ្រូគង្វាល ឬពួកចាស់ទុំ គឺសម្រាប់បម្រើក្រុមជំនុំ! សាវ័កពេត្រុស គឺជាគំរូដ៏ល្អមួយដែលបង្ហាញអំពីអំណោយទាននេះ។ គាត់បានផ្សាយដំណឹងល្អនៅឯបុណ្យថ្ងៃទី៥០។ ហើយគាត់បានសរសេរសំបុត្រមួយចំនួនទៅកាន់ពួកអ្នកបរិសុទ្ធរបស់ព្រះ។ លើសពីនេះទៅទៀត ទាំងការបង្រៀន និងការសរសេររបស់គាត់ គឺជាសេចក្តីពន្យល់ព្រះបន្ទូលរបស់ព្រះពីព្រះគម្ពីរសញ្ញាចាស់ដែរ។

សាវ័ក ប៉ុល ក៏ជាគំរូដ៏ល្អផងដែរ។ គាត់បានប្រាប់ គ្រូគង្វាលវ័យក្មេងគឺលោកធីម៉ូថេ ឲ្យប្រុងប្រយ័ត្នយ៉ាងខ្លាំងនឹងសេចក្តីបង្រៀនរបស់ខ្លួន (១ធីម៉ូថេ ៤:១៦)។ ហើយសំបុត្រទាំងពីររបស់គាត់ ផ្ញើទៅកាន់លោក ធីម៉ូថេ ដោយមានភ្ជាប់ជាមួយការព្រួយបារម្ភរបស់គាត់ដែលទូន្មានថា គ្រូគង្វាលត្រូវតែជាអ្នកដែលស្គាល់នូវព្រះបន្ទូលច្បាស់ ទទួលការប្រដៅតម្រង់តាមរយៈព្រះបន្ទូល និងអាចបង្រៀនបន្តទៅអ្នកឯទៀតបានដែរ។

ប្រសិនបើលោកអ្នកនៅក្នុងក្រុមជំនុំមួយ ដែលលោកអ្នកមិនបានឮព្រះបន្ទូលរបស់ព្រះទេ នោះមានន័យថា លោកអ្នកកំពុងតែខ្ជះខ្ជាយពេលវេលារបស់ខ្លួនហើយ។ នោះគឺដោយសារ គ្រូគង្វាល ត្រូវតែបង្រៀនព្រះបន្ទូល ហើយវាជាស្នូលនៃព័ន្ធកិច្ចនៃការបង្កើតសិស្សរបស់ក្រុមជំនុំ។ កិច្ចការនេះ នឹងដូចជាការផ្តល់អាហារ និងទឹកសម្រាប់ការចិញ្ចឹមទំនាក់ទំនងនៃការបង្កើតសិស្សទាំងអស់ផ្សេងទៀតនៅក្នុងក្រុមជំនុំ។ លោកអ្នកបានទទួលបទពិសោធន៍នេះចេញពីសេចក្តីបង្រៀនចេញពីព្រះបន្ទូលរបស់ព្រះនៅក្នុងការជួបជុំគ្នាកាលពីថ្ងៃអាទិត្យមុន ហើយយើងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោកអ្នកក៏បានទទួលបទពិសោធន៍នេះកន្លងមក

ដែរ នៅពេលលោកអ្នកបានស្វែងរកការប្រឹក្សាយោបល់ ពីសំណាក់ពួកចាស់ទុំណាម្នាក់នៅក្នុងក្រុមជំនុំ។ ប្រសិនបើលោកអ្នកមិនធ្លាប់ទទួលបានបទពិសោធន៍បែបនេះទេ សូមផ្លាស់ប្ដូរទៅក្រុមជំនុំថ្មីមួយទៀត។ សូមស្វែងរកក្រុមជំនុំមួយដែលមានការបង្រៀនព្រះបន្ទូលរបស់ព្រះទៅដល់លោកអ្នក—សម្រាប់ជាប្រយោជន៍ដល់ជីវិតខាងព្រលឹងវិញ្ញាណរបស់លោកអ្នក និងជាប្រយោជន៍ដល់លោកអ្នកក្នុងការជួយដល់អ្នកដទៃផងដែរ។

## គ្រូគង្វាលដឹកនាំការធ្វើពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់

ការចងភ្ជាប់ទៅនឹងព័ន្ធកិច្ចនៃការប្រកាសព្រះបន្ទូល គឺមានព័ន្ធកិច្ចនៃពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ផងដែរ។ សេចក្ដីបញ្ញត្តទាំងនេះក៏រួមបញ្ចូលជាមួយការបង្រៀនផងដែរ។ ឧទាហរណ៍៖ ពិធីលៀងព្រះអម្ចាស់ គឺជាការ "ប្រកាស" ពីការសុគតរបស់ព្រះគ្រីស្ទ រហូតដល់ទ្រង់យាងមកម្ដងទៀត (១កូរិនថូស ១១:២៦)។ ប៉ុន្តែ ពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់មិនគ្រាន់តែបង្រៀនយើងប៉ុណ្ណោះទេ ពិធីទាំងនេះគឺជា "សញ្ញាសម្គាល់" នៅក្នុងក្រុមជំនុំ ដោយប្រាប់យើងថា តើអ្នកណាជាសមាជិក ហើយអ្នកណាដែលមិនមែនជាសមាជិកនៃក្រុមជំនុំនោះ។ ហើយសេចក្ដីបញ្ញត្តទាំងនេះក៏ផ្ដល់នូវការទទួលខុសត្រូវសម្រាប់ជីវិតគ្រីស្ទបរិស័ទ ដូចដែលយើងបានពិចារណានៅក្នុងជំពូកមុនរួចមកហើយ។ សេចក្ដីបញ្ញត្តទាំងនេះបានបង្ហាញថា តើអ្នកណាជាសមាជិកនៅក្នុងក្រុមជំនុំ។

គ្រូគង្វាលគឺជាអ្នកដែលដឹកនាំការបង្រៀន និងការមានទំនួលខុសត្រូវទាំងនេះ។ និយាយរួម ពួកគាត់ត្រូវធ្វើការសម្ភាសន៍បេក្ខជនដែលត្រូវទទួលពិធីបុណ្យជ្រមុជទឹក និងអនាគតសមាជិកភាពនៅក្នុងក្រុមជំនុំ៖ "តើអ្នកបានក្លាយជាគ្រីស្ទបរិស័ទដោយរបៀបណា?" "តើអ្វីទៅជាដំណឹងល្អ?"។ល។ ខ្ញុំជឿថា ក្រុមជំនុំមានអំណាចចុងក្រោយលើការសម្រេចចិត្តមកលើសមាជិកភាព និងអ្នកដែលបានទទួលពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់។ ប៉ុន្តែ ជាធម្មតា ក្រុមជំនុំ

គួរធ្វើតាមការដឹកនាំរបស់ពួកចាស់ទុំ។ ពួកចាស់ទុំ ឬក៏គ្រូគង្វាលគឺជាអ្នកដឹកនាំ នៅពេលដែលមានការដាក់វិន័យជ្រួតជ្រាបទៅដល់ក្រុមជំនុំទាំងមូល។ ពួកគាត់ត្រូវបង្រៀនក្រុមជំនុំអំពីអត្ថន័យនៃការប្រឈមមុខនឹងអំពើបាបដែលមិនមានការប្រែចិត្ត ដោយណែនាំឲ្យដកអ្នកមិនប្រែចិត្តនោះចេញពីការមានចំណែកក្នុងកម្មវិធីរបស់ព្រះអម្ចាស់ទាំងនេះ និងដកពីសមាជិកភាពនៅក្នុងក្រុមជំនុំ។ តាមរបៀបទាំងអស់នេះ ពួកចាស់ទុំត្រូវជួយក្នុងការផ្ដល់ឲ្យក្រុមជំនុំនូវទម្រង់ និងធ្វើឲ្យក្រុមជំនុំមានបរិយាកាសមួយ ដែលអាចធ្វើការបង្កើតសិស្សឲ្យមានភាពរីកចម្រើនឡើងបាន។ ពួកគាត់ត្រូវធ្វើយ៉ាងណាឲ្យសមាជិកក្រុមជំនុំ កាន់តែមានភាពងាយស្រួល ក្នុងការបង្រៀនគ្នាទៅវិញទៅមក។ ពួកគាត់ត្រូវរក្សាក្រុមជំនុំមិនឲ្យក្លាយទៅជាហ្វូងមនុស្សមួយក្រុមដែលមិនមានការទទួលខុសត្រូវនៃមិត្តភាពក្រៅផ្លូវការ ដែលគ្មានសមាជិកណាម្នាក់មានការទទួលខុសត្រូវជាផ្លូវការចំពោះសមាជិកផ្សេងទៀត និងជាកន្លែងដែលមនុស្សម្នាក់ៗ ត្រូវបានទុកចោល ដើម្បីគ្រាន់តែកំណត់អត្ថន័យនៃដំណឹងល្អ និងភាពស្មោះត្រង់នៃដំណឹងល្អនោះ សម្រាប់តែខ្លួនគាត់។ ពេលដែលមិនមានការទទួលខុសត្រូវបែបនេះ តើវាមានភាពងាយស្រួលប៉ុណ្ណាសម្រាប់អ្នកជឿមានភាពក្មេងខ្ចីខាងឯសេចក្ដីជំនឿម្នាក់បង្រៀនអ្នកផ្សេងទៀតបាន? ទេ! គាត់មិនអាចទាំងដឹងថា ក្រុមជំនុំរាប់អ្នកណាថា ជាអ្នកជឿផង ឬក៏ថាក្រុមជំនុំរាប់អ្នកណាជាគ្រូខុសឆ្គង ឬមនុស្សមានពុតដែរ?

## គ្រូគង្វាលត្រូវផ្ដល់ជាគំរូ

យើងបានឃើញរួចមកហើយថា ការរស់នៅជាគំរូនៃឈើឆ្កាង គឺជាធាតុផ្សំដ៏សំខាន់នៃការបង្កើតសិស្ស។ សូមចាំថា សាវ័ក ប៉ុល បានមានប្រសាសន៍ថា “ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ” (១កូរិនថូស ១១:១)។

ពួកចាស់ទុំ (គ្រូគង្វាល) គឺជាអ្នកដែលត្រូវបានតែងតាំងដោយព្រះវិញ្ញាណ ហើយត្រូវបានទទួលស្គាល់ដោយក្រុមជំនុំក្នុងការធ្វើជាគំរូដល់ក្រុមជំនុំ។ ពួកគាត់មិនមែនល្អឥតខ្ចោះនោះទេ ប៉ុន្តែពួកគាត់ក៏ពុំមានអ្វី ដែលគួរឲ្យបន្ទោសដែរ។ នេះជាមូលហេតុដែលសាវ័ក ប៉ុល បាននិយាយសង្កត់ធ្ងន់ពីសារៈសំខាន់នៃចរិតលក្ខណៈ

របស់ពួកចាស់ទុំ នៅពេលគាត់ពណ៌នាអំពីគុណសម្បត្តិទាំងនោះប្រាប់ទៅដល់លោក ធីម៉ូថេ និងលោក ទីតុស (១ធីម៉ូថេ ៣:១-៧; ទីតុស ១:៦-៩)។ អ្នកនិពន្ធកណ្ឌគម្ពីរ ហេព្រើរ ក៏បានទូន្មានផងដែរថា៖ «ចូរនឹកចាំពីពួកអ្នកនាំមុខ ដែលបានផ្សាយព្រះបន្ទូលមកអ្នករាល់គ្នា ត្រូវតែត្រាប់តាមសេចក្ដីជំនឿរបស់អ្នកទាំងនោះ ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង» (ហេព្រើរ ១៣:៧)។ សូមកត់សម្គាល់ថា គាត់មិនគ្រាន់តែទូន្មានអ្នកអានរបស់គាត់ឲ្យយកគំរូតាមអ្នកដឹកនាំណាម្នាក់តាមតែចិត្តរបស់គាត់នោះទេ គាត់បានប្រាប់ពួកគេ ឲ្យយកគំរូតាមអ្នកដឹកនាំ «របស់អ្នក»។

មិនមានអ្វីខុសទេក្នុងការដែលលោកអ្នករៀនតាមរយៈសៀវភៅរបស់គ្រូគង្វាលផ្សេងៗ។ វាជាការល្អដែលលោកអ្នកស្ដាប់ដោយរីករាយនូវការអធិប្បាយរបស់គ្រូអធិប្បាយផ្សេងទៀតនៅតាមប្រព័ន្ធអ៊ីនធឺណិតដែរ។ ប៉ុន្តែ បទគម្ពីរបានហៅលោកអ្នកឲ្យត្រាប់តាមសេចក្ដីជំនឿរបស់ គ្រូគង្វាលដែលពួកគាត់បានថ្លែងព្រះបន្ទូលរបស់ព្រះទៅកាន់លោកអ្នក។ ពួកគាត់ទាំងនេះត្រូវរាប់រៀបទូលដល់ទ្រង់វិញ (ហេព្រើរ ១៣:១៧)។ ទំនួលខុសត្រូវរបស់ពួកគាត់គឺធំណាស់។ ដូច្នេះ សូមមើលពីជីវិតរបស់ពួកគាត់ក្នុងផ្នែកមួយនៃការបង្កើតសិស្សជាមួយលោកអ្នក ហើយរៀនពីជីវិតរបស់ពួកគាត់ ដើម្បីបង្កើតសិស្សជាមួយអ្នកដទៃផងដែរ។

ក្រុមជំនុំតាមតំបន់ គឺជាកន្លែងមួយដែលព្រះបានបង្កើតឡើងសម្រាប់ជាការប្រស្រ័យទាក់ទង ឬសម្រាប់ការបង្កើតសិស្ស ពីព្រោះកន្លែងនោះហើយជាកន្លែងដែលគ្រូគង្វាលត្រូវនៅ!

## ក្រុមជំនុំទទួល និងគាំទ្រព័ន្ធកិច្ចរបស់គ្រូគង្វាល

ឥឡូវនេះ សូមយើងពិចារណាមើលអំពីរបៀបដែលសមាជិកបានជួយឲ្យក្រុមជំនុំតាមតំបន់ក្លាយជាកន្លែងដ៏ត្រឹមត្រូវមួយសម្រាប់ទំនាក់ទំនងនៃការបង្កើតសិស្ស។ ជាដំបូង សមាជិកទទួល និងគាំទ្រព័ន្ធកិច្ចរបស់ពួកចាស់ទុំ។ តាមពិតទៅ គ្រូគង្វាលមិនអាចបំពេញព័ន្ធកិច្ចរបស់គាត់បានទេ ប្រសិនបើសមាជិកមិនទទួលស្គាល់ថា ពួកគាត់គឺជាអំណោយទានពីព្រះគ្រីស្ទ ហើយមិនបានជួយគាំទ្រពួក

គាត់។ ពួកគាត់ត្រូវការសេចក្តីស្រឡាញ់ និងការអធិស្ឋានរបស់ពួកជំនុំ ព្រមទាំងការគាំទ្រដ៏រីករាយផងដែរ។ ក្រុមជំនុំមួយដំណើរការបាននៅពេលដែលសមាជិកក្រុមជំនុំនោះ មានការគោរព និងចុះចូលចំពោះគ្រូគង្វាលរបស់ពួកគេ។ វាជាការងាយណាស់ដែលគ្រីស្ទបរិស័ទមើលរំលងការពិតមួយនេះ។

សូមពិចារណាអំពីរបៀបដែលសាវ័ក ប៉ុល បានដាស់តឿនដល់ពួកជំនុំថែស្សាឡូនីច៖ «តែបងប្អូនអើយ យើងខ្ញុំអង្វរអ្នករាល់គ្នាថា ចូរចំណាំឲ្យស្គាល់ពួកអ្នកដែលខំធ្វើកិច្ចការក្នុងពួកអ្នករាល់គ្នា និងពួកអ្នកដែលនាំមុខអ្នករាល់គ្នាក្នុងព្រះអម្ចាស់ ហើយនិងពួកអ្នកដែលទូន្មានដែរ ដើម្បីឲ្យបានរាប់អានជាខ្លាំងចំពោះពួកអ្នកយ៉ាងនោះ ដោយសេចក្តីស្រឡាញ់ ដោយព្រោះការដែលគេធ្វើ ចូរនៅជាមួយគ្នាដោយមេត្រីចុះ» (១ថែស្សាឡូនីច ៥:១២-១៣) ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា អ្នកណាដែលជាអ្នកនាំមុខ និងបង្រៀនបានយ៉ាងល្អ នោះត្រូវរាប់ជាគួរនឹង «គោរពប្រតិបត្តិជាទ្វេគុណឡើង» (១ធីម៉ូថេ ៥:១៧) ដែលនេះមានន័យថាពួកគាត់ទទួលបានការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ។ គាត់ក៏មានប្រសាសន៍ទៅកាន់ក្រុមជំនុំកាឡាទីដែរថា «អ្នកណាដែលមានគ្រូបង្រៀនខាងព្រះបន្ទូល នោះត្រូវចែកគ្រប់ទាំងរបស់ល្អដល់គ្រូនោះផង» (កាឡាទី ៦:៦)។ ប្រសិនបើមានបុរសណាម្នាក់បានទទួលអំណោយទានពីព្រះ ហើយគាត់ត្រូវបានត្រាស់ហៅឲ្យបង្រៀនព្រះបន្ទូលរបស់ទ្រង់ នោះក្រុមជំនុំនឹងទទួលបានអត្ថប្រយោជន៍ ដោយតាមរយៈការជួយគាត់ក្នុងការរៀបចំជីវិតរបស់គាត់ ដើម្បីឲ្យគាត់អាចផ្តោតទៅលើការបង្រៀននោះ។ សមត្ថភាពរបស់គាត់ក្នុងការរៀបចំបង្រៀនពួកគេ គឺអាស្រ័យលើការទទួលរបស់ពួកគេចំពោះគាត់ដូចគ្នា។

## ពេលខ្លះ ពួកជំនុំត្រូវតែបដិសេធព័ន្ធកិច្ចរបស់គ្រូគង្វាល

ក្នុងពេលជាមួយគ្នានេះដែរ ពួកជំនុំក៏ត្រូវជួយជំរុញឲ្យវប្បធម៌នៃការបង្កើតសិស្សមានការរីកចម្រើន ហើយពួកជំនុំក៏ត្រូវតែបដិសេធពួកចាស់ទុំរបស់ពួកគេ នៅពេលណាដែលពួកចាស់ទុំទាំងនោះ បានបដិសេធព្រះបន្ទូលរបស់ព្រះ។ ប្រសិនបើការបង្កើតសិស្សមានន័យថា ជាការជួយអ្នកដទៃឲ្យចេះដើរតាមព្រះយេស៊ូវ នោះពួកជំនុំ

ដែលទ្រាំទ្រនឹងគ្រូខុសឆ្គងមិនបានជួយអ្នកឯទៀតឲ្យដើរតាមព្រះយេស៊ូវនោះទេ។ គួរឲ្យស្ដាយណាស់ ដែលមានគ្រូគង្វាលជាច្រើនបានបដិសេធព្រះបន្ទូលរបស់ព្រះ ហើយមានក្រុមជំនុំជាច្រើន មិនបានយល់ដឹងអំពីទំនួលខុសត្រូវរបស់ខ្លួនក្នុងរឿងនេះ។ ព្រះគម្ពីរសញ្ញាថ្មីបានបង្រៀនថា ពួកជំនុំមួយនឹងចែករំលែកការទទួលខុសត្រូវចំពោះការបង្រៀនខុសឆ្គងដ៏ធ្ងន់ធ្ងរណាមួយ ដែលក្រុមជំនុំស៊ូទ្រាំនឹងសេចក្ដីលំបាកនោះ។ សាវ័ក ប៉ុល បានស្ដីបន្ទោសមិនត្រឹមតែចំពោះគ្រូក្លែងក្លាយប៉ុណ្ណោះទេ ប៉ុន្តែចំពោះសមាជិកក្រុមជំនុំណាដែលមាន «ត្រចៀករមាស់» ហើយអស់អ្នកណាដែល «ហៅគ្រូកាន់តែច្រើនឡើង មកបង្រៀនឲ្យត្រូវចិត្ត» (២ធីម៉ូថេ ៤:៣)។

ព្រះគម្ពីរបានកត់សម្គាល់ ពីទំនួលខុសត្រូវរបស់ពួកជំនុំ ក្នុងការបដិសេធចំពោះគ្រូក្លែងក្លាយ ដែលបង្រៀននៅក្នុងក្រុមជំនុំ។ សាវ័ក ប៉ុល បានមានប្រសាសន៍ប្រាប់ក្រុមជំនុំនៅកាឡាទីថា ពួកគេអាចបដិសេធសូម្បីតែគាត់ផ្ទាល់ប្រសិនបើគាត់បានងាកចេញពីដំណឹងល្អ៖ «ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ» (កាឡាទី ១:៨)។ ដូច្នេះ ខ្ញុំបានប្រាប់ក្រុមជំនុំរបស់ខ្ញុំជារឿយៗឲ្យបណ្ដេញខ្ញុំចេញប្រសិនបើការបង្រៀនរបស់ខ្ញុំបានបំពានលើព្រះគម្ពីរ។

ការដឹងថា ក្នុងនាមជាសមាជិកក្រុមជំនុំម្នាក់ លោកអ្នកក៏មានទំនួលខុសត្រូវបែបនេះគួរតែបង្កើនការយល់ដឹងរបស់លោកអ្នកអំពីភាពធ្ងន់ធ្ងរនៃភាពជាសមាជិក។ ទំនួលខុសត្រូវនេះតម្រូវឲ្យលោកអ្នកមានការយល់ដឹងអំពីដំណឹងល្អ សិក្សាស្វែងយល់បន្ថែមអំពីដំណឹងល្អ ហើយជាទូទៅ លោកអ្នកត្រូវយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះព្រះបន្ទូលរបស់ព្រះ! បើនិយាយឲ្យខ្លីទៅ ទំនួលខុសត្រូវនេះនឹងធ្វើឲ្យលោកអ្នកក្លាយជាអ្នកបង្កើតសិស្សកាន់តែប្រសើរឡើង។

## សមាជិកក្រុមជំនុំត្រូវមានទំនួលខុសត្រូវចំពោះគ្នាទៅវិញទៅមក

សមាជិកនៃក្រុមជំនុំក៏ត្រូវមានទំនួលខុសត្រូវចំពោះគ្នាទៅវិញទៅមកផងដែរ។ ពួក

ជំនុំទាំងមូលក៏មានទំនួលខុសត្រូវក្នុងការធ្វើឲ្យប្រាកដថា សមាជិកម្នាក់ៗទទួលបានសេចក្តីស្រឡាញ់ និងត្រូវបានជំរុញឲ្យមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក (ឧទាហរណ៍៖ ១កូរិនថូស ១២:១២-២៦; ហេព្រើរ ១០:២៤)។ យើងជារូបកាយតែមួយ៖ «រូបកាយមិនមែនសុទ្ធតែមានអវយវៈតែ១ទេ គឺមានច្រើនវិញ។ បើសិនជាជើងនឹងនិយាយថា អញមិនមែនជារបស់ផងរូបកាយទេ ពីព្រោះអញមិនមែនជាដៃ នោះតើមិនមែនជារបស់ផងរូបកាយ ដោយហេតុតែប៉ុណ្ណោះឬអី» (១កូរិនថូស ១២:១៤-១៥)។

ទំនួលខុសត្រូវនេះ គឺតម្រូវឲ្យមានទម្រង់ជាច្រើន។ សូមគ្រាន់តែរាប់ចំនួនឃ្លានៃ «គ្នាទៅវិញទៅមក» នៅក្នុងអត្ថបទខ្លីមួយរបស់ សាវ័ក ប៉ុល៖ «ខាងឯសេចក្តីស្រឡាញ់ជាបងជាប្អូន នោះចូរមានចិត្តថ្នមគ្នាទៅវិញទៅមកចុះ ខាងសេចក្តីរាប់អាន នោះឲ្យខំរាប់អានគេជាមុន។ ខាងសេចក្តីខ្វះខាតរបស់ពួកបរិសុទ្ធ នោះក៏ចូរផ្គត់ផ្គង់ឲ្យ ទាំងខំប្រឹងឲ្យមានសេចក្តីចៅរ៉ៅផងចុះ។ ចូរអរសប្បាយ ជាមួយនឹងអ្នកណាដែលអរសប្បាយ ហើយយំជាមួយនឹងអ្នកណាដែលយំផង។ ចូរឲ្យមានគំនិតព្រមព្រៀងគ្នាទៅវិញទៅមក» (រ៉ូម ១២:១០-១៦)។ ក្រុមជំនុំគឺជាសហគមន៍មួយដែលមានទំនួលខុសត្រូវចំពោះសមាជិករបស់ខ្លួន។

ប៉ុន្តែ អ្វីដែលខ្ញុំចង់ឲ្យលោកអ្នកបានឃើញនៅទីនេះ គឺជាទំនួលខុសត្រូវចំពោះ «គ្នាទៅវិញទៅមក» ទោះបើភាគច្រើនទំនួលខុសត្រូវទាំងនោះនឹងត្រូវបានបំពេញឡើងបែបជាបុគ្គលនីមួយៗ ហើយវាបានកើតឡើងក្នុងបរិបទនៃទំនួលខុសត្រូវរួមរបស់ពួកជំនុំ និងសម្រាប់ពួកជំនុំនោះផ្ទាល់ក៏ដោយ។ ខ្ញុំបានរៀបរាប់រួចមកហើយនៅក្នុងជំពូកមុនអំពីតួនាទីជាអ្នកនាំមុខរបស់ពួកចាស់ទុំ ដោយពួកគាត់ត្រូវមានការទទួលខុសត្រូវ និងការទូន្មានប្រដៅ។ ប៉ុន្តែ ព្រះគម្ពីរសញ្ញាថ្មីបានបង្គាប់ដល់ពួកជំនុំទាំងមូលដែលបានប្រជុំគ្នាដោយការទទួលខុសត្រូវទាំងនោះដើម្បីការធានាថា សមាជិករបស់ខ្លួនបានរស់នៅស្របតាមការទទួលស្គាល់ជាសាធារណៈនៃសេចក្តីជំនឿ និងសេចក្តីសញ្ញារបស់ពួកគេជាមួយគ្នាទៅវិញទៅមក។ ព្រះយេស៊ូវបានធ្វើបែបដូច្នេះ នៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ជំពូក១៨ នៅពេលដែលព្រះអង្គបានមានបន្ទូលអំពីការដាក់វិន័យនៅក្នុងក្រុមជំនុំ។ សាវ័ក ប៉ុល ក៏

មិនបានដាស់តឿនក្រុមជំនុំទាំងមូលមិនមែន គ្រាន់តែគ្រូគង្វាលប៉ុណ្ណោះទេ ឲ្យបណ្តេញអ្នកណា ដែលមិនបានប្រែចិត្ត ឲ្យចេញពីសមាជិកភាព (១កូរិនថូស ៥)។ ហើយគាត់បានដាស់តឿនពួកជំនុំ ឲ្យផ្តល់ការស្តារឡើងវិញដល់អ្នកណាដែលបានបង្ហាញពីការប្រែចិត្តរបស់ខ្លួនដែរ (២កូរិនថូស ២:៦)។ ទំនួលខុសត្រូវរួមក្នុងពួកជំនុំ គឺជាផ្នែកមួយនៃការបង្កើតសិស្ស ហើយក៏ជាជំនួយដល់ការងារនៃការបង្កើតសិស្សមួយទល់នឹងមួយដែរ។

សូមឲ្យខ្ញុំបានផ្តល់ជាឧទាហរណ៍ទាក់ទងទៅនឹងចំណុចនេះ។ ឧបមាថា ខ្ញុំមានមិត្តភក្តិជាគ្រីស្ទបរិស័ទពីរនាក់ ដោយមិត្តភក្តិខ្ញុំម្នាក់ ជាសមាជិកក្នុងក្រុមជំនុំរបស់ខ្ញុំ និងមិត្តភក្តិម្នាក់ទៀតមិនមែនជាសមាជិកក្នុងក្រុមជំនុំរបស់ខ្ញុំទេ ហើយខ្ញុំកំពុងព្យាយាមបង្រៀនព្រះបន្ទូលរបស់ព្រះដល់ពួកគាត់ទាំងពីរនាក់។ ចំពោះមិត្តភក្តិដែលជាសមាជិកនៃក្រុមជំនុំរបស់ខ្ញុំ ខ្ញុំអាចសុំឲ្យគាត់កែប្រែចិត្តដោយពឹងលើសេចក្តីអធិប្បាយកាលពីថ្ងៃអាទិត្យមុន។ ខ្ញុំអាចសុំឲ្យគាត់កែប្រែចិត្ត ដោយប្រើប្រាស់គំរូដែលបានផ្តល់ដោយពួកចាស់ទុំរបស់យើង។ ខ្ញុំអាចសុំឲ្យអ្នកណាម្នាក់កែប្រែចិត្ត ប្រសិនបើខ្ញុំត្រូវធ្វើវា ដើម្បីជាការគម្រាមកំហែងមួយក្នុងការទូន្មានប្រដៅរបស់ខ្ញុំ សម្រាប់អំពើបាបដែលមិនមានការប្រែចិត្ត។ លើសពីនេះ ខ្ញុំដឹងថា ខ្ញុំមានការទទួលខុសត្រូវដោយផ្ទាល់ដែលជាផ្នែកនៃការទទួលខុសត្រូវរួមរបស់ខ្ញុំ សម្រាប់ការបន្តតាមមិត្តភក្តិម្នាក់នោះ តាមរបៀបទាំងអស់នេះ។ ហើយការពិតដែលថា ទំនាក់ទំនងនៃការបង្កើតសិស្សរបស់យើង មួយទល់នឹងមួយ បានកើតឡើងនៅក្នុងបរិបទនៃការទទួលខុសត្រូវនេះ ដែលជំរុញការយល់ដឹងនៃភាពជាម្ចាស់ និងការយកចិត្តទុកដាក់របស់ខ្ញុំ។ ខ្ញុំត្រូវមានទំនួលខុសត្រូវចំពោះគាត់ ដូចជាខ្ញុំត្រូវមានទំនួលខុសត្រូវចំពោះប្រពន្ធរបស់ខ្ញុំ ជាងស្ត្រីផ្សេងទៀត ឬក៏ដូចជាការទទួលខុសត្រូវចំពោះកូនៗរបស់ខ្ញុំ ជាងកូនៗអ្នកដទៃទៀតដែរ។

ប៉ុន្តែ ជាមួយមិត្តភក្តិដែលមិនមែនជាសមាជិកនៃក្រុមជំនុំរបស់ខ្ញុំ ទោះបើខ្ញុំមានទំនួលខុសត្រូវចំពោះគាត់ ដើម្បីព្រះគ្រីស្ទដោយខ្ញុំត្រូវស្រឡាញ់ ហើយលើកទឹកចិត្ត និងទូន្មានគាត់ អំពីផលវិបាកនៃអំពើបាបដែលមិនមានការប្រែចិត្តក៏ដោយ ក៏ខ្ញុំមិនបានទទួលទំនួលខុសត្រូវពីព្រះយេស៊ូវក្នុងការផ្តល់នូវរចនាសម្ព័ន្ធ

នៃការទទួលខុសត្រូវចុងក្រោយសម្រាប់ជីវិតរបស់គាត់នោះដែរ។ ជំនួសនោះវិញ គឺសមាជិកនៃក្រុមជំនុំរបស់គាត់ទេដែលមានទំនួលខុសត្រូវចុងក្រោយ។ ខ្ញុំសង្ឃឹមថា ចំណុចនេះនឹងមិនធ្វើឲ្យខ្ញុំកាន់តែមិនមើលថែគាត់ឡើយ។ ប៉ុន្តែ ដូចដែលខ្ញុំបានលើកឡើង វាកាត់បន្ថយការទទួលខុសត្រូវរបស់ខ្ញុំចំពោះគាត់។ ហើយជាថ្មីម្តងទៀត វាដូចជាខ្ញុំមិនសូវមានការទទួលខុសត្រូវចំពោះកូនៗរបស់លោកអ្នក ជាងកូនៗរបស់ខ្ញុំផ្ទាល់ដែរ។ តើលោកអ្នកឃើញអំពីរបៀបដែលក្រុមជំនុំមានទំនួលខុសត្រូវចំពោះសមាជិកក្រុមជំនុំផ្ទាល់ខ្លួន ជួយដល់ការងារនៃការបង្កើតសិស្សដែរឬទេ? តើលោកអ្នកឃើញទេថា គ្រោងឆ្អឹងនៃរូបកាយ និងសាច់ដុំនៃរូបកាយនៅជាប់គ្នាដែរឬទេ?

ក្នុងនាមជាពួកជំនុំ ការកំណត់កាតព្វកិច្ចរបស់យើងជាផ្លូវការចំពោះគ្នាទៅវិញទៅមកអាចជួយយើងឲ្យមានការប្តេជ្ញាចិត្តចំពោះសមាជិកម្នាក់ៗដែលចូលរួមក្នុងក្រុមជំនុំជាមួយយើង។ វាជួយដល់យើងឲ្យមានការយល់ដឹងនៃភាពជាអ្នកដឹកនាំ និងទំនួលខុសត្រូវរបស់យើង។ វាបានផ្តល់នូវទម្រង់ និងរូបរាងដល់ទំនាក់ទំនងនៃការបង្កើតសិស្សរបស់យើង។

## វប្បធម៌នៃការបង្កើតសិស្សនៅក្នុងក្រុមជំនុំ

នៅទីបំផុត ទំនួលខុសត្រូវរបស់យើងក្នុងនាមជាក្រុមជំនុំ និងទំនួលខុសត្រូវក្នុងនាមជាបុគ្គលរបស់យើង បានបញ្ចូលគ្នានៅក្នុងវប្បធម៌ ឬក៏ទម្លាប់មួយនៃការបង្កើតសិស្ស។ យើងបានអាន និងបានថ្លែងព្រះបន្ទូល ទៅកាន់គ្នាទៅវិញទៅមក។ យើងបានចំណាយពេលជាមួយគ្នា។ យើងបានអធិស្ឋានឲ្យពួកចាស់ទុំ និងឲ្យគ្នាទៅវិញទៅមក។ យើងមានសេចក្តីស្រឡាញ់ ចំពោះគ្នាទៅវិញទៅមក។ យើងបានផ្តល់ឲ្យគ្នាទៅវិញទៅមក។ យើងបានចូលរួមការប្រជុំគ្នាប្រចាំសប្តាហ៍ដោយការអធិស្ឋានជាមួយការរំពឹងដ៏រំភើបរបស់យើង។ យើងបានមកចូលរួមក្នុងការរៀបចំនៅក្នុងព្រះវិហារ។ យើងបានរៀបចំចិត្តទុកជាស្រេច ដើម្បីទទួលព្រះបន្ទូលរបស់ព្រះ។ យើងដើរតាមគំរូអ្នកដឹកនាំរបស់យើង ដែលពួកគាត់បានបង្ហាញមកកាន់យើង អំពីរបៀបនៃការដើរតាមព្រះគ្រីស្ទដោយខ្លួនយើងផ្ទាល់។ យើងបានចុះចូល

នឹងការដឹកនាំដ៏ឆ្លាតវៃរបស់ពួកចាស់ទុំ ហើយយើងមិនចុះចូលនឹងពួកគាត់ បើពួកគាត់ដឹកនាំយើងឲ្យដើរខុសទិសដៅពីការបង្រៀនរបស់ព្រះបន្ទូល។ យើងផ្តល់ការគោរពចំពោះការមើលការខុសត្រូវដែលពួកជំនុំបានផ្តល់ដល់យើង។ យើងត្រូវទូន្មាន ហើយលើកទឹកចិត្ត និងដាស់តឿនគ្នាទៅវិញទៅមក។ «មិនត្រូវឲ្យមានពាក្យអាក្រក់ណាមួយ ចេញពីមាត់អ្នករាល់គ្នាឡើយ ចូរបញ្ចេញតែពាក្យណាដែលល្អៗ សម្រាប់នឹងស្អាងចិត្តតាមត្រូវការ ដើម្បីឲ្យបានផ្តល់ព្រះគុណដល់អស់អ្នកដែលស្តាប់» (អេភេសូរ ៤:២៩)។

នៅក្នុងជីវិតនៃក្រុមជំនុំ ការរីកលូតលាស់ និងការមានសុខភាពល្អខាងឯវិញ្ញាណគួរតែជាបទដ្ឋានដ៏ជាក់លាក់។ វាគួរតែជារឿងធម្មតាក្នុងការមើលឃើញមនុស្ស ដែលមានការលូតលាស់ និងមានភាពចាស់ទុំខាងឯវិញ្ញាណ។ តាមការពិត ការរីកលូតលាស់ខាងឯវិញ្ញាណ គឺមិនមែនជាជម្រើសសម្រាប់គ្រីស្ទបរិស័ទនោះទេ ប៉ុន្តែវាគឺបានចង្អុលបង្ហាញថា គ្រីស្ទបរិស័ទនោះមានជីវិត។ អ្វីៗដែលពិតជាមានជីវិតពិតមែន គឺនឹងមានការលូតលាស់។ អ្វីៗដែលស្លាប់ គឺនឹងមិនមានការលូតលាស់នោះឡើយ។ ព្រះជាម្ចាស់បានប្រទានអំណោយទានដល់ក្រុមជំនុំដោយមានពួកចាស់ទុំ ដើម្បីឲ្យគ្រីស្ទបរិស័ទរីកលូតលាស់បាន ហើយទ្រង់ក៏បានប្រទានឲ្យយើងមានគ្នាទៅវិញទៅមក។ នៅក្នុងការទំនាក់ទំនងនៃការតាំងសេចក្តីសញ្ញាជាមួយសមាជិកក្រុមជំនុំ និងគ្រូគង្វាល ហើយកិច្ចការទាំងនេះគឺយើងបានរកឃើញដីដែលមានជីវជាតិល្អបំផុត ក្នុងការដុះលូតលាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ (នេះក៏ជាការពិតដែរនៅក្នុងគ្រួសារគ្រីស្ទបរិស័ទ)។ គោលលទ្ធិ និងជីវិតរបស់យើងអាចសម្រេចចេញជារូបរាងបាន គឺអាស្រ័យនៅក្នុងគោលលទ្ធិ និងជីវិតនៃសហគមន៍ដែលយើងរស់នៅក្នុង។ នេះហើយគឺជាវប្បធម៌ ឬក៏ទម្លាប់នៃការបង្កើតសិស្ស។

តើលោកអ្នកកំពុងតែតយុទ្ធក្នុងការផ្សាយដំណឹងល្អផ្ទាល់ខ្លួនដែរឬទេ? ដូច្នេះខ្ញុំសង្ឃឹមថា លោកអ្នកនឹងស្តាប់ឲ្យបានច្រើន ដើម្បីបានជាជំនួយពីការអធិស្ឋាន និងទីបន្ទាល់នានា ពីសមាជិកផ្សេងទៀតក្នុងក្រុមជំនុំរបស់ខ្លួន។

តើលោកអ្នកកំពុងតែរីករាយនឹងអាពាហ៍ពិពាហ៍របស់ខ្លួន ឬលោកអ្នកកំពុង

តែតយុទ្ធជាមួយវានៅពេលឥឡូវនេះ? ក្រុមជំនុំតាមតំបន់ គឺជាកន្លែងដែលលោកអ្នកត្រូវស្វែងរកការលើកទឹកចិត្ត និងការប្រឹក្សាយោបល់ទាក់ទងនឹងរឿងនេះ។ វាគឺជាកន្លែងដែលយើងទទួលយកសេចក្តីទូន្មានប្រដៅ ហើយយើងផ្តល់សេចក្តីទូន្មានប្រដៅទៅដល់អ្នកដទៃដែរ ប្រៀបដូចជាយើងកំពុងបង្រៀនគ្នាទៅវិញទៅមកអញ្ចឹងដែរ។

តើសមាជិកវ័យចំណាស់នៅក្នុងក្រុមជំនុំម្នាក់អាចស៊ូទ្រាំក្នុងការដើរតាមព្រះគ្រីស្ទ បន្ទាប់ពីការទទួលការវះកាត់ដ៏ពិបាករបស់គាត់ដោយរបៀបណា? ផ្នែកមួយដ៏សំខាន់ គឺតាមរយៈការលើកទឹកចិត្ត និងសេចក្តីស្រឡាញ់របស់ក្រុមជំនុំរបស់គាត់។

តើគ្រីស្ទបរិស័ទក្មេងខ្ចីអាចឆ្លងកាត់ការធ្លាក់ទឹកចិត្ត និងការសង្ស័យរបស់ខ្លួនបានដោយរបៀបណា នៅពេលដែលមានមិត្តម្នាក់របស់គាត់បានដើរចេញពីសេចក្តីជំនឿ? គឺតាមរយៈការគាំទ្រ និងការដាស់តឿនរបស់ក្រុមជំនុំរបស់គាត់។

តើយើងត្រូវស្វែងរកប្តីប្រពន្ធ និងការចិញ្ចឹមអប់រំគ្រួសារយ៉ាងដូចម្តេច ដើម្បីឲ្យក្លាយជាបុគ្គលិកល្អ និងអ្នកជិតខាងស្មោះត្រង់មួយរូប? គឺតាមរយៈការបង្រៀនរបស់ក្រុមជំនុំតាមតំបន់ និងការបង្កើតសិស្ស ដែលយើងបានរកឃើញនៅទីនោះ។

តើក្រុមជំនុំផ្សេងទៀតបានចាប់ផ្តើម និងបានលើកទឹកចិត្តគ្នាទៅវិញទៅមកដោយរបៀបណា? តើគ្រួសារគ្រីស្ទបរិស័ទត្រូវបានបង្កើតឡើង និងមានការចិញ្ចឹមបីបាច់ដោយរបៀបណា? តើព័ន្ធកិច្ច និងឱកាសសម្រាប់ការចែករំលែកការបម្រើយ៉ាងណាដែរ? តើអ្នកដែលមានភាពទន់ខ្សោយត្រូវបានពង្រឹង អ្នកវង្វេងបានស្វែងរកឃើញ និងអ្នកផ្សាយដំណឹងល្អត្រូវបានបំផុសគំនិតឡើងវិញដោយរបៀបណាបាន? កិច្ចការទាំងអស់នេះ គឺអាចធ្វើបានតាមតែរយៈក្រុមជំនុំតាមតំបន់របស់គាត់!

នៅក្នុងរបៀបនេះ និងរបៀបជាច្រើនទៀត នោះយើងអាចជួយគ្នាទៅវិញទៅមកបានក្នុងការដើរតាមព្រះយេស៊ូវ។ យើងបង្រៀនគ្នាទៅវិញទៅមក។ ក្រុមជំនុំមិនត្រូវការកម្មវិធីច្រើនពេកទេ ប៉ុន្តែជំនួសការនេះវិញពួកគាត់ត្រូវការវប្បធម៌នៃការបង្កើតសិស្ស ដែលជាវប្បធម៌ដែលសមាជិកនីមួយៗបានផ្តល់ការយកចិត្តទុកដាក់ ចំពោះសុខភាពខាងឯវិញ្ញាណរបស់អ្នកដទៃ។ សមាជិកម្នាក់ៗបាន

ទទួលអំណោយទានពីព្រះសម្រាប់ជាប្រយោជន៍រួម ហើយសមាជិកម្នាក់ៗត្រូវប្រើអំណោយទានផ្សេងៗគ្នាដែលគាត់មាន ដើម្បីស្អាងរូបកាយរបស់ព្រះគ្រីស្ទ៖ «រីឯអំណោយទាន នោះមានផ្សេងៗពីគ្នា តែគឺជាព្រះវិញ្ញាណដដែលទេ ហើយក៏មានមុខងារផ្សេងៗពីគ្នា តែគឺជាព្រះអម្ចាស់ដដែលទេ ព្រមទាំងមានរបៀបធ្វើផ្សេងៗពីគ្នាទៀត តែគឺជាព្រះដដែលនោះឯង ដែលទ្រង់ធ្វើគ្រប់ទាំងអស់ក្នុងមនុស្សទាំងអស់។ ហើយទ្រង់ប្រទានឲ្យព្រះវិញ្ញាណសម្ដែងមកក្នុងគ្រប់គ្នា ដើម្បីឲ្យបានកើតផល» (១កូរិនថូស ១២:៤-៧)។

ក្នុងក្រុមជំនុំរបស់ខ្ញុំ ខ្ញុំកំពុងអធិស្ឋាន និងធ្វើការផ្សេងៗ ដើម្បីឲ្យមានវប្បធម៌នៃការបង្កើតសិស្ស។ ខ្ញុំអធិស្ឋានសូមឲ្យតាមរយៈការងារបង្រៀនរបស់ខ្ញុំផ្ទាល់ ក៏ដូចជាតាមរយៈការងារផ្សេងៗទៀតរបស់សមាជិកគ្រប់រូប ដែលយើងទាំងអស់គ្នាត្រូវបានលើកទឹកចិត្តឲ្យចែករំលែកដំណឹងល្អជាមួយអ្នកជិតខាងរបស់យើង អាចយកអាសាគ្នាទៅវិញទៅមក ឲ្យមានអារម្មណ៍ជំរុញទឹកចិត្តក្នុងការផ្ដល់ហិរញ្ញវត្ថុដល់ព័ន្ធកិច្ចរបស់ព្រះ ផ្ដល់ការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ចំពោះព្រះបន្ទូលរបស់ព្រះ ហើយយកចិត្តទុកដាក់ និងអធិស្ឋានសូមឲ្យមានការរួបរួមនៃអស់អ្នកដែលមានលក្ខណៈដូចគ្នាតិចតួចនៅក្នុងព្រះគ្រីស្ទផងដែរ។

## ក្រុមជំនុំតាមតំបន់ គឺមានភាពល្អប្រសើរជាង

ព្រះវរបិតាបានរចនាក្រុមជំនុំតាមតំបន់ឡើង ព្រះយេស៊ូវបានផ្ដល់សិទ្ធិអំណាច ហើយព្រះវិញ្ញាណបានប្រទានអំណោយទានដល់ពួកគាត់។ ដូច្នេះ ក្រុមជំនុំមានគ្រប់ទាំងសមត្ថភាពកាន់តែប្រសើរ ដើម្បីបំពេញកិច្ចការបង្រៀនទៅដល់អ្នកជឿផ្សេងទៀត ជាជាងការបង្រៀនដែលមានតែលោកអ្នក និងមិត្តភក្ដិតែម្នាក់របស់លោកអ្នកផ្ទាល់។ ព្រះយេស៊ូវមិនបានមានបន្ទូលសន្យាថា លោកអ្នក និងមិត្តភក្ដិតែម្នាក់របស់លោកអ្នក នឹងវាយបំបែកទ្វារស្ថាននរកបាននោះទេ។ តែទ្រង់បានមានបន្ទូលសន្យាថា ទ្រង់នឹងប្រទានសិទ្ធិអំណាចឲ្យក្រុមជំនុំ ដើម្បីធ្វើកិច្ចការនេះវិញ។ បុគ្គលម្នាក់មិនអាចទទួលស្គាល់ថា ខ្លួនមានអំណោយទាន និងទទួលបានការត្រាស់ហៅឲ្យបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់បានទេ។ បុគ្គលម្នាក់ក៏មិនអាច

ធ្វើពិធីបុណ្យជ្រមុជទឹក និងចាត់ចែងពិធីលៀងព្រះអម្ចាស់បានដែរ។ ប៉ុន្តែ ក្រុមជំនុំតាមតំបន់ទទួលបានសិទ្ធិអំណាចក្នុងការធ្វើនោះ។

ឧបមាថា ថ្ងៃស្អែក មិត្តភក្តិដែលមិនមែនជាគ្រីស្ទបរិស័ទរបស់លោកអ្នក ដែលលោកអ្នកបានអធិស្ឋានអស់ជាច្រើនឆ្នាំ ដើម្បីឲ្យគាត់បានក្លាយជាគ្រីស្ទបរិស័ទ ហើយឥឡូវនេះគាត់បានបើកចិត្តទទួលជឿលើព្រះយេស៊ូវ ដោយកំពុងស្ថិតនៅក្នុងទីក្រុងមួយផ្សេងទៀត ព្រមទាំងបានចាប់ផ្តើមចូលរួមថ្វាយបង្គំក្នុងក្រុមជំនុំដំណឹងល្អមួយ នៅក្នុងទីក្រុងនោះផង។ តើលោកអ្នកចង់ឲ្យក្រុមជំនុំនោះ ទទួលមិត្តភក្តិជាទីស្រឡាញ់របស់លោកអ្នកដោយរបៀបណា? ប្រហែលជាលោកអ្នកចង់ឲ្យពួកជំនុំទាំងមូលមានទំនួលខុសត្រូវចំពោះគាត់។ លោកអ្នកនឹងចង់ឲ្យពួកចាស់ទុំបង្រៀនដល់គាត់។ ហើយលោកអ្នកនឹងចង់ឲ្យសមាជិកមួយចំនួន មានការឈោងចាប់គាត់ ដើម្បីទទួលយកគាត់មកដាក់នៅក្រោមការមើលខុសត្រូវរបស់ពួកគេ និងបង្រៀនគាត់ ក្នុងការជួយឲ្យគាត់ដើរតាមព្រះយេស៊ូវ។ លោកអ្នកនឹងចង់ឲ្យពួកគេបង្រៀន និងផ្តល់គំរូដល់គាត់អំពីអ្វីដែលជាអត្ថន័យក្នុងការសិក្សាព្រះគម្ពីរ ការដើរក្នុងសេចក្តីសុចរិត ការផ្សាយដំណឹងល្អ ការក្លាយជាប្តីប្រពន្ធ និងឪពុកម្តាយជាគ្រីស្ទបរិស័ទ ការក្រោកឈរឡើងបង្ហាញសេចក្តីជំនឿទៅកាន់លោកីយ៍ និងការបង្រៀនអ្នកដទៃឲ្យបន្តវេនក្នុងការធ្វើការងារនេះ។ ហើយពិតណាស់ តើលោកអ្នកនឹងមានភាពរីករាយយ៉ាងណា ប្រសិនបើក្រុមជំនុំនោះ មានទំនួលខុសត្រូវចំពោះមិត្តភក្តិរបស់លោកអ្នកបែបនេះ?

ហើយនេះគឺជាសំណួរៈ តើក្រុមជំនុំរបស់លោកអ្នកបានទទួល និងកំពុងបង្រៀនសមាជិកក្រុមជំនុំរបស់ខ្លួនក្នុងរបៀបបែបដូច្នេះដែរឬទេ? តើលោកអ្នកបានជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវដែរឬទេ? តើលោកអ្នកជាចម្លើយចំពោះការអធិស្ឋានរបស់គ្រីស្ទបរិស័ទនៅទីក្រុងផ្សេងៗទៀតដែរឬទេ?

ប្រសិនបើលោកអ្នកមិនបានធ្វើរបៀបបែបដូច្នោះទេ សូមកុំមានការតក់ស្លុតនោះឡើយ។ ខ្ញុំនឹងមិនសុំឲ្យលោកអ្នកចាប់ផ្តើមបង្រៀនមនុស្សរាប់សិបនាក់នោះទេ។ ផ្ទុយទៅវិញ ខ្ញុំចង់ឲ្យលោកអ្នកគិតពីមនុស្សណាម្នាក់ក្នុងក្រុមជំនុំរបស់លោកអ្នក—គឺគិតពីមនុស្សម្នាក់ប៉ុណ្ណោះ។ សូមគិតអំពីមនុស្សម្នាក់ ដែលលោកអ្នកពិត

ជាចង់ឃើញគាត់ដើរតាមព្រះយេស៊ូវឲ្យបានកាន់តែខ្ជាប់ខ្ជួន។ ហើយបន្ទាប់មក សូមអធិស្ឋានឲ្យមនុស្សម្នាក់នោះ...

តើលោកអ្នកបានអធិស្ឋានដែរឬទេ? ជំហានបន្ទាប់៖ តើលោកអ្នកគិតថា លោកអ្នកអាចបង្រៀនមនុស្សម្នាក់នោះដោយរបៀបណាបាន?

មិនអីទេ! ប្រហែលជាពាក្យបង្កើតសិស្សនេះ វានៅតែធ្វើឲ្យលោកអ្នកមាន ការភិតភ័យ។ ខ្ញុំសូមនិយាយឡើងវិញ៖ តើលោកអ្នកគិតថា លោកអ្នកអាចនឹង ជួយអ្នកនោះឲ្យដើរតាមព្រះយេស៊ូវដោយរបៀបណា? ឬ តើលោកអ្នកអាចបង្ហាញ ចេតនាល្អខាងឯវិញ្ញាណក្នុងជីវិតរបស់គាត់ដោយរបៀបណាទៅ? តើអ្វីជាជំហាន ទីមួយ ឬជំហានទីពីរដែលលោកអ្នកអាចនឹងធ្វើវាបាន?

នៅក្នុងវគ្គបន្ទាប់ យើងនឹងបង្វែរទៅកាន់សំណួរអំពីរបៀបដែលយើងជួយអ្នក ណាម្នាក់ក្នុងការចេះដើរតាមព្រះយេស៊ូវ។

ផ្នែកទី៣៖

# តើយើងគួរបង្កើតសិស្ស ដោយរបៀបណា?

## ជំពូកទី៧

# ការជ្រើសរើសនរណាម្នាក់

ឧបមាថា មានសមាជិកក្រុមជំនុំពីរនាក់ គឺលោក សុខា និងលោក វិបុល។ លោក សុខា គឺជាសិស្សក្នុងថ្នាក់រៀនព្រះគម្ពីរម្នាក់។ គាត់ចូលចិត្តស្វែងយល់អំពីអ្វីដែលព្រះគម្ពីរបានចែងអំពីអ្វីៗគ្រប់យ៉ាងទាំងអស់។ គាត់ថែមទាំងអាចពន្យល់អំពីគោលលទ្ធិនៃព្រះត្រៃឯកបានផងដែរ ប្រសិនបើលោកអ្នកសួរគាត់ទាក់ទងនឹងគោលលទ្ធិនេះ។ សកម្មភាពមួយចំនួនរបស់គាត់ទំនងមិនបានបង្ហាញថា គាត់ជាគ្រីស្ទបរិស័ទនោះទេ។ ជីវិតជាក់ស្តែងរបស់គាត់ហាក់ដូចជាបង្ហាញថា គាត់មិនមែនគ្រីស្ទបរិស័ទទាល់តែសោះ។ ប៉ុន្តែ គាត់មានការយល់ដឹងអំពីព្រះគម្ពីរ!

ឥឡូវនេះ សូមគិតពិចារណាពីលោក វិបុល។ លោក វិបុល មិនសូវបានអានព្រះគម្ពីរច្រើននោះទេ។ ប្រាកដណាស់ គាត់ចង់ក្លាយជា «មនុស្សល្អ»។ គាត់បានព្យាយាមស្រឡាញ់អ្នកដទៃ។ ប៉ុន្តែ លោក វិបុល នឹងមានការលំបាកក្នុងការពន្យល់អំពីគោលលទ្ធិដែលត្រឹមត្រូវថា តើព្រះយេស៊ូវជានរណា? ឬតើក្រុមជំនុំជាអ្វី? ហើយគាត់មិនអាចធ្វើបានល្អក្នុងការកំណត់ពីបញ្ហានៃសីលធម៌ដោយប្រុងប្រយ័ត្ននោះទេ។ ប៉ុន្តែ  គាត់ចង់រស់នៅក្នុងជីវិតដែលគ្មានភាពអាត្មានិយមដោយគិតតែពីខ្លួនឯង ដែលគាត់បានមើលឃើញអ្នកដទៃកំពុងរស់នៅក្នុង។ គាត់មានទំនោរក្នុងការគិតថា ខ្លួនជាមនុស្សដែលពូកែមានទំនាក់ទំនង ជាជាងជាមនុស្សចេះព្រះគម្ពីរ ឬជាមនុស្សដែលចេះគោលលទ្ធិច្រើន។

តើការពណ៌នាអ្នកទាំងពីរនាក់នេះ ស្តាប់ទៅមានលក្ខណៈដូចលោកអ្នកដែរឬទេ?

លោក សុខា គួរតែយកចិត្តទុកដាក់ចំពោះមនុស្សជុំវិញខ្លួនឲ្យបានច្រើនជាងមុន ហើយចំណែកលោក វិបុល វិញ គួរតែយកចិត្តទុកដាក់ចំពោះសេចក្តីពិតបន្ថែម

ទៀត។ តាមពិតទៅ អ្នកទាំងពីរគួរតែមានការយកចិត្តទុកដាក់ចំពោះព្រះយេស៊ូវ ពីព្រោះព្រះយេស៊ូវស្រឡាញ់ទាំងសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះ និងជីវិតនៃរាស្រ្ត របស់ទ្រង់។ ហើយការងារនៃការបង្កើតសិស្សគួរតែជាការងារ ដែលជួយមនុស្ស ទាំងពីរប្រភេទនេះ ឲ្យដើរតាមព្រះយេស៊ូវកាន់តែប្រសើរឡើង។ ព្រះយេស៊ូវបាន មានបន្ទូលថា អ្នកណាដែលចង់ «មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ចោល ទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ» (ម៉ាកុស ៨:៣៤)។ លោក សុខា ត្រូវ តែលះកាត់ចិត្តខ្លួនឯងចោល ហើយដើរតាមព្រះយេស៊ូវដោយការស្រឡាញ់មនុស្ស ជុំវិញខ្លួនឲ្យបានកាន់តែច្រើនថែមទៀត។ លោក វិបុល ត្រូវតែលះកាត់ចិត្តខ្លួនឯង ចោល ដោយការស្រឡាញ់ព្រះបន្ទូលរបស់ព្រះឲ្យបានកាន់តែខ្លាំងឡើងបន្ថែម ទៀត។ សិស្សរបស់ព្រះយេស៊ូវគឺមិនមែនជាអ្នកដែលគ្រាន់តែអះអាងថា ជាអ្នក ដើរតាមព្រះគ្រីស្ទនោះទេ។ ប៉ុន្តែ គាត់ពិតជាអ្នកដើរតាមព្រះយេស៊ូវមែន។

គ្រប់ការសន្ទនាអំពីការបង្កើតសិស្សជាមួយអ្នកដទៃត្រូវតែចាប់ផ្តើមឡើង ដោយសួរនូវសំណួរនេះ៖ តើការដើរតាមព្រះយេស៊ូវមានន័យយ៉ាងដូចម្តេច? ការ បង្កើតសិស្សមានន័យថា ជាការជួយអ្នកដទៃឲ្យចេះដើរតាមព្រះយេស៊ូវ។ ការបង្កើត សិស្សគឺជាទំនាក់ទំនងមួយដែលយើងព្យាយាមធ្វើអំពើល្អខាងវិញ្ញាណសម្រាប់ នរណាម្នាក់ តាមរយៈការផ្តួចផ្តើមគំនិតក្នុងការបង្រៀន ការកែតម្រូវ ការធ្វើជាគំរូ ការស្រឡាញ់ ការបន្ទាបខ្លួន ការប្រឹក្សាយោបល់ និងការបង្ហាញពីឥទ្ធិពលល្អៗ ដល់អ្នកនោះ។

តើយើងធ្វើការបង្កើតសិស្សដោយរបៀបណា? តើយើងអាចជួយលោក សុខា ដោយរបៀបណា ដើម្បីឲ្យគាត់យកចិត្តទុកដាក់លើការរស់នៅតាមសេចក្តីជំនឿ របស់គាត់ និងដើម្បីជួយលោក វិបុល ឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀតអំពី ការយល់ដឹងទាក់ទងនឹងសេចក្តីជំនឿរបស់គាត់? នេះគឺជាសំណួរ ដែលយើងនឹង ពិចារណានៅក្នុងជំពូកនេះ និងជំពូកក្រោយៗទៀត។

វាមិនមែនគ្រាន់តែជាសំណួរមួយសម្រាប់តែគ្រូគង្វាលនោះទេ។ ព្រះគម្ពីរ បានបង្គាប់ឲ្យយើងទាំងអស់គ្នាធ្វើការទាំងនេះ។ សាវ័ក យ៉ូហាន បានប្រាប់យើង ឲ្យស្រឡាញ់គ្នាទៅវិញទៅមក (២យ៉ូហាន ៥)។ សាវ័ក ប៉ុល បានប្រាប់យើងឲ្យ

លើកទឹកចិត្តគ្នា ហើយស្អាងចិត្តគ្នាទៅវិញទៅមក (១ថែស្សាឡូនីច ៥:១១)។ គាត់ក៏ប្រាប់យើងឲ្យបង្រៀនគ្នាទៅវិញទៅមក ដោយសារយើងចង់ឃើញគ្រប់មនុស្សធ្វើជាដង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ (កូឡុស ១:២៨)។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានប្រាប់យើងឲ្យពិចារណាមើលគ្នាទៅវិញទៅមក ដើម្បីនឹងបណ្ដាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អ (ហេព្រើរ ១០:២៤)។

រឿងដំបូងដែលលោកអ្នកត្រូវធ្វើការសម្រេចចិត្តគឺ តើលោកអ្នកគួរចំណាយពេលជាមួយអ្នកណា? លោកអ្នកមិនមានពេលច្រើនទេក្នុងមួយសប្តាហ៍។ លោកអ្នកមិនអាចបង្រៀនគ្រប់គ្នាក្នុងក្រុមជំនុំទាំងមូលបានឡើង។ តើលោកអ្នកសម្រេចចិត្តក្នុងការវិនិយោគពេលវេលាលើនរណាម្នាក់ដោយរបៀបណា? លោកអ្នកត្រូវតែជ្រើសរើស។

ដោយមានព្រះគម្ពីរក្នុងដៃរបស់យើង តើយើងគួរសម្រេចចិត្តវិនិយោគលើនរណាម្នាក់ដោយរបៀបណា? ទាំងនេះគឺជាកត្តាទាំង៩ដែលយើងត្រូវពិចារណា ហើយប្រហែលជាការសម្រេចចិត្តរបស់យើង ស្ថិតនៅក្នុងលំដាប់លំដោយនៃកត្តាទាំងនេះដែរ។

## ១. តើបុគ្គលនេះជាសមាជិកគ្រួសារដែរឬទេ?

សាវ័ក ប៉ុល បានបង្រៀនថា «បើមានអ្នកណា ដែលមិនផ្គត់ផ្គង់ឲ្យពួកញាតិសន្តានខ្លួន គឺឲ្យពួកអ្នកផ្ទះខ្លួនជាដើម អ្នកនោះឈ្មោះថា បានបោះបង់ចោលសេចក្តីជំនឿហើយ ក៏អាក្រក់ជាងមនុស្សដែលមិនបានជឿទៅទៀត» (១ធីម៉ូថេ ៥:៨)។ ព្រះគម្ពីរបានបង្រៀនតាមរយៈបទគម្ពីរនេះ និងបទគម្ពីរផ្សេងទៀតថា យើងម្នាក់ៗមានទំនួលខុសត្រូវ ជាពិសេសចំពោះសមាជិកគ្រួសាររបស់យើងផ្ទាល់។ ព្រះបានប្រទាននូវទំនាក់ទំនងពេញមួយជីវិត និងជាមូលដ្ឋានធម្មជាតិសម្រាប់សេចក្តីស្រឡាញ់ និងការព្រួយបារម្ភក្នុងគ្រួសាររបស់យើង។ ហើយយើងគួរតែបានប្រើប្រាស់ការស្រឡាញ់ និងទំនួលខុសត្រូវពីធម្មជាតិទាំងនោះ សម្រាប់ជាការថ្វាយសិរីល្អដល់ព្រះគ្រីស្ទ។ នេះជារឿងដ៏សំខាន់ ប្រសិនបើលោកអ្នករស់នៅជាមួយសមាជិកគ្រួសារ។ វាក៏ជារឿងដ៏សំខាន់ថែមទៀត ប្រសិនបើបទគម្ពីរបានបង្គាប់

លោកអ្នកឲ្យមានការទទួលខុសត្រូវជាពិសេសចំពោះពួកគេ ដូចដែលបានកើតឡើងចំពោះឪពុកម្តាយ និងកូនៗ ឬប្តីប្រពន្ធ ដែលត្រូវធ្វើសម្រាប់គ្នាទៅវិញទៅមក។ ទំនាក់ទំនងទាំងនេះគឺជាការបង្រៀនដ៏សំខាន់បំផុតនៃទំនួលខុសត្រូវដែលលោកអ្នកមាន។

## ២. តើបុគ្គលនេះជាអ្នកជឿ ឬក៏អ្នកមិនជឿ?

លោកអ្នកគួរផ្សាយដំណឹងល្អដល់មិត្តដែលមិនមែនជាគ្រីស្ទបរិស័ទរបស់ខ្លួន ប៉ុន្តែវាពុំមានប្រយោជន៍ទេក្នុងការបង្រៀនពួកគេ ប្រសិនបើពួកគេមិនមែនជាគ្រីស្ទបរិស័ទនៅឡើយ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា៖ «ប៉ុន្តែ មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ» (១កូរិនថូស ២:១៤)។ លោកអ្នកគួរតែបង្រៀនសិស្ស ដែលគាត់ជាគ្រីស្ទបរិស័ទម្នាក់។

## ៣. តើបុគ្គលនេះជាសមាជិកក្នុងក្រុមជំនុំជាមួយលោកអ្នកដែរឬទេ?

ក្នុងជំពូកទី៦ យើងបានពិចារណាពីសេចក្តីបង្គាប់ទាំងនេះ នៅក្នុងកណ្ឌគម្ពីរហេព្រើរ៖

> «ចូរនឹកចាំពីពួកអ្នកនាំមុខ ដែលបានផ្សាយព្រះបន្ទូលមកអ្នករាល់គ្នា ត្រូវតែត្រាប់តាមសេចក្តីជំនឿរបស់អ្នកទាំងនោះ ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង។ ចូរស្តាប់តាម ហើយចុះចូលនឹងពួកអ្នក ដែលនាំមុខអ្នករាល់គ្នាចុះ ដើម្បីឲ្យអ្នកទាំងនោះបានចាំរក្សាព្រលឹងអ្នករាល់គ្នាដោយអំណរ មិនមែនដោយស្រែកថ្ងូរទេ ដ្បិតបើត្រូវស្រែកថ្ងូរ នោះបង់ប្រយោជន៍ដល់អ្នករាល់គ្នាហើយ ពីព្រោះអ្នកទាំងនោះចាំរក្សា ហាក់ដូចជានឹងត្រូវរាប់រៀបទូលដល់ទ្រង់វិញ» (ហេព្រើរ ១៣:៧, ១៧)។

ប្រាកដណាស់! ខគម្ពីរទាំងនេះបានប្រាប់យើងជាពិសេស ឲ្យស្តាប់តាមអ្នកនាំមុខក្នុងក្រុមជំនុំរបស់យើងផ្ទាល់។ ប៉ុន្តែ ខគម្ពីរទាំងនេះក៏បង្រៀនយើងថា របៀបធម្មតានៃភាពជាសិស្សដំណើរការបានល្អបំផុតក្នុងទំនាក់ទំនងដែលត្រូវមានការទាក់ទងគ្នាក្នុងក្រុមជំនុំនោះផ្ទាល់ ដូចដែលយើងបានពិភាក្សា និងវែកញែកក្នុងជំពូកមុនៗរួចមកហើយ។

យើងមានទំនួលខុសត្រូវ ច្រើនជាងអ្នកដទៃផ្សេងទៀតចំពោះពួកជំនុំរបស់យើង ដើម្បីជួយ និងទទួលការជួយពីពួកគាត់វិញដែរ។ សមាជិកនៃក្រុមជំនុំតែមួយត្រូវដើរតាម និងចុះចូលចំពោះពួកអ្នកចាស់ទុំដូចគ្នាដែលជារូបកាយដូចគ្នាដែរ។ ពួកគាត់បានអះអាងសេចក្តីប្រកាសអំពីសេចក្តីជំនឿ និងសេចក្តីសញ្ញារបស់ក្រុមជំនុំដូចគ្នា។ ពួកគាត់បានទទួលបទពិសោធន៍ពីការបង្រៀនអំពីគោលលទ្ធិដូចគ្នា។ យ៉ាងហោចណាស់ ពួកគាត់បានជួបមុខគ្នាមួយសប្តាហ៍ម្តង។ សម្រាប់ហេតុផលទាំងអស់នេះ ជាធម្មតា ការកសាងទំនាក់ទំនងនៃការបង្កើតសិស្សនៅក្នុងបរិបទនៃក្រុមជំនុំនោះផ្ទាល់ មានប្រយោជន៍ជាង។

បន្ថែមលើនេះទៀត ប្រសិនបើមិត្តភក្តិណាម្នាក់របស់លោកអ្នកបានចូលរួមក្នុងក្រុមជំនុំដែលមិនមានសុខភាពល្អ ហើយតាមរយៈការបង្រៀនពួកគាត់ នោះលោកអ្នកអាចនឹងធ្វើឲ្យខូចខាតជីវិតខាងឯវិញ្ញាណរបស់ពួកគាត់ផងដែរ។ តើវាអាចកើតឡើងបានដោយរបៀបណា? គឺដោយការគាំទ្រខាងឯវិញ្ញាណ នោះវាបានអនុញ្ញាតឲ្យគាត់នៅបន្តក្នុងក្រុមជំនុំមួយដែលមិនមានការបង្រៀនពីព្រះគម្ពីរ។ នេះមិនមែនជាការបង្កើតច្បាប់មួយដែលដាច់ខាតនោះទេ ប៉ុន្តែវាអាចនឹងមានភាពប្រសើរឡើង ដោយគ្រាន់តែលើកទឹកចិត្តមិត្តភក្តិរបស់លោកអ្នកឲ្យចូលរួមជាមួយក្រុមជំនុំដែលមានសុខភាពល្អវិញ។ គ្រីស្ទបរិស័ទត្រូវការរូបកាយទាំងមូល មិនមែនលោកអ្នកម្នាក់ តែម្នាក់ឯងនោះទេ។

## ៤. តើបុគ្គលនេះជាប្រុស ឬស្រី?

ព្រះគម្ពីរមានការប្រុងប្រយ័ត្ន អំពីបញ្ហាយេនឌ័រ ក្នុងការបង្កើតសិស្សនេះ។ ឧទាហរណ៍៖ សាវ័ក ប៉ុល បានប្រាប់លោក ទីតុស ថា «ឲ្យពួកស្ត្រីចាស់ៗ បាន

បែបដូចគ្នា ទាំងប្រព្រឹត្តបែបគួរនឹងពួកស្ត្រីបរិសុទ្ធ មិនត្រូវនិយាយដើមគេ ឬជាប់ស្រាទំពាំងបាយជូរឡើយ ត្រូវខំបង្រៀនសេចក្ដីត្រឹមត្រូវវិញ ដើម្បីនឹងបង្ហាត់ដល់ពួកស្ត្រីក្មេងៗ ឲ្យគេស្រឡាញ់ប្ដី និងកូនខ្លួន ឲ្យមានចិត្តធូន់ធ្ងរ ហើយបរិសុទ្ធ ជាអ្នករវល់តែនឹងការនៅផ្ទះខ្លួន ហើយមានចិត្តល្អ និងចុះចូលចំពោះប្ដី ដើម្បីកុំឲ្យមានអ្នកណាប្រមាថដល់ព្រះបន្ទូលបានឡើយ» (ទីតុស ២:៣-៥)។

ពេលខ្លះ ការបង្កើតសិស្សកើតឡើងក្នុងចំណោមទាំងប្រុស និងស្រី។ ឧទាហរណ៍៖ ដោយសារខ្ញុំជាគ្រូគង្វាល នៅកន្លែងសាធារណៈ ខ្ញុំបានបង្រៀនដល់ទាំងមនុស្សប្រុស និងមនុស្សស្រី។ ហើយនៅក្នុងគ្រួសារ យើងទាំងអស់គ្នាមានម្ដាយ និងឪពុក ហើយពួកយើងជាច្រើនមានបងប្អូនប្រុសស្រី ឬប្ដីប្រពន្ធ។ ពេលគឺការបង្កើតសិស្សជាមួយមនុស្សភេទផ្ទុយគ្នា ក៏មាននៅក្នុងទំនាក់ទំនងគ្រួសាររបស់យើងដែរ។ ហើយនៅក្នុងក្រុមជំនុំ ជាទូទៅទាំងមនុស្សប្រុស និងមនុស្សស្រី គឺយើងបានធ្វើសេចក្ដីតាំងសញ្ញារួមគ្នាជាមួយ និងមានមិត្តភក្ដិយ៉ាងច្រើនទៀតជាគ្រួសារក្នុងព្រះគ្រីស្ទផងដែរ។

ប៉ុន្តែ ជាទូទៅ នៅពេលនិយាយដល់ចេតនានៃទំនាក់ទំនងក្នុងការបង្កើតសិស្ស វាជាភាពឆ្លាតវៃសម្រាប់បុរសៗ ដើម្បីបង្រៀនដល់បុរសៗ និងស្ត្រីៗបង្រៀនដល់ស្ត្រីៗ។ យើងទទួលស្គាល់ថា យេនឌ័រគឺជាសេចក្ដីពិតមួយដែលព្រះបានប្រទានមកដល់យើង ហើយយើងមានបំណងចង់ប្រព្រឹត្តតាមសេចក្ដីពិតនោះដោយការគោរពរបស់យើងចំពោះព្រះ។ យើងគួរស្រឡាញ់មនុស្សគ្រប់គ្នាក្នុងក្រុមជំនុំ ហើយស្រេបពេលជាមួយគ្នាដែរ ត្រូវខិតខំជៀសវាងភាពស្និទ្ធស្នាលណាមួយដែលអាចនាំឲ្យមានកំហុសឆ្គង។

## ៥. តើបុគ្គលនេះចាស់ ឬក្មេងជាងខ្ញុំ?

ដូចដែលព្រះគម្ពីរមានការប្រុងប្រយ័ត្នអំពីយេនឌ័រ ដូច្នេះព្រះគម្ពីរក៏មានការប្រុងប្រយ័ត្នអំពីអាយុផងដែរ។ កណ្ឌគម្ពីរទីតុស បានលើកឡើងអំពីស្ត្រីៗចាស់ៗបង្រៀនដល់ស្ត្រីវ័យក្មេង។ នៅក្នុងខគម្ពីរផ្សេងទៀត៖ សាវ័ក ប៉ុល បានប្រាប់លោកធីម៉ូថេ ថា «កុំឲ្យអ្នកណាមើលងាយពីភាពនៅក្មេងរបស់គាត់ ដោយព្រោះគាត់នៅ

ក្មេងនោះឡើយ» ប៉ុន្តែនៅក្នុងសំបុត្រដដែលនេះ គាត់បានលើកទឹកចិត្ត ធីម៉ូថេ «ឲ្យគោរពដល់មនុស្សចាស់ៗវិញផងដែរ» (១ធីម៉ូថេ ៤:១២; ៥:១)។

ជាធម្មតា លោកអ្នកធ្វើការបង្រៀនដល់អ្នកដែលមានវ័យក្មេងជាងលោកអ្នក។ ដូច្នេះ យើងឃើញថាព្រះគម្ពីរមានពោរពេញទៅដោយគំរូយ៉ាងល្អប្រសើរនៃការបង្រៀនរបស់មនុស្សមានវ័យក្មេងៗដល់មនុស្សមានវ័យចំណាស់ៗ។ ហើយប្រាកដណាស់ នៅពេលដែលយើងកាន់តែចាស់ទៅ នោះយើងក៏ចង់កាន់តែចេះបន្ទាបខ្លួនក្នុងការរៀនពីអ្នកដែលមានអាយុស្របាលយើង និងអ្នកដែលអាយុតិចជាងយើងផងដែរ។ បើមិនដូច្នេះទេ នោះយើងនឹងកាន់តែមានមនុស្សតិចទៅៗដែលអាចបង្រៀនយើងបាន នៅពេលដែលយើងកាន់តែចាស់ទៅៗ! ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថា ខ្ញុំរៀនបានច្រើនពីមិត្តភក្តិរបស់ខ្ញុំដែលស្ថិតក្នុងវ័យម្ភៃឆ្នាំ និងសាមសិបឆ្នាំ ដូចជាខ្ញុំបានរៀនពីមនុស្សដែលមានអាយុចិតសិបឆ្នាំ និងប៉ែតសិបឆ្នាំផងដែរ។

## ៦. តើបុគ្គលនេះមានលក្ខណៈស្រដៀង ឬក៏ខុសគ្នាពីខ្ញុំ?

លោកីយ៍នេះបែងចែកមនុស្សជាក្រុមខុសៗគ្នារវាង៖ អ្នកមាន និងអ្នកក្រ ស្បែកស និងខ្មៅ ឋានៈខ្ពស់ និងតូចទាប។ ប៉ុន្តែ នៅពេលដែលគ្រីស្ទបរិស័ទមើលរំលងចំណុចខុសៗគ្នាទាំងនេះ ហើយមានការរួបរួមគ្នា នោះគេនឹងអាចមើលឃើញអំណាចនៃដំណឹងល្អបាន។ សូមធ្វើការសង្កេតនៅក្នុងកណ្ឌគម្ពីរអេភេសូរ «ដ្បិតដោយសារ [ព្រះគ្រីស្ទ] នោះយើងទាំង២ [សាសន៍យូដា និងសាសន៍ដទៃ] មានផ្លូវចូលទៅដល់ព្រះវរបិតា ដោយព្រះវិញ្ញាណតែ១» (អេភេសូរ ២:១៨)។ ជញ្ជាំងនៃការបែងចែករវាងសាសន៍យូដា និងសាសន៍ដទៃបានត្រូវបំបែកនៅឯឈើឆ្កាង។ ហើយឥឡូវនេះ ព្រះបានបង្ហាញប្រាជ្ញាតាមរយៈការរួបរួម នៃមនុស្សដែលបានបែងចែកការទាំងនេះ (អេភេសូរ ៣:១០)។ ហើយជាការពិតណាស់ ការរួបរួមដែលក្រុមជំនុំមាននៅពេលនេះ មាននៅទូទាំងពូជសាសន៍ សេដ្ឋកិច្ច ការអប់រំ និងការបែងចែកផ្សេងៗទៀត បានចង្អុលបង្ហាញទៅថ្ងៃដែលមាន «មនុស្ស១ហ្វូងយ៉ាងធំដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជ

មនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា» ក៏ឈរនៅមុខបល្ល័ង្ករបស់ព្រះ ដើម្បីការថ្វាយបង្គំ (វិវរណៈ ៧:៩-១០)។

តើនៅក្នុងការអនុវត្តនេះមានន័យយ៉ាងដូចម្តេច? នៅពេលលោកអ្នកស្វែងរកនរណាម្នាក់ ដើម្បីបង្រៀនដល់គាត់ វាជារឿងធម្មតាទេដែលលោកអ្នកបង្រៀនដល់បុគ្គលដែលមានលក្ខណៈដូចលោកអ្នកដែរ៖ អ្នកម្តាយៗវ័យកណ្តាលគួរតែស្វែងរកមិត្តភក្តិដែលជាអ្នកម្តាយវ័យកណ្តាលដូចគ្នា ហើយគូស្វាមីភរិយាថ្មោងថ្មីគួរចំណាយពេលជាមួយគ្នា និងបុរសៗនៅលីវដែលមានអាយុ២០ឆ្នាំជាង គួរតែចំណាយពេលជាមួយមិត្តភក្តិរបស់ពួកគាត់ក្នុងវ័យដូចគ្នាដែរ។ ពិតណាស់ ក្រុមមនុស្សទាំងនោះមានការគិតដូចគ្នាច្រើន ដែលព្រះអាចប្រើប្រាស់សម្រាប់ការរីកចម្រើននៅក្នុងសេចក្តីជំនឿរបស់ពួកគេបាន។ ប៉ុន្តែ សូមគិតពិចារណាផងដែរនូវអ្វីដែលមនុស្សដែលមានវ័យចំណាស់អាចរៀនបាន តាមរយៈការចំណាយពេលជាមួយនិស្សិតនៅមហាវិទ្យាល័យ ឬធ្វើការជាមួយកុមារ និងយុវជន។ ឬក៏សូមគិតពិចារណាអំពីការចំណាយពេលជាមួយនឹងអ្នកដទៃដែលមកពីប្រទេសផ្សេង ឬក៏មានសញ្ជាតិផ្សេងគ្នា។ ឬក៏ថា ប្រសិនបើលោកអ្នកជាអ្នកមកពីទីក្រុង សូមពិចារណាអំពីការចំណាយពេលជាមួយនឹងកសិករនៅជនបទផង។

ព្រះក៏អាចបង្រៀនយើងបានយ៉ាងច្រើនអំពីទ្រង់ផ្ទាល់ តាមរយៈមនុស្សដែលមានភាពខុសគ្នាពីយើង។ ហើយដំណឹងល្អក៏បានបង្ហាញនៅក្នុងការរួបរួមរបស់យើងដែរ—វាមិនគ្រាន់តែជាការរួបរួម នៃការចូលចិត្តគ្នាទៅវិញទៅមកប៉ុណ្ណោះទេ ប៉ុន្តែជាការរួបរួមនៃការរៀនពីគ្នាទៅវិញទៅមកផងដែរ។

## ៧. តើបុគ្គលនេះទទួលការបង្រៀន និងការកែតម្រង់ដែរឬទេ?

កណ្ឌគម្ពីរសុភាសិតតែងតែ លើកសរសើរកូនដែលទទួលយកការបង្រៀន ហើយស្តីបន្ទោសមនុស្សល្ងីល្ងើ ដែលមើលងាយការស្តីបន្ទោស ការបង្ហាត់បង្រៀន និងសេចក្តីទូន្មាន។ លើសពីនេះទៅទៀត បទគម្ពីរក៏បានប្រាប់យើងថា ព្រះអម្ចាស់ "នឹងនាំមនុស្សសុភាពក្នុងសេចក្តីយុត្តិធម៌ ហើយនឹងបង្រៀនមនុស្សរាបទាបឲ្យ

ស្គាល់ផ្លូវទ្រង់» (ទំនុកតម្កើង ២៥:៩; សុភាសិត ១១:២)។ ហេតុដូច្នេះហើយ បានជាសាវ័ក ពេត្រុស បានបង្គាប់ថា៖ «ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ។ ហើយត្រូវឲ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ» (១ពេត្រុស ៥:៥)។

លោកអ្នកមិនគួរចំណាយពេល ក្នុងការព្យាយាមបង្រៀននរណាម្នាក់ ដែលគិតថា លោកអ្នកគ្មានអ្វីសោះ ដើម្បីបង្រៀនពួកគេ ហើយថា ពួកគេក៏គ្មានអ្វីដែលត្រូវរៀនពីលោកអ្នកនោះដែរ។ សូមបង្រៀនដល់អស់អ្នកដែលចង់រៀន ហើយសូមព្យាយាមធ្វើជាអ្នកដែលគេអាចបង្រៀនបានផងដែរ។

## ៨. តើបុគ្គលនេះនឹងមានភាពស្មោះត្រង់ក្នុងការបង្រៀនឲ្យអ្នកដទៃដើរតាមព្រះយេស៊ូវដែរឬទេ?

ខ្ញុំក៏បានលើកយកនូវពាក្យទូន្មានរបស់សាវ័ក ប៉ុល ដែលផ្ញើទៅកាន់ ធីម៉ូថេ ពីរបីដងរួចមកហើយ បើគិតមកដល់ពេលនេះ៖ «ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្ហឹកបង្រៀនតទៅអ្នកឯទៀតដែរ» (២ធីម៉ូថេ ២:២)។

យើងចង់បង្រៀនដល់មនុស្សគ្រប់គ្នា ប៉ុន្តែពិសេសជាងនោះទៅទៀតគឺយើងចង់បង្រៀនដល់អ្នកណាដែលនឹងចេញទៅបង្រៀនបន្តជាបន្តបន្ទាប់ ពីមួយជំនាន់ទៅមួយជំនាន់ទៀត។ យើងនឹងការធ្វើ «បន្ថែម» ប្រសិនបើយើងត្រូវធ្វើ ប៉ុន្តែ «ការទ្វេគុណ» នោះល្អប្រសើរជាង។ យើងមិនគ្រាន់តែធ្វើការបង្រៀនណែនាំដល់មនុស្សជំនាន់ក្រោយ ត្រឹមតែមួយជំនាន់ប៉ុណ្ណោះនោះទេ។ យើងកំពុងព្យាយាមធ្វើការបង្រៀនណែនាំឲ្យបានទៅដល់គ្រប់ៗជំនាន់!

## ៩. តើបុគ្គលនេះរស់នៅជិតខ្ញុំ ហើយតើកាលវិភាគរបស់យើងត្រូវគ្នាដែរឬទេ?

ជាចុងក្រោយ ទោះយើងជឿ ឬមិនជឿក្តី។ ព្រះគម្ពីរបានយល់យ៉ាងច្បាស់អំពីពេល

វេលា និងកាលវិភាគដ៏មមាញឹករបស់យើង។ សាវ័ក ប៉ុល បានសរសេរថា “ដូច្នេះ កាលណាយើងមានឱកាស នោះត្រូវធ្វើល្អដល់មនុស្សទាំងអស់ ហើយគឺដល់ពួកអ្នកជឿជាដើម” (កាឡាទី ៦:១០)។ លោកអ្នកអាចរកឃើញខគម្ពីរមួយចំនួនទៀតដែលមានអត្ថន័យដូចខគម្ពីរនេះ ដែលប្រាប់យើងឲ្យប្រើពេលវេលារបស់យើងឲ្យបានល្អបំផុត (ឧទាហរណ៍៖ អេភេសូរ ៥:១៦)។ ក្នុងលក្ខណៈចុងក្រោយដែលខ្ញុំកំពុងនិយាយនេះ គឺជាបញ្ហានៃប្រាជ្ញា។ ប៉ុន្តែ ជាទូទៅខ្ញុំសូមណែនាំឲ្យស្វែងរកអ្នកដែលមានកាលវិភាគស្របទៅនឹងកាលវិភាគរបស់លោកអ្នក។ លោកអ្នកក៏ត្រូវពិចារណាផងដែរអំពីកន្លែងដែលលោកអ្នករស់នៅ ឬកន្លែងធ្វើការ ហើយការចំណាយពេលរបស់លោកអ្នកជាមួយគ្រួសារ ជាមួយការងារ និងជាមួយក្រុមជំនុំ។ សូមចាំថា ព្រះមិនបានត្រាស់ហៅលោកអ្នកឲ្យធ្វើអ្វីមួយដែលមិនអាចធ្វើទៅរួចនោះទេ។

ជាការពិតណាស់ ក្នុងកិច្ចការទាំងអស់នេះ ព្រះបានរៀបចំកិច្ចការល្អជាងមុនឲ្យយើងរាល់គ្នាប្រព្រឹត្តតាម (អេភេសូរ ២:១០)។ ហើយដូចទៅនឹងសាសន៍សាម៉ារីដ៏ល្អម្នាក់មនុស្សមានចិត្តសប្បុរសដែរ ពេលខ្លះទ្រង់បានដាក់មនុស្សណាម្នាក់នៅក្នុងផ្លូវនៃជីវិតរបស់យើង ដែលយើងប្រហែលជាមិនធ្លាប់បានគិតថា នឹងចំណាយពេលជាមួយអ្នកនោះបាន។ ប្រហែលជាអ្នកនោះជាសមាជិកនៃក្រុមជំនុំរបស់លោកអ្នក អាចជាអ្នកកំពុងធ្វើការនៅក្នុងការិយាល័យជាមួយលោកអ្នក ឬក៏អ្នកនោះមានកូនៗរបស់ពួកគេបានចូលរួមក្នុងព្រឹត្តិការណ៍កីឡាដូចគ្នាជាមួយនឹងកូនៗរបស់លោកអ្នកដែរ។ ឬប្រហែលជាប្តី ឬប្រពន្ធរបស់នរណាម្នាក់បានបែកបាក់គ្នា និងបុគ្គលដែលកំពុងសោកសៅនោះបានមករកលោកអ្នក ដើម្បីជួយប្រឹក្សាយោបល់។

ដូច្នេះ ចូរមានប្រាជ្ញា ហើយគិតពិចារណាអំពីអស់អ្នកដែលលោកអ្នកជ្រើសរើស ដើម្បីចំណាយពេលជាមួយពួកគេ ប៉ុន្តែចូរដឹងថា ពេលខ្លះការផ្គត់ផ្គង់របស់ព្រះអម្ចាស់បានគ្រប់គ្រងលើផែនការទាំងអស់របស់យើង។ សូមសរសើរតម្កើងព្រះអម្ចាស់ ដែលទ្រង់បានឲ្យយើងពឹងផ្អែកលើទ្រង់!

## ការដាក់វារួមបញ្ចូលគ្នា

ឧបមាថា កាលវិភាគរបស់លោអ្នកបានអនុញ្ញាតឲ្យលោកអ្នកចំណាយពេលវេលាបានតែជាមួយលោក សុខា ឬលោក វិបុល ប៉ុន្តែមិនអាចបានទាំងពីរនាក់នោះទេ។ តើលោកអ្នកត្រូវជ្រើសរើសយ៉ាងដូចម្តេច? ប្រាកដណាស់ លោកអ្នកគួរតែអធិស្ឋានអំពីរឿងនេះ ប៉ុន្តែមិនមានចម្លើយដ៏ត្រឹមត្រូវណាមួយសម្រាប់លោកអ្នកឡើយ ហើយលោកអ្នកក៏មិនគួរមានអារម្មណ៍ថា ខ្លួនមានកំហុសដែរ ប្រសិនបើលោកអ្នកមិនអាចចំណាយពេលជាមួយអ្នកទាំងពីរនាក់នោះបាន។ នេះជាមូលហេតុដែលយើងជារូបកាយរបស់ព្រះគ្រីស្ទ។

លោកអ្នកអាចជ្រើសរើសចំណាយពេលជាមួយលោក សុខា ដោយសារតែកាលវិភាគការងាររបស់គាត់ត្រូវគ្នានឹងលោកអ្នក ឬដោយសារគាត់រស់នៅក្នុងតំបន់របស់លោកអ្នក ឬប្រពន្ធរបស់លោកអ្នក គឺជាមិត្តល្អជាមួយប្រពន្ធរបស់គាត់រួចទៅហើយ។ ឬលោកអ្នកប្រហែលជាសម្រេចចិត្តចំណាយពេលជាមួយលោក វិបុល ដោយសារតែគាត់ជាអ្នកចំណាកប្រទេស ដើម្បីការងារ ហើយគាត់ហៀបនឹងត្រឡប់ទៅប្រទេសគាត់វិញនៅឆ្នាំក្រោយ ហើយគាត់បានបង្ហាញការស្រឡាញ់ និងមានអំណោយទានក្នុងការបង្រៀនអ្នកដទៃ ហើយលោកអ្នកចង់ឲ្យគាត់មានគ្រប់ទាំងចំណេះដឹង ដើម្បីឲ្យគាត់ផ្តល់ចំណេះដឹងនោះដល់អ្នកដទៃទៀតនៅប្រទេសគាត់វិញបាន។ មិនថាលោកអ្នកមានហេតុផលអ្វីក៏ដោយក្នុងការសម្រេចចិត្ត សូមអធិស្ឋាន ហើយសូមប្រាជ្ញាពីព្រះ ហើយបន្ទាប់មកសូមធ្វើការនោះចុះ។

ក្នុងករណីទាំងអស់នេះ មិនថាលោកអ្នកមានចេតនាបង្រៀនមនុស្សតែម្នាក់ ឬបួននាក់ក៏ដោយ សូមប្រាកដថា លោកអ្នកកំពុងមានភាពរីកចម្រើនខាងវិញ្ញាណ ហើយបន្ទាប់មកសូមជួយអស់អ្នកដែលនៅជុំវិញលោកអ្នកឲ្យមានភាពរីកចម្រើនបានដែរ។ ទាំងលោកអ្នក និងអ្នកដទៃ គឺមានសារៈសំខាន់ដូចគ្នា ហើយម្នាក់ៗត្រូវរួមចំណែកជួយដល់គ្នាទៅវិញទៅមក។

## ជំពូកទី៨

# ត្រូវមានគោលដៅច្បាស់លាស់

នៅពេលដែលលោកអ្នកជ្រើសរើសនរណាម្នាក់ ដើម្បីបង្រៀនធ្វើជាសិស្ស លោកអ្នកត្រូវមានគោលដៅច្បាស់លាស់សម្រាប់ទំនាក់ទំនងនោះ។ ពិតប្រាកដណាស់ គោលដៅធំជាងនេះ គឺជួយគាត់ឲ្យដើរតាមព្រះយេស៊ូវ។ ប៉ុន្តែ តើលោកអ្នកនឹងធ្វើវាឲ្យមានភាពជាក់លាក់ដោយរបៀបណា? ការបង្រៀនមនុស្សម្នាក់ដូចជាលោកសុខា ដែលចូលចិត្តគោលលទ្ធិនឹងមានភាពខុសពីការបង្រៀនមនុស្សដូចជាលោកវិបុល ដែលពូកែទំនាក់ទំនង (ចរិតលក្ខណៈរបស់តួអង្គទាំងពីររបស់យើងក្នុងជំពូកមុន)។

ដោយហេតុនេះ ខ្ញុំសូមលើកទឹកចិត្តលោកអ្នកឲ្យជួយអ្នកដទៃក្នុងរបៀបពីរយ៉ាង៖ ជួយពួកគាត់យល់នូវអ្វីដែលខ្លួនគួរយល់ និងជួយពួកគាត់ក្នុងរបៀបដែលត្រូវរស់នៅជាប្រចាំថ្ងៃដែរ។

### ១. ការជួយមនុស្សឲ្យយល់ដឹងបន្ថែមទៀត៖ ជីវិត → សេចក្តីពិត → ជីវិត

សម្រាប់ការចាប់ផ្តើម ការបង្កើតសិស្សរបស់អ្នកគួរជួយដល់មនុស្សឲ្យយល់ដឹងបន្ថែម។ យើងចង់ឲ្យមនុស្សមានភាពរីកចម្រើនក្នុងការយល់ដឹងអំពីព្រះនៅក្នុងព្រះគ្រីស្ទ ហើយក្នុងសេចក្តីជំនឿកើតចេញពីការឮព្រះបន្ទូលរបស់ព្រះគ្រីស្ទ។ ដូច្នេះ សាវ័ក ប៉ុល បានប្រាប់ ធីម៉ូថេ ឲ្យ “ប្រុងប្រយ័ត្ននឹងខ្លួនអ្នក ហើយនិងសេចក្តីបង្រៀន” ផងដែរ។ ដោយការខំតស៊ូព្យាយាមដូចនេះ សាវ័ក ប៉ុល មានប្រសាសន៍ថា “ដ្បិតដែលធ្វើដូច្នោះ នោះអ្នកនឹងសង្គ្រោះខ្លួនអ្នកបាន ព្រមទាំងពួកអ្នកដែលស្តាប់អ្នកផង” (១ធីម៉ូថេ ៤:១៦)។

នៅពេលដែលលោកអ្នកជួយអ្នកដទៃដើរតាមព្រះយេស៊ូវ លោកអ្នកនឹងចង់ឲ្យពួកគេកាន់តែយល់អំពីមូលហេតុដែលគ្រីស្ទបរិស័ទអធិស្ឋាន មូលហេតុដែលយើងចែកចាយដំណឹងល្អ មូលហេតុដែលយើងចូលរួមក្នុងក្រុមជំនុំ មូលហេតុដែលចំណេះដឹងរបស់យើងអំពីអធិបតេយ្យភាពរបស់ព្រះមានឥទ្ធិពលលើរបៀបរស់នៅរបស់យើង និងអ្វីៗជាច្រើនទៀត។ ការជួយអ្នកដទៃដើរតាមព្រះយេស៊ូវគឺមិនគ្រាន់តែអំពីការបង្រៀនអំពីការទទួលខុសត្រូវ និងការកែប្រែអាកប្បកិរិយាខាងក្រៅនោះទេ។ ពិតណាស់ ព្រះយេស៊ូវបានមានបន្ទូលប្រាប់យើង ឲ្យបង្កើតសិស្សដោយបង្រៀនពួកគេឲ្យកាន់តាមគ្រប់ទាំងសេចក្តី ប៉ុន្តែពួកគេមិនអាចធ្វើតាមអ្វីដែលពួកគេមិនធ្លាប់បានទទួលការបង្រៀននោះទេ។ ការបង្រៀនពួកគេគឺជាអ្វីដែលយើងត្រូវធ្វើដំបូង។

ព្រះបន្ទូលរបស់ព្រះគួរតែជាចំណុចស្នូល សម្រាប់គ្រប់ទាំងទំនាក់ទំនងនៃការបង្កើតសិស្ស។ ដូច្នេះ ការបង្កើតសិស្សអាចជាការបែងចែកព្រះគម្ពីរជាផ្នែកតូចៗជាមួយអ្នកណាម្នាក់ ឬការសិក្សាព្រះបន្ទូលតាមរបៀបណាផ្សេងទៀត។ យើងត្រូវជួយគ្នាទៅវិញទៅមក ដូចដែលសាវ័ក ប៉ុល បានប្រាប់យើងឲ្យ “ហុចព្រះបន្ទូលនៃជីវិតដល់គេ” (ភីលីព ២:១៦)។ នេះជាឃ្លាដ៏អស្ចារ្យមួយ! យើងត្រូវលើកទឹកចិត្តគ្រប់គ្នាឲ្យហុចព្រះបន្ទូលនៃជីវិតដល់គេ ដោយការអាន ការយល់ដឹង និងការស្តាប់បង្គាប់តាមព្រះបន្ទូល។ លោកអ្នកប្រហែលជាអាចអានសៀវភៅគ្រីស្ទបរិស័ទល្អៗក្នុងទំនាក់ទំនងនៃការបង្កើតសិស្សជាមួយគ្នា ប៉ុន្តែសៀវភៅល្អបំផុត គឺការនាំមនុស្សទៅរកព្រះគម្ពីរផ្ទាល់តែម្តង។ យើងចង់ឲ្យសិស្សរបស់យើងយល់អំពីមូលដ្ឋានគ្រឹះនៃជំនឿ និងជីវិតជាគ្រីស្ទបរិស័ទឲ្យបានច្បាស់លាស់។

តើលោកអ្នកធ្លាប់ឮអំពីលំនាំនៃ ជីវិត ➔ សេចក្តីពិត ➔ គំរូជីវិតដែរឬទេ? ជីវិតរបស់លោកអ្នកគួរតែទាក់ទាញមនុស្សឲ្យមកស្តាប់លោកអ្នក ហើយបន្ទាប់មក ការបង្រៀនរបស់លោកអ្នកគួរតែជាដំណើរការសម្រាប់ការផ្លាស់ប្រែរបស់ពួកគេ។ ហើយនៅចុងបញ្ចប់ ជីវិតដែលបានផ្លាស់ប្រែរបស់ពួកគេគួរតែបង្ហាញពីអ្វីដែលលោកអ្នកបានបង្រៀន ដែលវានឹងបន្តទាក់ទាញអ្នកផ្សេងទៀតឲ្យមកស្តាប់ពួកគេ។ល។

## ២. ជួយមនុស្សឲ្យរស់នៅកាន់តែប្រសើរ

យើងមិនត្រឹមតែចង់ជួយមនុស្សឲ្យមានការយល់ដឹងកាន់តែច្បាស់ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ចង់ជួយពួកគេឲ្យរស់នៅកាន់តែប្រសើរផងដែរ។ ការដើរតាមព្រះគ្រីស្ទ ត្រូវរួមបញ្ចូលកិច្ចការទាំងពីរនេះ។ សាវ័ក ប៉ុល បានមានប្រសាសន៍ទៅកាន់អ្នកអានសំបុត្ររបស់គាត់ម្តងហើយម្តងទៀតថា ចូរឲ្យត្រាប់តាមគាត់ ដូចជាគាត់បានត្រាប់តាមព្រះគ្រីស្ទដែរ (១កូរិនថូស ៤:១៥-១៧; ១១:១; ភីលីព ៣:១៧; ៤:៩; ២ថែស្សាឡូនីច ៣:៧-៩; ២ធីម៉ូថេ ៣:១០-១១)។ ហើយជាការពិតណាស់ គាត់កំពុងត្រាប់តាមព្រះយេស៊ូវនៅក្នុងរឿងទាំងនេះ។ ព្រះយេស៊ូវបានត្រាស់ហៅសិស្សទ្រង់ឲ្យមានសេចក្តីស្រឡាញ់ដូចជាទ្រង់បានស្រឡាញ់ពួកគេដែរ (យ៉ូហាន ១៣:៣៥; ១៥:៨-១៧)!

សូមទទួលស្គាល់ថា ព្រះបានផ្លាស់ប្តូររបៀបដែលយើងរស់នៅ (សូមមើល កាឡាទី ៤:៩)។ យើងរស់នៅដូចជាពួកប្រទេសក្រៅ ហើយដូចជាអ្នកដែលគ្រាន់តែសំណាក់នៅក្នុងលោកីយ៍ ដែលតែងតែទាស់ប្រឆាំង ហើយតែងតែប្រឈមមុខនឹងសម្ពាធ ដើម្បីធ្វើតាមការប៉ងប្រាថ្នាខាងសាច់ឈាមប៉ុណ្ណោះ។ ប៉ុន្តែ ព្រះគម្ពីរបានត្រាស់ហៅយើងឲ្យទប់ទល់នឹងសម្ពាធនៃការប៉ងប្រាថ្នាខាងសាច់ឈាមទាំងនោះ។ យើងត្រូវតែត្រៀមខ្លួនឲ្យបានក្លាយជា «ឥតសៅហ្មង ឥតកិច្ចកល ជាកូនព្រះដែលរកបន្ទោសមិនបាននៅក្នុងដំណមនុស្សវៀច ហើយខិលខូច ដែលអ្នករាល់គ្នាភ្លឺនៅកណ្តាលគេ ដូចជាតួពន្លឺនៅក្នុងលោក» (ភីលីព ២:១៥)។ នេះជាមូលហេតុដែលគ្រីស្ទបរិស័ទតែងតែត្រូវការគំរូដ៏ល្អប្រសើរពីអ្នកដែលគោរពកោតខ្លាចព្រះនៅមុខពួកគេ៖ «បងប្អូនអើយ ចូរត្រាប់តាមខ្ញុំគ្រប់គ្នា ហើយពិចារណាមើលឲ្យស្គាល់ពួកអ្នក ដែលដើរដូចជាយើងខ្ញុំបានធ្វើក្បួនឲ្យអ្នករាល់គ្នាហើយ» (ភីលីព ៣:១៧)។

តើលោកអ្នកបង្ហាញឥទ្ធិពលទៅលើការរស់នៅរបស់អ្នកដទៃដោយរបៀបណា? គឺដោយការចំណាយពេលជាមួយពួកគេ។ លោកស្រី ស៊ីថា បានអញ្ជើញលោកស្រី បុប្ផា មកផ្ទះរបស់គាត់ ដើម្បីជជែកគ្នាលេង នៅពេលគាត់កំពុងធ្វើម្ហូប។

លោក រ៉ូ បានអញ្ជើញលោក បូឡុង ចូលរួមញ៉ាំអាហារពេលល្ងាចជាមួយគ្រួសាររបស់គាត់ ហើយបន្ទាប់មកគាត់បានបង្ហាញគំរូនៃការដឹកនាំកូនៗ និងគ្រួសាររបស់គាត់ក្នុងការថ្វាយបង្គំព្រះ ឲ្យគាត់បានឃើញ។ មានរបៀបនៃការបង្កើតសិស្សជាច្រើនទម្រង់ដែលកំពុងធ្វើឡើងតាមរយៈសកម្មភាពធម្មតាប្រចាំថ្ងៃ ប៉ុន្តែតម្រូវឲ្យមានមនុស្សមកជាមួយលោកអ្នក ហើយមានការសន្ទនាដ៏ស៊ីជម្រៅ ដូចជាព្រះយេស៊ូវបានធ្វើអញ្ចឹងដែរ។ ហើយលោកអ្នកត្រូវមានតម្លាភាព នៅពេលដែលលោកអ្នកបានអញ្ជើញពួកគេឲ្យចូលមកក្នុងជីវិតរបស់លោកអ្នក។ ប្រសិនបើលោកអ្នកព្យាយាមលាក់បាំងអត្តចរិតរបស់ខ្លួន នោះលោកអ្នកនឹងមិនអាចជួយអ្នកដទៃក្នុងការដើរតាមព្រះយេស៊ូវបានទេ។ សូមអញ្ជើញអ្នកដទៃឲ្យរៀនពីកំហុសឆ្គងរបស់លោកអ្នកដែរ។

សេចក្តីពិតនោះគឺថា ពេលខ្លះខ្ញុំ និងប្រពន្ធក៏មានការឈ្លោះប្រកែកគ្នាដែរ។ ប៉ុន្តែ តើយើងអាចប្រើប្រាស់ការអាក្រក់នោះទៅជាការល្អវិញបានដែរឬទេ? តើយើងអាចចែករំលែកបញ្ហាទាំងនោះជាមួយអ្នកដទៃដោយការពារកិត្តិយសគ្នាទៅវិញទៅមកបានដែរឬទេ?

សូមស្តាប់អំពីរបៀបដែលសាវ័ក ប៉ុល បានមានប្រសាសន៍ទាក់ទងនឹងរឿងរ៉ាវទាំងអស់នេះទៅកាន់លោក ធីម៉ូថេ៖ «តែចំណែកអ្នក អ្នកបានស្គាល់គ្រប់សេចក្តីដែលខ្ញុំបង្រៀន កិរិយាដែលប្រព្រឹត្ត និងបំណងចិត្ត សេចក្តីជំនឿ សេចក្តីអត់ធ្មត់ សេចក្តីស្រឡាញ់ សេចក្តីខ្ជាប់ខ្ជួនរបស់ខ្ញុំហើយ ព្រមទាំងការដែលគេបៀតបៀនដល់ខ្ញុំ និងសេចក្តីទុក្ខលំបាករបស់ខ្ញុំដែរ ជាការដែលកើតដល់ខ្ញុំ នៅក្រុងអាន់ទីយ៉ូក ក្រុងអ៊ីកូនាម និងក្រុងលីស្ត្រា ក៏ស្គាល់សេចក្តីបៀតបៀនជាយ៉ាងណា ដែលខ្ញុំទ្រាំទ្រនោះដែរ» (២ធីម៉ូថេ ៣:១០-១១)។ តាមពិតទៅលោក ធីម៉ូថេ បានឃើញកិច្ចការទាំងអស់នេះ។ ហើយអ្វីដែលជាការអប់រំដ៏ច្រើនសន្ធឹកក្នុងការដើរតាមព្រះគ្រីស្ទ វាច្បាស់ជាត្រូវបានបង្ហាញឲ្យបានឃើញមែនដែរ!

លោកអ្នកចង់ឲ្យមនុស្សដែលលោកអ្នកបង្រៀនមានភាពរីកចម្រើនក្នុងការអធិស្ឋាន មានភាពឆេះឆួលឡើងក្នុងការផ្សាយដំណឹងល្អ អាចបន្តក្នុងសមាជិកភាពក្នុងក្រុមជំនុំ និងមានភាពអត់ធ្មត់ចំពោះសមាជិកណាដែលប្រមាថមើលងាយ

ពួកគាត់។ ជាញឹកញាប់ លោកអ្នកនឹងជជែកគ្នាអំពីចំណុចទាំងនេះចេញពីសេចក្ដីអធិប្បាយដែលបានអធិប្បាយកាលពីសប្ដាហ៍មុន។ ឬក៏ថា ការជជែកទាំងនេះក៏អាចកើតឡើងនៅក្នុងក្រុមតូច។

## ការសួរសំណួរ

មិនថាលោកអ្នកកំពុងបង្រៀនអ្នកណានោះទេ លោកអ្នកនឹងចង់ជួយពួកគាត់ឲ្យដើរតាមព្រះយេស៊ូវបានកាន់តែល្អប្រសើរជាងមុន ដោយការរីកចម្រើនក្នុងចំណេះដឹងអំពីព្រះ និងដោយការរៀនយកចំណេះដឹងនោះទៅអនុវត្តដោយឲ្យស្ដែងក្នុងជីវិតផ្ទាល់—ដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរ និងរស់នៅកាន់តែប្រសើរជាងមុនផងដែរ។

ពិតណាស់ វាពឹងផ្អែកលើភាពជាក់លាក់របស់មនុស្សម្នាក់ៗ៖ តើអ្វីជាចំណាប់អារម្មណ៍ ប្រវត្តិសាស្ត្រ ចំណង់ចំណូលចិត្ត ទម្លាប់នៃការប្រព្រឹត្តបាប ការឈឺចាប់ ការភ័យខ្លាច សេចក្ដីសង្ឃឹមរបស់គាត់ និងអ្វីៗជាច្រើនទៀតរបស់គាត់? ហើយប្រភេទរឿងរ៉ាវដែលលោកអ្នកបាននិយាយ ឬអាន ឬធ្វើ គឺវានឹងអាស្រ័យលើអ្នកដែលលោកអ្នកបានជ្រើសរើសនោះ។ ដូច្នេះ រឿងដំបូងដែលលោកអ្នកគួរធ្វើក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស គឺត្រូវស្គាល់ពួកគាត់ជាមុនសិនដោយការសួរជាសំណួរឲ្យបានច្រើន។ តើអ្នកបានក្លាយជាគ្រីស្ទបរិស័ទដោយរបៀបណា? តើអ្នកមកពីណា? តើឪពុកម្ដាយរបស់អ្នកជាគ្រីស្ទបរិស័ទមែនដែរឬទេ? តើជីដូនជីតារបស់អ្នកជាគ្រីស្ទបរិស័ទដែរឬទេ? ហេតុអ្វីបានជាអ្នកទទួលបានការងារដែលអ្នកកំពុងធ្វើ? និងសំណួរផ្សេងៗជាច្រើនទៀត។ កម្រិតនៃការជឿទុកចិត្ត និងតម្លាភាពគួរតែកើនឡើងទៅតាមពេលវេលា និងកាន់តែច្រើនឡើងៗបន្ថែមទៀត នៅពេលដែលលោកអ្នកនឹងអាចនិយាយអំពីបញ្ហាផ្ទាល់ខ្លួនបានកាន់តែស៊ីជម្រៅ ហើយតាមរយៈបញ្ហាទាំងនោះនឹងបង្ហាញឲ្យឃើញអំពីដំណឹងល្អនៅក្នុងគ្រប់ផ្នែកទាំងអស់ផងដែរ។

តាមពិតទៅ «របៀបនៃការបង្កើតសិស្ស» មិនមានភាពស្មុគស្មាញប៉ុន្មានទេ។ វាគឺជាការរស់នៅក្នុងជីវិតរបស់លោកអ្នកជាមួយអ្នកដទៃទៀត ខណៈពេលយើង

គ្រប់គ្នាធ្វើដំណើរសំដៅឆ្ពោះទៅរកព្រះគ្រីស្ទ។ យើងស្វែងរកមិត្តភក្តិ ហើយបន្ទាប់មកដើរជាមួយពួកគេក្នុងទិសដៅមួយសំដៅទៅកាន់ព្រះគ្រីស្ទ។ យើងចង់យល់ដឹងពីព្រះ និងផ្លូវរបស់ទ្រង់ ហើយរស់នៅក្នុងជីវិត ដូចដែលព្រះគម្ពីរបានត្រាស់ហៅយើងឲ្យរស់នៅបែបនោះមែន។ យើងចង់រស់នៅឲ្យមានភាពត្រឹមត្រូវ មានភាពស៊ីគ្នាអំពីការយល់ដឹងរបស់យើង និងភាពបរិសុទ្ធក្នុងការរស់នៅរបស់យើង។ យើងចង់ដឹងអំពីសេចក្តីពិត ហើយរស់នៅឲ្យបានល្អប្រសើរ។ កិច្ចការទាំងអស់នេះ គឺដើម្បីលើកតម្កើងព្រះដែលបានបង្កើតយើងក្នុងរូបអង្គរបស់ទ្រង់!

ជំពូកទី៩

# ការលៃលកមើលជាមុន

តើលោកអ្នកបង្កើតសិស្សដោយរបៀបណា? គឺលោកអ្នកត្រូវស្វែងរកនរណាម្នាក់ លោកអ្នកត្រូវដាក់គោលដៅ ហើយចុងក្រោយ លោកអ្នកគ្រាន់តែចាប់ផ្តើមធ្វើវា។ លោកអ្នកត្រូវបង្កើតសិស្ស។ ហើយដើម្បីធ្វើដូច្នេះបាន លោកអ្នកត្រូវការលៃលកមើលជាមុន។ ការចំណាយពេលវេលា ការសិក្សា ការអធិស្ឋាន និងសេចក្តីស្រឡាញ់គឺជាការលៃលកនោះ។

## ១. ការបង្កើតសិស្សត្រូវការចំណាយពេលវេលា

នៅពេលខ្ញុំនិយាយថា "ការបង្កើតសិស្ស" ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា ទំនាក់ទំនងនៃការបង្កើតសិស្សទាំងអស់មិនមានលក្ខណៈដូចគ្នាទេ។ ការបង្កើតសិស្សរបស់ខ្ញុំមិនដូចគ្នាឡើយ។ ការបង្កើតសិស្សរបស់ខ្ញុំបានសមស្របទៅនឹងស្ថានភាពនៃជីវិតរបស់ខ្ញុំ និងជីវិតរបស់អ្នកដែលខ្ញុំនឹងបង្កើតសិស្សជាមួយ។ ហើយទំនាក់ទំនងទាំងនោះបានផ្លាស់ប្តូរទៅតាមពេលវេលា។ ខ្ញុំអាចនឹងឃើញមនុស្សម្នាក់ស្ទើរតែរាល់ថ្ងៃមួយរយៈពេល បន្ទាប់មកឃើញគាត់ជារៀងរាល់សប្តាហ៍ និងបន្ទាប់មកឃើញគាត់មួយខែម្តង។ ដូចគ្នាដែរ ទំនាក់ទំនងទាំងនេះអាចជាផ្លូវនៃការរវាងច្រើន។ ទោះបីជាលោកអ្នកបានហៅទំនាក់ទំនងណាមួយថា "ទំនាក់ទំនងនៃការបង្កើតសិស្ស" វាមិនសំខាន់នោះទេ។ ប៉ុន្តែ ទំនាក់ទំនងទាំងអស់នេះមានលក្ខណៈដូចគ្នាត្រង់ចំណុចដែលថា យើងត្រូវការពេលវេលា!

វាជាការចំណាយពេលវេលារបស់យើង ដែលតម្រូវឲ្យយើងត្រូវមានគោលបំណងក្នុងការបង្រៀននរណាម្នាក់។ ហើយដោយសារយើងមានពេលវេលាតិច នោះយើងត្រូវតែមានពេលវេលាកំណត់ពីចំនួនទំនាក់ទំនងនៃការបង្កើតសិស្ស

របស់យើង។ ជាការពិតណាស់ លោកអ្នកអាចបង្រៀនមនុស្សជាច្រើនតាមរយៈការអធិប្បាយព្រះបន្ទូល ឬតាមរយៈការសរសេរអត្ថបទ ប៉ុន្តែយើងកំពុងពិភាក្សាអំពីការបង្រៀនម្នាក់ទល់ម្នាក់ ឬការបង្រៀនក្នុងក្រុមតូច។ ហើយទាំងនេះ លោកអ្នកត្រូវតែមានគោលបំណង និងមានចេតនាក្នុងការធ្វើវា។

ទោះបីជា កាលវិភាគរបស់លោកអ្នកមានដំណើរការស្របជាមួយមនុស្សដែលលោកអ្នកកំពុងបង្រៀនក៏ដោយ ក៏ទំនាក់ទំនងនៃការបង្កើតសិស្ស គឺត្រូវការពេលវេលាដែរ។ ភាពងាយស្រួលនឹងមិនលុបបំបាត់ការចំណាយទាំងស្រុងនោះទេ។ ពួកយើងផ្តល់អំណោយជាពេលវេលាដល់គ្នាទៅវិញទៅមក នៅរាល់ពេលដែលយើងមានទំនាក់ទំនងនៅក្នុងជីវិត។ លោកអ្នកអាចលៃលកមើលជាមុន តាមរបៀបតូចតាចដូចជា និយាយជាមួយអ្នកដទៃបន្ទាប់ពីបញ្ចប់ការថ្វាយបង្គំនៅព្រះវិហារ ឬក៏ធ្វើកិច្ចការជាមួយគ្នា។ លោកអ្នកអាចលៃលកមើលជាមុនតាមរបៀបធំជាងនេះ ដូចជាការណាត់ញ៉ាំអាហារជុំគ្នាមួយដងក្នុងមួយសប្តាហ៍។ យើងអាចចំណាយពេលជាមួយគ្នា តាមរបៀបផ្សេងៗទៀតដូចជានៅក្នុងហាងកាហ្វេ នៅបណ្ណាល័យ នៅហាងជួសជុលរថយន្ត ឬអំឡុងពេលធ្វើការនៅផ្ទះរបស់យើងជាដើម។

លោកអ្នកអាចនឹងរកឃើញថា មនុស្សមួយចំនួនពេញចិត្តក្នុងការចំណាយពេលជាមួយលោកអ្នកណាស់ ដើម្បីឲ្យពួកគេអាចចូលមកក្នុងជីវិតរបស់លោកអ្នក បម្រើលោកអ្នក ឬគ្រួសាររបស់លោកអ្នកទៀតផង។ លោកអ្នកត្រូវការជួយធ្វើឲ្យពេលវេលាមានតម្លៃជាមួយពួកគេ ដោយត្រូវមានតម្លាភាព និងភាពស្មោះត្រង់ក្នុងទំនាក់ទំនងនោះ។ ខ្ញុំបាននិយាយរួចមកហើយអំពីគំរូរបស់យើងក្នុងការស៊ូទ្រាំនឹងការលំបាកច្រើនតែមានឥទ្ធិពលជាជាងរឿងជោគជ័យ និងជ័យជម្នះរបស់យើង។ ទុក្ខលំបាកបង្ហាញនូវអ្វីដែលចិត្តរបស់យើងពិតជាមានការជឿជាក់ និងការដាក់សេចក្តីសង្ឃឹមរបស់យើងទៅលើព្រះអម្ចាស់។ នៅក្នុងលោកីយ៍ដែលធ្លាក់ក្នុងអំពើបាបនេះ ពេលវេលាបានកន្លងផុតទៅ ហើយតែងតែនាំមកនូវទុក្ខលំបាកដល់យើង។ ទុក្ខលំបាក គឺជាពេលវេលាដ៏សំខាន់ក្នុងទំនាក់ទំនងការបង្កើតសិស្សរបស់យើង មិនថាទុក្ខលំបាកនោះ នៅក្នុងជីវិតរបស់អ្នកកំពុងបង្រៀន ឬអ្នកបានទទួល

ការបង្រៀនពីគេនោះទេ។

ចូរប្រយ័ត្ន៖ ប្រសិនបើលោកអ្នករង់ចាំបង្កើតទំនាក់ទំនងទាំងនេះរហូតដល់លោកអ្នកត្រូវការវា នោះវាប្រហែលជាអាចយឺតពេលហើយ។

## ២. ការបង្កើតសិស្សតម្រូវឲ្យមានការសិក្សា

ប្រសិនបើសេចក្តីជំនឿកើតឡើងដោយសារការឮព្រះបន្ទូលព្រះ នោះយើងចង់បង្កើតឲ្យមានសេចក្តីជំនឿដោយប្រើព្រះបន្ទូលរបស់ព្រះ។ សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរដែលលោកអ្នកបានឮនៅក្នុងព្រះវិហារ (ខ្ញុំសង្ឃឹមបែបនោះ) បានផ្តល់នូវមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ការសន្ទនានៅសប្តាហ៍បន្តបន្ទាប់ទៀត។ សៀវភៅផ្សេងទៀតអាចជួយលោកអ្នកបានផងដែរ ព្រោះវានាំលោកអ្នកឲ្យកាន់តែមានភាពស៊ីជម្រៅក្នុងប្រធានបទនៃការអធិប្បាយនោះ។

យើងសិក្សាអំពីអ្វីដែលយើងស្រឡាញ់ចូលចិត្ត។ ភាពជាសិស្សរបស់គ្រីស្ទបរិស័ទ និងការបង្កើតសិស្សត្រូវរួមបញ្ចូលជាមួយការស្រឡាញ់ព្រះអម្ចាស់ឲ្យអស់អំពីគំនិតរបស់យើង។ យើងគួរមានបំណងចិត្តចង់ស្គាល់ព្រះអង្គ ហើយចង់ជួយអ្នកដទៃឲ្យបានស្គាល់ទ្រង់ ដូចដែលទ្រង់បានបើកសម្តែងអង្គទ្រង់ផ្ទាល់ក្នុងព្រះបន្ទូលដែរ។

សូមប្រើប្រាស់ព្រះគម្ពីរ នៅក្នុងទំនាក់ទំនងនៃការបង្កើតសិស្សរបស់លោកអ្នក។ សូមចំណាយពេលជាមួយព្រះបន្ទូលរបស់ព្រះ។

## ៣. ការបង្កើតសិស្សតម្រូវឲ្យមានការអធិស្ឋាន

សាវ័ក ប៉ុល បានប្រាប់យើងថា “ចូរអធិស្ឋានឥតឈប់ឈរ” (១ថែស្សាឡូនីច ៥:១៧)។ សូមអធិស្ឋានសម្រាប់អស់អ្នកដែលលោកអ្នកកំពុងបង្កើតសិស្សជាមួយ ហើយបង្រៀនពួកគេឲ្យចេះអធិស្ឋានដែរ។ ការអស្ចារ្យដែលយើងត្រូវការនៅក្នុងជីវិតរបស់យើង គឺជាការអស្ចារ្យដែលអាចកើតឡើងបានតាមតែរយៈព្រះជាម្ចាស់ ទោះបីជាព្រះជាម្ចាស់ប្រើប្រាស់មនុស្សក្នុងមធ្យោបាយណាមួយដូចជាការអធិស្ឋានក៏ដោយ។

ក្នុងរបៀបនៃការបង្កើតសិស្ស សូមសួរសំណួរដែលជួយមនុស្សឲ្យគិតពិចារណាតាមរយៈអ្វីដែលពួកគេគួរអធិស្ឋានអំពី។ តើពួកគេដឹងអំពីរបៀបយកបទគម្ពីរណាមួយនៅក្នុងព្រះគម្ពីរ ហើយអធិស្ឋានតាមបទគម្ពីរនោះដែរឬទេ? តើពួកគេចំណាយពេលផ្ទាល់ខ្លួនក្នុងការអធិស្ឋានដែរឬទេ? តើពួកគេអធិស្ឋានអំពីរឿងបែបណា? តើពួកគេអធិស្ឋានសម្រាប់អ្នកណា? តើពួកគេអធិស្ឋានអំពីមិត្តភាពរបស់ពួកគេដែរឬទេ? តើពួកគេអធិស្ឋានអំពីព័ន្ធកិច្ចដែរឬទេ? តើពួកគេអធិស្ឋានអំពីលុយកាក់ដែរឬទេ? តើពួកគេអធិស្ឋានអំពីមិត្តភក្តិដែលពួកគេចង់ឃើញការផ្លាស់ប្តូរសេចក្តីជំនឿឲ្យមកជឿលើព្រះយេស៊ូវដែរឬទេ? តើពួកគេអធិស្ឋានអំពីភាពត្រឹមត្រូវ និងភាពបរិសុទ្ធរបស់ពួកគេដែរឬទេ?

សូមអានសៀវភៅល្អៗដែលបង្ហាញពីរបៀបអធិស្ឋានតាមព្រះគម្ពីរ ដូចជាសៀវភៅរបស់លោក ឌី.អេ. ខាសុន (D. A. Carson) ដែលមានចំណងជើងថា “អធិស្ឋានជាមួយសាវ័ក ប៉ុល” (“Praying with Paul”) និងលោក ដូណាល់ វីតនី (Donald Whitney) ដែលមានចំណងជើងថា “អធិស្ឋានដោយប្រើប្រាស់ព្រះគម្ពីរ” (“Praying the Bible”)។ ហើយបន្ទាប់មកសូមអធិស្ឋាន។

## ៤. ការបង្កើតសិស្សត្រូវការឲ្យមានសេចក្តីស្រឡាញ់

ព្រះយេស៊ូវបានមានបន្ទូលបង្គាប់ថា “ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ” (យ៉ូហាន ១៣:៣៤)។ ទ្រង់ក៏បានសង្ខេបបទបញ្ញត្តិទាំងអស់ឲ្យទៅជាបញ្ញត្តិតែពីរវិញ គឺបញ្ញត្តិទី១ ត្រូវស្រឡាញ់ដល់ព្រះ និងបញ្ញត្តិទី២ ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯងដែរ (ម៉ាកុស ១២:២៨-៣១)។ ខ្ញុំសង្ឃឹមថាលោកអ្នកបានមើលឃើញអំពីសារៈសំខាន់នៃសេចក្តីស្រឡាញ់ក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស។

*សេចក្តីស្រឡាញ់គឺជាអ្វីដែលបានបណ្តាលឲ្យយើងចាប់ផ្តើមមានទំនាក់ទំនងនៃការបង្កើតសិស្ស*។ វាគឺជាសេចក្តីស្រឡាញ់ដែលបង្ខំឲ្យយើងឲ្យលះកាត់ចិត្តខ្លួនឯងចោល ដើម្បីបម្រើអ្នកដទៃ។ វាគឺជាសេចក្តីស្រឡាញ់ដែលបណ្តាលឲ្យយើងរងគ្រោះដោយការបដិសេធពីអ្នកដទៃ ដែលអាចកើតឡើងបាននៅពេល

យើងចាប់ផ្ដើមទំនាក់ទំនងណាមួយ។ វាតែងតែជាសេចក្ដីស្រឡាញ់ចំពោះព្រះ និងអ្នកដទៃ ដែលអាចនាំយើងឲ្យមើលរំលងការលំបាកនានា និងទទួលយកការលះបង់ទាំងនោះ ដោយព្រោះយើងចង់ឃើញនរណាម្នាក់មានភាពរីកចម្រើននៅក្នុងសេចក្ដីជំនឿរបស់គាត់។

*សេចក្ដីស្រឡាញ់នាំឲ្យមានការស៊ូទ្រាំក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស។* គ្មានអ្វីផ្សេងទៀតឡើយ គឺមានតែសេចក្ដីស្រឡាញ់ទេ ដែលអាចឲ្យយើងស៊ូទ្រាំនឹងការប្រឈមនានាដែលកើតមានឡើង! "គាត់យកខ្ញុំ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន"។ "នាងមិនយល់ទេថា ការនិយាយបែបនេះធ្វើឲ្យខ្ញុំឈឺចាប់ប៉ុណ្ណាទេ"។ "ខ្ញុំរវល់ណាស់"។ ទំនាក់ទំនងនៃការបង្កើតសិស្សអាចជារឿងដ៏អស្ចារ្យ ប៉ុន្តែទំនាក់ទំនងដ៏អស្ចារ្យក៏ត្រូវមានការស៊ូទ្រាំក្នុងសេចក្ដីស្រឡាញ់ ដូចជាក្នុងជីវិតអាពាហ៍ពិពាហ៍អញ្ចឹងដែរ។ ប្រាកដណាស់ កិច្ចការនេះតម្រូវឲ្យយើងនឹកចាំអំពីសេចក្ដីស្រឡាញ់យ៉ាងខ្លាំង និងពេញលេញរបស់ព្រះអម្ចាស់សម្រាប់យើង។ ហើយសេចក្ដីស្រឡាញ់នោះក៏បានបង្ហូរបំពេញ ហើយនៅតែបន្តបង្ហូរបំពេញបន្ថែមទៀតទៅកាន់ជីវិតរបស់អ្នកដទៃដែរ។

*សេចក្ដីស្រឡាញ់ចេះបន្ទាបខ្លួនក្នុងការទទួលយកការរិះគន់ ដែលជារឿយៗកើតមានឡើងក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស។* សេចក្ដីស្រឡាញ់ និងភាពឥតប្រយោជន៍ពុំអាចដើរទន្ទឹមគ្នាបាននោះទេ។ ប្រសិនបើ ខ្ញុំមានការខ្វល់ខ្វាយតែនឹងអ្វីដែលអ្នកដទៃគិតមកលើខ្ញុំ ជំនួសឲ្យអ្វីគាត់កំពុងធ្វើ នោះវានឹងពិបាកសម្រាប់ខ្ញុំក្នុងការស្រឡាញ់ និងបង្រៀនគាត់ក្នុងទំនាក់ទំនងមួយដែលខ្ញុំគួរធ្វើ។ ខ្ញុំមិនអាចនិយាយ ឬទទួលពាក្យកែតម្រូវគ្រប់ពេលនោះទេ។ ដើម្បីធ្វើដូច្នេះបាន គឺខ្ញុំត្រូវមានសេចក្ដីស្រឡាញ់ចំពោះព្រះ និងសេចក្ដីស្រឡាញ់ចំពោះមិត្តភក្ដិឲ្យលើសពីសេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះកេរ្ដិ៍ឈ្មោះរបស់ខ្លួនឯង។ "របួសដែលមិត្តសម្លាញ់ធ្វើដល់យើង នោះតែងធ្វើដោយស្មោះត្រង់ទេ" (សុភាសិត ២៧:៦)។

*នៅក្នុងទំនាក់ទំនងនៃការបង្កើតសិស្ស សេចក្ដីស្រឡាញ់ដែលលោកអ្នកមានបានបណ្ដាលឲ្យលោកអ្នក ផ្ដល់ជីវិតរបស់លោកអ្នកផ្ទាល់ទៅកាន់បុគ្គលនោះ។* ប្រហែលជាលោកអ្នកបានល្បួងឲ្យគិតថា លោកអ្នកមានតួនាទីធំពេក សំខាន់

ពេក រវល់ពេក មិនអាចស្រឡាញ់មនុស្សម្នាក់នេះ ឬមនុស្សម្នាក់នោះបាន (ដើម្បីឲ្យប្រាកដ លោកអ្នកត្រូវការកន្លែងណាមួយ ដើម្បីពិចារណាអំពីកាលវិភាគរបស់ខ្លួន)។ ប៉ុន្តែ សេចក្តីស្រឡាញ់នឹងជួយឲ្យលោកអ្នកអាចឲ្យតម្លៃអ្នកដទៃតាមដែលលោកអ្នកគួរធ្វើ ហើយបន្ទាប់មក លោកអ្នកក៏ចាប់ផ្តើមលះបង់ខ្លួនឯង។

*សេចក្តីស្រឡាញ់ ក៏អនុញ្ញាតឲ្យយើងបញ្ចប់ទំនាក់ទំនងនៃការបង្កើតសិស្សផងដែរ។ យើងមិនមែនជាព្រះនោះទេ។* យើងមិនអាចផ្តល់អ្វីគ្រប់យ៉ាងដល់នរណាម្នាក់តាមដែលគាត់ត្រូវការបានទេ។ យើងប្រហែលជាមិនមានពេលទំនេរគ្រប់ពេលនោះដែរ។ មនុស្សផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត។ ពួកគេមានកូនមួយទៀត។ លោកអ្នកមានការងារផ្សេង។ កាលៈទេសៈមានការផ្លាស់ប្តូរ។ ប្រហែលជាពួកគេត្រូវការអ្វីមួយដែលលោកអ្នកមិនមាន។ យើងត្រូវការសេចក្តីស្រឡាញ់ដែលមានការបន្ទាបខ្លួនគ្រប់គ្រាន់ ដើម្បីទទួលស្គាល់ថា អ្វីៗដែលពួកគេត្រូវការគឺមិនមែនជាយើងទេ ប៉ុន្តែគឺជាព្រះអម្ចាស់ ហើយព្រះអាចប្រើប្រាស់យើងបានមួយរយៈពេល និងពេលបន្ទាប់មកទ្រង់ប្រើប្រាស់អ្នកផ្សេងវិញ។

## សេចក្តីសន្និដ្ឋាន

ព្រះបានត្រាស់ហៅយើងម្នាក់ៗឲ្យស្រឡាញ់អ្នកដទៃ និងទទួលការស្រឡាញ់ពីអ្នកដទៃ។ អ្វីៗគ្រប់យ៉ាងដែលព្រះអម្ចាស់បានផ្តល់ឲ្យលោកអ្នក គឺទ្រង់ចង់ឲ្យលោកអ្នកបន្តផ្តល់ឲ្យដល់អ្នកនៅជុំវិញតាមទម្រង់ ឬគំរូមួយចំនួនដែលទ្រង់បានបង្ហាញមកដល់លោកអ្នក។ មិនថាពេលវេលា សេចក្តីពិត ការអធិស្ឋាន ឬសេចក្តីស្រឡាញ់ដែលទ្រង់បានផ្តល់ឲ្យលោកអ្នកនោះទេ ក៏លោកអ្នកអាចប្រើប្រាស់សម្រាប់អ្នកដទៃបាន។

លោក រីឆាត ស៊ីបស៍ (Richard Sibbes) បានសរសេរថា “ថ្ងៃណាមួយយើងត្រូវតែរៀបរាប់ប្រាប់ទៅកាន់ព្រះអង្គ គឺមិនមែនត្រឹមតែសេចក្តីអធិប្បាយដែលយើងបានឮប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ត្រូវប្រាប់អំពីរបៀបដែលយើងបានត្រាប់តាមគំរូ

របស់អ្នកដទៃផងដែរ»។[៦] ក្នុងក្រុមជំនុំដំណឹងល្អរបស់យើងសព្វថ្ងៃនេះ តើយើងបានផ្ដល់ឲ្យតែពាក្យសម្ដីប៉ុណ្ណោះឬ? ពិតណាស់ ពាក្យទាំងនោះគឺជាពាក្យល្អ ពាក្យពិត និងពាក្យដែលត្រូវការ ប៉ុន្តែដោយគ្រាន់តែមានពាក្យទាំងនោះមិនទាន់ពេញលេញទេ បើគ្មានការពន្យល់ និងការបង្ហាញអត្ថន័យតាមរយៈជីវិតរស់នៅរបស់យើង។

មិនថា លោកអ្នកចូលរួមជាមួយក្រុមជំនុំណាក៏ដោយ លោកអ្នកមានឱកាសធំធេងណាស់សម្រាប់ការបង្កើតសិស្ស! ទោះបីអ្នកខ្លះនៅក្រុមជំនុំរបស់លោកអ្នកក្នុងរយៈពេលខ្លីក៏ដោយ ក៏លោកអ្នកនៅមានឱកាសក្នុងការជះឥទ្ធិពលលើពួកគាត់ ដើម្បីនៅពេលដែលពួកគាត់ចាកចេញទៅ ពួកគេអាចពង្រីកព័ន្ធកិច្ចរបស់លោកអ្នកទៅក្រុមជំនុំមួយផ្សេងទៀតបាន។ ពិតប្រាកដណាស់ លោកអ្នកត្រូវមានការយល់ដឹងឲ្យច្បាស់ថា ការបង្កើតសិស្សត្រូវតែមានការប្រឈម និងការលះបង់។ ប៉ុន្តែ ព្រះអម្ចាស់ទទួលបានសិរីល្អតាមរយៈកិច្ចការទាំងអស់នេះ!

៦ លោក Richard Sibbes, "The Bride's Longing," in Works of Richard Sibbes, vol. ៦, ការសម្រួលដោយ៖ លោក Alexander B. Grosart (Carlisle, PA: Banner of Truth, ឆ្នាំ១៩៨៣), ទំព័រ៥៦០។

## ជំពូកទី១០

# ការបណ្ដុះបណ្ដាលឲ្យមាន អ្នកដឹកនាំបន្ថែម

ព្រះគម្ពីរសញ្ញាថ្មីមានពេញដោយការណែនាំអំពីការបង្រៀនដល់អ្នកជឿទូទៅ។ ប៉ុន្តែ ព្រះគម្ពីរក៏ផ្ដោតលើការបណ្ដុះបណ្ដាលឲ្យមានអ្នកដឹកនាំនៅក្នុងក្រុមជំនុំបន្ថែមទៀត ជាពិសេសផងដែរ។ ឧទាហរណ៍៖ សាវ័ក ប៉ុល បានប្រាប់លោក ទីតុស ថា «ខ្ញុំបានទុកឲ្យអ្នកនៅកោះក្រេត ដើម្បីនឹងរៀបចំការដែលនៅខ្វះ ឲ្យស្រួលបួលឡើង ហើយនិងតាំងឲ្យមានពួកចាស់ទុំនៅគ្រប់ទាំងទីក្រុង» (ទីតុស ១:៥)។ បន្ទាប់មក គាត់បានរៀបរាប់អំពីលក្ខណសម្បត្តិដែលពួកចាស់ទុំទាំងនេះត្រូវមាន។ ស្រដៀងគ្នានេះដែរ គាត់បានមានប្រសាសន៍ប្រាប់លោក ធីម៉ូថេ ឲ្យស្វែងរក «មនុស្សស្មោះត្រង់ ដែលអាចនឹងបង្ហឹកបង្រៀនតទៅអ្នកឯទៀតដែរ» (២ធីម៉ូថេ ២:២)។

តាមរបៀបដូចគ្នានេះ ខ្ញុំចង់បញ្ចប់សៀវភៅនេះដោយផ្ដល់ជាយោបល់អំពីរបៀបដែលខ្ញុំបានធ្វើការដោយផ្ទាល់ ដើម្បីស្វែងរក ដើម្បីលើកទឹកចិត្ត និងដើម្បីបណ្ដុះបណ្ដាលឲ្យមានអ្នកដឹកនាំបន្ថែមទៀតនៅក្នុងក្រុមជំនុំរបស់ខ្ញុំ ទោះបីអ្នកទាំងនោះត្រូវបម្រើក្នុងក្រុមជំនុំរបស់ខ្ញុំ ឬនៅក្នុងក្រុមជំនុំផ្សេងទៀតនៅពេលក្រោយក៏ដោយ។ រឿងរ៉ាវជាច្រើនដែលបានពិភាក្សាខាងក្រោមនេះនឹងឆ្លើយតបជាមួយការអនុវត្ត ចំពោះការបង្កើតសិស្សឲ្យកាន់តែមានភាពទូលំទូលាយ។ លើសពីនេះទៅទៀត លក្ខណសម្បត្តិដែលបានបញ្ចូលក្នុងបញ្ជីនៃពួកចាស់ទុំនៅក្នុងកណ្ឌគម្ពីរទីតុស ជំពូក១ និង១ធីម៉ូថេ ជំពូក៣ គួរតែបានកំណត់លក្ខណសម្បត្តិសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូប (លើកលែងតែអ្នកដែលមិនមែនជាអ្នកទើបទទួលជឿព្រះ និងអ្នកដែលអាចបង្រៀនអ្នកដទៃបាន)។ គោលដៅនៃការបង្រៀនអ្នកជឿ និង

អនាគតអ្នកដឹកនាំក្រុមជំនុំភាគច្រើន គឺមានលក្ខណៈដូចគ្នា។ យើងស្វែងរកភាពចាស់ទុំនៅក្នុងព្រះគ្រីស្ទ។ ដូច្នេះ ខ្ញុំសង្ឃឹម និងជឿជាក់ថា ចំណុចខាងក្រោមទាំងនេះនឹងបានជាប្រយោជន៍សម្រាប់អ្នកអានគ្រប់រូប។

ទោះជាយ៉ាងនេះក្តី ខ្ញុំចង់ផ្តល់ទំនួលខុសត្រូវនេះលើពួកចាស់ទុំ ជាពិសេសទៅលើការគិតអំពីរបៀបនៃការបណ្តុះបណ្តាលឲ្យមានអ្នកដឹកនាំបន្ថែមទៀតនាពេលអនាគត។ នោះគឺជាកាតព្វកិច្ចជាពិសេសមួយរបស់លោកអ្នក។ លោក សាំយូអែល មីល័រ (Samuel Miller) ធ្លាប់បានសង្កេតឃើញថា៖

> «មិនថា លោកអ្នករស់នៅទីណាទេ ចូរព្យាយាមជានិច្ច ដើម្បីទទួលឥទ្ធិពល និងបន្តជះឥទ្ធិពលនោះទៅដល់បុរសដែលមានវ័យក្មេងជាងលោកអ្នក។ ពួកគេគឺជាក្តីសង្ឃឹមរបស់ក្រុមជំនុំ និងប្រទេសជាតិ ហើយអ្នកណាដែលបានក្លាយជាឧបករណ៍ក្នុងការជួយដាក់សេចក្តីទាំងនោះទៅក្នុងគំនិតរបស់ពួកគេ ដោយឲ្យប្រាជ្ញា ភាពបរិសុទ្ធ និងការគោរពប្រណិប័តន៍ព្រះអម្ចាស់ គឺជាអ្នកផ្តល់អត្ថប្រយោជន៍ដ៏អស្ចារ្យបំផុតដល់មនុស្សជាតិ។ ដូច្នេះ បុរសវ័យក្មេងសមនឹងទទួលបានការយកចិត្តទុកដាក់ និងភាពមិនចេះនឿយហត់របស់លោកអ្នកជាពិសេស....សរុបមក សូមប្រើវិធីសាស្ត្រនីមួយៗដែលគ្រីស្ទបរិស័ទមានក្នុងការតភ្ជាប់ទៅនឹងបុគ្គលម្នាក់ៗ និងព័ន្ធកិច្ចរបស់លោកអ្នក ហើយជំរុញពួកគេឲ្យចាប់អារម្មណ៍ក្នុងកិច្ចការនៃក្រុមជំនុំ»។[៧]

នេះជាជំហានទាំងប្រាំបួនសម្រាប់បណ្តុះបណ្តាលឲ្យមានអ្នកដឹកនាំក្រុមជំនុំបន្ថែម៖

## ១. បណ្តុះបណ្តាលអ្នកដទៃឲ្យមានគុណសម្បត្តិស្របតាមព្រះគម្ពីរសម្រាប់អ្នកដឹកនាំ

---

៧ លោក Samuel Miller, *Letters on Clerical Manners and Habits: To a Student in the Theological Seminary at Princeton*, N.J., Applewood's American Philosophy and Religion Series (Bedford, MA: Applewood Books, ឆ្នាំ១៨២៧), ទំព័រ៤០៦-៤០៧។

ការចាប់ផ្តើមនៃគុណសម្បត្តិនៃអ្នកត្រួតត្រានេះ គឺកើតមានឡើងជាមួយពាក្យទូន្មាន ដែលសាវ័ក ប៉ុល បានផ្តល់ដល់លោក ធីម៉ូថេ និងលោក ទីតុសៈ

> «ពាក្យនេះគួរជឿដែលថា បើអ្នកណាប្រាថ្នាចង់ធ្វើជាអ្នកត្រួតត្រា នោះឈ្មោះថា ចង់បានល្អប្រសើរហើយ។ ដូច្នេះ ត្រូវឲ្យអ្នកត្រួតត្រាប្រព្រឹត្ត ដោយឥតកន្លែងចាប់ទោសបានចុះ ត្រូវជាមនុស្សមានប្រពន្ធតែ១ ជាមនុស្សដឹងខ្នាត មានចិត្តធ្ងន់ធ្ងរ កាន់គំនិតមារយាទ ជាអ្នកចៅរ៉ៅ ហើយប្រសប់នឹងការបង្រៀន។ មិនត្រូវជាអ្នកចំណូលស្រា ឬឈ្លោះប្រកែក ឬស៊ីសំណូកឡើយ ត្រូវមានចិត្តស្លូតបូត ឥតរករឿងរកហេតុ ឥតលោភចង់បានប្រាក់។ ត្រូវត្រួតត្រាផ្ទះរបស់ខ្លួន ដោយស្រួលបួល ទាំងឲ្យកូនចៅស្តាប់បង្គាប់ដោយនឹងធឹង។ បើអ្នកណាមិនចេះត្រួតត្រាផ្ទះខ្លួន ធ្វើដូចម្តេចឲ្យថែរក្សាពួកជំនុំព្រះបាន។ មនុស្សណាដែលទើបនឹងជឿថ្មី នោះធ្វើពុំបានទេ ក្រែងកើតមានចិត្តធំ ហើយធ្លាក់ទៅក្នុងទោសរបស់អារក្សវិញ។ ត្រូវឲ្យអ្នកនោះមានឈ្មោះល្អពីអ្នកដទៃផង ក្រែងគេត្មះតិះដៀល ហើយធ្លាក់ទៅក្នុងអន្ទាក់របស់អារក្ស» (១ធីម៉ូថេ ៣:១-៧; ទីតុស ១:៦-៩)។

គុណធម៌ទាំងនេះមិនមានអ្វីអស្ចារ្យទេ។ ប៉ុន្តែ ដូចដែលខ្ញុំបានឮលោក ឌី.អេ. ខាសុន ធ្លាប់បានមានប្រសាសន៍ថា ពួកចាស់ទុំម្នាក់អាចធ្វើអ្វីដែលគ្រីស្ទបរិស័ទធម្មតាម្នាក់គួរធ្វើឲ្យបានល្អបំផុត។ គាត់គឺជាគំរូសម្រាប់ហ្វូងចៀមទាំងមូល។ គាត់គឺជារូបភាពមួយ ដើម្បីបង្ហាញពីភាពចាស់ទុំនៅក្នុងសេចក្តីជំនឿសម្រាប់ពួកគេទាំងអស់គ្នា។

ពេលខ្លះ ខ្ញុំបានសួរយុវជនថា តើពួកគេបានគិតអំពីការបម្រើក្នុងតួនាទីជាពួកចាស់ទុំដែរឬទេ? ហើយខ្ញុំបានសួរសំណួរនោះទៅកាន់ពួកគេ គឺកំឡុងពេលដំបូងនៃការបង្កើតសិស្សរបស់ពួកគេ ដោយខ្ញុំដឹងថា ពួកគេប្រហែលជាត្រូវការរយៈពេលជាច្រើនឆ្នាំទៀត ដើម្បីត្រៀមខ្លួន និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយជាពួកចាស់ទុំក្នុងក្រុមជំនុំ។ វាជារបៀបដែលខ្ញុំសួរ ដើម្បីឲ្យដឹងថា តើការបម្រើ និងបង្កើតក្រុមជំនុំគឺជាមហិច្ឆតាមួយក្នុងចំណោមមហិច្ឆតាផ្សេងទៀតរបស់ពួកគេឬទេ? ហើយបើពួកគេមិនមានមហិច្ឆតាបែបនេះទេ តើមកពីអ្វី? របៀបមួយ

ទៀតក្នុងការនិយាយគឺថា បញ្ជីនៃគុណសម្បត្តិរបស់ពួកចាស់ទុំដែលសាវ័ក ប៉ុល បានផ្ដល់ឲ្យនោះ គឺជាបញ្ជីល្អមួយក្នុងការបង្កើតសិស្សសម្រាប់គ្រីស្ទបរិស័ទគ្រប់រូប (លើកលែងតែគុណសម្បត្តិនៃការមានសមត្ថភាពក្នុងការបង្រៀន)។

ដូច្នេះ ខ្ញុំមិនជឿថា សាវ័ក ប៉ុល មានបំណងឲ្យបញ្ជីនៃគុណសម្បត្តិនេះពេញលេញសម្រាប់អ្វីដែលពួកចាស់ទុំគួរតែមាននោះទេ។ ឧទាហរណ៍៖ គាត់មិនបាននិយាយថា ពួកចាស់ទុំ «ត្រូវតែជាអ្នកមានភាពស្មោះត្រង់ក្នុងការអានព្រះគម្ពីរ» ឬ «ជាអ្នកអធិស្ឋាន» នោះឡើយ ទោះបីជាខ្ញុំគិតថា ពួកចាស់ទុំគ្រប់រូបគួរតែមានលក្ខណសម្បត្តិទាំងពីរនេះក៏ដោយ។ ជាទូទៅ នៅពេលយើងនិយាយអំពីការបណ្ដុះបណ្ដាលអ្នកដឹកនាំបន្ថែម ជាពិសេសគឺបុរសៗដែលក្រុមជំនុំនឹងគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការក្លាយជាអ្នកចាស់ទុំ ឬក៏គ្រូគង្វាលនោះ ខ្ញុំគិតថា យើងក៏គួរតែស្វែងរកអស់អ្នកដែលមានអំណោយទាននៃភាពជាអ្នកដឹកនាំផងដែរ។ ខ្ញុំចង់ផ្សព្វផ្សាយ និងផ្ដល់ជាចំណេះដឹងដល់អស់អ្នកដែលអាចជួយជំរុញដល់ជំនឿគ្រីស្ទបរិស័ទទៅកាន់កន្លែងដែលខ្ញុំមិនធ្លាប់បានទៅ៖ ជាកន្លែងនាពេលអនាគតហួសពីពេលដែលខ្ញុំស្លាប់បាត់ទៅ។

តើនេះមានន័យថា ខ្ញុំកំពុងបំពានកណ្ឌគម្ពីរ យ៉ាកុប ២:១ ហើយកំពុងមានមនុស្សដែលខ្ញុំចូលចិត្តនៅក្នុងក្រុមជំនុំមែនឬ? ខ្ញុំមិនបានគិតបែបដូច្នេះទេ។ លោក យ៉ាកុប បានខ្វល់ខ្វាយនឹងភាពខុសឆ្គងនៃការលម្អៀងរវាងអ្នកមាន និងអ្នកក្រ។ ប៉ុន្តែ ទោះបើការវែកញែកបែបនោះមិនត្រឹមត្រូវក៏ដោយ ក៏នេះមិនមែនមានន័យថា គ្រប់ការលម្អៀងទាំងអស់គឺសុទ្ធតែខុសនោះទេ។ សូមចាំថា សាវ័ក ប៉ុល បានប្រាប់លោក ធីម៉ូថេ ឲ្យស្វែងរក «មនុស្សស្មោះត្រង់» ដែលអាច «នឹងបង្វឹកបង្រៀនតទៅអ្នកឯទៀតដែរ» ព្រមទាំងអ្នកណាដែលមាន «ប្រាថ្នាចង់ធ្វើជាអ្នកត្រួតត្រា»។ មនុស្សម្នាក់អាចមានការប៉ងប្រាថ្នាដែលមានហេតុផលមិនត្រឹមត្រូវ ប៉ុន្តែអ្នកណាដែលមិនប្រាថ្នាអ្វីទាំងអស់ នោះមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយជាអ្នកត្រួតត្រាបាននោះទេ។

ទីបំផុត លោកអ្នកចង់បង្រៀនមនុស្សឲ្យមានលក្ខណសម្បត្តិដោយយោងតាមការពណ៌នានៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ជំពូក៣។ នោះហើយគឺជាមូលដ្ឋានគ្រឹះ

របស់លោកអ្នក។ ហើយនឹងមានមនុស្សខ្លះដែលនឹងបង្ហាញអំពីការមានអំណោយទានបែបនោះដោយមានភាពងាយស្រួល ហើយយើងអាចឃើញការនេះបាននៅពេលដែលមានអ្នកដើរតាមគាត់។ បើលោកអ្នកឃើញមានមនុស្សបែបនេះ លោកអ្នកគួររកឱកាសឲ្យគាត់អនុវត្តក្នុងការដឹកនាំ។

## ២. សូមព្យាយាមមានទម្លាប់រកមើលអ្នកដឹកនាំនាពេលអនាគត

បើសិនលោកអ្នកចង់បណ្ដុះបណ្ដាលឲ្យមានអ្នកដឹកនាំបន្ថែម នោះលោកអ្នកត្រូវតែស្វែងរកអ្នកដឹកនាំបន្ថែមទៀតជានិច្ច។ នេះគួរតែជាផ្នត់គំនិតរបស់លោកអ្នក ជាពិសេសប្រសិនបើលោកអ្នកជាពួកចាស់ទុំម្នាក់នៅក្នុងក្រុមជំនុំ។

គ្រូគង្វាលគួរតែស្វែងរកឱកាសបណ្ដុះបណ្ដាលឲ្យមានគ្រូគង្វាលបន្ថែមទៀត។ ហើយក្រុមជំនុំទាំងមូលគួរមានទំនុកចិត្តយ៉ាងពេញលេញថា ព្រះអម្ចាស់ចង់ឲ្យមានការបណ្ដុះបណ្ដាលសម្រាប់អ្នកដឹកនាំថ្មីៗបន្ថែមទៀតសម្រាប់ក្រុមជំនុំ។

ភ្នែករបស់ខ្ញុំកំពុងបើកសម្លឹងរកមើលវិធីជាច្រើន។ ខ្ញុំកំពុងសម្លឹងមើលនៅក្នុងពួកជំនុំ និងកំពុងប្រាស្រ័យទាក់ទងជាមួយពួកគាត់ដែរ។ ខ្ញុំបានឈរនៅមាត់ទ្វារព្រះវិហារបន្ទាប់ពីការថ្វាយបង្គំនៅថ្ងៃអាទិត្យ ហើយខ្ញុំបានកត់សម្គាល់មើលថាអ្នកណាខ្លះបាននិយាយអ្វីខ្លះ ឬក៏អ្នកណាកំពុងមានប្រាស្រ័យទាក់ទងជាមួយអ្នកណា។ ខ្ញុំធ្វើបែបនេះ គឺដើម្បីផ្ដល់ឱកាសជាច្រើនសម្រាប់ការបង្រៀននៅក្នុងជីវិតប្រចាំសប្ដាហ៍នៃក្រុមជំនុំរបស់យើង ហើយគ្រូដែលមានអំណោយទានក្នុងការបង្រៀនក៏អាចបង្ហាញមុខមកឲ្យពួកយើងស្គាល់ផងដែរ។ ខ្ញុំតែងតែអធិស្ឋានជារៀងរាល់ថ្ងៃ ដោយប្រើប្រាស់បញ្ជីសមាជិកភាពនៃក្រុមជំនុំរបស់ខ្ញុំ ដើម្បីអធិស្ឋានឲ្យពួកគាត់ ហើយការធ្វើបែបនោះក៏អាចនាំមនុស្សណាម្នាក់ចូលមកក្នុងគំនិតរបស់ខ្ញុំបានដែរ។

## ៣. ចំណាយពេលវេលាផ្ទាល់ខ្លួនជាមួយពួកគេ

ការចំណាយពេលជាមួយមនុស្សនៅជុំវិញយើង គឺជាផ្នែកមួយដ៏សំខាន់ក្នុងការ

បណ្ដុះបណ្ដាលឲ្យមានអ្នកដឹកនាំបន្ថែម។ នៅក្នុងផ្នែកដំបូងនៃសៀវភៅនេះ ខ្ញុំបាននិយាយអំពីការដែលព្រះយេស៊ូវបានត្រាស់ហៅពួកសិស្សឲ្យឡើងលើភ្នំជាមួយទ្រង់ ដើម្បីឲ្យពួកគេអាច «ចំណាយពេលជាមួយទ្រង់» បាន។

គួរឲ្យសោកស្ដាយណាស់ ខ្ញុំបានឃើញគ្រូគង្វាលមួយចំនួនបានសង់ជញ្ជាំងយ៉ាងរឹងមាំនៅជុំវិញខ្លួនរបស់ពួកគាត់។ អ្នកទាំងនោះមិនមែនជាអ្នកដែលនឹងបង្កើតឲ្យមានអ្នកដឹកនាំបន្ថែមទៀតនោះទេ ដោយពួកគេយ៉ាងហោចណាស់មិនបានចំណាយពេលដោយផ្ទាល់។ ខ្ញុំមិនបាននិយាយថា លោកអ្នកចាំបាច់ត្រូវធ្វើជាមនុស្សរួសរាយរាក់ទាក់នោះទេ ប៉ុន្តែគ្រូគង្វាលត្រូវរកវិធីចំណាយពេលជាមួយអ្នកដឹកនាំដែលមានសក្ដានុពលផ្សេងទៀតនៅក្នុងក្រុមជំនុំរបស់ពួកគាត់។ នៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ជំពូក១៣ បានដាស់តឿនក្រុមជំនុំឲ្យធ្វើតាមគំរូរបស់អ្នកនាំមុខ។ តើពួកគេអាចធ្វើបែបនេះបានដោយរបៀបណា បើពួកគេមិនស្គាល់អ្នកដឹកនាំរបស់ខ្លួនផង? សាវ័ក ប៉ុល បានទូន្មានឲ្យយើងធ្វើត្រាប់តាមគាត់ ដែលតម្រូវឲ្យធ្វើដូច្នេះបាន—គឺការចំណាយពេលវេលាជាមួយអ្នកនៅក្នុងក្រុមជំនុំយើង។

ដូច្នេះ គ្រូគង្វាលត្រូវចំណាយពេលជាមួយយុវជននៅក្នុងក្រុមជំនុំរបស់ពួកគាត់។ ការចំណាយពេលទទួលទានអាហារជាមួយគ្នាគឺជាការសំខាន់មួយ។ ជួនកាល ប្រពន្ធខ្ញុំបានសុំឲ្យខ្ញុំទៅទិញគ្រឿងទេសនៅផ្សារ ហើយខ្ញុំតែងតែយកឱកាសនោះ ដើម្បីហៅប្អូនប្រុសណាម្នាក់ទៅជាមួយគ្នា។ ការធ្វើបែបនេះ យើងអាចចំណាយពេលជាមួយគ្នាដោយមានគោលបំណង។ ខ្ញុំអញ្ជើញអ្នកដទៃនៅពេលដែលខ្ញុំកំពុងរៀបចំសេចក្ដីអធិប្បាយដែរ។ ខ្ញុំធ្វើការនោះដោយចំណាយពេលទទួលទានអាហារថ្ងៃត្រង់ជាមួយអ្នកដឹកនាំវ័យក្មេង ដើម្បីឲ្យយើងអាចចំណាយពេលជាមួយគ្នាពិភាក្សាអំពីរបៀបដែលយើងអនុវត្តខគម្ពីរនៅក្នុងសេចក្ដីអធិប្បាយរបស់ខ្ញុំ។ ខ្ញុំក៏អញ្ជើញឲ្យគាត់មកចំណាយពេលជាមួយខ្ញុំនៅយប់ថ្ងៃសៅរ៍ ដើម្បីអាន និងពិភាក្សាអំពីសេចក្ដីអធិប្បាយដែលខ្ញុំបានត្រៀមទុកសម្រាប់ថ្ងៃអាទិត្យ។ ការជួបជុំគ្នាទាំងនេះមិនត្រឹមតែធ្វើឲ្យសេចក្ដីអធិប្បាយរបស់ខ្ញុំប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំក៏អាចកាន់តែយល់អំពីទឹកចិត្តរបស់បុរសទាំងនោះ ហើយខ្ញុំក៏អាចលើកទឹកចិត្តដល់ពួកគាត់ផងដែរ។

ទាំងអស់នេះ ត្រូវបានរចនាឡើងនៅជុំវិញខ្ញុំ ឧទាហរណ៍៖ ការងាររបស់ខ្ញុំ និងនៅក្នុងកាលវិភាគប្រចាំថ្ងៃរបស់ខ្ញុំ។ សូមសម្លឹងរកមើលថា តើកាលវិភាគណាដែលមានដំណើរការសម្រាប់លោកអ្នក ហើយសូមទាញបញ្ចូលការបង្កើតសិស្សនៅក្នុងនោះ។

## ៤. ដាក់ទំនុកចិត្តលើអនាគតអ្នកដឹកនាំរបស់លោកអ្នក

ប្រសិនបើលោកអ្នកចង់ឃើញ ការបណ្តុះបណ្តាលឲ្យមានអ្នកដឹកនាំបន្ថែមទៀត នោះឥរិយាបថទូទៅរបស់លោកអ្នកគួរតែត្រូវបានកំណត់ដោយឆន្ទៈមានការជឿទុកចិត្តលើពួកគាត់។ ដោយសារខ្ញុំបានរស់នៅកន្លែងផ្សេងៗគ្នា និងការធ្វើដំណើរជាច្រើន នោះខ្ញុំដឹងថា ទំនុកចិត្តរបស់គ្រូគង្វាលលើអ្នកដឹកនាំវ័យក្មេងម្នាក់ក៏អាចប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយដែរ។ ប៉ុន្តែ ខ្ញុំគិតថា វាគឺជាលក្ខណសម្បត្តិដ៏មានតម្លៃមួយនៃការស្រឡាញ់៖ សេចក្តីស្រឡាញ់ជឿទាំងអស់ សង្ឃឹមទាំងអស់ (១កូរិនថូស ១៣:៧)។ លោកអ្នកប្រហែលជាមានសមាជិកនៃក្រុមជំនុំ ដែលព្រះអម្ចាស់បានប្រគល់ឲ្យនូវអំណោយទានដ៏ពូកែដល់ពួកគេ។ ប៉ុន្តែ ដើម្បីរកឲ្យឃើញការជឿទុកចិត្តនោះបាន នោះគឺត្រូវមានអ្នកណាម្នាក់ត្រូវជឿទុកចិត្តលើពួកគេជាមុនសិន។ ហើយអ្នកដឹកនាំល្អត្រូវតែធ្វើបែបដូច្នេះ។ ពួកគាត់មិនត្រូវរង់ចាំឲ្យអ្នកណាម្នាក់កំណត់សមត្ថភាព និងបន្ទាប់មក ទើបត្រូវផ្តល់ឱកាសនៃការបង្រៀនដល់ពួកគេឡើយ។ ទេ! ពួកគាត់ឃើញតម្រុយអ្វីមួយ ហើយជាមួយនឹងការលើកទឹកចិត្តបន្តិចបន្តួច នោះវាអាចនឹងមានការលូតលាស់ និងភាពរីកចម្រើនបាន។ ដូច្នេះ ពួកគាត់ជឿទុកចិត្តជាមុន ហើយទុកឱកាសឲ្យសិស្សវ័យក្មេងចំណាយពេលរបស់ពួកគេ ដើម្បីធ្វើកិច្ចការនេះ!

ទោះបីជាមានការជំរុញទឹកចិត្តដ៏ល្អបំផុត ក៏នៅមានអ្នកដឹកនាំជាច្រើន អាចមានការប្រុងប្រយ័ត្នខ្លាំងពេកទាក់ទងនឹងចំណុចនេះ។ ជួនកាល ខ្ញុំបានឃើញគ្រូគង្វាលរៀមច្បងខ្លះមិនគាំទ្រភាពជាអ្នកដឹកនាំរបស់អ្នកណាម្នាក់បានឡើយ។ ខ្ញុំក៏ធ្លាប់បានឃើញបុរសៗដែលបានឡើងជណ្តើរនៃការក្លាយជាអ្នកដឹកនាំ ហើយនៅពេលដែលពួកគាត់បានទៅដល់ខាងលើ ពួកគាត់ក៏ដកជណ្តើរនោះចេញដែរ

ដើម្បីកុំឲ្យនរណាម្នាក់អាចឡើងបាន។ ពួកគាត់តម្រូវឲ្យមានលក្ខខណ្ឌជាច្រើនពីអ្នកដឹកនាំនៅថ្ងៃអនាគត ច្រើនជាងដែលអ្នកផ្សេងទៀតបានទាមទារពីពួកគាត់ទៅទៀត! ទោះបើអាចមានគ្រោះថ្នាក់ខ្លះៗក្នុងការមានអ្នកដឹកនាំផងក៏ដោយក៏វានៅមានតម្លៃដែរ។ ព្រះគ្រីស្ទនឹងតាំងពួកជំនុំរបស់ទ្រង់ឡើង។ ព្រះអម្ចាស់មានពេញដោយអធិបតេយ្យភាព។ ដូច្នេះ យើងគួរមានចិត្តឲ្យឱកាសដល់អ្នកដឹកនាំថ្មីក្នុងការបម្រើដូចគ្នាដែរ។

ពួកជំនុំក៏មានតួនាទីរបស់ខ្លួនដែរ គឺត្រូវមានភាពអត់ធ្មត់ជាមួយបុរសវ័យក្មេងក្នុងការដឹកនាំ ខណៈពេលដែលពួកគាត់ធ្វើខុស ដោយសារនោះជារឿងធម្មតាសម្រាប់បុរសវ័យក្មេង។ ជាញឹកញយ ខ្ញុំបានប្រាប់ដល់ពួកជំនុំថា សូមកុំឲ្យមានការភ័យខ្លាចក្នុងការអនុញ្ញាតឲ្យអនាគតអ្នកដឹកនាំនៅមានឱកាសបម្រើឡើយ។ គាត់ប្រៀបដូចជាកូនគោតូចមួយដែលអាចនឹងបង្កើតឲ្យមានស្នាមឆ្កូតលើកម្រាលឥដ្ឋ ឬខូចគ្រឿងសង្ហារិម ប៉ុន្តែបើអ្នកមានភាពអត់ធ្មត់នឹងគាត់ នោះគាត់នឹងអាចក្លាយដូចជាសត្វគោមួយដែលមានពេញទៅដោយប្រាជ្ញា និងកម្លាំងដែលស្រឡាញ់ និងការពារក្រុមជំនុំរបស់អ្នកអស់មួយជីវិតគាត់។

## ៥. ចែកចាយទំនួលខុសត្រូវជាមួយអ្នកដែលនឹងក្លាយជាអ្នកដឹកនាំនៅអនាគត

ចំណុចនេះត្រូវបានភ្ជាប់ទៅនឹងចំណុចចុងក្រោយ។ តើលោកអ្នកអាចទុកចិត្តចំពោះអ្នកដឹកនាំថ្មីជាមុនបានដោយរបៀបណា? ដោយការផ្ទេរទំនួលខុសត្រូវ និងការឲ្យឱកាសដល់ពួកគាត់ក្នុងការដឹកនាំ។ ខ្ញុំមានបីផ្នែកអំពីចំណុចមួយនេះ៖

*ក. ការផ្តល់ឱកាសឲ្យពួកគាត់ដឹកនាំ។* សូមរក្សាបញ្ជីឈ្មោះបុរសៗមួយចំនួននៅក្នុងក្រុមជំនុំរបស់លោកអ្នកដោយស្ងៀមស្ងាត់ដែលលោកអ្នកគិតថា គួរផ្តល់ឱកាសឲ្យបង្រៀន ឬក៏ដឹកនាំកម្មវិធីអធិស្ឋាននៅក្នុងវេនថ្វាយបង្គំ ឬដឹកនាំការថ្វាយបង្គំ ឬក៏ធ្វើជាគ្រូបង្រៀនកុមារថ្នាក់ថ្ងៃអាទិត្យ។ សូមធ្វើការសាកល្បងសមត្ថភាពពួកគេ ដោយការផ្ទេរទំនួលខុសត្រូវនោះដល់ពួកគេ។ ជាថ្មីម្តងទៀត ខ្ញុំទទួលស្គាល់ថា គ្រូគង្វាលមួយចំនួនមានអារម្មណ៍ថា ពួកគាត់មានការការពារយ៉ាងខ្លាំងចំពោះ

ហ្វូងចៀមរបស់គាត់៖ «ព្រះវិញ្ញាណបរិសុទ្ធបានតាំង [ខ្ញុំ] ឲ្យធ្វើជាអ្នកគង្វាលដល់គេ» (កិច្ចការ ២០:២៨)។ មកដល់ចំណុចនេះ គឺខ្ញុំចង់និយាយថា «លោកគ្រូគង្វាលជាទីគោរពស្រឡាញ់អើយ! នឹងមានថ្ងៃមួយមកដល់ដែលលោកគ្រូនឹងស្លាប់ទៅ ហើយក្រុមជំនុំក៏នឹងមិនអីដែរទោះបីជាគ្មានលោកគ្រូ! ហើយលោកគ្រូគួរតែចង់ឲ្យក្រុមជំនុំកាន់តែល្អប្រសើរឡើងបន្ថែមទៀត ដោយការប្រលែងកិច្ចការបន្តិចបន្តួច និងរៀបចំអ្នកដឹកនាំផ្សេងទៀតដោយការផ្ទេរទំនួលខុសត្រូវដល់ពួកគេក្នុងការត្រៀមខ្លួនធ្វើជាអ្នកបន្តតំណែងទៅមុខទៀត។ គោលដៅរបស់លោកគ្រូ គឺមិនមែនដើម្បីកសាងនគររបស់លោកគ្រូផ្ទាល់នោះទេ លោកគ្រូត្រូវប្រគល់អំណាចដោយផ្ដល់ឱកាសឲ្យអ្នកដទៃដឹកនាំ និងបង្រៀនបន្តពីលោកគ្រូ»។

*ខ. ត្រៀមខ្លួនបាត់បង់សម្លេងឆ្នោត និងការជជែកវែកញែក។* ការផ្ទេរសិទ្ធិអំណាចមានន័យថា ជាការប្រគល់សិទ្ធិនៃការគ្រប់គ្រងក្នុងកម្រិតណាមួយ ហើយប្រសិនបើលោកអ្នកមានឆន្ទៈក្នុងការធ្វើបែបនោះ គឺលោកអ្នកត្រូវមានឆន្ទៈចំពោះការបាត់បង់សម្លេងឆ្នោត នៅពេលមានការបោះឆ្នោតពេលកំពុងប្រជុំគ្នាផងដែរ។ ហើយលោកអ្នកក៏ត្រូវមានឆន្ទៈបោះបង់ចោលការសម្រេចចិត្តចុងក្រោយដែរ។ មិនមែនអ្វីៗទាំងអស់ត្រូវតែដើរតាមផ្លូវស្របតាមការគិតរបស់លោកអ្នកនោះទេ។ បើលោកអ្នកមិនអនុញ្ញាតឲ្យមានអ្នកដឹកនាំផ្ទុយពីគំនិតរបស់លោកអ្នកទេ នោះលោកអ្នកពុំបានអនុញ្ញាតឲ្យពួកគេដឹកនាំនៅឡើយទេ! ដូច្នេះ ជាការពិតណាស់! លោកអ្នកប្រហែលជាមានការខកចិត្ត ដោយសារ «ការចាញ់សម្លេងឆ្នោត» ក្នុងរឿងនេះ ឬរឿងនោះ ខណៈពេលកំពុងប្រជុំគ្នា។ ប៉ុន្តែ តាមរយៈការនេះ លោកអ្នកនឹងទទួលបានការវិនិយោគដ៏យូរអង្វែង ទាក់ទងទៅនឹងការលើកទឹកចិត្តដល់អ្នកដឹកនាំផ្សេងទៀតឲ្យដឹកនាំ (លើសពីនេះ ការប្រទានពរដល់ក្រុមជំនុំតាមរយៈអំណោយទាននៃប្រាជ្ញារបស់ពួកគេ)។

*គ. ការបណ្ដុះការគោរពចំពោះអ្នកដឹកនាំផ្សេងទៀត។* កាលពីប៉ុន្មានឆ្នាំមុន ជំនួយការគ្រូគង្វាលរបស់យើង និងខ្ញុំបានឈរនៅលើវេទិកាខាងមុខពួកជំនុំ មុនពេលចាប់ផ្ដើមសិក្សាព្រះគម្ពីរ។ គាត់ហៀបនឹងដឹកនាំការសិក្សាព្រះគម្ពីរពេលនោះ។ កំឡុងពេលដែលពួកយើងបាននិយាយលេងជាមួយគ្នានោះ ខ្ញុំបានប៉ះក្បាលរបស់

គាត់ (គាត់ទាបជាងខ្ញុំ)។ ភ្លាមៗនោះ គាត់បាននាំខ្ញុំទៅជ្រុងម្ខាង ហើយគាត់បាននិយាយដោយពាក្យទន់ភ្លន់ ប៉ុន្តែយ៉ាងម៉ឺងម៉ាត់ថា "ម៉ាក (Mark) ឈប់ធ្វើបែបនេះទៀត។ អ្នកមិនអាចប្រព្រឹត្តដាក់ខ្ញុំដូច្នេះនៅពីមុខពួកជំនុំទេ បើសិនអ្នកចង់ឲ្យពួកគេគោរពខ្ញុំ"។ នៅពេលគាត់និយាយពាក្យនេះមកកាន់ខ្ញុំ វាហាក់ដូចជាឲ្យខ្ញុំយល់បានកាន់តែច្បាស់ណាស់។ ពិតប្រាកដណាស់! ខ្ញុំត្រូវប្រព្រឹត្តនឹងគាត់ទុកដូចជាអ្នកដឹកនាំម្នាក់ជាសាធារណៈ ហើយជំរុញឲ្យមានការបណ្តុះការគោរពចំពោះគាត់ក្នុងពួកជំនុំដែរ។

## ៦. ការផ្តល់មតិយោបល់កែលម្អដល់អ្នកដឹកនាំជំនាន់ក្រោយ

នៅពេលដែលលោកអ្នកផ្ទេរទំនួលខុសត្រូវដល់អ្នកដែលនឹងក្លាយជាអ្នកដឹកនាំនៅពេលអនាគត និងផ្តល់ឱកាសឲ្យពួកគេក្នុងការបម្រើ នោះលោកអ្នកក៏ត្រូវបង្កើតឲ្យមានរចនាសម្ព័ន្ធសម្រាប់ការផ្តល់យោបល់កែលម្អដល់អ្នកនោះផងដែរ។ ជាការចាប់ផ្តើម គឺលោកអ្នកចាប់ផ្តើមដោយបង្ហាញថា លោកអ្នកកំពុងបង្រៀនដល់ពួកគេអំពីរបៀបផ្តល់ឲ្យ និងទទួលមតិរិះគន់ដូចព្រះអង្គធ្វើដែរ។ សូមមានភាពស្មោះត្រង់ និងភាពស្លូតបូតជាមួយបងប្អូនទាំងនោះក្នុងការប្រាប់អំពីអ្វីដែលពួកគេអាចកែលម្អបាន។

ពួកគេនឹងទទួលមតិរិះគន់របស់លោកអ្នកដោយមានការបើកចិត្ត ប្រសិនបើពួកគេឃើញថា លោកអ្នកជាគំរូម្នាក់ដែលមានសមត្ថភាពក្នុងការទទួលមតិរិះគន់ផងដែរ។ ទោះបើខ្ញុំបានបរាជ័យពេលខ្លះក៏ដោយ ក៏ខ្ញុំបានព្យាយាមទទួលមតិរិះគន់ពីអ្នកដទៃ ដោយខ្ញុំពុំបានផ្តល់ចម្លើយឆ្លើយតបវិញនោះទេ ទោះបីជាខ្ញុំមិនយល់ស្របនឹងមតិរិះគន់ទាំងនោះ។ (ចំពោះរឿងនេះ ខ្ញុំមានករណីលើកលែងតែមួយ គឺប្រសិនបើខ្ញុំគិតថា មតិរិះគន់នោះអាចមានការបំភាន់ដល់អ្នកដទៃ)។ ប៉ុន្តែ ប្រសិនបើខ្ញុំតែងតែបដិសេធនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា ដែលយុវជនម្នាក់បានផ្តល់ដល់ខ្ញុំ ជាពិសេសបន្ទាប់ពីខ្ញុំបានអញ្ជើញឲ្យគាត់បានផ្តល់មតិកែលម្អ នោះគាត់នឹងដឹងភ្លាមៗថា វាជាកិច្ចការដែលគ្មានប្រយោជន៍ (និងអាម៉ាស់) សម្រាប់គាត់ក្នុងការផ្តល់ជូនយោបល់ស្មោះត្រង់មកដល់ខ្ញុំ។ ហើយវានឹងបង្ហាញថា

វាមានប្រយោជន៍តិចតួចបំផុតសម្រាប់ខ្ញុំ! វាតែងតែមានចំណុចខ្វះខាតក្នុងព័ន្ធកិច្ចរបស់ខ្ញុំ ដែលខ្ញុំត្រូវធ្វើការកែលម្អឲ្យកាន់តែប្រសើរឡើង។ មតិកែលម្អដែលខ្ញុំបានទទួលអស់រយៈពេលម្ភៃឆ្នាំមកនេះ បានជួយខ្ញុំយ៉ាងខ្លាំងក្នុងការបម្រើក្នុងក្រុមជំនុំឲ្យកាន់តែប្រសើរជាងមុន។

បន្ថែមពីលើការធ្វើគំរូនៃការផ្ដល់ និងការទទួលមតិរិះគន់ដូចព្រះអង្គធ្វើដែរ យើងក៏ត្រូវធ្វើជាគំរូនៃការលើកទឹកចិត្តនិងការទទួលមតិរិះគន់ដូចព្រះអង្គធ្វើផងដែរ។ សាវ័ក ប៉ុល មានរឿងជាច្រើន ដែលត្រូវផ្ដល់មតិរិះគន់ទៅកាន់ក្រុមជំនុំនៅក្រុងកូរិនថូស ប៉ុន្តែគាត់បានសរសេរនៅដើមសំបុត្ររបស់គាត់ ដោយការអរព្រះគុណដល់ព្រះសម្រាប់ពួកគេ «ព្រោះអ្នករាល់គ្នាបានចម្រើនឡើងគ្រប់ជំពូក ដោយសារទ្រង់ គឺក្នុងគ្រប់ទាំងពាក្យសម្ដី និងចំណេះទាំងអស់ដែរ ដល់ម្ល៉េះបានជាអ្នករាល់គ្នាមិនចាញ់គេ ខាងអំណោយទានណាមួយឡើយ» (១កូរិនថូស ១:៥, ៧)។ ខ្ញុំពុំបានគិតថា សាវ័ក ប៉ុល បានមានប្រសាសន៍សរសើរដល់ពួកជំនុំនៅក្រុងកូរិនថូសនោះទេ។ ខ្ញុំគិតថា គាត់បានទទួលស្គាល់យ៉ាងត្រឹមត្រូវនូវអ្វីដែលព្រះបានធ្វើសម្រាប់ពួកគេ។ តើយើងមិនគួរទទួលស្គាល់ភស្តុតាងនៃព្រះគុណនៅក្នុងជីវិតរបស់យើងរាល់គ្នាទេឬអី? ការលើកទឹកចិត្តដល់អ្នកដែលនឹងក្លាយជាអ្នកដឹកនាំនាពេលអនាគតគឺគួរធ្វើឡើង ដើម្បីបង្រៀនពួកគេឲ្យសរសើរតម្កើងដល់ព្រះ។

ជាច្រើនដងមកហើយ ខ្ញុំបានឃើញបុរសៗ ជាពិសេសបុរសដែលមានវ័យក្មេងជាងបានផ្ដល់យោបល់ថា ការធ្វើជាអ្នកដឹកនាំពិតប្រាកដគឺជាការបង្ហាញអំពីការកែតម្រូវដល់អ្នកដទៃឥតឈប់ឈរ។ ដូច្នេះហើយ បានជាក្នុងសេចក្ដីអធិប្បាយរបស់អ្នកដែលមានវ័យក្មេងជាង គឺជាញឹកញយមានការស្ដីបន្ទោសដល់ក្រុមជំនុំ។ អ្វីដែលពួកគេមិនបានគិតឃើញនោះគឺថា ជាញឹកញយលោកអ្នកអាចសម្រេចកិច្ចការបានកាន់តែច្រើន តាមរយៈការលើកទឹកចិត្ត។ មានពេលវេលាសម្រាប់ស្ដីបន្ទោសដែរ។ ប៉ុន្តែ ពី៨០ទៅ៩០ភាគរយនៃអ្វីដែលលោកអ្នកសង្ឃឹមថា នឹងត្រូវបានកែតម្រូវអាចសម្រេចបានតាមរយៈការលើកទឹកចិត្ត។ ប្រសិនបើ លោកអ្នកក្រឡេកមើលទៅជីវិតរបស់លោកអ្នកវិញ ហើយពិចារណាថា តើអ្នកណាបានផ្ដល់ឥទ្ធិពលខ្លាំងបំផុតដល់លោកអ្នក នោះទំនងជាលោកអ្នកដឹងថា គឺអស់អ្នកដែល

មានការជឿជាក់លើលោកអ្នក។ លោក ហេនរី ដ្រាំមម៉ុន (Henry Drummond) ធ្លាប់បានសង្កេតឃើញថា៖ «បើលោកអ្នកគិតមួយភ្លែត នោះលោកអ្នកនឹងឃើញថា មនុស្សដែលមានឥទ្ធិពលលើលោកអ្នក គឺជាមនុស្សដែលមានការជឿជាក់លើលោកអ្នក។ នៅក្នុងបរិយាកាសនៃការសង្ស័យគ្នា គឺមានសភាពស្លេកស្លាំង ប៉ុន្តែតាមរយៈការលើកទឹកចិត្ត នោះពួកគេបានរីកចម្រើនឡើង ហើយក៏នឹងស្វែងរកការលើកទឹកចិត្ត និងការប្រកបគ្នាដែលនឹងជួយឲ្យពួកគាត់កាន់តែរៀនបានថែមទៀត»។[៨]

នៅពេលដែលខ្ញុំបានសង្កេតឃើញថា បុរសៗដែលខ្ញុំកំពុងបង្រៀនបានផ្តល់ការលើកទឹកចិត្ត និងមតិរិះគន់មកកាន់ខ្ញុំ ឬទៅកាន់គ្នាទៅវិញទៅមក នោះខ្ញុំរៀនបានច្រើនអំពីពួកគេ ដោយពួកគេកំពុងបញ្ចេញមតិយោបល់នោះតាមរយៈអ្វីដែលខ្ញុំបានធ្វើ។ (វាប្រៀបដូចជាការឈរក្នុងសាលសិល្បៈមួយ ដោយមិនបានសម្លឹងមើលផ្ទាំងគំនូរនៅក្នុងសាលនោះ ប៉ុន្តែគ្រាន់តែឈរនៅចំពោះមនុស្សដែលកំពុងសង្កេតមើលផ្ទាំងគំនូរទាំងនោះប៉ុណ្ណោះ)។ ខ្ញុំឃើញថា ពួកគាត់មានចំណាប់អារម្មណ៍លើអ្វី ហើយថាតើពួកគាត់ចង់ផ្តោតទៅលើអ្វី។ ប្រសិនបើលោកអ្នកដែលជាគ្រូគង្វាលផ្តល់ឱកាសក្នុងការបញ្ចេញមតិយោបល់ ការនោះនឹងជួយឲ្យមានការបង្រៀនកើតឡើងដែរ។

## ៧. ការលើកទឹកចិត្តអំពីការកាន់អំណាចដែលចេះកោតខ្លាចដល់ព្រះជាម្ចាស់

ជាញឹកញយ មនុស្សបច្ចុប្បន្ននេះពុំបានយល់អំពីអ្វីដែលជាអំណោយទាននៃការមានអំណាចដែលចេះកោតខ្លាចដល់ព្រះនោះទេ។ ការបណ្តុះបណ្តាលឲ្យមានអ្នកដឹកនាំបន្ថែមតម្រូវឲ្យយើងបង្រៀនពីអំណាចនៃការគោរពកោតខ្លាចដល់ព្រះ និងការលើកទឹកចិត្តដោយអំណាចនោះដែរ។ ពិតណាស់ ព្រះយេស៊ូវបានបង្រៀន

---

៨ លោក Henry Drummond, The Greatest Thing in the World and Other Addresses (London: Hodder and Stoughton, ឆ្នាំ១៩៥៩), ទំព័រ៣៦។

សិស្សទ្រង់អំពីការប្រើអំណាចនោះឲ្យបានត្រឹមត្រូវ (ម៉ាថាយ ២០:២៥-២៧)។

លោកីយ៍ដែលធ្លាក់ក្នុងអំពើបាបនេះ វាបាននាំឲ្យមានការប្រើប្រាស់អំណាចក្នុងរបៀបមិនត្រឹមត្រូវ ហើយក៏បានកុហកភូតភរពីអំណាចដែលត្រឹមត្រូវផងដែរ។ ការកុហកជាមូលដ្ឋានរបស់សាតាំងទៅកាន់លោក អ័ដាម និងនាង អេវ៉ា គឺថា ព្រះពិតជាមិនអាចស្រឡាញ់ពួកគេទេ ប្រសិនបើព្រះអង្គមិនអនុញ្ញាតឲ្យពួកគេមានអ្វីមួយ។

ឧទាហរណ៍៖ មនុស្សមួយចំនួនមានការខ្មាសអៀនអំពីសេចក្ដីបង្រៀនថា គឺជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយដែលឲ្យបុរសធ្វើជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ និងនៅក្នុងផ្ទះ ទោះបើនៅក្នុងព្រះនេត្ររបស់ព្រះអង្គ មនុស្សប្រុស និងមនុស្សស្រីមានតម្លៃស្មើគ្នាក៏ដោយ។ ការខ្មាសអៀនបែបនេះបង្ហាញឲ្យខ្ញុំឃើញថា ពួកគាត់ទំនងជាកំពុងតែគិតអំពីសិទ្ធិអំណាចក្នុងរបៀបខុសឆ្គងហើយ ហាក់បីដូចជាពួកគេគិតថា អំណាចគ្រាន់តែជាការផ្ដល់អត្ថប្រយោជន៍សម្រាប់អ្នកដែលមានវាប៉ុណ្ណោះ។ មើលទៅ ទំនងពួកគាត់មិនទាន់ធ្លាប់មានកូនទេ។ មើលទៅ អំណាចហាក់បីដូចជាការទទួលបានប្រយោជន៍តែចំពោះអស់អ្នកដែលមិនមានអំណាចទាល់តែសោះ។ នៅពេលដែលលោកអ្នកមានអំណាច ស្ទើរតែទាំងអស់នៃ «អត្ថប្រយោជន៍» របស់លោកអ្នក វាហាក់ដូចជាបានបាត់ទៅវិញ ហើយលោកអ្នកចាប់ផ្ដើមយល់ឃើញថា ការមានអំណាចគឺស្ទើរតែពាក់ព័ន្ធទាំងស្រុងទៅនឹងការបម្រើវិញ—ជាការបម្រើដល់សិរីល្អ ប៉ុន្តែវាជាការបម្រើព្រះ និងអ្នកដទៃ។

រឿងនេះបានបង្ហាញមកកាន់ខ្ញុំកាន់តែច្បាស់កាលពីប៉ុន្មានឆ្នាំមុន ពេលដែលខ្ញុំបានអធិប្បាយព្រះបន្ទូលតាមរយៈកណ្ឌគម្ពីរ ២សាំយូអែល។ «ពាក្យចុងក្រោយ» របស់ស្ដេច ដាវីឌ គឺពិតជាគួរឲ្យចាប់អារម្មណ៍ណាស់៖ «អ្នកណាដែលសោយរាជ្យលើប្រជាជន នោះត្រូវតែបានសុចរិត ហើយត្រូវសោយរាជ្យដោយសេចក្ដីកោតខ្លាចដល់ព្រះ អ្នកនោះនឹងបានដូចជាពន្លឺនៅពេលព្រលឹមស្រាង កាលថ្ងៃកំពុងតែរះ ជាពេលព្រឹកមេឃស្រឡះ ដែលមានស្មៅពន្លកពីដីឡើង ដោយពន្លឺភ្លឺមកក្រោយពេលភ្លៀងធ្លាក់» (២សាំយូអែល ២៣:៣-៤)។ ការគ្រប់គ្រងអំណាចដោយត្រឹមត្រូវនោះនឹងផ្ដល់ព្រះពរដល់អស់អ្នកនៅក្រោមអំណាចនោះ។ វាជាការចិញ្ចឹមថែរក្សា

ពួកគេ។ ប្រជាជននឹងងាកទៅរកអំណាចមានសុខភាពល្អ ដែលចេះលះបង់ខ្លួនឯង ដើម្បីជាប្រយោជន៍ដល់អ្នកដែលស្ថិតក្រោមការថែទាំរបស់ខ្លួន ជាជាងការប្រើប្រាស់អំណាចនោះ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។ សូមសម្លឹងមើលអំពីរបៀបដែលគ្រួសារីកចម្រើនក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយល្អ ឬក្រុមមួយដែលនៅក្រោមការគ្រប់គ្រងពីគ្រូបង្វឹកដ៏ល្អម្នាក់។

នោះហើយជាមូលហេតុ ដែលការរំលោភបំពានសិទ្ធិអំណាចដោយគ្រូគង្វាល គឺជាអំពើបាបដែលបំផ្លិចបំផ្លាញ និងប្រមាថយ៉ាងធ្ងន់ធ្ងរ។ លើសពីនេះទៅទៀត រឿងរ៉ាវនៃការដែលគ្រូអធិប្បាយបានបង្រៀនភាពចម្រុងចម្រើន ដែលបានទិញយន្តហោះឯកជនតម្លៃរាប់សិបលានដុល្លារ បានចង្អុលបង្ហាញទៅរកអ្វីមួយដែលមិនគួរឲ្យជឿ និងបង្ហាញពីការងាររបស់សាតាំង។ “គ្រូគង្វាល” ទាំងនោះបានដើរក្នុងការភូតភរកុហក ដូចដែលសាតាំងបានបន្លឺសម្លេងសើៗទៅក្នុងត្រចៀករបស់លោក អ័ដាម និងនាង អេវ៉ា នៅក្នុងសួនច្បារអេដែនអញ្ចឹងដែរ៖ អំណាចនោះ គឺគ្រាន់តែជារបៀបមួយ ដើម្បីរំលោភបំពានលោកអ្នក ដើម្បីផលប្រយោជន៍របស់អ្នកដឹកនាំប៉ុណ្ណោះ។ សូមអរព្រះគុណព្រះជាម្ចាស់ ពីព្រោះព្រះយេស៊ូវដ៏ជាស្តេចដែលបានបង្ហាញដល់យើងតាមរយៈឈើឆ្កាងថា ភាពផ្ទុយគ្នានោះពិតជាកើតមានមែន នៅក្នុងអំណាចនៃការចេះកោតខ្លាចដល់ព្រះចុះ។

ដូចដែលព្រះយេស៊ូវបាន បង្ហាត់បង្រៀនសិស្សទ្រង់ក្នុងការប្រើប្រាស់អំណាចដោយការកោតខ្លាចដល់ព្រះយើងក៏ត្រូវធ្វើដូច្នោះដែរជាមួយនឹងបុរសៗ ដែលយើងកំពុងបណ្តុះបណ្តាលក្នុងភាពជាអ្នកដឹកនាំរបស់ពួកគាត់នោះ។ ហើយគ្រូគង្វាលត្រូវតែបង្ហាញអំពីគំរូនៃការគ្រប់គ្រងអំណាចបែបនោះ។

## ៨. សូមបង្រៀនអ្នកដឹកនាំវ័យក្មេងឲ្យបានយល់អំពីដំណឹងល្អ និងទេវវិទ្យាឲ្យបានច្បាស់លាស់

អ្នកដឹកនាំក្នុងក្រុមជំនុំ ត្រូវតែដឹងឲ្យច្បាស់លាស់អំពីរបៀបដែលខុសពីធម្មតាទាក់ទងទៅលើគោលលទ្ធិ និងការបង្រៀនសេចក្តីពិតជាទូទៅ។ សាវ័ក ប៉ុល បានបង្រៀនចំណុចនេះដល់អ្នកដឹកនាំនៅក្រុងអេភេសូរនៅក្នុងកណ្ឌគម្ពីរ  កិច្ចការ

ជំពូក២០។ ហើយគាត់ក៏បានបង្រៀននៅក្នុងសំបុត្ររបស់គាត់ ដែលបានផ្ញើទៅកាន់លោក ធីម៉ូថេ និងលោក ទីតុស ផងដែរ។ ជាឧទាហរណ៍៖ គាត់បានសង្កេតឃើញថា «ហើយមិនមែនលោក អ័ដាម ដែលចាញ់បញ្ឆោតទេ គឺជាស្រ្តីវិញទេតើ ដែលចាញ់បញ្ឆោតនោះ ព្រមទាំងរំលងច្បាប់ផង» (១ធីម៉ូថេ ២:១៤)។ អ្នកដឹកនាំត្រូវតែមានភាពច្បាស់លាស់អំពីសេចក្តីពិត។ លោកអ្នកចង់ឲ្យអ្នកដែលនឹងក្លាយជាអ្នកដឹកនាំនៅអនាគតមានភាពងាយស្រួលក្នុងការឆ្លើយតបទៅនឹងសំណួរ «ហេតុអ្វី?»។ ហើយពួកគាត់ត្រូវតែច្បាស់លាស់ ជាពិសេសអំពីប្រធានបទមួយចំនួន៖ បញ្ហាមូលដ្ឋានសំខាន់បំផុតនៃទេវសាស្ត្រ និងដំណឹងល្អ ដោយគោលលទ្ធិទាំងនោះអាចបែងចែកក្រុមជំនុំរបស់លោកអ្នកពីក្រុមជំនុំអ្នកដទៃទៀតបាន ហើយការបង្រៀនព្រះគម្ពីរទាំងនោះ [ដែលកំពុងស្ថិតនៅក្រោមកម្តៅភ្លើង និងបច្ចុប្បន្ន] មិនមានភាពពេញនិយមនៅលើពិភពលោកទាំងមូលទេ។

## ៩. បង្កើតក្រុមជំនុំឲ្យមានវប្បធម៌នៃការចេះបន្ទាបខ្លួន

ការអនុវត្តទាំងប្រាំបីចំណុចខាងលើនេះ គឺតម្រូវឲ្យមានវប្បធម៌នៃការបន្ទាបខ្លួន។ ការបង្កើតសិស្សរបស់គ្រីស្ទបរិស័ទ គឺអាស្រ័យលើការបន្ទាបខ្លួន មិនមែនការច្រណែននោះឡើយ។

វាមិនអាចមានសញ្ញានៃការបន្ទាបខ្លួននៅក្នុងខ្ញុំនោះទេ ប្រសិនបើខ្ញុំកំពុងមើលអ្នកណាម្នាក់ធ្វើព័ន្ធកិច្ច ហើយបានគិតបែបនេះថា «ខ្ញុំអាចធ្វើបានល្អជាងនេះ!» ឬក៏មានអារម្មណ៍បាក់ទឹកចិត្តដោយសារ «ខ្ញុំមិនអាចធ្វើវាបានល្អដូច្នោះបាន»។ ព្រះធ្វើការល្អខុសៗគ្នានឹងជាមួយមនុស្សផ្សេងៗគ្នា។ យើងដូចជាឧបករណ៍ផ្សេងៗនៅក្នុងវង់តន្ត្រីមួយអញ្ចឹងដែរ ហើយអ្នកដឹកនាំដ៏ល្អម្នាក់នឹងជួយមនុស្សម្នាក់ៗឲ្យអាចស្វែងរកជំនាញរបស់យើងរៀងៗខ្លួនបាន។ ហេតុអ្វីបានជាត្រូវច្រណែននឹងស្គរ? ឧបករណ៍ទាំងពីរអាចធ្វើឲ្យយើងរីករាយសម្រាប់អ្វីដែលពួកគេកំពុងមាន ទាក់ទងទៅនឹងភាពខុសគ្នា។

ការលើកទឹកចិត្ត ឲ្យក្រុមជំនុំមានវប្បធម៌នៃការចេះបន្ទាបខ្លួនមានន័យថា គឺជាការប្រឆាំងនឹងការភ័យខ្លាចរបស់មនុស្ស។ ហើយប្រាកដណាស់ យើងអាចធ្វើ

ដូច្នោះបានដោយការរៀនកោតខ្លាចដល់ព្រះអម្ចាស់។ មុនពេលបុរសៗ ចូលរួមកម្មសិក្សាថ្នាក់បណ្តុះបណ្តាលគ្រូគង្វាលក្នុងក្រុមជំនុំរបស់ខ្ញុំ យើងបានស្នើសុំឲ្យពួកគេអានសៀវភៅរបស់លោក អេដ វេលច៍ (Ed Welch) ដែលមានចំណងជើងថា "នៅពេលដែលមនុស្សកាន់តែធំ ហើយព្រះកាន់តែតូច" (When People Are Big and God Is Small)។ ប្រសិនបើលោកអ្នកមិនទាន់បានអានសៀវភៅនោះទេ ខ្ញុំសូមណែនាំឲ្យលោកអ្នកអានសៀវភៅនោះ។ អ្នកដែលនឹងក្លាយជាអ្នកដឹកនាំគ្រប់រូបគួរតែរៀនទទួលស្គាល់នូវការភ័យខ្លាចរបស់មនុស្សដែលមាននៅក្នុងខ្លួនរបស់គាត់។ ការមួយដែលយើងអាចមើលឃើញការភ័យខ្លាចនៅក្នុងខ្លួនអ្នកហាត់ការថ្មីៗ គឺនៅពេលដែលគាត់បានបង្ហាញខ្លួននៅក្នុងក្រុមជំនុំរបស់យើង ហើយទទួលបានការភិតភ័យ (បាក់ទឹកចិត្ត) ដោយអ្នកដឹកនាំខ្លាំងៗផ្សេងទៀត។ ប៉ុន្តែ ខ្ញុំចង់បានអ្នកដឹកនាំខ្លាំងៗឲ្យបានច្រើន តាមដែលខ្ញុំអាចធ្វើទៅបាន។ លើសពីនេះទៅទៀត វិធីមួយដែលអាចសម្លឹងមើលពីព័ន្ធកិច្ចរបស់ខ្ញុំទាំងស្រុងគឺថា ខ្ញុំកំពុងតែរៀបចំក្រុមជំនុំរបស់ខ្ញុំឲ្យបានត្រៀមខ្លួនជាស្រេចសម្រាប់គ្រូគង្វាលជំនាន់ក្រោយទៀត។

ជាទូទៅ ការបន្ទាបខ្លួន គឺអាចនាំឲ្យយើងនិយាយ នៅពេលដែលយើងគួរនិយាយ ហើយនៅស្ងៀមស្ងាត់ នៅពេលដែលយើងគួរនៅស្ងៀមស្ងាត់។ វាក៏នាំឲ្យយើងមានទាំងចិត្តទន់ភ្លន់ និងចិត្តមានជំហររឹងមាំផងដែរ។ ខ្ញុំចង់ឃើញក្រុមជំនុំរបស់ព្រះមានភាពរីកចម្រើន ដោយមានអ្នកដឹកនាំដែលបន្ទាបខ្លួនកាន់តែច្រើនបានបណ្តុះបណ្តាលឡើង។ ដើម្បីឲ្យការនោះអាចកើតឡើងបាន ខ្ញុំក៏ត្រូវបន្ទាបខ្លួនក្នុងនាមជាអ្នកដឹកនាំម្នាក់ផងដែរ។

វាជាសេចក្តីអំណររីករាយណាស់ ដែលព្រះប្រើប្រាស់យើង ដើម្បីបង្រៀនដល់អ្នកដទៃ! ហេតុអ្វីបានជាលោកអ្នកមិនចំណាយពេលក្នុងជីវិតរបស់ខ្លួនធ្វើកិច្ចការនេះ?

# សេចក្ដីសន្និដ្ឋាន៖

## ការប្រើប្រាស់ និងការចែកចាយអំណាច

ដោយលោក យ៉ូណាថា លីម៉ាន់
(Jonathan Leeman)

នៅក្នុងសៀវភៅមួយក្បាលនេះលោកគ្រូ ម៉ាក ដិវើរ (Mark Dever) បានលើកយកឧទាហរណ៍មួយចំនួនអំពីរបៀបដែលគាត់ផ្ទាល់បានផ្ដល់ការណែនាំខ្លះៗ ដើម្បីជួយឲ្យអ្នកអានអាចអនុវត្តផ្ទាល់នៅក្នុងជីវិត។ អ្វីដែលអ្នកអានអាចមើលរំលង (ដោយលោកគ្រូ ម៉ាក ដិវើរ មិនចង់និយាយអំពីខ្លួនគាត់ផ្ទាល់) នោះគឺគាត់ផ្ទាល់គឺជាគំរូដ៏ល្អមួយក្នុងការបង្កើតសិស្ស។ ខ្ញុំបានស្គាល់លោកគ្រូ ម៉ាក ជិត២០ឆ្នាំហើយ ដោយសារខ្ញុំជាសមាជិកម្នាក់ក្នុងក្រុមជំនុំរបស់គាត់ ហើយក្រោយមកក៏បានចូលរួមបម្រើជាមួយគាត់អស់រយៈពេលជិតដប់ឆ្នាំដែរ។ ដូច្នេះ ខ្ញុំចង់ឲ្យអ្នកអានសៀវភៅនេះគ្រប់រូបបានឃើញនូវអ្វីដែលខ្ញុំបានឃើញនៅក្នុងគំរូរបស់ លោកគ្រូ ម៉ាក ដើម្បីយកសាច់ឈាមដាក់ទៅលើគោលការណ៍ទាំងនោះ ដែលលោកអ្នកបានជួបរៀនទាំង១០ជំពូកមុននៅក្នុងសៀវភៅនេះ។

រឿងរ៉ាវមួយចំនួនដែលលោកគ្រូ ម៉ាក បានធ្វើក្នុងការបង្កើតសិស្ស គឺជាលក្ខណសម្បត្តិផ្ទាល់ខ្លួនរបស់គាត់ ហើយក៏មិនអាចត្រាប់តាមបានទាំងស្រុងនោះទេ។ ដំណឹងល្អសម្រាប់លោកអ្នក និងខ្ញុំគឺថា ប្រធានបទដែលយើងបានលើកឡើងទាក់ទងនឹងព្រះគម្ពីរ គឺយើងអាចត្រាប់តាមបាន។ ដូច្នេះ ទោះបើការអនុវត្តមានលក្ខណៈខុសគ្នា ក៏គោលការណ៍នៅតែដូចគ្នា ដែលខ្ញុំចង់ស្វែងយល់នៅក្នុងសេចក្ដីសន្និដ្ឋាននេះផងដែរ។ ទាំងនោះគឺជាមេរៀនលើប្រធានបទនៃសិទ្ធិអំណាច។

ខ្ញុំត្រូវបានស្នើសុំ—ឬក៏ខ្ញុំបានទទួលយក ឯកសិទ្ធិនៃការសរសេរសេចក្តីសន្និដ្ឋានបញ្ចប់នៃសៀវភៅជាភាគនេះ ដើម្បីឲ្យខ្ញុំអាចបង្ហាញថា ជីវិតរបស់គាត់បានបង្ហាញឲ្យយើងឃើញ—ហើយក៏ដើម្បីជួយលោកអ្នកឲ្យអាចមើលឃើញនូវអ្វីដែលខ្ញុំបានឃើញដែរ។ នៅក្នុងប្រយោគមួយ ខ្ញុំបានមើលឃើញថា អ្វីដែលលោកគ្រូ ម៉ាក ធ្វើបានល្អខុសពីធម្មតា និងអ្វីដែលខ្ញុំសូមកោតសរសើរដល់លោកអ្នកនោះគឺ មិនថាលោកអ្នកកំពុងមានការងារ ឬមានតួនាទីអ្វីនៅក្នុងក្រុមជំនុំនោះទេ លោកអ្នកចាំបាច់ត្រូវបញ្ចូលនូវរឿងទាំងពីរនេះឲ្យចូលគ្នាគឺ៖ ការអនុវត្តសិទ្ធិអំណាច និងការផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃ។

ខ្ញុំសង្ស័យថា មនុស្សភាគច្រើនបានចាត់ទុកថា សកម្មភាពទាំងនេះ ជាភាពផ្ទុយគ្នាទៅវិញ ទោះបើវាជាការគិតបែបត្រឹមត្រូវក៏ដោយ នៅក្នុងលោកីយ៍មានពេញដោយអំពើបាបនេះ។ ប៉ុន្តែ អស់អ្នកដែលស្គាល់អំពីជីវិតរបស់ព្រះគ្រីស្ទ ហើយយល់ដឹងពីរបៀបដែលអំណាចនៃការចេះកោតខ្លាចដល់ព្រះមានដំណើរការជាទូទៅយ៉ាងដូចម្តេច នោះពួកគេនឹងដឹងថា ការអនុវត្តសិទ្ធិអំណាច និងការប្រគល់សិទ្ធិអំណាចដល់អ្នកដទៃ គឺដូចជាផ្នែកទាំងសងខាងនៃកាក់តែមួយអញ្ចឹងដែរ។

លោកអ្នកអាចស្មានបានថា តើខ្ញុំចង់មានន័យយ៉ាងណា នៅពេលខ្ញុំនិយាយអំពីការអនុវត្តសិទ្ធិអំណាចនោះ។ វាមានន័យថា មនុស្សម្នាក់ត្រូវទទួលខុសត្រូវលើការងារដែលគាត់ត្រូវធ្វើ ហើយក៏សម្រេចចិត្តតាមអ្វីដែលគាត់បានធ្វើដែរ។ គាត់មានអំណាចធ្វើការសម្រេចចិត្តលើដែនកំណត់មួយចំនួន ដោយប្រើប្រាស់សិទ្ធិខាងក្រមសីលធម៌របស់គាត់។ ដូច្នេះ គាត់នឹងផ្តួចផ្តើមគំនិត មានការគ្រប់គ្រង ធ្វើការសម្រេចចិត្ត និងត្រូវធានាថា ការងារនោះនឹងបានសម្រេច។ ប្រាកដណាស់ ទាំងអស់នេះគឺជាអ្វីដែលលោកគ្រូ ម៉ាក ដិវើរ បានធ្វើនៅក្នុងក្រុមជំនុំរបស់គាត់។ គាត់បានដឹកនាំក្រុមជំនុំ។ គាត់បានកាច់ចង្កូត ដើម្បីនាំផ្លូវក្រុមជំនុំ។ វាជាការតម្រង់ទិសដៅ ដែលគាត់បានគ្រងទុករួមជាមួយនឹងពួកចាស់ទុំផ្សេងទៀតសម្រាប់ក្រុមជំនុំរបស់យើងឲ្យដើរតាម។ ហើយលោកអ្នកមិនមានភាពអៀនខ្មាសឬការស្ទាក់ស្ទើរក្នុងចិត្តចំពោះការដឹកនាំរបស់គាត់នោះឡើយ។

ប្រសិនបើបុគ្គលណាម្នាក់អនុវត្តសិទ្ធិអំណាចនេះដោយមានចិត្តអួតអាង

នោះគាត់នឹងប្រើប្រាស់អំណាចក្នុងលក្ខណៈដែលមិនគិតពីអ្នកដទៃ និងឃោរឃៅបំផុត។ គាត់នឹងចាត់ទុកមនុស្សជុំវិញថា ជាមធ្យោបាយមួយ ដើម្បីឲ្យគាត់ទទួលបាននូវអ្វីដែលគាត់ចង់បាន ហើយពួកគេនឹងមិនរីកចម្រើន ឬលូតលាស់បានឡើយ។

ទោះជាយ៉ាងណាក្ដី ប្រសិនបើបុគ្គលណាអនុវត្តសិទ្ធិអំណាចនេះដោយបន្ទាបខ្លួន នោះគាត់នឹងអនុវត្តសិទ្ធិអំណាចនេះ ព្រមទាំងប្រគល់អំណាចនេះដល់អ្នកដទៃផងដែរ។ លើសពីនេះ គាត់នឹងមិនស្វែងរកតែគោលបំណងផ្ទាល់ខ្លួនរបស់គាត់នោះទេ គឺគាត់កំពុងស្វែងរកគោលបំណងរបស់ព្រះគ្រីស្ទ ដែលបានតែងតាំងគាត់ក្នុងមុខតំណែងរបស់គាត់នោះឯង។ ដូច្នេះ គាត់នឹងខិតខំផ្គត់ផ្គង់ និងផ្ដល់សិទ្ធិអំណាចនេះដល់មនុស្សបន្ថែមទៀតសម្រាប់ការងារក្នុងក្រុមជំនុំ។ សូមប្រាកដថា ទាំងនេះក៏បង្ហាញពីលោកគ្រូ ម៉ាក ផងដែរ។ គាត់នៅតែបន្តផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃ ផ្ដល់ឱកាសដល់អ្នកដទៃ និងផ្គត់ផ្គង់អ្នកដទៃឲ្យដឹកនាំបន្តនៅក្នុងក្រុមជំនុំ។

## របៀបផ្សេងៗក្នុងការផ្ទេរអំណាចដល់អ្នកដទៃ

សម្រាប់អ្នកអានគ្រប់រូប ខ្ញុំនឹងទុកសេចក្ដីនេះជូនលោកអ្នក ដើម្បីស្វែងយល់ថា តើការផ្ទេរអំណាចដល់អ្នកដទៃអាចមើលទៅដូចជាការបង្កើតសិស្សរបស់អ្នកឬទេ មិនថាអ្នកកំពុងបង្កើតសិស្សនៅតាមផ្ទះ កន្លែងធ្វើការ ថ្នាក់រៀនថ្ងៃអាទិត្យ ក្រុមតូច ព័ន្ធកិច្ចចម្រុះក្នុងពួកជំនុំ ដោយមិត្តភាព ឬតាមរបៀបណាផ្សេងទៀតនោះទេ។ ប៉ុន្ដែ ខ្ញុំសូមផ្ដល់ការពណ៌នាមួយចំនួនដែលខ្ញុំបានឃើញលោកគ្រូ ម៉ាក បានផ្ទេរសិទ្ធិអំណាច ជាពិសេសក្នុងតួនាទីរបស់គាត់ គឺជាគ្រូគង្វាលរៀមច្បង។ ខ្ញុំនឹងលើកឡើងគំរូរបស់គាត់នៅខាងក្រោមនេះ ទុកជាការលើកទឹកចិត្តដល់លោកអ្នក។ គោលដៅនៅទីនេះ គឺមិនមែនដើម្បីលើកតម្កើងលោក ម៉ាក នោះទេ ប៉ុន្ដែដើម្បីនិយាយ (ដូចដែលសាវ័ក ប៉ុល បាននិយាយអំពីខ្លួនគាត់ដែរ) ចូរត្រាប់តាមខ្ញុំដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ។ ខ្ញុំក៏សង្ឃឹមដែរថា លោកអ្នកនឹងរកឃើញរឿងដូចគ្នានេះផងដែរ៖ ការងារនៃការបង្កើតសិស្ស គឺវាលើសពីទំនាក់ទំនងនៃមនុស្សម្នាក់ទល់នឹងមនុស្សម្នាក់ទៀត ដែលសៀវភៅនេះបានផ្ដោតជាសំខាន់ដែរ។

នៅទីបំផុត ការបង្កើតសិស្ស គឺជារបៀបរស់នៅ និងបែបបទនៃការរស់នៅជាមួយអ្នកដទៃ។ វាគឺជាការរៀបចំរចនាសម្ព័ន្ធនៃទំនាក់ទំនងទាំងអស់របស់លោកអ្នក ដើម្បីឲ្យលោកអ្នកអាចក្លាយជាអ្នកនាំចេញនូវឱកាសដល់អ្នកដទៃ។ ដូច្នេះ នេះជារបៀបដែលគ្រូគង្វាលអាចធ្វើ និងរួមបញ្ចូលជាមួយនឹងសំណួរមួយចំនួនសម្រាប់អ្នកអានគ្រប់រូប ដែលបានសរសេរជាអក្សរដិតខាងក្រោមនេះ៖

- សូមកសាងក្រុមជំនុំលើដំណឹងល្អ។ មិនថាអ្នកណាជាអ្នកបង្រៀននោះទេ គាត់ត្រូវតែបង្រៀនដោយយកដំណឹងល្អជាចំណុចស្នូលនៅក្នុងសេចក្តីបង្រៀននោះ។ នៅពេលទំនាក់ទំនង និងសិទ្ធិអំណាចមានមូលដ្ឋានគ្រឹះនៅលើដំណឹងល្អ នោះពួកគាត់ប្រើប្រាស់អំណាចរបស់ខ្លួនដោយមិនយកវា ដើម្បីធ្វើជាម្ចាស់លើគ្នាទៅវិញទៅមកនោះទេ ប៉ុន្តែដើម្បីបម្រើគ្នាទៅវិញទៅមកវិញ (ម៉ាថាយ ២០:២៥-២៨)។ *តើលោកអ្នកកំពុងកសាងទំនាក់ទំនងនៃការបង្កើតសិស្សរបស់អ្នកតាមរយៈដំណឹងល្អ ឬតាមរយៈសមិទ្ធផលរបស់លោកអ្នក?*
- សូមបង្កើតក្រុមពួកចាស់ទុំដែលមានជាបុគ្គលិក និងពួកចាស់ទុំដែលមិនមែនជាបុគ្គលិកក្នុងក្រុមជំនុំ។ នៅក្នុងក្រុមជំនុំមួយចំនួន ជាពិសេសក្រុមជំនុំធំៗ ស្ទើរតែគ្រប់គ្នានៅក្នុងក្រុមគ្រូគង្វាលសុទ្ធតែជាបុគ្គលិកដែលជាសមាជិកដែលទទួលបានប្រាក់ខែ។ បញ្ហានៅក្នុងស្ថានភាពដូចនេះគឺថា ទោះបើគ្រប់គ្នាមានការបោះឆ្នោតតែមួយក្នុងការប្រជុំ ក៏ពួកគេនៅមានអារម្មណ៍ថា ស្ថិតនៅក្រោមឋានានុក្រម ឬក៏ការគ្រប់គ្រងដែរ ដោយសារពួកគេត្រូវឆ្លើយតបទៅកាន់គ្រូគង្វាលច្បងរបស់ខ្លួន។ ប៉ុន្តែ ការមានពួកចាស់ទុំដែលមិនមែនជាបុគ្គលិក (គ្រូគង្វាលដែលមិនទទួលកម្រៃ) ក្នុងក្រុមប្រឹក្សាភិបាលនឹងសង្កត់ ឬក៏រុញខ្ទប់ឋានានុក្រមវិញ ដើម្បីឲ្យពួកចាស់ទុំម្នាក់ៗមានសិទ្ធិស្មើគ្នា។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូផ្តល់ឲ្យអ្នកដទៃនូវទំនួលខុសត្រូវជាផ្លូវការដែរឬទេ? តើលោកគ្រូស្តាប់ការប្រឹក្សាយោបល់ពីខាងក្រៅក្នុងដែនកំណត់នៃជំនាញ និងសិទ្ធិអំណាចរបស់លោកគ្រូដែរឬទេ?*
- សូមមានឆន្ទៈក្នុងការចាញ់សម្លេងឆ្នោតនៅពេលពួកចាស់ទុំបោះឆ្នោត។ ខ្ញុំបានស្តាប់ឮពីគ្រូគង្វាលរៀមច្បងមួយចំនួនបានអួតថា ពួកគាត់ «មិនធ្លាប់ចាញ់ការបោះឆ្នោតទេ»។ បើវាដូច្នោះមែន ហេតុអ្វីបានជាលោកអ្នកត្រូវការមានពួកចាស់ទុំសម្រាប់ជាក្រុមប្រឹក្សាភិបាល? លោកអ្នកទំនងជាកំពុងតែឈ្លានពានលើការដឹកនាំរបស់ពួកគាត់ហើយ! សំណួរសម្រាប់គ្រូគង្វាល៖

*តើការសម្រេចចិត្តត្រូវតែស្របតាមការគិតរបស់លោកគ្រូគ្រប់ពេលមែនឬ?*

- សូមកុំអធិប្បាយព្រះបន្ទូលតែម្នាក់ឯង។ ដោយមានការព្រមព្រៀងពីពួកចាស់ទុំ លោកគ្រូ ម៉ាក ដិវើរ បានកំណត់ខ្លួនគាត់ក្នុងការអធិប្បាយព្រះបន្ទូលពី ៥០ទៅ៦៥ភាគរយនៃពេលវេលានៅព្រឹកថ្ងៃអាទិត្យ។ ការធ្វើបែបនេះនឹងអាចផ្ដល់ឱកាសឲ្យអ្នកដឹកនាំផ្សេងទៀតមានភាពរីកចម្រើន និងទទួលបានសិទ្ធិអំណាចក្នុងការបម្រើផងដែរ។ ហើយក្រុមជំនុំពឹងផ្អែកលើព្រះបន្ទូល ជាជាងពឹងផ្អែកលើមនុស្សតែម្នាក់ដែរ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូផ្ដល់ឱកាស ដល់អ្នកដែលលោកគ្រូកំពុងបង្រៀនឲ្យមានការចែករំលែកលើវេទិកាដែលលោកគ្រូកំពុងឈរនោះដែរឬទេ?*
- សូមបង្កើតឲ្យមានឱកាសជាច្រើនទៀត ដើម្បីបង្រៀន។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូកំពុងស្វែងរកឱកាសយ៉ាងសកម្មក្នុងការបង្កើតព័ន្ធកិច្ចសម្រាប់អ្នកដទៃមែនឬទេ?*
- សូមផ្ដល់សេរីភាពឲ្យគ្រូវ័យក្មេងមានពេលវេលាអាចធ្វើខុសដែរ។ ខ្ញុំអាចគិតអំពីឧទាហរណ៍មួយ ឬពីរ ដែលគ្រូ ឬអ្នកអធិប្បាយវ័យក្មេងបាននិយាយអ្វីដែលមិនសមរម្យ ហើយគេក៏មិនបានអនុញ្ញាតឲ្យគាត់បង្រៀនតទៀតដែរ។ ប៉ុន្តែ យើងអាចនិយាយជាទូទៅថា នៅក្នុងក្រុមជំនុំរបស់យើង គ្រូបង្រៀនវ័យក្មេងមានសេរីភាពក្នុងការធុញទ្រាន់ និងឱកាសក្នុងការធ្វើខុសផងដែរ។ ដោយសារក្រុមជំនុំរបស់យើងពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះ ជាជាងពឹងផ្អែកលើលោកគ្រូ ម៉ាក ដិវើរ នោះក្រុមជំនុំមានការអត់ធ្មត់ច្រើនចំពោះអ្នកដឹកនាំដែលមានវ័យក្មេងនៅក្នុងក្រុមជំនុំដែរ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូឈប់ឲ្យអ្នកដឹកនាំវ័យក្មេងមានឱកាស បន្ទាប់ពីគាត់បានធ្វើខុសម្ដងហើយមែនឬ ឬក៏ថាលោកគ្រូនៅផ្ដល់ឱកាសឲ្យអ្នកដឹកនាំថ្មីៗអាចធ្វើខុសបានដោយសារតែពួកគាត់ថ្មី?*
- សូមអនុញ្ញាតឲ្យអ្នកដទៃយកគំនិតរបស់លោកអ្នក។ លោកគ្រូ ម៉ាក បានអនុញ្ញាតឲ្យគ្រូផ្សេងទៀតនៅក្នុងក្រុមជំនុំយកលំនាំតាមរឿងរ៉ាវ និងឧទាហរណ៍ពីជីវិតរបស់គាត់ដោយសេរី ខ្ទីឃ្លាដែលគាត់បាននិយាយដ៏ល្អបំផុត យកទៅប្រើប្រាស់បន្ត និងចម្លងសេចក្ដីអធិប្បាយព្រះបន្ទូលរបស់គាត់បានទៀតផង។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូត្រូវតែទទួលបានការផ្ដល់កិត្តិយសគ្រប់ពេលមែនឬ?*

- សូមកុំសូវនិយាយពេកនៅក្នុងពេលប្រជុំរបស់ពួកចាស់ទុំ។ សំណួរសម្រាប់គ្រូគង្វាល៖ *មិនថាការដ៏តូចដូចជាការជ្រើសរើសភោជនីយដ្ឋាន ឬក៏ការសំខាន់ក្នុងការពិភាក្សាអំពីបញ្ហាដ៏ស្មុគស្មាញនៃសីលធម៌ក៏ដោយ តើការបន្លឺសម្លេងរបស់លោកគ្រូត្រូវតែជាសម្លេងចុងក្រោយក្នុងការបញ្ចប់សន្ទនាណាមួយមែនឬទេ?*
- សូមអនុញ្ញាតឲ្យអ្នកដទៃធ្វើជាប្រធាននៅក្នុងការប្រជុំរបស់ពួកចាស់ទុំ ឬការប្រជុំរបស់សមាជិកក្រុមជំនុំ។ ការផ្តល់ឱកាសឲ្យអ្នកឯទៀតធ្វើជាប្រធាន ដោយចាប់ពីការកំណត់របៀបវារៈ និងការដឹកនាំប្រជុំ គឺជាវិធីងាយស្រួលមួយក្នុងការចែករំលែកសិទ្ធិអំណាចនៅក្នុងក្រុមជំនុំ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូត្រូវធ្វើជាស្តេចគ្រប់ពេល ឬក៏ថាលោកគ្រូចូលចិត្តតែងតាំងឲ្យមានស្តេចផ្សេងទៀតក្នុងការសោយរាជ្យបន្តដែរឬទេ?*
- សូមឲ្យពួកចាស់ទុំផ្សេងទៀតដឹកនាំពួកជំនុំក្នុងការប្រជុំ នៅពេលមានបញ្ហាលំបាកនានាសម្រាប់ពិភាក្សាគ្នានៅក្នុងក្រុមជំនុំ។ នៅពេលនិយាយអំពីការដឹកនាំក្រុមជំនុំដូចជាក្នុងករណីការដាក់វិន័យក្នុងក្រុមជំនុំ ការសម្រេចចិត្តលើផ្នែកហិរញ្ញវត្ថុធំៗ ឬប្រធានបទដ៏លំបាកៗផ្សេងទៀត អ្នកចាស់ទុំដែលបានចូលរួមច្រើនបំផុតក្នុងការដឹកនាំប្រជុំទាំងនោះ គាត់អាចជាអ្នកល្អបំផុតក្នុងការដឹកនាំការប្រជុំនៅក្នុងក្រុមជំនុំ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូបានដឹងដោយស៊ីជម្រៅអំពីការពិតដែលថា ព្រះវិញ្ញាណបានប្រទានអំណោយទានដល់រូបកាយរបស់ព្រះគ្រីស្ទដោយអំណោយទានផ្សេងៗគ្នា ហើយផ្នែកនីមួយៗនៃរូបកាយត្រូវការគ្នាទៅវិញទៅមក ហើយលោកគ្រូក៏ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើរូបកាយទាំងមូលនេះដែរឬទេ? តើការដឹកនាំ និងការបង្រៀនរបស់លោកគ្រូបានឆ្លុះបញ្ចាំងអំពីចំណុចនេះដែរឬទេ? តើលោកគ្រូតែងតែអំពាវនាវដល់អ្នកដទៃ ដើម្បីខ្ចីជំនាញ និងកម្លាំងរបស់ពួកគេដែរឬទេ?*
- សូមចំណាយពេលទៅលើរឿងមួយ ឬពីរនៅក្នុងក្រុមជំនុំ ហើយផ្ទេរអំណាចទៅកាន់អ្នកផ្សេង សម្រាប់រឿងផ្សេងៗទៀត។ លោកគ្រូ ម៉ាក បានលះបង់យ៉ាងខ្លាំងចំពោះការរៀបចំសេចក្តីអធិប្បាយរបស់គាត់ ហើយគាត់បានរក្សាភាពធូររលុងលើអ្វីៗផ្សេងទៀតវិញ។ ដូច្នេះ ប្រសិនបើលោកអ្នកចង់ឃើញក្រុមជំនុំធ្វើអ្វីបន្ថែមទៀតនៅក្នុងផ្នែកណាមួយ នោះគាត់នឹងអនុញ្ញាតឲ្យលោកអ្នកធ្វើវា ហើយគាត់នឹងលែងដៃរបស់គាត់ចេញ។ ដំណើរការបែបនេះនឹង

បង្ហាញឲ្យមានអ្នកដឹកនាំផ្សេងទៀតឡើង។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូរីករាយនឹងចំណុចខ្លាំង និងទេពកោសល្យដែលអ្នកដទៃមាន ដែលខ្លួនមិនមាន ព្រមទាំងលើកទឹកចិត្តអ្នកដទៃឲ្យប្រើប្រាស់វាដែរឬទេ? ឬតើលោកគ្រូជាអ្នកលេងត្រែដែលយកចិត្តទុកដាក់ចំពោះតែឧបករណ៍ផ្នែកត្រែក្នុងការប្រគំតន្ត្រី ហើយមិនរីករាយជាមួយនឹងផ្នែកខ្សែ?*

- សូមកុំគ្រប់គ្រងផ្នែកតូចៗ [សូមកុំព្យាយាមគ្រប់គ្រងលើគ្រប់ចំណុចលម្អិតទាំងអស់នៅក្នុងក្រុមជំនុំឡើយ]។ មានផ្នែកមួយចំនួនដែលលោកគ្រូ ម៉ាក បានគ្រប់គ្រងផ្នែកតូចៗដូចជា គាត់ត្រូវប្រាកដថា បុគ្គលិករបស់គាត់មានវត្តមាននៅក្នុងការប្រជុំ និងការបម្រើទាន់ពេលវេលា។ ប៉ុន្តែ នៅគ្រប់កន្លែងផ្សេងទៀត គាត់បានផ្តល់សេរីភាពទៅវិញ។ ការគ្រប់គ្រងនៅគ្រប់ផ្នែកតូចៗគឺមិនត្រឹមតែធ្វើឲ្យអ្នកដឹកនាំម្នាក់អស់កម្លាំងប៉ុណ្ណោះទេ វាក៏ធ្វើឲ្យប៉ះពាល់ដល់គំនិតផ្តួចផ្តើមក្នុងការងាររបស់អ្នកដទៃផងដែរ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូអនុញ្ញាតឲ្យអ្នកដទៃចាប់ផ្តើមធ្វើ និងបញ្ចប់ការងាររបស់ខ្លួន ទោះបីជាលោកគ្រូដឹងថា លោកគ្រូអាចធ្វើវាបានប្រសើរជាងគេក៏ដោយ?*
- សូមមានឆន្ទៈក្នុងការទទួលយកការរិះគន់ពីអ្នកដទៃ។ លោកគ្រូ ម៉ាក បានផ្តល់គំរូក្នុងការអញ្ជើញឲ្យមានការរិះគន់នៅក្នុងក្រុមជំនុំ។ គំរូនេះបានផ្តល់ឱកាសដល់អ្នកដឹកនាំថ្មីផ្សេងទៀត ដើម្បីពង្រីកស្លាបនៃការគ្រប់គ្រងរបស់ពួកគេ។ ប្រសិនបើអ្នកមិនដែលអញ្ជើញឲ្យមានការរិះគន់ទេ នោះលោកអ្នកកំពុងបង្រៀនមនុស្សគ្រប់គ្នានៅជុំវិញអ្នកថា ពួកគេត្រូវតែធ្វើតាមការចូលចិត្តរបស់អ្នក ឬពួកគេត្រូវទទួលការដាក់ទោសពីលោកអ្នក។ អ្នកដឹកនាំនឹងមិនមានការរីកចម្រើនក្នុងបរិយាកាសបែបនេះនោះទេ។ ពួកគេនឹងត្រូវក្រៀមស្វិត ឬត្រូវគេបោះបង់ចោលវិញ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូបើកឲ្យមានការរិះគន់ដែរឬទេ? តើលោកគ្រូនិយាយពាក្យថា «អរគុណ» នៅពេលមានគេរិះគន់ ឬក៏លោកគ្រូឈ្លោះប្រកែកជាមួយនឹងអ្នកនោះ?*
- សូមអធិស្ឋានសម្រាប់ក្រុមជំនុំនានា និងនិកាយផ្សេងៗទៀត។ ការធ្វើបែបនេះនឹងលុបបំបាត់ការបែងចែកបក្សពួក ហើយយើងអាចផ្តោតទៅលើដំណឹងល្អជំនួសឲ្យការផ្តោតទៅលើអ្នកដឹកនាំក្រុមជំនុំ។ ការអធិស្ឋានសម្រាប់ក្រុមជំនុំផ្សេងៗជួយបង្កើនការផ្តួចផ្តើមដំណឹងល្អបន្ថែមទៀត ក្នុងចំណោមអ្នកដឹកនាំថ្មីឲ្យមានការរីកលូតលាស់នៅក្នុងក្រុមជំនុំបាន។ សំណួរសម្រាប់គ្រូគង្វាល៖

*តើលោកគ្រូលើកទឹកចិត្តការងាររបស់អ្នកដទៃ និងក្រុមដែលកំពុងស្វែងរកគោលដៅដូចគ្នានឹងលោកគ្រូដែរឬទេ? ឬក៏ថា វាជាការសំខាន់ណាស់ដែលលោកគ្រូត្រូវតែឈ្នះគ្រប់ពេល?*

- សូមឆាប់អត់ទោសឲ្យអ្នកដទៃ។ វាពិបាកណាស់សម្រាប់អ្នកដែលស្វែងរកកំហុសអ្នកដទៃ ក្នុងការផ្ទេរសិទ្ធិអំណាចឲ្យដល់អ្នកដទៃ។ ប្រសិនបើលោកអ្នកមើលឃើញតែកំហុសអ្នកដទៃ នោះលោកអ្នកនឹងក្លាយជាមនុស្សដែលមិនចេះទុកចិត្តអ្នកដទៃ ឬក៏ផ្ទេរទំនួលខុសត្រូវដល់ពួកគាត់ដែរ។ ប៉ុន្តែ ប្រសិនបើលោកអ្នកជាមនុស្សដែលឆាប់អត់ទោសដល់អ្នកដទៃ នោះលោកអ្នកនឹងមានភាពងាយស្រួលក្នុងការផ្តល់ទំនុកចិត្ត និងផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃដែរ។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកគ្រូឆាប់អត់ទោសដល់អ្នកដទៃដែរឬទេ? ឬក៏ថា តើលោកគ្រូជាមនុស្សដែលឆាប់បដិសេធអ្នកដែលបានធ្វើខុសដាក់លោកគ្រូ?*
- សូមមានអំណរជាមួយនឹងជ័យជម្នះរបស់អ្នកដទៃ។ តើលោកគ្រូត្រូវតែធ្វើជាអ្នកដែលទាត់បាល់បញ្ចូលទី ឬក៏ថា តើលោកគ្រូនៅតែសប្បាយចិត្តក្នុងការជួយឲ្យអ្នកដទៃទាត់បញ្ចូលទីដែរ? លោកគ្រូ ម៉ាក បានអរសប្បាយនឹងជ័យជម្នះរបស់អ្នកដទៃ និងចាត់ទុកជ័យជម្នះនោះដូចជារបស់ខ្លួនគាត់ដែរ។ ប្រសិនបើមានអ្នកផ្សេងអាចធ្វើការងារនោះបាន នោះគាត់ពេញចិត្តនឹងឲ្យគេធ្វើវិញ។ ការធ្វើបែបនេះ នឹងផ្តល់ឲ្យគាត់នូវសេរីភាពក្នុងការធ្វើកិច្ចការអ្វីផ្សេងទៀត។ សំណួរសម្រាប់គ្រូគង្វាល៖ *តើលោកអ្នកនិយាយលើកទឹកចិត្តដល់ពួកគេញឹកញាប់ប៉ុណ្ណា? តើលោកអ្នកបានអបអរសាទរនឹងសមិទ្ធផលរបស់អ្នកដទៃញឹកញាប់ប៉ុណ្ណា ជាពិសេសនៅពេលដែលវាស្ថិតក្នុងផ្នែកនៃសមត្ថភាពរបស់លោកអ្នក?*

ដូចដែលខ្ញុំបាននិយាយរួចមកហើយថា មិនមែនថាឧទាហរណ៍ និងសំណួរទាំងអស់នេះសុទ្ធតែទាក់ទងទៅនឹងទំនាក់ទំនងនៃការបង្កើតសិស្សម្នាក់ទល់ម្នាក់នោះទេ។ ផ្ទុយទៅវិញ ឧទាហរណ៍ និងសំណួរទាំងអស់នេះចង្អុលបង្ហាញទៅកាន់ទស្សនៈធំ និងរបៀបរស់នៅទាំងស្រុងវិញ។ ហើយទស្សនៈធំនេះគឺ៖ «ព្រះបានប្រទានពេលវេលា និងទេពកោសល្យដល់ខ្ញុំ ហើយខ្ញុំនឹងប្រើប្រាស់ពេលវេលាដែលល្អបំផុត ដើម្បីគាំទ្រ និងផ្តល់អំណាចដល់អ្នកដទៃទៀតដែរ។ ខ្ញុំនឹងមិនគ្រាន់

តែមើលថែសួនច្បារផ្ទាល់ខ្លួនរបស់ខ្ញុំប៉ុណ្ណោះទេ។ ខ្ញុំនឹងជួយពួកគេក្នុងការមើលថែសួនច្បាររបស់ពួកគេដែរ»។ លើសពីនេះទៅទៀត អ្វីដែលកាន់តែស្រស់ស្អាតជាងនេះទៅទៀតគឺ៖ សួនច្បារមួយដែលមានទំហំតូច ហើយមានពេញទៅដោយផ្កាកុលាបរបស់អ្នក? ឬក៏ទីក្រុងដែលមានសួនច្បាររាប់រយដែលមានទំហំតូច ឲ្យមានពេញទៅដោយផ្កាកុលាបរបស់អ្នក ផ្កាថូលីបរបស់គាត់ ផ្កាឈូករ័ត្នរបស់នាង ផ្កាបេកូនៀរបស់ពួកគាត់ ផ្កាលីលី ផ្កាអាយរីស ផ្កាហ៊ីដ្រង់ជេ ផ្កាកាណាន និងផ្កាផ្សេងៗជាច្រើនទៀត?

## របៀបនៃការផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃបង្កើតឲ្យមានវប្បធម៌ក្នុងក្រុមជំនុំ

សូមគិតអំពីអ្វីដែលនឹងកើតឡើង នៅពេលដែលអ្នកដឹកនាំ «នៅលើផ្នែកកំពូល» មានទម្លាប់ក្នុងការផ្ទេរសិទ្ធិអំណាចដោយសប្បុរសដល់ពួកចាស់ទុំជំនួយរបស់គាត់ និងអ្នកផ្សេងទៀតនៅក្នុងក្រុមជំនុំ។ សូមគិតអំពីអ្វីដែលនឹងកើតឡើង នៅពេលដែលសមាជិកក្រុមជំនុំទាំងអស់កំពុងធ្វើការ ដើម្បីបង្កើត និងផ្តល់នូវឱកាសថ្មីៗដល់អ្នកផ្សេងទៀត។ សូមគិតអំពីអ្វីដែលនឹងកើតឡើង នៅពេលដែលលោកអ្នកប្រើប្រាស់ទំនាក់ទំនងនៃការបង្កើតសិស្សរបស់ខ្លួន ដើម្បីផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃ។ តើនឹងមានអ្វីកើតឡើង? វា នឹងជះឥទ្ធិពលទៅលើវប្បធម៌ក្នុងក្រុមជំនុំ តាមរបៀបដ៏អស្ចារ្យយ៉ាងច្រើនប្រភេទ។ វាបានដាំ និងបំប៉ននូវរាល់សួនច្បាររាប់រយដ៏ស្រស់ស្អាតនោះ។ នេះគឺជារបៀបនៃការផ្ទេរអំណាចមានឥទ្ធិពលដល់ក្រុមជំនុំ៖

១. វាជួយរក្សាដំណឹងល្អឲ្យនៅកន្លែងខ្ពស់បំផុត។ ការផ្ទេរសិទ្ធិអំណាច គឺផ្តោតសំដៅលើភ្នែករបស់ក្រុមជំនុំចំពោះគោលបំណងនៃដំណឹងល្អរបស់ខ្លួន ជាជាងការផ្តោតសំដៅលើអ្នកដឹកនាំ។
២. វាបានជំរុញឲ្យមានទំនាក់ទំនងពិតប្រាកដ។ នៅក្នុងបរិយាកាសមួយ ដែលអំណាចត្រូវបានការពារដោយការច្រណែន គេបានកំណត់ទំនាក់ទំនងដោយលក្ខណៈជាគោលនយោបាយ និងយុទ្ធសាស្ត្រ។ គាត់នឹងកាន់ខែលគាត់ឡើង ភាពងាយរងគ្រោះមិនត្រូវបានលាតត្រដាង និងតម្លាភាពត្រូវបានថយចុះ។

ប៉ុន្តែ នៅពេលដែលមនុស្សមានអារម្មណ៍ថា មានគេទុកចិត្តពួកគេ នោះពួកគេទំនងជាមានភាពបើកចំហ និងមានភាពស្មោះត្រង់ឡើងវិញ។

៣. វាបានរក្សាក្រុមជំនុំមួយពីការបែងចែកបក្សពួក។ មនុស្សដែលបន្តផ្តល់សិទ្ធិអំណាចដល់អ្នកដទៃ បានបង្រៀនអ្នកដែលនៅជុំវិញពួកគេថា ពួកគេបានចាប់អារម្មណ៍បំផុតចំពោះតែភាពជោគជ័យនៃដំណឹងល្អ ដោយមិនប្រកាន់ថា អ្នកណាម្នាក់ជាអ្នកដឹកនាំនោះឡើយ (ភីលីព ១:១២-៣០)។

៤. វាបានលើកទឹកចិត្តដល់សមាជិកក្រុមជំនុំឲ្យចេះចែករំលែកធនធានជាមួយគ្នាទៅវិញទៅមក។ ពេលខ្ញុំឃើញថា អ្នកដឹកនាំរបស់ខ្ញុំមិនគ្រាន់តែគិតតែអំពីខ្លួនឯង នោះខ្ញុំក៏មានទំនោរចិត្ត ដើម្បីផ្តល់ឲ្យដល់អ្នកដទៃផងដែរ។

៥. វាបានបំផ្លាញឋានានុក្រមនៃសង្គមធម្មជាតិ។ សមាជិកក្រុមជំនុំត្រូវមានទំនាក់ទំនងស្មើៗគ្នា។ ហេតុអ្វី? ដោយសារគេបានរក្សាទុកដំណឹងល្អ នៅចំកណ្តាលនៃពួកជំនុំ។ យើងទាំងអស់គ្នាជាមនុស្សមានបាប ហើយបានទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណរបស់ព្រះ។ អ្នកដឹកនាំមិនគួរប្រើប្រាស់អំណាចគ្រប់គ្រងលើអ្នកដទៃទេ ហើយនេះត្រូវតែកំណត់ជាគំរូមួយសម្រាប់មនុស្សគ្រប់រូបដែរ។

៦. វាបានបណ្តុះឲ្យមានការជឿទុកចិត្ត។ នៅពេលដែលអ្នកដឹកនាំ និងសមាជិកក្រុមជំនុំមិនគិតតែអំពីខ្លួនឯង នោះពួកគេនឹងកាន់តែមានភាពងាយស្រួលក្នុងការជឿទុកចិត្តលើការជំរុញចិត្ត សូម្បីតែនៅពេលដែលពួកគេសុំឲ្យមានការលះបង់ពីក្រុមជំនុំក៏ដោយ។

៧. វាបានបណ្តុះឲ្យមានការបង្រៀន និងមានឆន្ទៈក្នុងការទទួលការរិះគន់ពីអ្នកដទៃ។ ជាថ្មីម្តងទៀត ប្រសិនបើខ្ញុំបានជឿទុកចិត្តលើមនុស្សដែលមានតួនាទីនៅលើខ្ញុំ (មិនថាជាផ្លូវការ ឬក្រៅផ្លូវការ) ខ្ញុំមានឆន្ទៈស្តាប់ការរិះគន់របស់ពួកគេមកលើខ្ញុំ កាន់តែខ្លាំងឡើងបន្ថែមទៀត។ ខ្ញុំជឿថា ពួកគេមានការជំរុញចិត្តដែលកើតចេញពីសេចក្តីស្រឡាញ់ ជាជាងគ្រាន់តែចង់ឈ្នះ។

៨. វាបានជំរុញឲ្យមានឆន្ទៈក្នុងការអត់ទោសដល់អ្នកដទៃ។ នៅពេលដែលអ្នកដឹកនាំម្នាក់ មានភាពឆាប់រហ័សក្នុងការអត់ទោសចំពោះកំហុសរបស់អ្នកដទៃ នោះគាត់នឹងកាន់តែមានឆន្ទៈក្នុងការផ្ទេរសិទ្ធិអំណាចដល់អ្នកដទៃ។ ការនោះនឹងជួយអ្នកដទៃ ដើម្បីឲ្យធ្វើបែបដូចគ្នានេះដែរ។

៩. វាបានលើកទឹកចិត្តក្រុមជំនុំឲ្យផ្តោតលើការហ្វឹកហ្វឺន។ ក្រុមជំនុំមួយដែលបានមើលឃើញថា អ្នកដឹកនាំរបស់ខ្លួនបន្តក្នុងកិច្ចការហ្វឹកហ្វឺន និងផ្តល់សិទ្ធិអំណាចដល់អ្នកដទៃ នឹងយកទៅប្រើប្រាស់ដូចជាគំនិតរបស់ខ្លួន។

១០. វាបានជួយក្រុមជំនុំឲ្យផ្តោតអារម្មណ៍ទៅលើផ្នែកខាងក្រៅ។ ដំណើរការនៃការបង្កើតឲ្យមានអ្នកដឹកនាំបន្ថែម បានជួយក្រុមជំនុំមួយឲ្យយល់ដឹងថា គោលដៅរបស់ក្រុមជំនុំមិនត្រឹមតែធ្វើឲ្យផ្ទះរបស់ខ្លួនល្អជាងគេបំផុតនោះទេ ប៉ុន្តែក៏ត្រូវជួយឲ្យផ្ទះដទៃទៀតកាន់តែមានសុភមង្គល និងមានសុខភាពល្អផងដែរ។

ប្រាកដណាស់ ការផ្ទេរអំណាចអាចធ្វើឡើងដោយមិនបានល្អ ឬដោយមានភាពខ្ជិលច្រអូស។ ក្រុមជំនុំដែលឃើញអ្នកដឹកនាំព្យាយាមបន្តព័ន្ធកិច្ចនៃការហ្វឹកហ្វឺន និងការទុកចិត្តលើអ្នកដទៃនឹងពិតជាទទួលយកនិមិត្តដូចនេះ។ យើងត្រូវការប្រាជ្ញា ដើម្បីឲ្យការផ្ទេរសិទ្ធិអំណាចប្រព្រឹត្តទៅបានល្អ។ សំណួរដែលត្រូវសួរ ដើម្បីពិនិត្យមើលអាកប្បកិរិយានៃដួងចិត្តគឺថា៖ តើយើងសប្បាយចិត្តទេពេលឃើញអ្នកដទៃទទួលបានសិទ្ធិអំណាច ឬតើយើងប្រកាន់ជំហរការពារអំណាចនោះដោយភាពច្រណែន ហើយភ័យខ្លាចថា ពួកគេអាចនឹងល្អលើសយើងដែរឬទេ? ប្រសិនបើយើងសប្បាយចិត្ត តើយើងកំពុងធ្វើអ្វី ដើម្បីពង្រីកបន្ថែមទៀត?

គំរូដ៏ប្រសើរបំផុតរបស់យើងនៃការអនុវត្តសិទ្ធិអំណាច នៅពេលដែលមានការផ្ទេរសិទ្ធិអំណាចនោះដល់អ្នកដទៃ គឺគ្មាននរណាក្រៅពីព្រះអម្ចាស់ផ្ទាល់នោះទេ ជាពិសេសតាមរយៈបុគ្គលភាពរបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះជាម្ចាស់បានបង្កើតលោក អ័ដាម ក្នុងរូបអង្គទ្រង់ ហើយ «បានបំពាក់» គាត់ដោយសិរីល្អ និងអំណាចឲ្យទុកជាមកុដ ដោយទ្រង់ដាក់អ្វីៗគ្រប់ទាំងអស់ឲ្យនៅក្រោមជើងគាត់ (ទំនុកតម្កើង ៨:៥-៦)។ បន្ទាប់មក ទ្រង់បានប្រគល់គ្រប់ទាំងអំណាចដល់ព្រះគ្រីស្ទទាំងនៅស្ថានសួគ៌ ហើយផែនដីផង ដើម្បីត្រាស់ហៅមនុស្សនៅគ្រប់ទាំងសាសន៍សម្រាប់ទ្រង់ (ម៉ាថាយ ២៨:១៨; ហេព្រើរ ២:៦-៨)។ នៅពេលនោះ ព្រះគ្រីស្ទបានមានបន្ទូលបង្គាប់ដល់មនុស្សទាំងនេះ—ដល់យើង—ឲ្យបង្កើតសិស្ស ដើម្បីអាចឲ្យយើងសោយរាជ្យជាមួយនឹងទ្រង់បានដែរ។ គួរឲ្យភ្ញាក់ផ្អើលណាស់ ព្រះគម្ពីរថែមទាំងបានប្រើប្រាស់ភាសាសំដៅលើមនុស្សជាតិដែលបានប្រោសលោះថា ពួកគេនឹងសោយរាជ្យជាមួយនឹងព្រះ (២ធីម៉ូថេ ២:១២; វិវរណៈ ២០:៦—តាមន័យត្រង់ថា «ធ្វើជាស្តេចជាមួយនឹងទ្រង់»)។

ប្រសិនបើនោះជាប្រយោជន៍នៃសេចក្តីអំណររបស់ព្រះគ្រីស្ទ ដោយទ្រង់បាន

ចែករំលែកការគ្រងរាជ្យរបស់ទ្រង់ជាមួយយើង តើលោកអ្នកគិតថា យើងនឹងមានអំណារប៉ុណ្ណាក្នុងការចែករំលែកការគ្រប់គ្រងរបស់យើងជាមួយអ្នកដទៃ? ខ្ញុំគិតថានោះគឺជាចំណុចស្នូលនៃការបង្កើតសិស្ស៖ ដែលនោះជាការចែករំលែកការគ្រប់គ្រងរបស់យើងជាមួយអ្នកដទៃ។ ហើយតើលទ្ធផលនឹងទៅជាយ៉ាងណា? ដែលយើងដឹងអំពីសេចក្តីអំណាររបស់ព្រះអម្ចាស់ផ្ទាល់ ដែលទ្រង់គឺជាព្រះអាទិករ និងព្រះប្រោសលោះ។

# ឧបសម្ព័ន្ធ

ដោយឡែកពីព្រះគម្ពីរ ខាងក្រោមនេះគឺជាសៀវភៅផ្សេងទៀតដែល
លោកអ្នកអាចប្រើប្រាស់បាន ក្នុងការបង្កើតទំនាក់ទំនងក្នុងការ
បង្កើតសិស្ស៖


លោក Sam Allberry. Is God Anti-Gay? And Other Questions about Homosexuality, the Bible and Same-Sex Attraction. Purcellville, VA: The Good Book Company, ឆ្នាំ២០១៣។

លោក Thabiti Anyabwile. Finding Faithful Elders and Deacons. Wheaton, IL: Crossway, ឆ្នាំ២០១២។

លោក D. A. Carson. The Difficult Doctrine of the Love of God. Wheaton, IL: Crossway, ឆ្នាំ២០០០។

———. Praying with Paul: A Call to Spiritual Reformation. Grand Rapids, MI: Baker Academic, ឆ្នាំ២០១៤។

លោក Robert Coleman. The Master Plan of Evangelism. Grand Rapids, MI: Revell, ឆ្នាំ១៩៦៣, ទំព័រ១៩៩៣។

លោក Mark Dever. The Gospel and Personal Evangelism. Wheaton, IL: Crossway, ឆ្នាំ២០០៧។

———. What Is a Healthy Church? Wheaton, IL: Crossway, ឆ្នាំ២០០៧។

លោក Kevin DeYoung. Taking God At His Word: Why the Bible Is Knowable, Necessary, and Enough, and What That Means for You and Me. Wheaton, IL: Crossway, ឆ្នាំ២០១៤។

———. Just Do Something: A Liberating Approach to Finding God's Will. Chicago: Moody, ឆ្នាំ២០០៩។

លោក Greg Gilbert. What Is the Gospel? Wheaton, IL: Crossway, ឆ្នាំ២០១០។

លោក David Helm. One to One Bible Reading: A Simple Guide for Every Christian. Kingsford: Matthias Media, ឆ្នាំ២០១១។

លោក Jonathan Leeman. Church Membership: How the World Knows Who Represents Jesus. Wheaton, IL: Crossway, ឆ្នាំ២០១២។

———. Reverberation: How God's Word Brings Light, Freedom, and Action to His People. Chicago: Moody, ឆ្នាំ២០១១។

លោកស្រី Carolyn Mahaney. Feminine Appeal. Wheaton, IL: Crossway, ឆ្នាំ២០០៤។

លោក C. J. Mahaney. Living the Cross-Centered Life: Keeping the Gospel the Main Thing. Sisters, OR: Multnomah, ឆ្នាំ២០០៦។

———. Humility: True Greatness. Sisters, OR: Multnomah, ឆ្នាំ២០០៥។ លោក Jason Mandryk. Operation World: The Definitive Prayer Guide to Every Nation. Colorado Springs: Biblica, ឆ្នាំ២០១០។

លោក Will Metzger. Tell the Truth: The Whole Gospel Wholly by Grace Communicated Truthfully and Lovingly. Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨១, ២០២១។

លោក J. I. Packer. Concise Theology: A Guide to Historic Christian Beliefs. Wheaton, IL: Tyndale, ឆ្នាំ១៩៩៣។

———. Evangelism and the Sovereignty of God. Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៦១។

———. Knowing God. Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៧៣។

លោក Richard Phillips. The Masculine Mandate: God's Calling to Men. Lake Mary, FL: Reformation Trust, ឆ្នាំ២០០៩។

លោក John Piper. God Is the Gospel: Meditations on God's Love as the Gift of Himself. Wheaton, IL: Crossway, ឆ្នាំ២០០៥។

———. Future Grace: The Purifying Power of the Promises of God.

កែសម្រួល Colorado Springs: Multnomah, ឆ្នាំ២០១២។

———. The Pleasures of God: Meditations on God's Delight in Being God. Colorado Springs: Multnomah, ឆ្នាំ១៩៩១, ២០០០។

លោក Gary Ricucci និងលោកស្រី Betsy Ricucci. Love That Lasts: When Marriage Meets Grace. Wheaton, IL: Crossway, ឆ្នាំ២០០៦។

លោក Vaughan Roberts. God's Big Picture: Tracing the Storyline of the Bible. Downers Grove, IL: InterVarsity Press, ឆ្នាំ២០០២។

លោក J. C. Ryle. A Call to Prayer. Carlisle, PA: Banner of Truth, ឆ្នាំ២០០៥។

———. Holiness. Abridged ed. Chicago: Moody, ឆ្នាំ២០១០។

លោក Orlando Saer. Big God: How to Approach Suffering, Spread the Gospel, Make Decisions and Pray in the Light of a God Who Really Is in the Driving Seat of the World. Ross-shire: Christian Focus,

ឆ្នាំ២០១៤។

លោក Richard Sibbes. The Bruised Reed. Edinburgh: Banner of Truth, ឆ្នាំ១៩៩៨។

លោក R. C. Sproul. The Holiness of God. ២nd ed. Wheaton, IL: Tyndale, ឆ្នាំ១៩៩៨។

លោក Mack Stiles. Evangelism: How the Whole World Speaks of Jesus. Wheaton, IL: Crossway, ឆ្នាំ២០១៤។

លោក Sebastian Traeger និងលោក Greg Gilbert. The Gospel at Work: How Working for King Jesus Gives Purpose and Meaning to Our Jobs. Grand Rapids, MI: Zondervan, ឆ្នាំ២០១៣។

លោក Ed Welch. When People Are Big and God Is Small: Overcoming Peer Pressure, Codependency, and the Fear of Man. Phillips- burg, NJ: P&R, ឆ្នាំ១៩៩៧។

លោក Don Whitney. Spiritual Disciplines of the Christian Life. កែសម្រួល Colorado Springs: NavPress, ឆ្នាំ២០១៤។

# ឯកសារយោង

***សេចក្តីផ្តើម***

១. លោក Robert D. Putnam, Bowling Alone: The Collapse and Revival of American Community (New York: Simon & Schuster, ឆ្នាំ២០០០); លោកស្រី Sherry Turkle, Alone Together: Why We Expect More from Technology and Less from Each Other (New York: Basic Books, ឆ្នាំ២០១១); លោក Eric Klinenberg, Going Solo: The Extraordinary Rise and Surprising Appeal of Living Alone (New York, Penguin, ឆ្នាំ២០១២)។

២. លោក Klinenberg, Going Solo, ទំព័រ២០៨។

៣. ក្នុងសៀវភៅដូចគ្នា។

៤. លោក David F. Wells, Above All Earthly Pow'rs: Christ in a Postmodern World (Grand Rapids, MI: Eerdmans, ឆ្នាំ២០០៥), ទំព័រ១១៩។

***ជំពូកទី២ តម្រង់ទិសទៅរកអ្នកដទៃ***

១. លោក Charles Bridges, The Christian Ministry: With an Inquiry into the Causes of Its Inefficiency (Carlisle, PA: Banner of Truth, ឆ្នាំ១៩៥៩), ទំព័រ៧៥។

***ជំពូកទី៣ ការងារនៃការបង្កើតសិស្ស***

១. លោកស្រី Erin Wheeler, "Discipling When You Need to Be Discipled," នៅក្នុងទស្សនាវដ្តី 9Marks, "Discipling in the Church," ខែកញ្ញា-ខែតុលា ឆ្នាំ២០១២, http://9marks.org/article/

journaldiscipling-when-you-need
-be-discipled/.

២. លោក C. H. Spurgeon, C. H. Spurgeon Autobiography, vol. ២, The Full Harvest (Carlisle, PA: Banner of Truth, ឆ្នាំ១៩៧៣), ទំព័រ១៣១។

### *ជំពូកទី៨ ការជំទាស់ផ្សេងៗទៅនឹងការបង្កើតសិស្ស*

១. លោកស្រី Alice Fryling, Disciplemakers’ Handbook: Helping People Grow in Christ (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៩), ទំព័រ៤៨។

### *ជំពូកទី៩ បង់ថ្លៃការចំណាយ*

១. លោក Richard Sibbes, “The Bride’s Longing,” in Works of Richard Sibbes, vol. ៦, ការសម្រួលដោយ៖ លោក Alexander B. Grosart (Carlisle, PA: Banner of Truth, ឆ្នាំ១៩៨៣), ទំព័រ៥៦០។

### *ជំពូកទី១០ ការបង្កើតឲ្យមានអ្នកដឹកនាំបន្ថែម*

១. លោក Samuel Miller, Letters on Clerical Manners and Habits: To a Student in the Theological Seminary at Princeton, N.J., Applewood’s American Philosophy and Religion Series (Bedford, MA: Applewood Books, ឆ្នាំ១៨២៧), ទំព័រ៤០៦-៧។

២. លោក Henry Drummond, The Greatest Thing in the World and Other Addresses (London: Hodder and Stoughton, ឆ្នាំ១៩៥៩), ទំព័រ៣៦។

# លិបិក្រមទូទៅ


***ចោទិយកថា***
៦:៦ ៣៥

***២សាំយូអែល***
២៣:៣ ១៣១

***ទំនុកតម្កើង***
៨:៥ ១៤៥
២៥:៩ ១០១

***សុភាសិត***
១១:២ ១០១
២៧:៦ ១១៥

***ម៉ាថាយ***
១៣:៣១ ៤៥
១៦:១៣ ៧០, ៧១
១៨:១៥ ៥០, ៧១
២០:២៥ ១៣១, ១៣៨
២៨:១៨ ៩, ៧២, ១៤៥
២៨:១៩ ១៣, ១៩

***ម៉ាកុស***
៣:១៣ ៣៦
៨:៣៤ ១៦, ៩៤
១០:៤៥ ៣៤
១២:២៨ ១១៤
១២:៣០ ១៨
១២:៣១ ១៨

***លូកា***
៦:៤០ ២៩

***យ៉ូហាន***
៣:១១ ១២
៤:១៩ ១៩
១០:១១ ១៥
១៣:៣៤ ៦៣, ៦៨, ១១៤
១៣:៣៥ ១២, ១០៧
១៤:១៥ ១៩
១៤:២៣ ១៩

***កិច្ចការ***
១៦:៣ ៣៦
២០:២៨ ១២៧

***រ៉ូម***
១០:១៧ ៧៥
១២:២ ២៨
១២:១០ ១២, ៨២
១៥:៧ ១២

***១កូរិនថូស***
១:៥ ១២៩
២:១៤ ៩៦
៤:១៥ ១០៧
៥:៦ ២៩
៦:១៩ ១៧
១០:១៧ ៤៨, ៧២
១១:១ ៥២, ៧៨

១១:២៦ ៧៧
១២:៤ ៨៧
១២:១២ ៨២
១២:១៤ ៨២
១៣:៧ ១២៥
១៥:៣៣ ២៩

***២កូរិនថូស***

២:៦ ៨៣
៤:៧ ៤៧, ៥៥
៥:១៥ ១៧
១២:៩ ៣១

***កាឡាទី***

១:៨ ៨១
៤:៩ ១០៧
៥:១៣ ១២
៦:២ ១២
៦:៦ ៨០
៦:១០ ១០២

***អេភេសូរ***

២:២ ២៨
២:១០ ១០២
២:១៨ ៩៩
៣:១០ ៩៩
៤:១១ ៧៦
៤:១៣ ៩
៤:២៥ ១២
៤:២៩ ៨៥
៤:៣២ ១២
៥:១៦ ១០២
៥:២១ ១២
៥:២៥ ១៥

***ភីលីព***

១:១២ ១៤៤
២:១ ១៤
២:១៥ ១០៧
២:១៦ ១០៦
២:១៧ ៥៥
៣:១៧ ១០៧, ១០៧

***កូឡុស***

១:២៨ ៣៧, ៣៧, ៣៨, ៣៩, ៤០, ៩៥
១:២៩ ៣៨
២:២ ៤០
៣:១៦ ១២, ៥២

***១ថែស្សាឡូនីច***

៥:១១ ៩៥
៥:១២ ៨០
៥:១៧ ១១៣

***២ថែស្សាឡូនីច***

៣:៧ ១០៧

***១ធីម៉ូថេ***

២:១៤ ១៣៣
៣:១ ៧៩, ១២១
៤:១២ ៩៩
៤:១៦ ៧៦, ១០៥
៥:៨ ៩៥
៥:១៧ ៨០

***២ធីម៉ូថេ***

២:២ ៣៦, ១០១, ១១៩
២:១២ ១៤៥
៣:១០ ១០៧, ១០៨

| | |
|---|---|
| ៤:៣ | ៨១ |
| ៤:៥ | ៧៥ |

***ទីតុស***

| | |
|---|---|
| ១:៥ | ១១៩ |
| ១:៦ | ៧៩, ១២១ |
| ២:៣ | ៩៨ |

***ហេព្រើរ***

| | |
|---|---|
| ២:៦ | ១៤៥ |
| ១០:២៤ | ១២, ៥២, ៦៩, ៨២, ៩៥ |
| ១៣:៧ | ៥២, ៧៩, ៩៦ |
| ១៣:១៧ | ៧៩ |

***យ៉ាកុប***

| | |
|---|---|
| ២:១ | ១២២ |
| ៥:១៦ | ១២, ១២ |

***១ពេត្រុស***

| | |
|---|---|
| ២:៩ | ៥៦ |
| ២:១៨ | ៣០ |
| ២:២១ | ៣០, ៥១ |
| ៣:១ | ៤៧ |
| ៤:៤ | ២៨ |
| ៤:៩ | ១២ |
| ៤:១០ | ៩ |
| ៥:៥ | ១០១ |

***១យ៉ូហាន***

| | |
|---|---|
| ៣:១១ | ១២ |
| ៤:១៩ | ១៩ |

***វិវរណៈ***

| | |
|---|---|
| ៧:៩ | ១០០ |
| ២០:៦ | ១៤៥ |

IX 9Marks

Building Healthy Churches
ការកសាងក្រុមជំនុំដែលមានសុខភាពល្អ

IS YOUR CHURCH HEALTHY?
តើពួកជំនុំរបស់អ្នកមានសុខភាពល្អដែរឬទេ?
ព័ន្ធកិច្ច 9Marks គឺដើម្បីជួយអ្នកដឹកនាំក្រុមជំនុំឲ្យមានចក្ខុវិស័យព្រះគម្ពីរ និង ធនធានជាក់ស្ដែងសម្រាប់បង្ហាញសិរីល្អរបស់ព្រះដល់ប្រជាជាតិនានា តាមរយៈ ក្រុមជំនុំដែលមានសុខភាពល្អ។
ដើម្បីបំពេញការនោះ យើងចង់ឃើញក្រុមជំនុំដែលមានសុខភាពល្អដោយមាន លក្ខណៈ ៩ យ៉ាងខាងក្រោមនេះ៖
១. សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ
២. គោលលទ្ធិដែលផ្តោតលើដំណឹងល្អ
៣. ការយល់ដឹងដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ និងប្រកាសដំណឹងល្អ តាមព្រះគម្ពីរ
៤. ការយល់ដឹងដ៏ត្រឹមត្រូវពីសមាជិកភាពនៃពួកជំនុំតាមព្រះគម្ពីរ
៥. ការយល់ដឹងពីការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ
៦. ការយល់ដឹងពីការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ
៧. ការយល់ដឹងពីការដឹកនាំពួកជំនុំតាមព្រះគម្ពីរ
៨. ការយល់ដឹងពីការអធិស្ឋានតាមព្រះគម្ពីរ
៩. ការយល់ដឹងពីការធ្វើបេសកកម្ម
នៅ 9Marks យើងបានសរសេរអត្ថបទផ្សេងៗ សៀវភៅជាច្រើន ការពិនិត្យសៀវភៅ ឡើងវិញ និងទស្សនាវដ្តីតាមប្រព័ន្ធអ៊ីនធឺណិត។ ពួកយើងក៏បានរៀបចំសន្និសីទ បានថតទុកការសម្ភាសន៍ និងផលិតធនធានផ្សេងៗទៀត ដើម្បីជួយទ្រទ្រង់ក្រុម ជំនុំ និងបង្ហាញពីសិរីល្អរបស់ព្រះ។

សូមចូលទៅកាន់គេហទំព័ររបស់យើង ដើម្បីស្វែងរកមាតិកាជាង ៦០+ ភាសា ហើយចុះឈ្មោះ ដើម្បីទទួលបានទស្សនាវដ្តីតាមប្រព័ន្ធអ៊ីនធឺណិតរបស់យើង ដោយឥតគិតថ្លៃ។ សូមមើលបញ្ជីឈ្មោះពេញលេញនៃគេហទំព័រជាភាសាផ្សេងៗទៀតរបស់យើង នៅតំណខាងក្រោមនេះ៖

9marks.org/international

នៅក្នុងសៀវភៅដ៏ខ្លីនេះលោកគ្រូ ម៉ាក ដិវើរ បានលើកឡើងជាងគ្រោងអំពីបុគ្គល ទីកន្លែង ពេលវេលា មូលហេតុ និងរបៀបនៃការបង្កើតសិស្ស—ក្នុងការជួយអ្នកដទៃឲ្យដើរតាមព្រះយេស៊ូវ។ ដោយគ្រាប់តាមលំនាំដែលមានចែងនៅក្នុងព្រះគម្ពីរ សៀវភៅនេះពន្យល់អំពីរបៀបនៃទំនាក់ទំនងនៃការបង្កើតសិស្សថា វាគួរមានតួនាទីយ៉ាងដូចម្ដេចក្នុងបរិបទនៃក្រុមជំនុំតាមតំបន់ ដោយបង្រៀនយើងអំពីរបៀបនៃការបង្កើតវប្បធម៌នៃការបង្កើតសិស្ស ជាផ្នែកធម្មតាមួយនៃជីវិតប្រចាំថ្ងៃរបស់យើង។

«សូមចំណាយពេលអានសៀវភៅនេះ ប្រសិនបើលោកអ្នកចង់ផ្លាស់ប្ដូរទៅកាន់កម្រិតមួយផ្សេងទៀតក្នុងជីវិតខាងឯវិញ្ញាណ និងភាពជាអ្នកដឹកនាំរបស់លោកអ្នក»។

លោក Ronnie Floyd, President, Southern Baptist Convention;
Senior Pastor,
Cross Church, Springdale, Arkansas

ប្រសិនបើលោកអ្នកស្គាល់លោក ម៉ាក ដិវើរ នោះលោកអ្នកក៏នឹងដឹងផងដែរថា គាត់ជាអ្នកបង្កើតសិស្សដែលមានារប្ដេជ្ញាចិត្ត។ អ្វីដែលជំរុញចិត្តគាត់ និងរបៀបដែលគាត់បង្រៀនដល់អ្នកដទៃ និងជួយឲ្យសមាជិកក្រុមជំនុំរបស់គាត់ធ្វីដែរ នោះគឺជាអ្វីដែលសៀវភៅនេះបានរៀបរាប់។ សូមត្រៀមខ្លួនទទួលបានបទពិសោធន៍ដែលផ្លាស់ប្ដូរជីវិត នៅពលលោកអ្នកអានសៀវភៅនេះ»។

លោក Conrad Mwebe, Pastor, Kabwata Baptist Church, Lusaka, Zambia

អ្នកដើរតាមព្រះគ្រីស្ទគ្រប់ៗរូបចាំបាច់ត្រូវអានសៀវភៅមួយក្បាលនេះ! វាជាសៀវភៅដ៏ល្អបំផុតដែលខ្ញុំធ្លាប់បានអានភក់ទងនឹងការបង្កើតសិស្ស»។

លោកស្រី Jani Ortlund, Executive Vice President, Renewal Ministries;
author, Fearlessly Feminine and His Loving Law, Our Lasting Legacy

លោកសាស្ត្រាចារ្យ ម៉ាក ដិវើរ បានបញ្ចប់ការសិក្សានៅ University of Cambridge។ លោកជាគ្រូគង្វាលរៀមច្បងនៅពួកជំនុំ កាពីតូលហៀលបាទីស្ទ (Capitol Hill Baptist Church) នៅរដ្ឋធានី វ៉ាស៊ីនតោនឌីស៊ី។ លោកបាននិពន្ធសៀវភៅជាច្រើនក្បាលដែលមានរួមដូចជា «ពួកជំនុំដែលមានសុខភាពល្អ» ហើយក៏ជាអ្នកបង្រៀននៅឯសិក្ខាសាលាជាច្រើនជុំវិញពិភពលោក។

** សៀវភៅនេះជាសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅនៃស៊េរី «ការកសាងក្រុមជំនុំដែលមានសុខភាពល្អ»។*

IX 9Marks
www.9marks.org

ផ្លូវពិត